# កម្ពុជាក្នុងអាស៊ាន
# ប្រាំឆ្នាំក្រោយមក

## Cambodia in ASEAN
## Five Years Later

រៀបរៀងដោយៈ
បណ្ឌិត ចាបសុថារិទ្ធ





វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព
ភ្នំពេញ ២០០៥

# កម្ពុជាក្នុងអាស៊ាន
# ប្រាំឆ្នាំក្រោយមក

## Cambodia in ASEAN: Five Years Later


រៀបរៀងដោយ

**បណ្ឌិត ចាប សុធារិទ្ធ**

Edited By Chap Sotharith



ឧបត្ថម្ភដោយ មូលនិធិ Friedrich-Ebert-Stiftung

បោះពុម្ពនៅ ព្រះរាជាណាចក្រកម្ពុជា ដោយ

**វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព**

២០០៥

សូមរក្សាសិទ្ធិគ្រប់បែបយ៉ាង។ មិនអនុញ្ញាតឱ្យយកវគ្គ ឬផ្នែកណាមួយនៃសៀវភៅនេះទៅផលិតជាថ្មី ឬក៏យកទៅធ្វើតាមរូបភាព ឬមធ្យោបាយអេឡិកត្រូនិក គ្រឿងយន្តណាមួយ ដូចជាការថតចម្លង ជាខ្សែអាត់ ការរក្សាទុកពតិមាន ក្នុងទីណាមួយ និងយកទៅធ្វើជាប្រព័ន្ធផ្តល់ពតិមានណាមួយ ដោយគ្មានការ អនុញ្ញាតពី វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ឡើយ។

**បោះពុម្ពផ្សាយលើកទី១ នៅព្រះរាជាណាចក្រកម្ពុជា ២០០៥**

© Cambodian Institute for Cooperation and Peace
First published in 2005 by Cambodian Institute for Cooperation and Peace
Phum Paung Peay, Sangkat Phnom Penh Thmey, Khan Russey Keo,
Phnom Penh, Kingdom of Cambodia
Mailing Address: P.O. Box 1007
Phnom Penh 12202, Kingdom of Cambodia
Telephone: 855-23-982 559
855-12-819-953 (Mobile)
855-12-835-509 (Mobile)
Fax: 855-23-982 559
E-mail: cicp@everyday.com.kh
Website: http://www.cicp.org.kh

# មា តិ កា

**ការថ្លែងអំណរគុណ** **៤**

**អារម្ភកថា** **៦**

**ព្រះសុន្ទរកថាស្វាគមន៍** **១០**

ដោយសម្តេច នរោត្តម សិរីវុឌ្ឍ ១០

**សុន្ទរកថាស្វាគមន៍** **១៧**

ដោយលោក ណ័រប៊ឺត វ៉ុន ហូម៉ាន់ ១៧

**ព្រះសុន្ទរកថាគន្លឹះបើកសន្និសីទជាតិ** **២៤**

ដោយសម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិ ២៤

**ប្រទេសកម្ពុជា ក្នុងអាស៊ាន : ការវាយតំលៃរួម** **៣១**

ដោយបណ្ឌិត ចាប សុថារិទ្ធ ៣១

**អាស៊ាន និង សហគមន៍សន្តិសុខ** **៤៥**

ដោយ ឯកឧត្តមឧត្តមសេនីយ៍ទោ ណឹម សុវត្ថិ ៤៥

**កម្ពុជានិងសហគមន៍សេដ្ឋកិច្ចអាស៊ានៈ ផលប៉ះពាល់លើសេដ្ឋកិច្ចកម្ពុជា** **៥៧**

ដោយបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី ៥៧

**កម្ពុជា និង សហគមន៍សង្គមវប្បធម៌អាស៊ាន ៧៨**

ដោយឯកឧត្តមបណ្ឌិត ឆយ យីហ៊ាង ៧៨

**កម្ពុជា និង ដៃគូពិភាក្សាអាស៊ាន ៩៨**

ដោយលោក អ៊ុំ ស៊ីផុល ៩៨

**កម្ពុជា ក្នុងអាស៊ាន: ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍កម្ពុជា ១១០**

ឯកឧត្តម នុត និនឿន ១១០

**កម្ពុជា និងអាស៊ានបូក ៣ ១១៨**

ដោយលោក កេត សុផាន់ ១១៨

**កម្ពុជា និង អាស៊ាន: សហប្រតិបត្តិការផ្នែកនគរបាល ១២៤**

ដោយឯកឧត្តមឧត្តមសេនីយ៍ឯក ខៀវ សុភ័ក្រ ១២៤

**កម្ពុជា និង អាស៊ាន ៥ ឆ្នាំ :**

**ការអភិវឌ្ឍន៍វិស័យឥណទានជនបទនៅកម្ពុជា ១២៩**

ដោយឯកឧត្តម សុន គន្ធរ ១២៩

**ការអភិវឌ្ឍក្នុងសហប្រតិបត្តិការវិស័យទេសចរណ៍អាស៊ាន ១៣៥**

ដោយលោក ច្រឡឹង សុមេធា ១៣៥

**សុន្ទរកថាគន្លឹះបិទសន្និសីទជាតិ ១៤១**

ឯកឧត្តមបណ្ឌិត កៅ គឹមហួន ១៤១

**ឧបសម្ព័ន្ធ១ របាយការណ៍នៃអង្គសន្និសីទជាតិ ស្តីពី "ប្រទេសកម្ពុជា**

**ក្នុងអាស៊ាន : ប្រាំឆ្នាំក្រោយមក" ១៥១**

**ឧបសម្ព័ន្ធ២ : របាយការណ៍នៃវេទិកាទាំង ១០ លើក ក្នុងឆ្នាំ ២០០៤ ស្តីពី "កម្ពុជា និងអាស៊ាន" ១៦២**

វេទិកា ទី ១: ប្រទេសកម្ពុជា ក្នុងអាស៊ាន : ទស្សនៈរួម ១៦២

វេទិកា ទី ២ ប្រទេសកម្ពុជា និង សហគមន៍សន្តិសុខអាស៊ាន ១៧៨

វេទិកា ទី ៣ ប្រទេសកម្ពុជា និង តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ១៩៣

វេទិកា ទី ៤ ប្រទេសកម្ពុជា និង សហគមន៍សេដ្ឋកិច្ចអាស៊ាន ២០៧

វេទិកា ទី ៥ ប្រទេសកម្ពុជា និងសហគមន៍វប្បធម៌សង្គមអាស៊ាន ២១៧

វេទិកាទី ៦ ប្រទេសកម្ពុជា និងដៃគូចរចាអាស៊ាន ២២៨

វេទិកាទី ៧ ប្រទេសកម្ពុជា និងវេទិកាតំបន់អាស៊ាន ២៣៦

វេទិកាទី ៨ ប្រទេសកម្ពុជា និងអាស៊ាន+៣ ២៤៥

វេទិកាទី ៩ ប្រទេសកម្ពុជា និង ផែនការសកម្មភាពវៀងច័ន្ទ ២៥៥

វេទិកា ទី ១០ ប្រទេសកម្ពុជា និងការងារទូតអាស៊ានបណ្តាញទី ២ ២៦៥

**ឧបសម្ព័ន្ធ៣ សំណូមពរ និង អនុសាសន៍ ២៧៥**

**ឧបសម្ព័ន្ធ៤ កម្មវិធីនៃវេទិកាទាំង ១០ លើក និងសន្និសីទជាតិ ២៨០**

ក-កម្មវិធីនៃវេទិកាទាំង ១០ លើក ២៨០

ខ-កម្មវិធីអង្គសន្និសីទជាតិ ៣០០

**ឧបសម្ព័ន្ធ៥ បញ្ជីរាយនាមប្រធានសម័យប្រជុំ និងវាគ្មិន ៣១១**

**អំពីអ្នករៀបរៀង ៣១៦**

# ការថ្លែងអំណរគុណ

ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះ មូលនិធិ ហ្វ្រីឌ្រីច-អេប៊ែត (FES) ជាពិសេស លោក **ណរ៉បឺត ហ្វុនហូម៉ាន់** (Nobert von Hofmann) និង លោក **អាក់សែល ស្មីត** (Axel Schmitd) ដែលចូលបំរើការជំនួស លោក **ហ្វុនហូម៉ាន** ប្រធានការិយាល័យសំរាប់សហប្រតិបត្តិការតំបន់ប្រចាំសិង្ហបុរី ដែលបានជួយឧបត្ថម្ភ ទាំងស្មារតី ទាំងសម្ភារៈ និងមូលនិធិ ឱ្យដល់ការរៀបចំវេទិកាទាំង ១០ លើក និងសន្និសីទជាតិ ស្តីពី "**កម្ពុជានិងអាស៊ាន : ប្រាំឆ្នាំកន្លងមក**" ដែលបានប្រព្រឹត្ត ទៅប្រកបដោយលទ្ធផលល្អប្រសើរ កាលពីថ្ងៃ ទី២១-២២ ខែធ្នូ ឆ្នាំ ២០០៤។

ព្រមជាមួយនេះផងដែរ ខ្ញុំសូមសម្តែងកោតសរសើរ នូវកតញ្ញូតាដ៏ស្មោះចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ ដែលជាគណៈវាគ្មិនកិត្តិយស និងជាសមាជិក សមាជិកា ស្ថាប័នរដ្ឋ សមាគម អង្គការសង្គមស៊ីវិល ដែលបានអញ្ជើញចូលរួមក្នុងវេទិកាទាំង ១០ លើក និងនៅក្នុងអង្គសន្និសីទថ្នាក់ជាតិ និងបានរួមចំណែកផ្តល់ជាវិភាគទានជាគតិបណ្ឌិត ទស្សនៈ យោបល់ ស្មារតី និងបទពិសោធន៍ដ៏ល្អៗ ដើម្បីជាគុណប្រយោជន៍ដល់ការអភិវឌ្ឍ នៃគោលនយោបាយជាតិ សេដ្ឋកិច្ចជាតិ សង្គមកិច្ច សន្តិភាព និងស្ថេរភាព សន្តិសុខអាស៊ានទាំងមូល។ ទស្សនៈ យោបល់

និងអនុសាសន៍របស់សមាជិក សមាជិកានៃអង្គវេទិកា និងអង្គសន្និសីទជាតិត្រូវបាន ប្រមូលផ្តុំ និងចងក្រងបញ្ចូលនៅក្នុងសៀវភៅនេះ សម្រាប់ជាឯកសារពិគ្រោះ។

នៅទីបញ្ចប់នេះ ខ្ញុំសូមវាយតម្លៃ និងសរសើរដោយស្មោះ ចំពោះការខិតខំប្រឹងប្រែង ទាំងបញ្ញា និងស្មារតីទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ បុគ្គលិក វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពរួមមាន: **ឯកឧត្តមបណ្ឌិត កៅ គីមហួន** (អតីតនាយកប្រតិបត្តិវិទ្យាស្ថាន) **លោក ស៊ីសុវត្ថិ ដួងច័ន្ទធោ** (អតីតនាយកប្រតិបត្តិរងវិទ្យាស្ថាន) **លោក សំរ៉ាំង កំសាន្ត** (អតីតអ្នកសំរបសំរួលគំរោងកម្មវិធី) **កញ្ញា នេត ច័ន្ទថា លោក ហម សំណាង លោក អ៊ុន តុងអាន លោក គ្នុំ គីម លោក សេង សុវីរៈ លោក អ៊ុនតុន អ៊ីង លោក អ៊ុក ផល្លី លោក ហ៊ិន សុធី លោក នេត ណារ៉ូ កញ្ញា នេត ណារ៉េន កញ្ញា នេត បញ្ញា អ្នកស្រី ប៉ក់ ផារ៉ាណែត អ៊ុន បូផាននី** (អតីតអ្នកស្រាវជ្រាវ) **និង កញ្ញា ចាន់ ធី** ដែលបានរួមចំណែកខិតខំប្រឹងប្រែងយ៉ាងសកម្ម អស់ពីកម្លាំងកាយ កម្លាំងចិត្ត កម្លាំងបញ្ញា ជួយសម្រួលក្នុងការរៀបចំធ្វើឱ្យវេទិកាទាំង ១០ លើក និងអង្គសន្និសីទជាតិនេះ បានសម្រេចលទ្ធផលល្អប្រសើរគួរជាទីមោទនៈ។

អ្នករៀបរៀង

បណ្ឌិត **ចាប សុថារិទ្ធ**

នាយកប្រតិបត្តិ

វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

# អារម្ភកថា

សមាហរណកម្មរបស់ប្រទេសកម្ពុជាទៅក្នុងតំបន់ និងក្នុងពិភពលោក គឺជាគោលដៅអាទិភាពមួយរបស់រាជរដ្ឋាភិបាល ដើម្បីបំបាត់នូវភាពឯកោរបស់ខ្លួនលើឆាកអន្តរជាតិ។ រាជរដ្ឋាភិបាលបានខិតខំពុះពារគ្រប់បែបយ៉ាងប្រកបដោយឆន្ទៈនយោបាយយ៉ាង មោះមុត ដើម្បីធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ ហើយនៅទីបំផុតប្រទេសកម្ពុជាបាន ក្លាយទៅជាសមាជិកពេញសិទ្ធិ របស់អាស៊ាននៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៩។ ចាប់តាំងពីបានក្លាយជាសមាជិកពេញសិទ្ធិរបស់អាស៊ានមកកម្ពុជា បានធ្វើការងារយ៉ាង សកម្មក្នុងការលើកកំពស់ទំនាក់ទំនងការទូត និងធ្វើសហប្រតិបត្តិការជាមួយប្រទេសជាសមាជិកលើគ្រប់វិស័យ មានជាអាទិ វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម សន្តិសុខ និងនយោបាយ។

ដើម្បីវាយតំលៃ និងសិក្សាឱ្យបានច្បាស់លាស់ អំពីសមិទ្ធផលដែលកម្ពុជាទទួលបាន និងការប្រឈមទាំងឡាយដែលកម្ពុជាបានជួបប្រទះ ក្នុងរយៈពេលប្រាំឆ្នាំក្រោយពីកម្ពុជាបានក្លាយជាសមាជិកអាស៊ាននេះ វិទ្យាស្ថានយើង បានរៀបចំវេទិកាសាធារណៈចំនួន ១០ លើក និងសន្និសីទជាតិមួយ ស្តីពី "**កម្ពុជា និងអាស៊ាន : ប្រាំឆ្នាំកន្លងមក**" ដែលជាគំរោងមានរយៈពេលមួយឆ្នាំ ក្នុងឆ្នាំ ២០០៤។

វត្ថុបំណងនៃវេទិកា និងអង្គសន្និសីទជាតិនេះគឺដើម្បី :

- ត្រួតពិនិត្យ និងវាយតំលៃអំពីការអភិវឌ្ឍទាំងឡាយ របស់កម្ពុជានៅក្នុងអាស៊ាន។
- ផ្សព្វផ្សាយពត៌មាន ស្តីអំពី គោលដៅអនាគតរបស់អាស៊ាន និងបញ្ហាប្រឈមទាំងឡាយដែលអាស៊ានជួបប្រទះ ដើម្បីឱ្យកម្ពុជាមានការយល់ដឹង កាន់តែប្រសើរ អំពីការវិវឌ្ឍន៍ទាំងឡាយរបស់អាស៊ាន។
- ជំរុញ និងលើកកំពស់ការពិភាក្សាក្នុងន័យស្ថាបនា រវាង សាធារណជន និងអ្នកធ្វើសេចក្តីសំរេចចិត្តទាំងឡាយ ដើម្បីលើកឡើងនូវ បញ្ហា ព្រួយបារម្ភ និងការផ្តល់នូវអនុសាសន៍ ទាំងឡាយ ទៅ រាជរដ្ឋាភិបាល។
- ផ្តោតអារម្មណ៍ និងយកចិត្តទុកដាក់លើបញ្ហាទាំងឡាយ ដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងក្លាមកលើប្រជាជនកម្ពុជា ក៏ដូចជា មកលើប្រទេសកម្ពុជាទាំងមូល។
- គូសបញ្ជាក់ពីតួនាទី សេចក្តីសង្ឃឹម ការព្រួយបារម្ភ ក៏ដូចជាការប្រឈមទាំងឡាយ របស់កម្ពុជានៅក្នុងបញ្ហាទាំងឡាយរបស់អាស៊ាន។
- ជំរុញឱ្យមានការគិតគូយ៉ាងខ្លាំងក្លាដល់ប្រទេសកម្ពុជា និងសង្គមស៊ីវិលអំពីអាស៊ាន និងលើកកំពស់នូវទំនាក់ទំនងរវាងដៃគូអភិវឌ្ឍន៍ទាំងអស់ ឱ្យកាន់តែប្រសើរឡើង។

វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពយល់ថា ប្រធានបទ "**កម្ពុជា ក្នុងអាស៊ាន : ប្រាំឆ្នាំកន្លងមក**" មានសារៈសំខាន់ណាស់ ដើម្បីធ្វើការវាយតំលៃ និងយល់ដឹងឱ្យបានច្បាស់នូវសមិទ្ធផល និងការប្រឈមទាំងឡាយដែលកម្ពុជាជួបប្រទះ ពិសេសវាមានសារៈសំខាន់បំផុត សម្រាប់ប្រទេសកម្ពុជា ដែល

កំពុងតែ អនុវត្តនូវគោលនយោបាយសេដ្ឋកិច្ចបើកចំហ និងធ្វើសមាហរណកម្មនៅក្នុងចរន្តសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ច ពិភពលោក ។ ដោយហេតុនេះហើយ បានជា យើងខិតខំសិរិតសំរាំង ចងក្រងជាសៀវភៅនេះ ដោយប្រមូលផ្ដុំនូវគំនិត និង ទស្សនៈទាំងឡាយ និងជ្រើសរើសអត្ថបទ ជំរើសខ្លះៗ ដែលវាគ្មិនបានបង្ហាញក្នុង វេទិកា សាធារណៈ និងសន្និសីទជាតិ។ ការចងក្រង ឯកសានេះគឺ សំដៅលើកកំពស់ការយល់ដឹង នៅក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវ និង អ្នករៀបចំ គោលនយោបាយទាំងឡាយ អំពីដំណើរការបញ្ចាប្រឈម ក៏ដូចជាការវិវឌ្ឍន៍ ទាំងឡាយរបស់អាស៊ាន ដែលបានជះឥទ្ធិពលមកលើកម្ពុជា មកពិចារណាដកស្រង់ បទពិសោធន៍ល្អៗ និងរំលេចឱ្យឃើញ នូវញ្ហានានាដែលកម្ពុជាបានជួបប្រទះ ដើម្បីធ្វើការដោះស្រាយ និងកែលំអ ក្នុងគោលបំណងអភិវឌ្ឍប្រទេសប្រកបដោយចិរភាព។

ទន្ទឹមនឹងនេះដែរ វិទ្យាស្ថានសូមបញ្ជាក់ថា រាល់ការពន្យល់ ការអធិប្បាយ និងជំហរនានាដែលមានចែងក្នុងឯកសានេះ គឺជារបស់អ្នកនិពន្ធផ្ទាល់ និងជាការទទួលខុសត្រូវក្នុងការកែសំរួលពាក្យពេចន៍ និងខ្លឹមសារខ្លះរបស់អ្នករៀបរៀង គឺបណ្ឌិត **ចាប សុថារិទ្ធ** ដែលជានាយកប្រតិបត្តិនៃវិទ្យាស្ថានយើង ហើយមិនបានឆ្លុះបញ្ចាំងនូវមតិឬជំហរបស់វិទ្យាស្ថានទេ។ យើងខ្ញុំក៏សូមអធ្យាស្រ័យ ចំពោះការយឺតយ៉ាវក្នុងការបោះពុម្ព និងសូមអភ័យទោសចំពោះ ចំណុចខ្វះខាត និងកំហុសឆ្គងបច្ចេកទេសឬពាក្យពេចន៍នានា ដែលអាចមានជាយថាហេតុនៅក្នុងការបោះពុម្ពសៀវភៅនេះ។

សៀវភៅនេះនឹងមាន អត្ថប្រយោជន៍សម្រាប់យើង ដើម្បីស្វែងយល់អំពីកម្ពុជា និងអាស៊ាន។ ដូច្នេះសៀវភៅនេះនឹងអាចប្រើប្រាស់ ជាឯកសារយោងចំពោះប្រិយមិត្តទាំងឡាយណា ដែលមានការចាប់អារម្មណ៍ ស្ដីអំពីគោលនយោបាយ

ពាណិជ្ជកម្ម យុទ្ធសាស្ត្រសេដ្ឋកិច្ច និងទិសដៅអនាគតសម្រាប់កម្ពុជា ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមាពីសមាហរណកម្មក្នុងអាស៊ាន។

សូមប្រិយមិត្ត អ្នកអានទាំងអស់ ជួបប្រទះតែសេចក្ដីសុខ និងជោគជ័យគ្រប់ភារកិច្ច ដើម្បីកសាងប្រទេសជាតិយើងឱ្យសម្បូររុងរឿង និងមានកិត្តិសព្ទល្បីល្បាញលើឆាកអន្តរជាតិ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៥

**សម្ដេច នរោត្តម សិរីវុឌ្ឍ**

ព្រះប្រធានក្រុមប្រឹក្សាភិបាល

វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

# ព្រះសុន្ទរកថាស្វាគមន៍

**ដោយសម្តេច នរោត្តម សិរីវុឌ្ឍ**

*ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ*

*និងជាព្រះប្រធានក្រុមប្រឹក្សាភិបាល វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និង សន្តិភាព*

ថ្ងៃនេះ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព មានកិត្តិយសដ៏ឧត្តុង្គឧត្តមបំផុត ដោយបានទទួលព្រះវត្តមានដ៏ខ្ពង់ខ្ពស់ របស់សម្តេច ក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានសភាជាតិ ក្នុងសន្និសីទជាតិ ស្តីពី **"ប្រទេសកម្ពុជា និងសមាគមអាស៊ាន : ក្នុងរយៈពេលប្រាំឆ្នាំក្រោយមក"** ដែលរៀបចំឡើងដោយវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និង សន្តិភាព និងមូលនិធិ ហ្វ្រីឌ្រិច អេប៊ែត (FES) នៅក្នុងទិវាដ៏មហោឡារិកនេះ។

ក្នុងនាមក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និង សន្តិភាព ទូលព្រះបង្គំ សូមសម្តែងនូវមនោសញ្ចេតនាអបអរសាទរ និង ប្រសិទ្ធពរសាគមន៏ ដោយស្មោះស្ម័គ្រ និងអំណរគុណដ៏ខ្ពង់ខ្ពស់ ចំពោះសម្តេច ក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានសភាជាតិ ដែលបានចំណាយ ព្រះកាយពល និងពេលវេលា

ដ៏មានតម្លៃយ៉ាងចូលរួម ក្នុងពិធីបើកសន្និសីទជាតិ ដ៏មានសារៈសំខាន់ ស្តីពី **"ប្រទេសកម្ពុជា និងសមាគមអាស៊ាន"** នេះ។

ម្យ៉ាងទៀត ទូលបង្គំ-ខ្ញុំ សូមឆ្លៀតឱកាសដ៏មានតម្លៃនេះដែរ ដើម្បី សម្តែងនូវសេចក្តីដឹងគុណដ៏ខ្ពង់ខ្ពស់ ចំពោះមូលនិធិ ហ្វ្រីឌ្រិច អេប៊ែត (FES) ដែលបានឧបត្ថម្ភទាំងសម្ភារៈ និងស្មារតី ក៏ដូចជាថវិកាដល់ការបង្កើត និងរៀបចំ ឱ្យមាននូវវេទិកាទាំង ១០ លើក និងសន្និសីទជាតិ ស្តីពី **"ប្រទេសកម្ពុជា និងសមាគមអាស៊ាន"** ក្នុងឆ្នាំ ២០០៤ នេះ។ មិនតែប៉ុណ្ណោះ មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត ដែលតំណាងដោយ លោក Norbert von Hofmann ប្រធានការិយាល័យសម្រាប់ សហប្រតិបត្តិការតំបន់អាស៊ីអាគ្នេយ៍នេះ តែងបានជួយឧបត្ថម្ភ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព មួយផ្នែកធំលើវិស័យរដ្ឋបាល ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ ១០ ឆ្នាំ មកហើយ។ សហប្រតិបត្តិការ និងការឧបត្ថម្ភដ៏សប្បុរសរបស់មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត គឺជា អំណោយដ៏ថ្លៃថ្លាដែលពុំអាចបំភ្លេចបាន។

ឆ្លៀតឱកាសនេះដែរ ក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព សូមសម្តែងនូវកតញ្ញូតាដ៏ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល សភាជាតិ ព្រឹទ្ធសភា ក៏ដូចជា អង្គការសង្គមស៊ីវិលគ្រប់ជាន់ថ្នាក់ រួមទាំងផ្នែកឯកជនផងដែលបានចូលរួមផ្តល់មតិពិភាក្សាផ្លាស់ប្តូរទស្សនៈ នៅក្នុងគ្រប់វេទិកា ស្តីពី ប្រទេសកម្ពុជា និងសមាគមអាស៊ានទាំង ១០ លើក ដែលបានប្រព្រឹត្តទៅ ប្រកបដោយលទ្ធផលល្អប្រសើរ ក្នុងរយៈពេលពេញមួយឆ្នាំកន្លងមកនេះ។ សហប្រតិបត្តិការ និងការចូលរួមដ៏មានតម្លៃនេះ គឺពិតជាអាចឆ្លុះ បញ្ចាំងបាននូវសមានចិត្តដ៏ល្អ និង

ការឧបត្ថម្ភគាំទ្រដ៏ស្មោះដល់សកម្មភាពដ៏ត្រឹម ត្រូវរបស់វិទ្យាស្ថានខ្មែរសំរាប់ សហប្រតិបត្តិការ និងសន្តិភាព ក្នុងការលើកស្ទួយ ចំណេះដឹង ការអប់រំផ្សព្វផ្សាយ និងការប្រមូលផ្តុំទស្សនៈបញ្ញវន្ត និងប្រជា ពលរដ្ឋ ដើម្បីរួមចំណែកកសាង និងអភិវឌ្ឍប្រទេសជាតិយើង។

សន្និសីទជាតិ ស្តីពី "**ប្រទេសកម្ពុជា និង សមាគមអាស៊ាន : ក្នុងរយៈពេលប្រាំឆ្នាំក្រោយមក**" ដែលនឹងប្រព្រឹត្តទៅក្នុងរយៈពេលពីរថ្ងៃ នេះ គឺមានបំណង ដាក់ជូនពិនិត្យ និងស្នើសុំយោបល់សម្រេចទៅលើលទ្ធផលនៃ វេទិកាពិភាក្សាទាំង ១០ លើក ក្នុងឆ្នាំ ២០០៤ ស្តីពី ការពិនិត្យមើលការវិវត្តន៍ ឬវឌ្ឍនភាពនៃប្រទេសកម្ពុជាក្នុងការធ្វើសមាហរណកម្មអស់រយៈពេល ០៥ ឆ្នាំ ទៅក្នុងតំបន់អាស៊ាន។ លទ្ធផលជាចំណេះដឹង និងបទពិសោធន៍ ក៏ដូចជា ទស្សនៈ និងអនុសាសន៍ទាំងឡាយ ដែលប្រមូលផ្តុំតាមរយៈវេទិកាអស់រយៈពេលពេញ មួយឆ្នាំកន្លងមកនេះ គឺជាការឆ្លុះបញ្ចាំងឱ្យឃើញ "**ឧស្សនៈ** (Insight)" ប្រកបដោយការវិភាគ និងវិចារណញ្ញាណរបស់មន្ត្រីរាជការ អ្នកដឹកនាំអង្គការសង្គមស៊ីវិល ផ្នែកឯកជន និស្សិត បញ្ញវន្ត និងមហាជនជាច្រើន ដែលបានយកចិត្តទុកដាក់ទៅលើការពិនិត្យមើល ដំណើរការនៃការធ្វើសមាហរណកម្ម ប្រទេសកម្ពុជាទៅក្នុងតំបន់ ទាំងជ័យជំនះ និងការខ្វះខាត សំដៅស្វែងរកវិធានការកែលំអ ដើម្បីជំរុញឱ្យសមាជិកភាពនៃប្រទេកម្ពុជា ទៅក្នុងសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍កាន់ តែមានភាពសកម្ម និងទទួលបានផលប្រយោជន៍ពិតប្រាកដជូនប្រជាពលរដ្ឋ និងប្រទេសជាតិ។

មតិរបស់មហាជន និងប្រជាពលរដ្ឋ គឺជាមតិ ដែលចាំបាច់ត្រូវគោរពលើកស្ទួយ ព្រោះនោះគឺជាគតិបណ្ឌិតមហាជន ដែលជាគន្លឹះនៃវឌ្ឍនភាព និងលទ្ធិប្រជាធិបតេយ្យ។ មតិមហាជន គឺជាមតិប្រកបដោយ សេរីភាព និងជាការចូលរួមចំណែកគួសវាស វាសនារបស់ប្រទេសជាតិ ដែលជាសិទ្ធិមួយ ដែលត្រូវគោរព និងទទួលស្គាល់ ដោយរដ្ឋធម្មនុញ្ញ។ ការដែលយើងប្រមូលផ្តុំបានទស្សនៈ សម្បូរបែប និងមតិមហាជនកាន់តែច្រើន នៅលើវេទិកានេះ នោះនឹងធ្វើឱ្យយើងកាន់តែ លើកស្ទួយបាននូវសិទ្ធិ និងសេរីភាព របស់មហាជន និងប្រជាពលរដ្ឋ ក្នុងការចូលរួម មតិស្ថាបនា និងអភិវឌ្ឍន៍ប្រទេស ជាតិយើង។

ឆ្លងតាមរយៈនៃវេទិកាទាំង ១០ លើក ស្តីពី **"ប្រទេសកម្ពុជា និងសមាគមអាស៊ាន"** អស់រយៈពេញមួយឆ្នាំកន្លងមកនេះ អង្គពិភាក្សាបានរក ឃើញថា ការពិនិត្យមើលការវិវត្តន៍នៃសមាហរណកម្មប្រទេសកម្ពុជា ទៅក្នុង តំបន់ (អាស៊ាន) មានសារៈសំខាន់ណាស់ដល់ការជំរុញសមាជិកភាព នៃប្រទេសជាតិយើងឱ្យកាន់តែមានភាពរឹងមាំ និងទទួលបាននូវអត្ថប្រយោជន៍ពិតប្រាកដ ជូនប្រជាពលរដ្ឋយើង។ ដរាបណាសមាជិកភាពនេះ ពុំត្រូវបានពិនិត្យ និងធ្វើការវាយតម្លៃឱ្យបានត្រឹមត្រូវអំពីសមិទ្ធផល និងការខ្វះខាតទេ ដរាបនោះ សមាជិកភាពនេះ ពុំអាច ឆ្លើយតបបានទៅនឹងបំណងប្រាថ្នា និងសំណូមពរពិត ប្រាកដរបស់ប្រជាពលរដ្ឋ យើងក្នុងការចូលរួមក្នុងតំបន់ឡើយ។ ការស្វែងរកឱ្យឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយនៃការចូលរួមក្នុងតំបន់ គឺជាគន្លឹះនៃវឌ្ឍនភាព និងការទទួលបានផលប្រយោជន៍ជាក់ច្បាស់អំពីសមាហរណកម្មនេះ។

ដោយយល់ឃើញដូច្នោះហើយ បានជាវេទិកាទាំង ១០លើក ស្តីពី **ប្រទេសកម្ពុជា និងសមាគមអាស៊ាន** និងសន្និសីទជាតិ ស្តីពី បញ្ហានេះ ត្រូវបានបង្កើត និងរៀបចំឱ្យកើតជារូបរាងឡើង។ គោលដៅជាសក្តានុពលនៃអង្គសន្និសីទនេះ នោះគឺ ដើម្បីពិនិត្យមើលដោយការយកចិត្តទុកដាក់បំផុត នូវសមិទ្ធផល ជាគុណសម្បត្តិ និងការប្រឈមមុខក្នុងការធ្វើសមាហរណកម្ម នៃប្រទេសជាតិយើង ទៅក្នុងតំបន់ក្នុងរយៈពេល ០៥ ឆ្នាំ កន្លងមកនេះ ដើម្បីស្វែងរកវិធានការកែលំអ និងដៅទិសអនុវត្តទៅអនាគត។ សំណូមពរដ៏ចាំបាច់ និងគោលដៅចម្បងនៃការបើក អង្គសន្និសីទជាតិនេះគឺការស្នើសុំឱ្យអង្គសន្និសីទ ជាតិ មេត្តាជួយពិនិត្យមើលលទ្ធផលនៃវេទិកាទាំង ១០ លើក ដែលវិទ្យាស្ថានបានចងក្រងជារបាយការណ៍ និងដាក់ជូនពិនិត្យនេះ ដើម្បីបានជាឯកសារសម្រាប់ ការផ្សព្វផ្សាយ។ តើចំណេះដឹងជាបទពិសោធន៍ និងសំណូមពរជាអនុសាសន៍ដែលអង្គវេទិកាទាំង ១០ លើក បានរកឃើញនេះអាចចាត់ទុកថា ជាចំណេះដឹង និងជាបទពិសោធន៍របស់មហាជន និងបញ្ញវន្ត ដើម្បីរួមចំណែកស្ថាបនាសមាហរណកម្មកម្ពុជា ឱ្យបានរុងរឿងទៅអនាគតបានឬទេ? ប្រសិន បើមានការខ្វះខាត តើយើងគួរកែលំអដូចម្តេច?

ទូលព្រះបង្គំ-ខ្ញុំ សូមទូលថ្វាយ និងជម្រាបជូននូវគោលបំណងសំខាន់ៗ នៃការរៀបចំអង្គសន្និសីទជាតិតែប៉ុណ្ណេះ។ សង្ឃឹមថា អ្នកសម្របសម្រួលនៃអង្គសន្និសីទជាតិ និងជម្រាបជូនពិស្តារថែមទៀត នូវលទ្ធផលសំខាន់ៗ នៃកិច្ចពិភាក្សាទាំង ១០ លើក ក្នុងពេលព្រឹកនេះ ដើម្បីបានជាមូលដ្ឋានសម្រាប់ការពិចារណាមុននឹងបើក សម័យប្រជុំពិភាក្សា។

ទូលព្រះបង្គំ-ខ្ញុំ មានក្តីសង្ឃឹមយ៉ាងមុតមាំថា សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម, លោកជំទាវ អស់លោក-លោកស្រី ជាគណៈវាគ្មិន និងជាសមាជិក សមាជិកា នៃ អង្គសន្និសីទជាតិ ពិតជាចូលរួមចំណែកផ្តល់ទស្សនៈ និងមតិយោបល់ជាច្រើនទៀត ដើម្បីឱ្យលទ្ធផលនៃកិច្ចពិភាក្សា ក្នុងវេទិកាទាំង ១០ លើក ក្នុងឆ្នាំ ២០០៤ នេះ ឱ្យកាន់តែមានសុក្រឹតភាព ប្រសិទ្ធិភាព និងគុណប្រយោជន៍ ពិតប្រាកដដល់ការធ្វើ សមាហរណកម្ម នៃប្រទេសជាតិយើងទៅក្នុងតំបន់។ សូមទូលថ្វាយ និងជម្រាបថា គោលដៅរួមរបស់យើងខ្ញុំមានតែមួយទេ នោះគឺការចូលរួមចំណែកលើកស្ទួយចំណេះដឹង និងការអប់រំផ្សព្វផ្សាយអំពីសារៈសំខាន់ នៃសមាជិកភាពរបស់ប្រទេសជាតិយើង ក្នុង សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា អាស៊ាន នេះឱ្យបានដល់ ប្រជាពលរដ្ឋ យើងទាំងមូលសំដៅ ស្ថាបនាកម្លាំងគាំទ្រ និងការចូលរួមរបស់មហាជន ដែលជាគន្លឹះដ៏រឹងមាំដល់ ការចូលរួមក្នុងតំបន់ និងលើពិភពលោក។ ការផ្តល់មតិរបស់ យើងគឺជាការផ្តល់ យោបល់ស្ថាបនា យើងគ្មានចេតនា ផ្ចាញ់ផ្ចាល បន្តុះបង្អាប់ ឬបំផ្លិចបំផ្លាញអ្វីឡើយ។ ដូច្នេះ រាល់មតិយោបល់ដែល មានចរិតរិះគន់ទាំងឡាយ គួរតែធ្វើ ឡើងដោយចិត្តស្រឡាញ់ ដោយក្តីស្មោះសរ ដោយឆន្ទៈស្ថាបនា ដើម្បីឧត្តម ប្រយោជន៍របស់ប្រទេសជាតិ និងប្រជាពលរដ្ឋយើង។ សិទ្ធិសេរីភាព ក្នុងការបញ្ចេញ មតិនៅក្នុងវេទិកានេះចាំបាច់ត្រូវតែបានគោរព។

នៅទីបញ្ចប់នេះ ក្នុងនាមក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានខ្មែរសំរាប់ សហប្រតិបត្តិការ និងសន្តិភាព ទូលព្រះបង្គំ-ខ្ញុំ សូមសម្តែងសារជាថ្មីម្តងទៀត នូវអំណរសាទរ និងការប្រសិទ្ធពរ ស្វាគមន៍ដ៏ស្មោះអស់ពីចិត្ត ចំពោះព្រះវត្តមាន

ដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានសភាជាតិ ដែលបានចំណាយព្រះកាយពល និងពេលវេលាដ៏មានតម្លៃ-យាងចូលរួមផ្តល់ ព្រះកិត្តិយសដ៏ឧត្តុង្គឧត្តមដល់ពិធីបើកអង្គសន្និសីទជាតិ និងសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់ ចំពោះឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ អន្តរជាតិ គណៈវាគ្មិនកិត្តិយស សមាជិក សមាជិកានៃអង្គសន្និសីទទាំងមូល ដែលបានអញ្ជើញចូលរួមដ៏ កុះករនេះ។

សូមថ្វាយព្រះពរ និងជូនពរឱ្យបានប្រកបដោយពុទ្ធពរទាំង ប្រាំប្រការ គឺអាយុវណ្ណ សុខៈពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# សុន្ទរកថាស្វាគមន៍

## ដោយលោក ណ័រប៊ឺត វ៉ុន ហូហ៍ាន់

*ប្រធានការិយាល័យសម្រាប់សហប្រតិបត្តិការ ភូមិភាគអាស៊ីអាគ្នេយ៍នៃមូលនិធិ ហ្វ្រីឌ្រិច-អេប៊ែត Friedrich-Ebert -Stiftung (FES) សឹង្ហបុរី*

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានស្វាគមន៍អស់លោក ក្នុងនាម មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត ស្ទីហ្វទុង (Friedrich Ebert Stiftung) ដែលបានមកចូលរួមក្នុងសន្និសីទជាតិស្តីពី "**កម្ពុជា និងអាស៊ាន : ប្រាំឆ្នាំ ក្រោយមក**"។

មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត (FES) បានបង្កើតឡើងនៅក្នុងឆ្នាំ ១៩២៥ គឺជាមូលនិធិឯកជនមិនមែនរដ្ឋាភិបាល នៅក្នុងសាធារណរដ្ឋសហព័ន្ធ អាឡឺម៉ង់ដ៏។ មូលនិធិនេះមានការប្តេជ្ញាចិត្តចំពោះគំនិត និងតម្លៃជាមូលដ្ឋាននៃ សង្គមប្រជាធិបតេយ្យ ហើយបានពិនិត្យដើម្បីថា ខ្លួនជាស្ថាប័នស្រាវជ្រាវជាន់ខ្ពស់ (Think Tank) នៃគណបក្សកាន់អំណាចបច្ចុប្បន្ន គឺជាគណបក្សសង្គម ប្រជាធិបតេយ្យអាឡឺម៉ង់ដ៏។

ដោយយកឈ្មោះប្រធានាធិបតីជាប់ឆ្នោត ដោយលក្ខណៈប្រជាធិបតេយ្យដំបូងគឺលោក Friedrich Ebert មូលនិធិបានបន្តមរតក ស្តីពីការអភិវឌ្ឍន៍

នយោបាយនៃសេរីភាព សាមគ្គីភាព និងយុត្តិធម៌សង្គម។ លោក Ebert ជាជនប្រជាធិបតេយ្យសង្គម ដែលមានប្រវត្តិជាមនុស្សសាមញ្ញម្នាក់បានរះឡើង ដោយកាន់អំណាចនយោបាយខ្ពស់បំផុតនៅក្នុងប្រទេស ទោះបីជាមាន ការប្រឆាំងតវ៉ាជាច្រើនពីគូបដិបក្ខនយោបាយរបស់គាត់ក៏ដោយ។ គាត់បាន ឡើងកាន់អំណាចឡើងវិញ ជាប្រធានាធិបតី នៅក្នុងរដ្ឋដែលរងគ្រោះដោយវិបត្តិ បន្ទាប់ពីប្រទេសអាឡឺម៉ង់ដ៏បរាជ័យនៅក្នុងសង្គ្រាមលោកលើកទី ១ ។

មូលនិធិ FES បច្ចុប្បន្នបានរក្សាតំណាងរបស់ខ្លួននៅក្នុងប្រទេសជាង ៨០ នៅក្នុងពិភពលោក ហើយបានដើរតួនាទីយ៉ាងសកម្មនៅក្នុងអាស៊ីអាគ្នេយ៍ អស់រយៈពេលជាច្រើនឆ្នាំ ដែលមានការិយាល័យនៅក្នុងក្រុងបាងកក ហ្សាកាតា ទីក្រុងម៉ានីល ហាណូយ និងសិង្ហបុរី។

ការលើកកំពស់ ការយល់ដឹងជាអន្តរជាតិ ក្នុងចំណោមទ្វីបអាស៊ី និង អឺរ៉ុប ក៏ដូចជាក្នុងចំណោមទ្វីបអាស៊ី គឺជាគោលបំណងមួយនៃគោលបំណងរបស់មូលនិធិ។ មូលនិធិចាត់ទុកសកម្មភាពរបស់ខ្លួន នៅក្នុងផ្នែកនេះនៃពិភពលោកថា ជាការរួមចំណែកចំពោះការសម្របសម្រួលសហប្រតិបត្តិការតំបន់ និងពិភពលោករវាងរដ្ឋ និងរវាងក្រុមដែលមានចំណាប់អារម្មណ៍ ដើម្បីជួយធ្វើឱ្យមាន លំនឹងផលប្រយោជន៍ ដើម្បីដោះស្រាយជម្លោះ និងដើម្បីធ្វើឱ្យរីកចម្រើននូវ ជំរើសនានា។

នៅក្នុង FES យើងមានមោទនភាពដោយបានសហការយ៉ាងជិតស្និទ្ធជាមួយវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ជាដៃគូរបស់យើង បានធ្វើឱ្យ

មានផ្លែផ្កា និងមានបទពិសោធន៍ជាវិជ្ជមាន ចំពោះភាគីទាំង២ ចាប់ តាំងពីការបង្កើត វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព នៅឆ្នាំ ១៩៩៤ មក។

នៅពេលដែលអ្នកបង្កើតអាស៊ានបានជួបប្រជុំគ្នាកាលពី ៣៧ ឆ្នាំមុន ក្នុងទីក្រុងបាងកក ដើម្បីបង្កើតសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ ពួកគេមិនអាចស្រមៃឃើញភ្លាមៗ ពីការផ្លាស់ប្តូររបស់ពិភពលោក ហើយទិសដៅរបស់ពួក គេបាន ត្រូវគេធ្វើទៅហួស។ ការភ័យខ្លាចពីលទ្ធិកុម្មុយនីស គឺជាកម្លាំងជំរុញនៅពី ខាងក្រោយអ្នកបង្កើតអាស៊ានទាំង ៥ គឺប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សង្ហបុរី និងប្រទេសថៃ។ គ្មាននរណាម្នាក់ចង់ក្លាយជាសមាជិកបន្ទាប់គេ ដែលនឹងត្រូវធ្លាក់ នោះទេ (next domino-stone to fall)។

ទោះយ៉ាងនេះក៏ដោយ នៅចុងបញ្ចប់នៃសង្គ្រាមត្រជាក់ វាមិនមែនជាយោធា ដែលត្រូវឈ្នះសមរភូមិ ប្រឆាំងលទ្ធិកុម្មុយនីសដែលកំពុងរីកចម្រើននោះទេ តែវាជាកំណើនសេដ្ឋកិច្ចយ៉ាងរហ័ស។ លទ្ធិកុម្មុយនីសបានបាត់បង់នូវការទាក់ទាញរបស់ខ្លួន។

សមាជិកអាស៊ានបន្ទាប់មកក៏បានយល់បន្តិចបន្តួចថា មានតម្រូវការទំរង់ថ្មី នៃភាពប្រាកដនិយម។ អាស៊ានក៏បានមានប្រតិកម្មជាលើកដំបូងដោយ ចាប់យកប្រទេសដែលនៅសេសសល់មកធ្វើជាសមាជិក។

ប្រទេសវៀតណាមបានក្លាយជាសមាជិកអាស៊ាននៅឆ្នាំ ១៩៩៥ ប្រទេសឡាវ និងភូមា នៅឆ្នាំ ១៩៩៧ ហើយចុងក្រោយគឺ កម្ពុជានៅឆ្នាំ ១៩៩៩ គឺ ៥ ឆ្នាំមុននេះឯង។ បច្ចុប្បន្នអាស៊ានមាន ១០ ប្រទេសជាសមាជិក ហើយប្រជាពលរដ្ឋមាន ជាង ៥០០ លាននាក់ គឺ១ភាគ១២ នៃប្រជាជនក្នុងពិភពលោក។ លើសពីអ្វីដែលរដ្ឋ

ជាសមាជិក ដែលជាអ្នកជិតខាងគ្នាតាមរយៈភូមិសាស្ត្រ តាមខ្ញុំយល់អាស៊ានមានអ្វីមួយជារួមតិចតួចណាស់។ សមាជិកអាស៊ាន ជាឧទាហរណ៍ មានប្រព័ន្ធគ្រប់គ្រងខុសផ្លែក១គ្នា ចាប់តាំងពីការគ្រប់គ្រង ដោយរបបរាជានិយមទាំងស្រុងនៅក្នុងប្រទេសប្រ៊ុយណេ រហូតដល់របបប្រជាធិប តេយ្យ 3/4 2/4 ឬ 1/4 នៅក្នុងប្រទេសថៃ ម៉ាឡេស៊ី និងកម្ពុជា និងមានប្រទេសកុំម្មុយនីសគណបក្សតែមួយ ដូចជាប្រទេសវៀតណាម ឡាវ និង របបផ្តាច់ការយោធា គឺប្រទេសភូមា។

យោងតាមរបាយការណ៍ អភិវឌ្ឍមនុស្សឆ្នាំ ២០០៤ របស់អង្គការ UNDP ដែលបានយកចិត្តទុកដាក់ដល់កំណើត អត្រាអក្ខកម្ម ការអប់រំ និងកំណើនក្នុងស្រុក នៃប្រទេសចំនួន ១៧៧ បានចំណាត់ថ្នាក់ប្រទេសសឹង្ហបូរី ក្នុងលំដាប់ទី ២៥ ក្នុងកម្រិតអភិវឌ្ឍមនុស្សខ្ពស់ បន្ទាប់មកមានប្រទេសប្រ៊ុយណេលំដាប់ទី ៣៣ ម៉ាឡេស៊ី ៥៩ ដែលនាំមុខ។ ប្រទេសដែលមានការអភិវឌ្ឍមនុស្សមធ្យម គឺប្រទេសថៃលំដាប់ ៧៦ ប្រទេសហ្វីលីពីន ៨៣ ឥណ្ឌូនេស៊ី ១១១ វៀតណាម ១១២ កម្ពុជា ១៣០ ភូមា ១៣២ និងឡាវ ១៣៥។ ជាការប្រៀបធៀបគ្រប់សមាជិកទាំង ២៥ នៃសហភាពអឺរ៉ុប បានស្ថិតក្នុង ប្រភេទទី ១ នៃប្រទេសចំនួន ៥០ ដែលមាន "ការអភិវឌ្ឍមនុស្សខ្ពស់"។ អង្គការតំបន់ណាមួយក៏ដោយ ដែលមានសមាជិកជួបប្រទះនូវប្រព័ន្ធនយោបាយ និងដំណាក់ការ នៃការអភិវឌ្ឍន៍ខុសគ្នាបែបនេះពិតជាមានបញ្ហាស្រដៀងគ្នា នឹងសមាជិកនៃសមាគមអាស៊ានដែរ។ ដូច្នេះ គេគិតថា គោលដៅជាអាទិភាពបំផុតត្រូវលើកកំពស់ផ្នែកនយោបាយ និងសេដ្ឋកិច្ចរបស់ប្រទេសទន់ខ្សោយដើម្បីឱ្យទាន់គេ ទៅតាមកម្លាំងរបស់ខ្លួនដែលមានទាំងអស់។

ក្នុងកិច្ចប្រជុំកំពូលក្រៅផ្លូវការអាស៊ានទី ២ ដែលបានរៀបចំធ្វើនៅ ទីក្រុងកូឡាឡាំពួ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ បានដាក់ចេញនូវទស្សនាទាន អាស៊ានឆ្នាំ ២០២០ ដែលជាទស្សនាទានទូលំទូលាយសម្រាប់អាស៊ាន គឺជាប្រជាជាតិអាស៊ីអាគ្នេយ៍ រួបរួមគ្នា សំលឹងទៅមុខរស់នៅដោយសន្តិភាព ស្ថេរភាព និងវិបុលសុខ ចងបាច់គ្នាជាដៃគូ នៅក្នុងការអភិវឌ្ឍន៍ជាថាមពល និងក្នុងសហគមន៍ដែលយកចិត្តទុកដាក់ដល់សង្គម។

ដើម្បីអនុវត្តទស្សនាទានយូរអង្វែង គំរោងសកម្មភាពទីក្រុង ហាណូយ (HPA) ត្រូវបានបង្កើតឡើង។

នៅកិច្ចប្រជុំកំពូលអាស៊ានលើកទី ១០ កាលពីប៉ុន្មានថ្ងៃមុននៅក្នុងទីក្រុងវៀងច័ន្ទ មេដឹកនាំអាស៊ានបានចុះហត្ថលេខាលើកម្មវិធីសកម្មភាពក្រុងវៀងច័ន្ទ (VAP) ដែលជាគំរោងសម្រាប់រយៈពេល ៦ ឆ្នាំ ដែលជាគំរោងបន្ត វេនពី HPA ដើម្បីធ្វើឱ្យសម្រេចនូវគោលដៅចុងបញ្ចប់នៃទស្សនាទានអាស៊ាន និងសេចក្តីប្រកាស កិច្ចព្រមព្រៀង អាស៊ាន II (Declaration of ASEAN Concord II)។ កម្មវិធីសកម្មភាពទីក្រុងវៀងច័ន្ទ បានពិនិត្យជាពិសេសលើការ ធ្វើឱ្យស៊ីជំរៅនូវសមាហរណកម្មតំបន់ និងការបង្រួញគំលាតអភិវឌ្ឍនៅក្នុងអាស៊ាន ពិសេសជាមួយប្រទេសជាសមាជិកដែលមានការអភិវឌ្ឍន៍ទាបបំផុត។

នៅក្នុងកិច្ចព្រមព្រៀង បាលី II មេដឹកនាំអាស៊ានបានយល់ស្របគ្នា ដើម្បីបង្កើតសហគមន៍អាស៊ានដែលរួមមាន ៣ ដូចជា សហគមន៍នយោបាយ និងសហប្រតិបត្តិការសន្តិសុខ សហប្រតិបត្តិការសេដ្ឋកិច្ច និងសហប្រតិបត្តិការសង្គម វប្បធម៌

ដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ និងជំរុញគ្នាទៅវិញទៅមកដើម្បីសន្តិភាពយូរអង្វែង ស្ថេរភាព និងរួមវិបុលសុខនៅក្នុងតំបន់។

ដោយពិនិត្យឃើញពីតំណាក់ការនៃការខ្វែងគំនិតគ្នា ដែលកំពុងកើត ឡើងក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច មេដឹកនាំអាស៊ានបានគូសបញ្ជាក់ថា :

សហគមន៍សេដ្ឋកិច្ចអាស៊ានត្រូវធានាថា ការធ្វើឱ្យស៊ីជំរៅ និងទូលំទូលាយនូវការធ្វើសមាហរណកម្មអាស៊ាន ត្រូវតែមានការសហប្រតិបត្តិការ និងអភិវឌ្ឍន៍ដើម្បីដោះស្រាយ ការបែងចែកការអភិវឌ្ឍន៍ និងបង្កើនល្បឿននៃ សហមារណកម្មសេដ្ឋកិច្ចរបស់កម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ ភូមា និង វៀតណាម តាមរយៈគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន (IAI) និង តាមរយៈផែនទីសកម្មភាពសម្រាប់សមាហរណកម្ម (RIA)ដែលផលប្រយោជន៍ នៃសមាហរណកម្មអាស៊ានត្រូវ បានចែករំលែក និងអាចធ្វើឱ្យប្រទេសជាសមាជិកអាស៊ានទាំងអស់រំកិលទៅមុខ តាមបែបផែនសាមគ្គីគ្នា។

នៅក្នុងការវាយតំលៃគំរោងសកម្មភាពទីក្រុង ហាណូយ ដែល FES បានអនុវត្តជាមួយ ASEAN-ISIS នៅក្នុងខែសីហា ឆ្នាំ ២០០៣ នៅក្នុងទីក្រុង វៀងច័ន្ទអ្នកចូលរួមទាំងអស់បានសន្និដ្ឋានថា ចំពោះ HPA មានសមិទ្ធផល តិចតួចណាស់ត្រូវបានធ្វើឱ្យសម្រេច ទោះបីជាចំណុចទាំងអស់នៅក្នុង HPA មានសារៈសំខាន់ធំធេងយ៉ាងណាក៏ដោយ។ ទោះយ៉ាងនេះក្តី ក៏ការបំលែងនិង ការអនុវត្តន៍ បញ្ជីសកម្មភាព និងទិសដៅបានបរាជ័យដោយសារតែកង្វះឆន្ទៈ នយោបាយរបស់រដ្ឋាភិបាលមានគំនិតផ្តួចផ្តើមបន្តិចបន្តួច និងមានកំរិតអាស្រ័យ ដោយចំណុចទាំងអស់ មិនបានចង

គ្នាជាបាច់។ ហើយយើងបានសន្និដ្ឋាន ដោយស្នើថា គំរោងសកម្មភាពអនាគត គួរត្រូវបាន អនុវត្តអាចធ្វើទៅបាន និងត្រូវមានទំនាក់ទំនងទៅនឹងតំរូវការ និងភាពចាំបាច់ដោយ ចងចាំថា សភាពការណ៍មានការវិវត្តរហ័សខ្លាំងណាស់។ អាស៊ានអាចរំកិលទៅមុខ បានរហ័សតែគួរប្រកាន់ជំហរច្បាស់លាស់ ចំពោះអ្វីដែលគេអាចធ្វើកើត។

ជាការពិតណាស់ ប្រទេសកម្ពុជាបានធ្វើឱ្យសម្រេចនូវកាតព្វកិច្ចរបស់ខ្លួន ជា សមាជិកថ្មីរបស់អាស៊ានដែលរួមមានការប្រារព្ធដោយជោគជ័យ និងកិច្ចប្រជុំ កំពូល និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីរបស់អាស៊ាន។ ឥឡូវនេះ ៥ ឆ្នាំ ទៅមុខទៀត វាជាពេលវេលា ដ៏ល្អ ។ ដូច្នេះ អង្គសន្និសីទជាតិនៅទីនេះ ថ្ងៃនេះ និងពិនិត្យមើល ផលប្រយោជន៍ដែល ប្រទេសកម្ពុជា បានសម្រេចក្នុងនាមជា សមាជិកអាស៊ាន ពិសេសការប្រឹងប្រែង របស់ខ្លួន ដើម្បីបង្រួញគំលាតក្នុងសមាគម។

ខ្ញុំគិតថា ជាមួយចំណាប់អារម្មណ៍ដែលខ្ញុំបានលើកឡើង យើងអាចសំលឹង ទៅមុខនៅក្នុងកិច្ចពិភាក្សាដ៏មានសារៈសំខាន់ និងមានភាពចំរូងចំរាស់ រយៈពេល ២ថ្ងៃ ដូច្នេះ ជាថ្មីម្តងទៀត ក្នុងនាម FES ខ្ញុំសូមស្វាគមន៍ការចូលរួមរបស់ ឯកឧត្តម អស់ លោក លោកស្រីទាំងអស់ និង សូមបួងសួងឱ្យកិច្ចប្រជុំរបស់យើងប្រព្រឹត្តទៅប្រកប ដោយជោគជ័យ។

# ព្រះសុន្ទរកថាគន្លឹះបើកសន្និសីទជាតិ

**ដោយសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ**

*ព្រះប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា*

ថ្ងៃនេះ ខ្ញុំមានកិត្តិយស ដែលបានមកចូលរួមជាប្រធានអធិបតីក្នុងពិធីបើកអង្គសន្និសីទជាតិ ស្តីពី "**ប្រទេសកម្ពុជា និងសមាគមអាស៊ាន : ប្រាំឆ្នាំក្រោយមក**" ដ៏មានសារៈសំខាន់នាពេលព្រឹកនេះ។

ជាបឋម ក្នុងនាមរដ្ឋសភាជាតិទាំងមូល ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) ដែលបានខិតខំ ប្រឹងប្រែងធ្វើសកម្មភាព ក្នុងឋានៈជាស្ថាប័នពុំមែនរដ្ឋាភិបាលមួយ ដោយរួមចំណែក ផ្តល់ទស្សនៈមតិយោបល់ និងអនុសាសន៍ជាច្រើនដល់ រាជរដ្ឋាភិបាល និងសភាជាតិ ដើម្បីស្ថាបនាគោលនយោបាយសំខាន់ៗ ពិសេសគឺ គោលនយោបាយក្នុងការធ្វើសមាហរណកម្មប្រទេសកម្ពុជាទៅក្នុងតំបន់ និងលើពិភពលោក។

ការផ្តល់មតិយោបល់ និងអនុសាសន៍ទាំងនេះពិតជាថ្លៃថ្លាឧត្តុង្គឧត្តម និងមានសារៈសំខាន់បំផុតដល់ការ ស្ថាបនា និងអភិវឌ្ឍន៍ជាតិយើងឱ្យរួចផុតពី ភាពក្រីក្រ និងបានរុងរឿងទៅអនាគត។

ខ្ញុំសូមសម្តែងនូវសេចក្តីកោតសរសើរដោយស្មោះ អស់ពីដួងចិត្ត ចំពោះសកម្មភាពដ៏ល្អប្រពៃនេះ និងសូម គាំទ្រ ឱ្យបន្តប្រតិបត្តិឱ្យបានល្អថែមទៀត ដើម្បីជាគំរូ និងជាកម្លាំងគាំទ្រដល់ការកសាង និងការអភិវឌ្ឍន៍ជាតិ ។

ខ្ញុំសូមថ្លែងអំណរគុណ ចំពោះអង្គការ Fridrich Ebert Stiftung (FES) នៃប្រទេសអាឡឺម៉ង់ដីដែលជានិច្ចកាលបានជួយឧបត្ថម្ភគាំទ្រទាំងសម្ភារៈ និងស្មារតីព្រមទាំងមូលនិធិ ដល់ការអភិវឌ្ឍន៍អង្គការសង្គមស៊ីវិលខ្មែរជាច្រើន ដូចជាវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពនេះជាដើម ឱ្យក្លាយទៅ ជាស្ថាប័នជំនាញឈានមុខមួយ នៅព្រះរាជាណាចក្រកម្ពុជា ។ យើងត្រូវការជាចាំបាច់ នូវការចូលរួម និងភាពជាដៃគូពីអង្គការស៊ីវិល គ្រប់ជាន់ថ្នាក់ក្នុងការ អភិវឌ្ឍន៍ជាតិ ។

មាតុភូមិកម្ពុជាយើងធ្លាប់បានទទួលរងគ្រោះដោយសង្គ្រាម និងស្ថិតនៅ ឯកោពីសហគមន៍អន្តរជាតិ ។ ភាពដាច់ឆ្ងាយនេះ បានបង្កើតនូវផលវិបាកជាច្រើន ដល់ការកសាង និងការអភិវឌ្ឍន៍ជាតិ មានអាទិ៍ កង្វះនូវជំនួយឧបត្ថម្ភ និងការ គាំទ្រពីសហគមន៍អន្តរជាតិ ភាពឱនថយក្នុងការទទួលបាននូវបច្ចេកទេសវិទ្យាសាស្ត្រ ចំណេះដឹង និងសមត្ថភាពផលិតកម្ម ការខកខានក្នុងការបញ្ជូនធនធាន មនុស្សទៅសិក្សានៅក្រៅប្រទេស និងការបាត់បង់ទំនាក់ទំនងការទូត ដែលជា ឧបសគ្គដ៏ធំដល់ការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ។ល។

ភាពដាច់ឆ្ងាយពីពិភពលោក និងការកាត់ផ្តាច់ទំនាក់ទំនងអន្តរជាតិ ច្រើនតែបណ្តាលមកពីចម្បាំងរាំងជល់ ការបែកបាក់ ការបែងចែក និងការប្រកាន់ពូជសាសន៍ មហិច្ឆតានយោបាយ ការរំាតទីអាណានិគមនិយម ភាពស្រុត ចុះ នៃវប្បធម៌-គុណធម៌

និងការបាត់បង់មនុស្ស។ បញ្ហាទាំងនេះបង្កើតឱ្យមាន ភាពក្រីក្រ និងអវិជ្ជាដែលយើងត្រូវដកពិសោធន៍ និងចៀសវាងឱ្យបាន ដើម្បីរស់នៅស្មើមុខដូចគេឯងក្នុងតំបន់ និងមានវឌ្ឍនភាព ក្នុងយុគសម័យនៃសាកលភាវូបនីយកម្មនេះ។

ដោយបានឃើញនូវបញ្ហាទាំងនេះ យើងបានសម្រេចចិត្តជាឯកឆន្ទថា ចាំបាច់ត្រូវតែបើកចំហទទួលយកទីផ្សារសេរី និងផ្សារភ្ជាប់មាតុភូមិយើងទៅនឹង សហគមន៍អន្តរជាតិ តាមរយៈការចូលរួមក្នុងតំបន់ និងក្នុងពិភពលោក។ សេចក្តី សម្រេចដ៏ថ្លៃថ្លាឧត្តុង្គឧត្តមនេះ គឺជាមធ្យោបាយដ៏ពិសេសមួយ ដែលលើកស្ទួយ ដល់ការរីកចម្រើនក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សន្តិសុខ វប្បធម៌ និងសង្គមកិច្ច របស់ជាតិយើងឱ្យមានការអភិវឌ្ឍន៍ ស្របតាមនិន្នាការនៃយុគសម័យសាកលភាវូបនីយកម្ម ដែលពិភពលោកកំពុងរួមបញ្ចូលគ្នា ដើម្បីធានា វឌ្ឍនភាព សន្តិភាព និងវិបុលភាព។

ចលនានៃការខិតខំប្រឹងប្រែងរបស់យើង នៅក្នុងយុគសម័យនេះ គឺការ ប្រកួតប្រជែងលើវិស័យទំនាក់ទំនងការទូត សេដ្ឋកិច្ច ទីផ្សារអន្តរជាតិ និងការ ប្រមូលផ្តុំធនធាននិងថាមពល ដែលជាកត្តាចម្បងនៃវឌ្ឍនភាព និងឧត្តមភាពពិភពលោក។ ការផ្លាស់ប្តូរនេះ គឺជាទំនោរថ្មី និងជាអាទិភាព ដែលជាតិយើងចាំ បាច់ត្រូវចាប់យកឱ្យបាន ដើម្បីស្តារនិងអភិវឌ្ឍន៍ វិស័យសេដ្ឋកិច្ច សន្តិសុខ វប្បធម៌ និងសង្គមកិច្ច ឱ្យបានរុងរឿង ដូចអារ្យប្រទេសក្នុងតំបន់ និងលើពិភពលោក។

ជាការពិតណាស់ ការធ្វើសមាហរណកម្មរបស់កម្ពុជា ទៅក្នុងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (ASEAN) ចាំបាច់ត្រូវមានការចំណាយដើមទុន ធនធាននិងការខិតខំប្រឹងប្រែង ដើម្បីបានមកវិញនូវផលប្រយោជន៍ជាក់លាក់មួយ ជូនប្រទេស

ជាតិ និងប្រជាពលរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ យើងអាចវាយ តម្លៃបានថា សមាហរណកម្ម នៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងតំបន់បានផ្តល់គុណប្រយោជន៍សំខាន់ៗ យ៉ាងច្រើន ជូនដល់សង្គមជាតិ :

- យើងអាចរក្សាការពារ និងលើកស្ទួយនូវផលប្រយោជន៍ជាយុទ្ធសាស្ត្ររបស់ប្រទេសជាតិយើងក្នុងការលុបបំបាត់សត្រូវ និងស្ថាបនាមិត្តក្នុងតំបន់ ដើម្បីធានាឱ្យមានភាពល្អប្រសើរ នូវសន្តិសុខខាងក្រៅរបស់ជាតិ។
- យើងអាចអភិវឌ្ឍសេដ្ឋកិច្ចជាតិយើង ក្រោយសម័យសង្គ្រាមឱ្យរួចផុត ពីភាពក្រីក្រ តាមរយៈការចូលរួមជាសមាជិក ក្នុងតំបន់ពាណិជ្ជកម្មសេរី អាស៊ាន AFTA ដែលបង្កើតបាននូវជំនឿ ពីវិនិយោគិនបរទេស ដោយសារលក្ខណៈទីផ្សារធំ ទូលាយរបស់អាស៊ាន។ អាស៊ានគឺជាច្រកដ៏ សំខាន់ សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ជាតិឱ្យរួចផុតពីភាពទុនខ្សោយ។
- យើងអាចលើកស្ទួយការងារទំនាក់ទំនងការទូត និងសហប្រតិបត្តិការអន្តរ-ជាតិ ជៀសផុតពីភាពឯកោ ព្រមទាំងអាចស្តារឡើងវិញនូវ កិត្យានុភាពជាតិដែល បានបាត់បង់ដោយសង្គ្រាម។
- យើងអាចទទួលបានការទទួលស្គាល់ តាមផ្លូវច្បាប់ និងពង្រឹងប្រព័ន្ធច្បាប់គ្រប់គ្រងរបស់ជាតិ ឱ្យកាន់តែមានភាពយុត្តិធម៌ សមភាព និងតម្លាភាពត្រឹមត្រូវ សមស្របតាមប្រព័ន្ធច្បាប់ក្នុងតំបន់។

- យើងអាចលើកស្ទួយវិស័យទេសចរណ៍របស់ជាតិ និងអភិវឌ្ឍវិស័យវប្បធម៌ អប់រំ សិក្សាធិការ សង្គមកិច្ច យោធា និង សន្តិសុខ ប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ការជួញដូរគ្រឿងញៀន ការជួញដូរស្ត្រី កុមារ ឧក្រិដ្ឋកម្មឆ្លងដែន និងជំងឺឆ្លងនានា ។ល ។

- យើងអាចទទួលបាននូវកិច្ចសហប្រតិបត្តិការ កិច្ចពិភាក្សា និងភាពជាដៃគូជាច្រើនក្នុងតំបន់ និងលើពិភពលោកដើម្បីកសាង និងអភិវឌ្ឍ ជាតិ ។

- យើងអាចរក្សាការពារបាននូវសន្តិសុខ ស្ថេរភាព សន្តិភាព និង វឌ្ឍនភាពជាតិតាមរយៈការធ្វើសមាហរណកម្មកម្ពុជា ទៅក្នុងតំបន់ និងពិភពលោកនេះ ។

ទាំងអស់នេះ គឺជាផលប្រយោជន៍សំខាន់ៗ ដែលយើងទទួលបានពីការ ចូលរួមក្នុងតំបន់ ។ ទោះជាយ៉ាងណាក្តី ការធ្វើសមាហរណកម្មរបស់កម្ពុជាទៅក្នុង សមាគមអាស៊ាន នៅជួបប្រទះបញ្ហាប្រឈមមុខមួយចំនួន ដែលយើងត្រូវតែជំនះឱ្យបាន។ ការប្រឈមមុខទាំងនោះមានដូចជា បញ្ហាចំណាយថវិកាផ្សេងៗ ក្នុងឋានៈកម្ពុជាជាសមាជិកមួយរបស់អាស៊ាន ការបាត់បង់ពន្ធគយក្នុងពេលចូល ជាសមាជិកតំបន់ពាណិជ្ជកម្ម សេរីអាស៊ានជាដំបូង ភាពទន់ខ្សោយនៃខឿនសេដ្ឋកិច្ចបច្ចេកទេសផលិតមុខទំនិញការគ្រប់គ្រងផ្នែកឯកជន សហគ្រាសឧស្សាហកម្ម កសិកម្ម និងពាណិជ្ជកម្ម ការអភិវឌ្ឍន៍ធនធានមនុស្សនៅពុំទាន់ឆ្លើយបានទៅនឹង សេចក្តីត្រូវការរបស់ជាតិ ក្នុងការចូលរួមក្នុងតំបន់។

ប្រសិនបើយើងជំនះបាននូវបញ្ហាប្រឈមមុខក្នុងគ្រាដំបូង នោះយើង នឹងអាចទទួលបាន នូវផលចំណេញជាច្រើនជូនដល់ប្រទេសជាតិ និងប្រជាពលរដ្ឋ។ ការចូលជា

សមាជិកអាស៊ានរបស់កម្ពុជា គឺជាការសម្រេចចិត្តដ៏ឧត្តុង្គឧត្តម និងជាមធ្យោបាយតែមួយគត់ សម្រាប់ការអភិវឌ្ឍន៍ជាតិយើងស្របតាម និន្នាការក្នុងតំបន់ និងលើពិភពលោក។

ដូច្នេះ តើយើងគួរធ្វើដូចម្តេច ដើម្បីលើកស្ទួយសមាជិកភាពនៃប្រទេសជាតិយើង នៅក្នុងតំបន់ឱ្យបានប្រសើរទៅអនាគត ហើយទទួលបានផល ប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ តើយើងគួរធ្វើអ្វីខ្លះ ដើម្បីឱ្យសម្រេចផលប្រយោជន៍ទាំងនេះ? តើយើងទាំងអស់គ្នា ជាអ្នកដឹកនាំ មន្ត្រីរាជការ សង្គម ស៊ីវិល និងផ្នែកឯកជន និងប្រជាពលរដ្ឋ ត្រូវមានតួនាទី និងភារកិច្ចដូចម្តេចខ្លះ ក្នុងការចូលរួមជាមួយរដ្ឋសភា និងរាជរដ្ឋាភិបាល ដើម្បីជំរុញឱ្យសមាជិកភាពនេះ ទទួលបានជោគជ័យ សមតាមបំណងប្រាថ្នារបស់ជាតិ។

សំណួរទាំងនេះ គឺជាគោលដៅ និងសំណូមពរដែលអង្គសន្និសីទជាតិចង់បាន ហើយសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងចូលរួមផ្តល់ទស្សនៈ មតិយោបល់ និងការសិក្សា ឆ្លើយតបទៅនឹងសំណួរទាំងនេះ ដើម្បីរកឱ្យ ឃើញនូវចំណេះដឹង និងអនុសាសន៍ល្អៗ សំដៅជំរុញ និងលើកស្ទួយឱ្យប្រទេស ជាតិយើង ក្លាយជាសមាជិកដ៏សកម្មមួយក្នុងតំបន់ និងទទួលបាននូវផល ប្រយោជន៍ទូលំទូលាយ។

នៅទីបញ្ចប់នេះ ខ្ញុំសូមប្រសិទ្ធពរជូន សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមឱ្យអង្គសន្និសីទជាតិ ទទួលបានលទ្ធផលល្អ ប្រមូលផ្តុំនូវចំណេះដឹង ទស្សនៈ និងអនុសាសន៍ល្អៗ ដើម្បីជាទុនដ៏ប្រសើរដល់ការអប់រំ ផ្សព្វផ្សាយដល់ រាជរដ្ឋាភិបាល ក៏ដូចជារដ្ឋសភា ដើម្បីពិនិត្យពិចារណា សំដៅបន្តការស្ថាបនា គោលនយោបាយ សមា-ហរណកម្មកម្ពុជាទៅក្នុងតំបន់ និងក្នុងពិភពលោក ឱ្យបានល្អ ប្រសើរទៅអនាគត ។

ខ្ញុំសូមប្រកាសបើកអង្គសន្និសីទជាតិចាប់ពីពេលនេះតទៅ ។

# ប្រទេសកម្ពុជា ក្នុងអាស៊ាន : ការវាយតំលៃរួម

ដោយបណ្ឌិត ចាប សុថារិទ្ធ

## សេចក្តីផ្តើម

ប្រទេសកម្ពុជាធ្លាប់រងគ្រោះ ជាច្រើនទសវត្សមកហើយ ដោយសារឥទ្ធិពលនៃសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ ដែលបង្កដោយអ្នកនយោបាយ និងការតស៊ូបដិវត្តក្នុងប្រទេស និងសង្គ្រាមត្រជាក់ក្នុងតំបន់ រវាងមហាអំណាចក្នុងពិភពលោក។ លទ្ធផលនៃសង្គ្រាម និងវិបត្តិនយោបាយ ដែលបានអូសបន្លាយពីអតីតកាល បានបន្សល់ទុកនូវ សោកនាដកម្មយ៉ាងធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋកម្ពុជា ដែលរស់នៅយ៉ាងលំបាក ក្នុងគំនរផេះ និងសេដ្ឋកិច្ចដែលខ្ទេចខ្ទាំ។

ក្រោយពីជោគជ័យនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅខែមេសា ឆ្នាំ១៩៧៥ ប្រជាជនគួរតែបានរស់ឡើងវិញ កសាងប្រទេសជាតិដ៏កំសត់នេះ តែគួរឱ្យស្តាយរបបពេជ្ឈឃាតជ្រុលនិយមខ្មែរក្រហម បានសំលាប់រង្គាលលើជនជាតិឯង និងកាត់ផ្តាច់ប្រទេសកម្ពុជាពីទំនាក់ទំនងជាមួយអន្តរជាតិស្ទើរទាំងស្រុង។ កម្ពុជាបានលង់ខ្លួនយ៉ាងជ្រៅនៅក្នុងមហាវិនាសកម្ម និងសោកនាកម្មជាថ្មី។

ដោយមានសហប្រតិបត្តិការ និងការជួយឧបត្ថម្ភគាំទ្រពីសហគមន៍អន្តរជាតិ ជាមួយនឹងស្មារតីស្នេហាជាតិ និងបង្រួបបង្រួមជាតិខ្ពស់ របស់មេដឹកនាំកម្ពុជាគ្រប់ភាគី កម្ពុជាបានឈានដល់ការបញ្ចប់សង្គ្រាមស៊ីវិល និងបង្កើតព្រះរាជាណាចក្រមួយ អាស្រ័យរដ្ឋធម្មនុញ្ញជាថ្មីឡើងវិញ នៅឆ្នាំ ១៩៩៣។

ដោយយល់ឃើញថា ភាពឯកោលើឆាកអន្តរជាតិ បាននាំមកនូវការអាប់ឱនកិត្តិយសនិងភាពទន់ខ្សោយដល់ប្រទេសជាតិ រាជរដ្ឋាភិបាលថ្មី ដែលជារដ្ឋាភិបាលចំរុះបង្កើតឡើងតាមរយៈ ការបោះឆ្នោត បានសំរេចចិត្តនយោបាយដ៏ត្រឹមត្រូវមួយ គឺការធ្វើសមាហរណកម្មកម្ពុជាចូលទៅ ក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។

ការត្រៀមចូលជាសមាជិកអាស៊ាន ត្រូវបានរៀបចំឡើង ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ពីសំណាក់គ្រប់ស្ថាប័នរដ្ឋ ដោយមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋទូទៅ រួមទាំងអង្គការសង្គមស៊ីវិលផងដែរ។

មុនពេលចូលជាសមាជិកអាស៊ាន ក៏ដូចជា បច្ចុប្បន្នក្រោយពេលចូលអាស៊ានបានរយៈពេលប្រាំឆ្នាំកន្លងទៅនេះ នៅតែមានការមន្ទិលសង្ស័យពីអ្នកវិភាគចំនួនទៅលើផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាន ពីសមាជិកភាពនេះមកលើ សេដ្ឋកិច្ច និងសង្គមកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ យើងមិនត្រូវមានគំនិតទុទិដ្ឋនិយមពេកទេ លើបញ្ហាចូលអាស៊ាន។ ចំពោះផលប៉ះពាល់អវិជ្ជមានខ្លះ ដែលជាគ្រាន់តែជាការប្រឈមចំពោះមុខ ហើយយើងប្រហែលជាអាចជំនះបាន បើយើងមានយុទ្ធសាស្ត្រត្រឹមត្រូវ និងត្រូវប្រឹងប្រែងធ្វើការងារ ទាំង អស់គ្នា។

# កម្ពុជា ក្នុងអាស៊ាន: ការប្រៀបធៀបខ្លះៗ

## ប្រជាជន និង នគរូបនីយកម្ម

កម្ពុជាជាប្រទេសមានលំដាប់ទី ៧ លើចំនួនប្រជាជន ក្នុងអាស៊ាន ដែលឥណ្ឌូណេស៊ីជាប្រទេសទី១ ដែលមានប្រជាពលរដ្ឋ ចំនួន ២១៦ លាននាក់នៅឆ្នាំ ២០០៤ (តារាងទី១) ។ កម្ពុជាជា ប្រទេសមានដីធំទូលាយ ប្រៀបធៀបនឹងប្រជាជន ឬដង់ស៊ីតេទាបជាងគេទី ៧ ពោលគឺ ៧៦ នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា ប្រៀបនឹងសឹង្ហបុរី ៦០០៣ នាក់ មួយ គីឡូម៉ែត្រការ៉េ (តារាងទី២) ។ កម្ពុជាមានល្បឿន កំណើននគរូបនីយកម្មលឿនជាងគេ បើប្រៀបធៀប ជាមួយប្រទេសអាស៊ានទាំងអស់ ពោលគឺ ១០,២២ ភាគរយ ចន្លោះឆ្នាំ ១៩៩០ ទៅ ២០០០ ។ នេះមានន័យថាប្រជាជនកម្ពុជាកាន់តែច្រើនឡើងៗ បាននាំគ្នាមកតាំងទីលំនៅនិងធ្វើការងារ នៅតាមទីប្រជុំជន។ ទោះជាយ៉ាងនេះក្តី អត្រា ប្រជាជនទីក្រុងធៀបនឹងប្រជាជនសរុបរបស់កម្ពុជានៅទាបនៅឡើយ ពោល គឺមានតែ ១៩ភាគរយនៅឆ្នាំ២០០៣ ធៀបនឹងអាស៊ានទាំងមូលដែលមានអត្រាដល់ទៅ ៤២ ភាគរយ ។ អត្រានេះរួមបញ្ចូលប្រទេសសឹង្ហបូរី ដែលមានអត្រាប្រជាជនរស់នៅ ទីក្រុង ១០០ ភាគរយ (មើលតារាងទី៣) ។

## សេដ្ឋកិច្ច

អាស៊ាន ជាក្រុមប្រទេសដែលមានខឿនសេដ្ឋកិច្ចលូតលាស់យ៉ាងលឿនបំផុតក្នុងពិភពលោក ។ គេចាត់ទុកថាអាស៊ានជាគំរូនៃការអភិវឌ្ឍន៏អស្ចារ្យ (Miracle) ជាពិសេសក្នុងសម័យកាលមុនវិបត្តិហិរញ្ញវត្ថុ ឆ្នាំ១៩៩៧ ។ ប្រទេសអាស៊ានបានខិតខំពុះពារលើឧបសគ្គនានា រួមមាន: ការស្តារតំលៃរូបិយប័ណ្ណជាតិឡើងវិញ ការរៀបចំ

កំណែទំរង់សេដ្ឋកិច្ច ហិរញ្ញវត្ថុ ការជំរុញវិស័យជាអទិភាពទៅតាមប្រទេសនីមួយៗ រួមមានៈ ទេសចរណ៍ សេវាកម្ម ឧស្សាហកម្ម ដឹកជញ្ជូន សំណង់ ជាដើម ។

កម្ពុជាមានខឿនសេដ្ឋកិច្ចតូចជាងគេ (លើសតែប្រទេសឡាវប៉ុណ្ណោះ) ទៅតាមផលទុនជាតិសរុប (តារាងទី ៤) ។ ផលិតផលសង្គមសរុបរបស់យើងមានតែ ៤,៧១៥ ពាន់លានដុល្លា ដែលតូចជាងទំហំទុនរបស់ក្រុមហ៊ុនធំៗខ្លះនៅប្រទេសឧស្សាហកម្មជឿនលឿនផង ។ ចំណែកផលទុនជាតិក្នុងមនុស្សម្នាក់ៗ កម្ពុជាទទួលបានតែ ៣០៥ ដុល្លាប៉ុណ្ណោះនៅឆ្នាំ ២០០៣ បើប្រៀបទៅសឹង្ហបូរី ២១,៨២៩ ដុល្លា ប្រ៊ុយណេ ១២,៩៧៣ ដុល្លា ម៉ាឡេស៊ី ៤,១៤១ ដុល្លា និងអាស៊ានទាំងមូលជាមធ្យម ១,២៦៥ ដុល្លា (តារាងទី៥) ។

កម្ពុជាអាចទទួលបានបទពិសោធន៏ផ្នែកអភិវឌ្ឍន៏សេដ្ឋកិច្ចជាច្រើន ពីការអភិវឌ្ឍន៏កសិកម្មនិងឧស្សាហកម្មពី ប្រទេសអាស៊ានជាមិត្តជាពិសេស លើផ្នែក គ្រប់គ្រងសហគ្រាស វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ។

## ទេសចរណ៏

ប្រទេសអាស៊ានសុទ្ធតែមានសក្តានុពល ខាងការអភិវឌ្ឍវិស័យទេសចរណ៏ ។ ការទាក់ទាញទេសចរណ៏ពីបណ្តាប្រទេសអាស៊ាន គឺជាផលចំណេញមួយយ៉ាងពិតប្រាកដក្រោយការចូលជា សមាជិករបស់យើង ។

ក្រោយពីមានគោលនយោបាយបើកចំហរជើងមេឃ និងដោយមានការដកស្រង់បទពិសោធន៏ពីប្រទេសអាស៊ានជាមិត្ត និងដោយរួមផ្សំជាមួយសក្តានុពលផ្នែក

ទេសចរណ៏របស់កម្ពុជា យើងបានទាក់ទាញទេសចរណ៏រាប់ពី ២២០,០០០ នាក់ នៅឆ្នាំ ១៩៩៥ មកដល់ ៧០១,០០០ នាក់ នៅឆ្នាំ ២០០៣ (តារាងទី៦) ។ ទោះជាយើងនៅចាញ់ ប្រទេសអាស៊ានខ្លះ (បើគឺតជាចំនួនទេសចរ) យ៉ាងណាក៏ដោយ ក៏យើងនៅតែឈានមុខគេបើធៀបចំណូលទេសចរណ៏ ទៅនឹងផលិតផលសង្គមសរុប GDP (តារាងទី ៧) ឬចំនួន ទេសចរធៀបនឹងចំនួនប្រជាពលរដ្ឋ។ នៅឆ្នាំ ២០០៤ ចំនួនទេសចរមកទស្សនាប្រទេសកម្ពុជាបានកើនឡើងដល់ជាង១ លាននាក់ និងទទួលបានចំណូលសរុប ៧៧៧ លានដុល្លាអាមេរិច ដែលបានរួមចំណែកដល់ការអភិវឌ្ឍន៏សេដ្ឋកិច្ច និងផ្តល់ការងារយ៉ាងច្រើនដល់ប្រជាជនកម្ពុជា ។

## វិនិយោគទុនផ្ទាល់ពីបរទេស (FDI) និងពាណិជ្ជកម្ម

ក្រោយរយៈពេល ៥ឆ្នាំចូលអាស៊ាន លំហូរនៃ FDI បានធ្លាក់ចុះពី ២៩៤ លានដុល្លា នៅឆ្នាំ ១៩៩៦ មក ១៤៩ លានដុល្លានៅឆ្នាំ ២០០០ និង ៨៧ លានដុល្លា នៅឆ្នាំ ២០០៣ (តារាងទី ៨)។ ការធ្លាក់ចុះនេះមិនមែនមកពីផលប៉ះពាល់ នៃការចូលជាសមាជិកអាស៊ានទេ។ តែវាដោយសារកត្តាធំៗពីរគឺ កត្តាខាងក្នុង និងកត្តាខាងក្រៅ។ កត្តាខាងក្នុងគឺ ដោយសារប្រទេសយើងនៅខ្វះខាតក្របខណ្ឌច្បាប់ សំរាប់ការពារអ្នកវិនិយោគ ការខ្វះពតិមានសំរាប់វិនិយោគ និងអំពើពុករលួយក្នុងការផ្តល់អាជ្ញាប័ណ្ណ ។ កត្តាខាងក្រៅ គឺបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុតំបន់នៅឆ្នាំ ១៩៩៧-១៩៩៨ និងការទាក់ទាញ និងការបើកចំហរសេដ្ឋកិច្ចរបស់ចិន ដែលធ្វើអោយអ្នកវិនិយោគធំៗ ងាកទៅវិនិយោគនៅប្រទេសចិន ដែលមានទីផ្សារដ៏ធំក្នុងលោក។

លើសពីនេះទៅទៀតការចូលជាអាស៊ានក្នុងរយៈពេល ៥ឆ្នាំ កន្លងមកធ្វើអោយប្រទេសយើងមានការរីកលូតលាស់ ខាងពាណិជ្ជកម្មគួរជាទីមោទនៈ ។ ពាណិជ្ជកម្មកម្ពុជា កើនពីទំហំ ១៩៦៦ លានដុល្លា នៅឆ្នាំ ១៩៩៨ ទៅដល់ ៤៤៩៩ លានដុល្លា នៅឆ្នាំ ២០០៣ ។ ក្នុងនោះការនាំចេញកើនឡើងពី ៨០០ លានដុល្លា នៅឆ្នាំ១៩៩៨ ដល់ ២០៧៦ លានដុល្លាមកវិញនៅឆ្នាំ ២០០៣ (តារាងទី ៩ និងទី ១០) ។

## នយោបាយនិងការទូត

រយៈពេល ៥ ឆ្នាំក្រោយពេលចូលអាស៊ាន ប្រទេសយើងបានទទួលនូវឯករាជ្យ និងអធិបតេយ្យភាពទាំងស្រុង ក្រោយពីមានការកៀបសង្កត់ និងភាពឯកកោលើឆាកអន្តរជាតិ ។ យើងបានបង្កើតស្ថានទូតបន្ថែមទៀតនៅគ្រប់ប្រទេសសមាជិកអាស៊ានទាំងអស់ ដែលធ្វើអោយប្រទេសយើងមានទំនាក់ទំនងកាន់តែប្រសើរឡើង ជាមួយបណ្តាប្រទេសសមាជិកអាស៊ាន ។

កម្ពុជាធ្លាប់ទទួលរ៉ាប់រងធ្វើជាម្ចាស់ផ្ទះតាមការប្តូរវេនគ្នា នូវសន្និសីទកិច្ចប្រជុំ និងព្រឹត្តិការណ៍អាស៊ាននានាជាច្រើន ដែលក្នុងនោះរួមមាន កិច្ចប្រជុំកំពូលអាស៊ានលើកទី ៨ នៅខែ វិច្ឆិកា ឆ្នាំ ២០០៣ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស និងវេទិកាតំបន់អាស៊ានផង ។ ទោះជាកិច្ចប្រជុំទាំងនោះ ត្រូវចំណាយថវិការជាតិច្រើនយ៉ាងណាក៏ដោយ ក៏យើងបានបង្ហាញពិភពលោកពីសមត្ថភាពចាត់ចែង ទទួលភ្ញៀវ និងការធាបាននូវសន្តិសុខ និងសុវត្ថិភាពដល់អ្នកចូលរួមទាំងអស់ព្រមទាំងថ្នាក់ដឹកនាំកំពូលៗផង ។

មិនតែប៉ុណ្ណោះ កម្ពុជាបានពង្រឹងការទូតលើ គ្រប់វិស័យជាមួយបណ្តាប្រទេសលើ ពិភពលោក ជាពិសេសប្រទេសធំៗក្នុងតំបន់រួមមាន ជប៉ុន ចិន កូរ៉េ និងឥណ្ឌា ។

ទំនាក់ទំនងជាមួយមហាអំណាចទាំងអស់រួមមាន សហរដ្ឋអាមេរិច និងអឺរ៉ុបក៏មានភាពកាន់តែជិតស្និទ្ធឡើង ។

## ការអភិវឌ្ឍន៍ធនធានមនុស្ស

ក្រោយពីការចូលអាស៊ានមក យើងបានទទួល ជំនួយពីការបណ្តុះបណ្តាលធនធានមនុស្សពីប្រទេសអាស៊ានចាស់ និងអាស៊ានបូកបី ក្នុងក្របខ័ណ្ឌការ ផ្តួចផ្តើមគំនិតសមាហរណកម្មអាស៊ាន (IAI) ។ ការបណ្តុះបណ្តាលនេះរួមមាន ផ្នែកទំនាក់ទំនងអន្តរជាតិ ការទូត ពាណិជ្ជកម្ម ការគ្រប់គ្រង សេដ្ឋកិច្ច ច្បាប់ និង វិស័យផ្សេងទៀតជាច្រើន។

តាមរយៈការចូលរួមប្រជុំអាស៊ានជាច្រើន ធ្វើអោយមន្ត្រីរាជការ និងអ្នកចូលរួមដ៏ទៃទៀតមានឱកាសបញ្ចេញមតិយោបល់ និងរៀនសូត្រនូវចំណេះដឹងថ្មីៗទៀតពីអាស៊ាន ។ ចំណេះដឹងខាងភាសាអង់គ្លេស ក៏ត្រូវបានជំរុញ និងកាន់តែពេញនិយមនៅប្រទេសយើង ។

## ការប្រឈម

ការប្រឈមរបស់យើងក្នុងសមាហរកម្មអាស៊ាននេះ គឺការពុះពារយកឈ្នះលើការប្រកួតប្រជែង ដណ្តើមទីផ្សារអាស៊ាន ។ ដូចយើងដឹងហើយថា ទោះជាការចូលជាអាស៊ាននេះ មានលក្ខណៈនយោបាយ និងសន្តិសុខក្តី ក៏ការប្រកួតប្រជែង រវាងសមាជិកនីមួយៗ ដើម្បីជំរុញផលិតផលខ្លួនអោយមានលក្ខណៈប្រកួតប្រជែង ទាំងតំលៃទាំងបរិមាណ និងគុណភាពមានភាពខ្លាំងក្លា និងប្រកបដោយយុទ្ធសាស្ត្រដ៏ឈ្លាសវៃ ។

ដើម្បីដណ្តើមទីផ្សារអាស៊ាន ដែលភាគច្រើនមានកម្លាំងសេដ្ឋកិច្ច និងមានសក្តានុពលអភិវឌ្ឍខ្លាំងក្លា ជាងយើង មិនមែនជាការងាយស្រួលឡើយ ជាពិសេសការប្រកួតប្រជែងខាងវិស័យកសិកម្ម។

ការប្រកួតប្រជែង ក្នុងការទាក់ទាញអ្នកវិនិយោគ និងទេសចរពីបណ្តាប្រទេសអាស៊ាន និងពីប្រទេសធំៗ ដ៏ទៃទៀត ក៏មានសភាពខ្លាំងក្លាណាស់ដែរ។ យើងត្រូវតែចេះឆ្លៀតឱកាសទាក់ទាញអ្នកវិនយោគ និង ទេសចរណ៍ពីបណ្តា ប្រទេស អាស៊ានអោយមកបណ្តាក់ទុន និងមកទស្សនាប្រទេសយើង អោយបានច្រើន ។

ការធ្វើអោយប្រទេសមួយ ប្រែក្លាយពីសេដ្ឋកិច្ច ដែលមានឱនភាពពាណិជ្ជកម្ម (Trade Deficit) អោយទៅជាប្រទេស ដែលមានអតិរេកពាណិជ្ជកម្ម (Trade Surplus) ពិតជាការងារ មួយយ៉ាងលំបាក ដែលទាមទារការខិតខំពីគ្រប់ភាគី ទាំងរដ្ឋ ទាំងឯកជន ។

## សន្និដ្ឋាន

តាមរយៈការវាយតំលៃត្រួសៗពីខាងដើម យើងអាចសន្និដ្ឋានបានថា ការចូលជាសមាជិកក្នុងអាស៊ានរយៈពេល ៥ ឆ្នាំកន្លងមកនេះ ធ្វើអោយប្រទេសយើងទទួលបានផលចំណេញ និងមានការវិវត្តន៏ជាវិជ្ជមានជាច្រើន ។ ផលប្រយោជន៏ខ្លះមានភាពជាក់ស្តែង ដូចជាការទទួលជំនួយបច្ចេកទេស ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងការទាក់ទាញអ្នកវិនិយោគ និងទេសចរ ជាដើម។ ផលប្រយោជន៏ខ្លះពី ការចូលរួមអាស៊ានរបស់យើងមានលក្ខណៈអរូបិយ ដូចជា ការជំរុញកិត្យានុភាពប្រទេសយើង ការបង្កើនសមត្ថភាព និងចំណេះដឹង និងការផ្លាស់ប្តូរបទពិសោធន៏ជាដើម។

យើងមានមោទនភាព និងចាត់ទុកការចូលរួមក្នុងអាស៊ាននេះ ជាការសំរេចចិត្តនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ដើម្បីបើកចំហរប្រទេសកម្ពុជា ឱ្យដើរទាន់សម័យសកលភាវូបនីយកម្ម ។

យើងមានភារកិច្ចចំពោះមុខច្រើនណាស់ ដើម្បីធ្វើអោយប្រទេសយើងជឿនលឿន និងមានលទ្ធភាពប្រកួតប្រជែងក្នុងការទាញយកផលប្រយោជន៏ជាអតិបរិមាពីការចូលរួមក្នុងអាស៊ាន ។ យើងត្រូវខិតខំប្រឹងប្រែងធ្វើការងារ ក្នុងស្មារតីសុទិដ្ឋិនិយម ។

*<u>តារាងទី១:</u> ចំនួនប្រជាជនអាស៊ានតាមប្រទេស*

| **ប្រទេស** | **១៩៨០** | **១៩៩០** | **២០០០** | **២០០១** | **២០០២** | **២០០៣** | **២០០៤** |
|---|---|---|---|---|---|---|---|
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) |
| ប្រុយណេ | ១៨៦ | ២៥៣,៤ | ៣៣៨,៤ | ៣៤៤,៥ | ៣៥៣,៨ | ៣៦៣,៥ | ៣៧៣,៥ |
| កម្ពុជា | ៦,៩៩០ | ៨,៦០០ | ១២,២០០ | ១៣,១៤៨ | ១៣,៤៧៣ | ១៣,៧៩៨ | ១៤,១៣១ |
| ឥណ្ឌូណេស៊ី | ១៤៧,៤៩០ | ១៧៩,៣៧៩ | ២០៦,២៦៥ | ២០៨,៦៤៧ | ២១១,០៥៧ | ២១៣,៤៩៤ | ២១៥,៩៦០ |
| ឡាវ | ៣,១៨៥ | ៤,០៧៧ | ៥,២១៨ | ៥,៣៤៨ | ៥,៤៨១ | ៥,៦១៨ | ៥,៧៥៨ |
| ម៉ាឡេស៊ី | ១៣,៧៤៥ | ១៨,១០២ | ២៣,២៧៥ | ២៣,៨៥២ | ២៤,៤៤៤ | ២៥,០៥០ | ២៥,៦៧១ |
| ភូមា | ៣៣,៦១០ | ៤០,៧៨៦ | ៥០,១២៥ | ៥១,១៣៨ | ៥២,៣១៣ | ៥៣,៥១៥ | ៥៤,៧៤៥ |
| ហ្វីលីពីន | ៤៨,២៨៥ | ៦០,៩៣៨ | ៧៦,៣៤៨ | ៧៧,៩២៥,៩ | ៧៩,៥០៤,០ | ៨១,០៨១,០ | ៨២,៦៦៤,០ |
| សឹង្ហបូរី | ២,៤១៤ | ៣,០៤៧ | ៤,០១៨ | ៤,០៩៥,០ | ៤,១៧២,០ | ៤,១៨៥,០ | ៤,១៩៨,០ |
| ថៃឡង់ | ៤៦,៧០០ | ៥៥,៨៤០ | ៦២,៤០៨ | ៦២,៩១៤,០ | ៦៣,៤៣០,០ | ៦៣,៩៥០,០ | ៦៤,៤៧០,០ |
| វៀតណាម | ៥២,៤៦២ | ៦៦,០១៧ | ៧៧,៦៣៥ | ៧៨,៦៨៥,៨ | ៨០,១៦១,០ | ៨១,១៨៥,០ | ៨២,២២២,០ |
| **អាស៊ាន** | **៣៥៤,៦៦៧** | **៤៣៧,០៤០** | **៥១៧,៨៣០** | **៥២៦,០៩៨** | **៥៣៤,៣៨៩** | **៥៤២,២៣៩** | **៥៥០,១៩៣** |

ប្រភព: សៀវភៅស្ថិតិអាស៊ាន ឆ្នាំ ២០០៤

## តារាងទី២ : ដង់ស៊ីតេប្រជាជន

| Country | Area ('000 Sq.km) | Population Density (per Sq.Km) | | | | Rank of Density in 2003 |
|---|---|---|---|---|---|---|
| | | 1980 | 1990 | 2000 | 2003 | |
| Brunei Darussalam | 5.8 | 32 | 44 | 59 | 63 | 9 |
| Cambodia | 181 | 36 | 48 | 67 | 76 | 7 |
| Indonesia | 1,891 | 78 | 95 | 109 | 113 | 5 |
| Lao PDR | 237 | 13 | 17 | 22 | 24 | 10 |
| Malaysia | 330 | 42 | 55 | 70 | 76 | 8 |
| Mayanmar | 677 | 50 | 60 | 74 | 79 | 6 |
| The Philippines | 300 | 161 | 203 | 254 | 270 | 2 |
| Singapore | 0.697 | 3,657 | 4,617 | 5,763 | 6,003 | 1 |
| Thailand | 513 | 91 | 109 | 122 | 125 | 4 |
| Viet Nam | 330 | 159 | 200 | 235 | 246 | 3 |
| ASEAN | 4,466 | 79 | 98 | 166 | 121 | - |

ប្រភព: សៀវភៅស្ថិតិអាស៊ាន ឆ្នាំ ២០០៤

## តារាងទី៣: ប្រជាជនទីក្រុង ១៩៨០-២០០៣

| Country | Urban Population as % of Total Population | | | | | | Rate of Annual Growth of Urban Population | | Rank of % of Urban Pop. in 2003 |
|---|---|---|---|---|---|---|---|---|---|
| | 1980 | 1990 | 2000 | 2001 | 2002 | 2003 | 1980-1990 | 1990-2000 | |
| Brunei Darussalam | - | - | 72.0 | - | 75.5 | 76.0 | - | - | 2 |
| Cambodia | 12.4 | 12.6 | 23.5 | 17.5 | 18.0 | 16.0 | 2.86 | 10.22 | 10 |
| Indonesia | 22.2 | 30.6 | 40.2 | 42.1 | 44.5 | 46.0 | 5.30 | 4.14 | 5 |
| Lao PDR | 13.4 | 18.1 | 23.5 | 19.7 | 20.2 | 21.0 | 5.63 | 5.21 | 9 |
| Malaysia | 42.0 | 50.7 | 62.0 | 58.1 | 63.3 | 64.0 | 4.72 | 3.83 | 3 |
| Mayanmar | 24.0 | 24.6 | 27.7 | 28.1 | 28.9 | 29.0 | 2.21 | 3.07 | 7 |
| The Philippines | 37.5 | 48.8 | 58.6 | 59.4 | 60.2 | 61.0 | 5.07 | 4.81 | 4 |
| Singapore | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 2.36 | 2.80 | 1 |
| Thailand | 17.0 | 18.7 | 21.6 | 28.6 | 31.6 | 32.0 | 2.81 | 2.50 | 6 |
| Viet Nam | 19.2 | 19.7 | 19.7 | 24.5 | 25.2 | 26.0 | 2.59 | 1.64 | 8 |
| **ASEAN** | **24.3** | **30.1** | **37.1** | **39.5** | **41.3** | **42.2** | **4.29** | **3.94** | **-** |

ប្រភព: សៀវភៅស្ថិតិអាស៊ាន ឆ្នាំ ២០០៤

## តារាងទី ៤ ផលិតផលសង្គមសរុប តាមថ្លៃទីផ្សារបច្ចុប្បន្ន ១៩៩៦- ២០០៣

| Country | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 |
|---|---|---|---|---|---|---|---|---|
| Brunei Darussalam | 5,216 | 5,102 | 3,865 | 4,190 | 4,315 | 4,176 | 4,270 | 4,715 |
| Cambodia | 3,393 | 3,320 | 3,027 | 3,427 | 3,546 | 3,702 | 3,945 | 4,215 |
| Indonesia | 227,312 | 222,702 | 97,808 | 140,787 | 150,567 | 143,602 | 173,508 | 208,625 |
| Lao PDR | 1,874 | 1,747 | 1,286 | 1,451 | 1,733 | 1,754 | 1,829 | 2,043 |
| Malaysia | 100,888 | 101,213 | 72,237 | 79,149 | 90,320 | 88,001 | 95,164 | 103,737 |
| Myanmar | 4,956 | 4,657 | 6,953 | 9,275 | 10,549 | 8,281 | 9,135 | 9,605 |
| The Philippines | 82,840 | 82,764 | 65,548 | 76,076 | 74,837 | 71,985 | 76,402 | 79,270 |
| Singapore | 92,227 | 95,399 | 81,940 | 81,414 | 91,429 | 84,909 | 88,302 | 91,355 |
| Thailand | 182,107 | 155,965 | 112,751 | 122,698 | 122,969 | 115,601 | 126,915 | 143,303 |
| Viet Nam | 24,658 | 26,843 | 27,209 | 28,677 | 31,319 | 32,647 | 35,066 | 39,021 |
| ASEAN *) | 725,470 | 699,712 | 472,622 | 547,144 | 581,584 | 554,658 | 614,537 | 685,891 |

ប្រភព: សៀវភៅស្ថិតិអាស៊ាន ឆ្នាំ ២០០៤

## តារាងទី ៥: ផលិតផលសង្គមសរុបក្នុងមនុស្សម្នាក់ៗ តាមថ្លៃទីផ្សារបច្ចុប្បន្ន ១៩៩៦-២០០៣

| Country | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 |
|---|---|---|---|---|---|---|---|---|
| Brunei Darussalam | 17,096 | 16,227 | 11,961 | 12,670 | 12,751 | 12,121 | 12,068 | 12,973 |
| Cambodia | 317 | 320 | 265 | 295 | 291 | 282 | 293 | 305 |
| Indonesia | 1,154 | 1,118 | 485 | 690 | 730 | 688 | 822 | 977 |
| Lao PDR | 396 | 360 | 259 | 285 | 332 | 328 | 334 | 364 |
| Malaysia | 4,814 | 4,704 | 3,271 | 3,491 | 3,881 | 3,689 | 3,893 | 4,141 |
| Myanmar | 109 | 100 | 144 | 189 | 210 | 162 | 175 | 179 |
| The Philippines | 1,184 | 1,157 | 896 | 1,018 | 980 | 924 | 961 | 978 |
| Singapore | 25,127 | 25,147 | 20,892 | 20,606 | 22,757 | 20,735 | 21,165 | 21,829 |
| Thailand | 3,035 | 2,572 | 1,845 | 1,985 | 1,970 | 1,837 | 2,001 | 2,241 |
| Viet Nam | 337 | 361 | 361 | 374 | 403 | 415 | 437 | 481 |
| ASEAN | 1,493 | 1,419 | 941 | 1,073 | 1,123 | 1,054 | 1,150 | 1,265 |

ប្រភព: សៀវភៅស្ថិតិអាស៊ាន ឆ្នាំ ២០០៤

## តារាងទី ៦: ចំនួនទេសចរមកទស្សនា តាមប្រទេស ១៩៩៥- ២០០៣ (ពាន់នាក់)

| Country of Destination | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 |
|---|---|---|---|---|---|---|---|---|---|
| (1) | (2) | (3) | (4) | (5) | (6) | (7) | (8) | (9) | (10) |
| Brunei Darussalam | – | – | 643 | 964 | 955 | 984 | 1,083 | 1,117 | 1,057 |
| Cambodia | 220 | 260 | 219 | 176 | 263 | 466 | 605 | 787 | 701 |
| Indonesia | 4,324 | 5,034 | 5,185 | 4,606 | 4,728 | 5,064 | 5,154 | 4,914 | 4,411 |
| Lao PDR | 346 | 403 | 463 | 500 | 624 | 737 | 674 | 736 | 465 |
| Malaysia | 7,469 | 7,138 | 6,211 | 5,551 | 7,931 | 10,272 | 12,775 | 13,292 | 10,577 |
| Myanmar | 110 | 163 | 189 | 198 | 195 | 271 | 205 | 217 | 597 |
| The Philippines | 1,760 | 2,049 | 2,223 | 2,149 | 1,971 | 1,992 | 1,797 | 1,933 | 1,907 |
| Singapore | 7,137 | 7,293 | 7,198 | 6,242 | 6,967 | 7,691 | 7,519 | 7,567 | 6,127 |
| Thailand | 6,952 | 7,244 | 7,294 | 7,843 | 8,798 | 9,509 | 10,062 | 10,799 | 10,082 |
| Viet Nam | 1,351 | 1,607 | 1,716 | 1,504 | 1,782 | 2,150 | 2,330 | 2,628 | 2,429 |
| ASEAN | 29,669 | 31,193 | 31,340 | 29,733 | 34,215 | 39,136 | 42,202 | 43,989 | 38,354 |
| ASEAN 5 | 27,642 | 28,759 | 28,111 | 26,391 | 30,396 | 34,528 | 37,306 | 38,505 | 33,104 |
| BCLMV | – | – | 3,230 | 3,342 | 3,819 | 4,608 | 4,896 | 5,484 | 5,250 |

ប្រភព: សៀវភៅស្ថិតិអាស៊ាន ឆ្នាំ ២០០៤

## តារាងទី ៧: ចំណូលពីវិស័យទេសចរណ៍ ២០០១-២០០២

| ប្រទេស | ចំណូលពីទេសចរណ៍ (លានដុល្លា) | | ចំណូលធៀបនឹង ផ.ស.ស (ភាគរយ) | |
|---|---|---|---|---|
| | 2001 | 2002 | 2001 | 2002 |
| (1) | (2) | (3) | (4) | (5) |
| Brunei Darussalam | na | na | na | na |
| Cambodia | 296.0 | 379.0 | 10.24 | 7.50 |
| Indonesia | 5,428.6 | 4,305.6 | 3.04 | 3.13 |
| Lao PDR | 103.8 | 113.4 | 6.50 | 5.75 |
| Malaysia | 6,790.0 | 6,784.5 | 7.71 | 7.15 |
| Myanmar | 90.0 | 99.0 | 1.56 | 1.65 |
| Philippines | 1,722.7 | 1,740.1 | 2.42 | 2.22 |
| Singapore | 5,350.0 | 5,176.5 | 6.10 | 6.15 |
| Thailand | 6,730.8 | 7,529.9 | 6.53 | 5.32 |
| Vietnam | 1,370.0 | 1,560.0 | 4.74 | 3.90 |
| ASEAN | 27,881.9 | 27,687.9 | 5.03 | 4.57 |

ប្រភព: សៀវភៅស្ថិតិអាស៊ាន ឆ្នាំ ២០០៤

## *តារាងទី ៨: ការហូរចូលវិនិយោគផ្ទាល់ពីបរទេស ក្នុងអាស៊ាន តាមប្រទេស ១៩៩៥-ឆមាសទី១ ឆ្នាំ ២០០៤ (លានដុល្លា)*

| Host Countries | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 1st Qtr 2004 | 1995-2003 |
|---|---|---|---|---|---|---|---|---|---|---|---|
| (1) | (2) | (3) | (4) | (5) | (6) | (7) | (8) | (9) | (10) | (11) | (12) |
| Brunei Darussalam | 583 | 654 | 702 | 573 | 748 | 549 | 526 | 1,035 | 3,123 | 34 | 8,493 |
| Cambodia | 151 | 294 | 168 | 243 | 232 | 149 | 149 | 145 | 87 | 18 | 1,618 |
| Indonesia | 4,346 | 6,194 | 4,678 | -356 | -2,745 | -4,550 | -3,279 | 145 | -596 | 432 | 3,838 |
| Lao PDR | 88 | 128 | 86 | 45 | 52 | 34 | 24 | 25 | 19 | 5 | 502 |
| Malaysia | 5,815 | 7,297 | 6,323 | 2,714 | 3,895 | 3,788 | 554 | 3,203 | 2,473 | 927 | 36,062 |
| Myanmar | 318 | 581 | 879 | 684 | 304 | 208 | 192 | 191 | 128 | n.a | 3,484 |
| Philippines | 1,577 | 1,618 | 1,261 | 1,718 | 1,725 | 1,345 | 982 | 1,111 | 319 | -15 | 11,656 |
| Singapore | 11,503 | 9,303 | 13,533 | 7,594 | 16,067 | 17,218 | 15,038 | 5,730 | 11,431 | 5,775 | 107,416 |
| Thailand | 2,070 | 2,338 | 3,882 | 7,491 | 6,091 | 3,350 | 3,886 | 947 | 1,869 | 166 | 31,924 |
| Viet Nam | 1,780 | 1,803 | 2,587 | 1,700 | 1,484 | 1,289 | 1,300 | 1,200 | 1,450 | N.A | 14,594 |
| ASEAN | 28,231 | 30,209 | 34,099 | 22,406 | 27,853 | 23,379 | 19,373 | 13,733 | 20,304 | 7,342 | 219,587 |
| ASEAN 5 | 25,311 | 26,750 | 29,676 | 19,161 | 25,033 | 21,151 | 17,181 | 11,136 | 15,496 | 7,285 | 190,895 |
| BCLMV | 2,920 | 3,459 | 4,422 | 3,245 | 2,820 | 2,229 | 2,192 | 2,597 | 4,808 | – | 28,691 |

ប្រភព: សៀវភៅស្ថិតិអាស៊ាន ឆ្នាំ ២០០៤

## តារាងទី៩ ការនាំចេញរបស់អាស៊ាន ១៩៩៨- ២០០៣

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 |
|---|---|---|---|---|---|---|
| Brunei | 1,923.7 | 2,340.7 | 2,169.1 | 3,530.4 | 2,690.9 | 3,211.1 |
| Cambodia | – | – | 1,367.5 | 1,495.1 | 1,916.1 | 2,115.7 |
| Indonesia | 48,847.6 | 48,665.5 | 62,124.0 | 56,317.6 | 57,158.8 | 61,058.2 |
| Malaysia | 77,098.6 | 84,287.9 | 98,154.5 | 88,031.6 | 93,277.2 | 99,377.6 |
| Myanmar | – | 744.8 | 1,193.8 | 2,218.4 | 2,452.2 | 4,463.8 |
| Philippines | 29,496.4 | 35,036.9 | 38,078.2 | 32,150.2 | 35,208.2 | 36,231.2 |
| Singapore | 109,802.9 | 114,625.1 | 138,352.5 | 121,686.8 | 125,042.7 | 143,483.3 |
| Thailand | 49,481.6 | 56,110.9 | 68,700.9 | 64,925.6 | 66,108.2 | 80,450.1 |
| ASEAN 10 | 316,650.8 | 341,811.8 | 410,140.6 | 370,355.7 | 383,854.1 | 430,391.1 |
| ASEAN 6 | 316,650.8 | 341,067.0 | 407,579.3 | 366,642.3 | 379,485.9 | 423,811.5 |

## តារាង ទី ១០: ការនាំចូលរបស់អាស៊ាន ១៩៩៨- ២០០៣

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 |
|---|---|---|---|---|---|---|
| Brunei | 1,276.3 | 1,720.4 | 1,067.6 | 1,310.0 | 1,600.4 | 1,351.9 |
| Cambodia | – | – | 1,404.6 | 1,502.0 | 1,664.8 | 2,906.4 |
| Indonesia | 27,336.9 | 24,003.3 | 33,514.8 | 30,962.1 | 31,288.9 | 32,550.7 |
| Malaysia | 60,976.5 | 63,677.8 | 79,647.5 | 73,097.9 | 78,797.8 | 80,091.1 |
| Myanmar | – | 1,886.1 | 2,219.4 | 2,811.4 | 2,118.1 | 1,843.3 |
| Philippines | 29,659.9 | 30,742.5 | 31,387.4 1) | 29,550.8 | 33,576.4 | 37,496.5 |
| Singapore | 101,495.9 | 110,998.0 | 134,680.1 | 115,919.0 | 116,336.4 | 127,320.7 |
| Thailand | 38,711.6 | 48,318.0 | 61,935.3 | 61,975.4 | 62,729.9 | 75,759.4 |
| ASEAN 10 | 259,456.9 | 281,346.0 | 345,856.7 | 317,128.6 | 328,112.6 | 359,320.0 |
| ASEAN 6 | 259,456.9 | 279,459.9 | 342,232.7 | 312,815.2 | 324,329.8 | 354,570.3 |

ប្រភព: សៀវភៅស្ថិតិអាស៊ាន ឆ្នាំ ២០០៤

# អាស៊ាន និង សហគមន៍សន្តិសុខ

## ដោយ ឯកឧត្តមឧត្តមសេនីយ៍ទោ ណឹម សុវត្ថិ

*អគ្គនាយករង អគ្គនាយកដ្ឋាន យោធសេវា នាយក នាយកដ្ឋាននយោបាយ*

*និងផែនការក្រសួងការពារជាតិ និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អម*

*វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព*

ក្នុងការប្រជុំកំពូលអាស៊ាននៅ Bali កាលពីខែតុលាកន្លងទៅថ្មីៗនេះ បានបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។

និន្នាការនេះបានបង្កើតនូវសំនួរមួយថាៈ តើអាស៊ានអាចនឹងបង្កើតជាសហគមន៍សន្តិសុខ ASEAN Security Community (ASC) បានដែរឬទេ? ហើយតើដំណើរការបែបនេះអាចនឹងប្រព្រឹត្តទៅបែបណា?

ជាបឋម យើងគួរចាប់ផ្តើមឈ្វេងយល់ នូវខ្លឹមសារនៃពាក្យ "**សហគមន៍សន្តិសុខ**" ជាមុនសិន។ ទស្សនទាននៃសហគមន៍សន្តិសុខចាប់ផ្តើមតាំងពីឆ្នាំ ១៩៥៧ ដោយ Karl Denteh ក្នុងការសិក្សាអំពី "សហគមន៍នយោបាយនៅភូមិភាគអាត្លង់ទិកខាងជើង"។ អត្ថន័យយ៉ាងសាមញ្ញបំផុតរបស់សហគមន៍សន្តិសុខ កើតមានឡើងពេលដែលពលរដ្ឋមួយចំនួនរួមគ្នា ដើម្បីធ្វើជាសហគមន៍ ឬសមូហភាពលើ

អត្តសញ្ញាណ ឬវិស័យណាមួយដោយមានការឯកភាពគ្នាដើម្បីដោះស្រាយ នូវការខ្វែងយោបល់ ឬមិនចុះសំរុងគ្នាតាមសន្តិវិធី ដោយមិនប្រើប្រាស់កម្លាំងយោធា។ សហគមន៍សន្តិសុខពុំដូចគ្នាទៅនឹងអ្វីដែលហៅថា សម្ព័ន្ធភាពយោធាឬ ក្រុមសម្ព័ន្ធមិត្តទេ ទោះបីជាសហគមន៍សន្តិសុខអាចមានការវិវត្តន៍យ៉ាងមានសក្តានុពល និងមានទំនាក់ទំនងគ្នាលើផ្នែកយោធាក្តី។

*ប្រភេទនៃសហគមន៍សន្តិសុខអាចមានពីរយ៉ាង :*

ប្រភេទទី១ គឺការរួមបញ្ចូលនៃរដ្ឋឯករាជ្យអធិបតេយ្យភាពពីរ ឬច្រើន ធ្វើជាសហគមន៍រដ្ឋធំមួយដោយមានរដ្ឋាភិបាលរួម ដូចជាអតីតសហភាពសូវៀត និងសហរដ្ឋអាមេរិចបច្ចុប្បន្ន។

ឯប្រភេទទី២ នៃសហគមន៍សន្តិសុខគឺ សមាជិកនៃសហគមន៍នីមួយៗ នៅរក្សាអធិបតេយ្យ ឯករាជ្យភាពរបស់ខ្លួន និងមានរដ្ឋាភិបាលដាច់ដោយឡែកពីគ្នា ឧទាហរណ៍ដូចជា សហរដ្ឋអាមេរិច កាណាដា បណ្តាប្រទេសនៅអឺរ៉ុបខាងលិច និងបណ្តារដ្ឋនៅតំបន់បាល់ទិកជាដើម។

## លក្ខខ័ណ្ឌ

ដើម្បីបានក្លាយជាសហគមន៍សន្តិសុខមួយ យ៉ាងហោចណាស់ក៏ទាមទារ នូវលក្ខខ័ណ្ឌមួយចំនួនដូចតទៅ :

១- សំខាន់បំផុត គឺពុំត្រូវមានទំនាស់ផ្នែកកំលាំងប្រដាប់អាវុធជាមួយគ្នា ត្រូវ បញ្ចៀសឱ្យបាននូវរាល់ការវិវាទ ឬអារិភាពក្នុងចំណោមសមាជិកក្នុងសហគមន៍។ តែនេះក៏

ពុំមែនមានន័យថា នឹងគ្មានការទាស់ទែង ខ្វែងគំនិត គ្នាខ្លះនោះទេ។ ប៉ុន្តែ ន័យសំខាន់បំផុតនោះគឺ ការស្វះស្វែងរកមធ្យោបាយ ដើម្បីបង្ការដល់រដ្ឋាភិបាលនីមួយៗ កុំឱ្យឈានរហូតដល់ការប្រើប្រាស់ ឬគំរាមកំហែងគ្នាដោយកម្លាំងប្រដាប់អាវុធ។ ន័យនេះគឺ សហគមន៍ត្រូវផ្អែកទៅលើសភាពការណ៍ ដោយសង្ឃឹមថាពឹងពាក់ដំណោះស្រាយតាមសន្តិវិធីនូវរាល់ទំនាក់ទំនងទៅវិញទៅមក ព្រមទាំងបដិសេធការប្រើប្រាស់កម្លាំងជាដំណោះស្រាយបញ្ហា។

២- លក្ខខ័ណ្ឌសម្រាប់សហគមន៍អន្តរជាតិមួយទៀតគឺ ពុំត្រូវឱ្យមានការកសាងឬការបង្កើតឡើង នូវការប្រកួតប្រជែងគ្នាលើវិស័យសព្វាវុធ និងយោធាក្នុងចំណោមសមាជិកសហគមន៍។ មិនត្រឹមតែមិនត្រូវប្រើកម្លាំងប៉ុណ្ណោះទេ តែការប្រុងប្រៀបឬរៀបចំកម្លាំងឆ្ពោះទៅរកវិធានការយោធាទាំងឡាយ ក៏ពុំត្រូវបានអនុញ្ញាតឱ្យមានដែរ។ គឺថា រដ្ឋជាសមាជិកពុំត្រូវមានប្រព័ន្ធសព្វាវុធវាយលុក និងមិនត្រូវរៀបចផែនការ ឬប្រភពប្រមូលផ្តុំ សម្រាប់ធ្វើសង្គ្រាមប្រឆាំងរដ្ឋផ្សេងទៀតក្នុងសហគមន៍។

៣- ការបង្កើតឱ្យមាននូវស្ថាប័នផ្លូវការ ឬមិនផ្លូវការ ឬពាក់កណ្តាលផ្លូវការ សម្រាប់បំរើនូវការដោះស្រាយ បន្ធូរបន្ថយការតានតឹង ការការពារបង្ការ និងការគ្រប់គ្រងដោះស្រាយវិវាទជាយថាហេតុ។

៤- សហគមន៍សន្តិសុខមួយក៏ត្រូវការនូវ "កំរិតខ្ពស់នៃការធ្វើសមាហរណកម្ម ផ្នែកនយោបាយ និងសេដ្ឋកិច្ចដែលជាបុរេលក្ខខ័ណ្ឌ នៃទំនាក់ទំនងដោយសន្តិវិធី"។ ពុំមែនមានន័យថា ជាការចាំបាច់រហូតដល់មានជាប្រភេទអំណាច នយោបាយធំធេង

ពេកនោះទេ ប៉ុន្តែអាចត្រឹមថា មាននូវសហប្រតិបត្តិការ នយោបាយលើវិស័យនានា ឬសមាហរណកម្មខាងសេដ្ឋកិច្ចខ្លះ និងខាងបច្ចេកទេសខ្លះ ដូចជាផ្នែកពាណិជ្ជកម្មសេរី សហគមន៍គយ សហគមន៍សេដ្ឋកិច្ច ។ល។

តម្រូវការនេះផ្អែកទៅតាមបទពិសោធន៍ដែលធ្លាប់មាន គឺប្រសិនបើការ ពុំនាក់អាស្រ័យគ្នាទៅវិញទៅមកផ្នែកសេដ្ឋកិច្ច នយោបាយរវាងរដ្ឋ និងរដ្ឋ កើនឡើងពេលណា និងកាន់តែលើកកម្ពស់ នូវសហប្រតិបត្តិការលើវិស័យសន្តិសុខពេលនោះ ដោយគេមើលឃើញនូវភាព ពុំចាំបាច់នូវការប្រើប្រាស់កម្លាំង ដែលត្រូវចំណាយធនធានច្រើន តែបានផលប្រយោជន៍តិចតួច ដូចដែលបទពិសោធន៍នៃសហគមន៍សន្តិសុខ ដែលយើងបានឃើញរួចមក គឺរវាងសហរដ្ឋអាមេរិច និងកាដាណា។ ទោះបីជាប្រទេសទាំងពីរមានព្រំប្រទល់ផ្ទៃដី ព្រំដែនជាមួយគ្នា រហូត ៥.000 ម៉ៃល៏ តែពុំមានសញ្ញា កើតឡើងនូវសង្គ្រាមរវាងគ្នាអស់ពេលជិតមួយសតវត្សមកហើយ។ ព្រំដែនទាំងស្រុងស្ទើរពុំមានកម្លាំងការពារឡើយ។

ដោយឡែករវាងអូស្ត្រាលី និងញូហ្សីឡែន បណ្តារដ្ឋនៅបាល់ទិក ព្រមទាំងរដ្ឋនៅអឺរ៉ុបខាងលិច ក៏បានទទួលបទពិសោធន៍នៃការកសាងសហគមន៍ សន្តិសុខមួយដ៏ល្អផងដែរ។

## ASEAN និង សហគមន៍សន្តិសុខ

ពេលថ្មីៗនេះ ថ្នាក់ដឹកនាំប្រទេសអាស៊ានរំពឹងថា តើនឹងរៀបចំមូលដ្ឋានមួយសម្រាប់ការបង្កើតឡើងនូវសហគមន៍សន្តិសុខអាស៊ាន ឬ យ៉ាងណា?

គំនិតស្ដីពីសហគមន៍សន្តិសុខនេះ ច្រើនកើតឡើងនៅពេលដែល រដ្ឋមួយចំនួនទទួលស្គាល់ថា នៅក្នុងតំបន់ នៅមានការខ្វះខាតយន្តការ ឬរចនាសម្ព័ន្ធណាមួយសម្រាប់ដោះស្រាយនូវវិបត្តិ ឬបញ្ហាកើតឡើង ដូចជា វិបត្តិហិរញ្ញវត្ថុនៅអាស៊ី ដែលបានកើតមានកន្លងមក។

ក៏ប៉ុន្តែកត្តាទាំងអស់នេះ ក៏បានជំរុញអាស៊ានឱ្យពិនិត្យឡើងវិញនូវគោល ជំហរធ្លាប់អនុវត្តយូរកន្លងមកហើយ ដូចជា ការមិនអន្តរាគមន៍ ការមិនជ្រៀតជ្រែក ព្រមទាំងដំណើរការវិសហមជ្ឈការ នៃសហប្រតិបត្តិការអន្តរតំបន់។

ក្នុងគោលគំនិតនេះ ពិតជាត្រូវការឱ្យមានគំរោងការមួយដែលអនុញ្ញាត ឱ្យរដ្ឋនានាបំពេញកិច្ចការជាមួយគ្នា ដើម្បីដោះស្រាយបញ្ហាសន្តិសុខសំខាន់ៗ ពិសេសដូចជាបញ្ហាដែលមានចរិតឆ្លងដែន ដោយពុំធ្វើឱ្យមានការប៉ះពាល់ដល់គោលការណ៍ មិនជ្រៀកជ្រែក និងមិនអន្តរាគមន៍។

ជាការពិតហើយដែលថា សេចក្ដីត្រូវការចាំបាច់ក្នុងតំបន់គឺសហប្រតិបត្តិការរួមគ្នា ក្នុងការប្រឆាំងទប់ទល់ភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន និងដំណោះស្រាយជម្លោះដែលអំណោយផលឱ្យប្រទេសនានាទទួលបាននូវជំនួយគាំទ្រ ពេលមានវិបត្តិ ឬការគំរាមកំហែងណាមួយដែលកើតមានជាយថាហេតុ។

ដូចបានជម្រាបជូនខាងដើម ហើយថាទស្សនទានស្ដីពីសហគមន៍សន្តិសុខ បានកើតឡើងតាំងពីកណ្ដាលទសវត្ស ១៩៥០។ ដែលបានដៅឆ្ពោះទៅរកការ មានស្ថាប័នរួម ទំនាក់ទំនងគ្នា និងបន្លាស់ប្ដូរទៅមកបញ្ជៀសនូវការបង្កសង្គ្រាម រវាងប្រទេសអាមេរិចខាងជើង និងបណ្ដាប្រទេសអឺរ៉ុបខាងលិច សារៈសំខាន់នៃ ទស្សទាននេះគឺ

ការបង្កើតអន្តរកម្ម ទៅមករវាងរដ្ឋគ្រប់កម្រិត ដើម្បីដោះស្រាយដោយសន្តិវិធី នូវរាល់ទំនាស់ ឬអារិភាពផ្សេងៗ។

ដើម្បីវិភាគឱ្យច្បាស់ អំពីផលប៉ះពាល់ដល់ការបង្កើតសហគមន៍ សន្តិសុខអាស៊ាននេះ គួរមានការចាប់អារម្មណ៍លើចំណុចខ្លះ ដែលផ្អែកតាមទស្សនទាន ខាងលើ។

ដូចនេះសម្រាប់អាស៊ានឃើញថា មានលក្ខណៈសម្បត្តិខ្លះសមស្រប និងលក្ខខ័ណ្ឌសហគមន៍។

អាស៊ានបានបង្កើតពីឆ្នាំ ១៩៦៧ គោលបំណងចម្បងរបស់អាស៊ាន គឺ ការលើកកម្ពស់សហគមន៍សន្តិសុខ តែកាលនោះជាសម័យកាលសង្គ្រាមត្រជាក់។ អាស៊ានបានអះអាងថា នឹងពុំត្រូវឱ្យមានសង្គ្រាមប្រឆាំងគ្នារវាង សមាជិក សហគមន៍តាំងពីកាលជាង ៣០ ហើយ។ សហគមន៍អាស៊ានក៏បាន អនុម័តនូវ គោលការណ៍ និងទិសដៅដ៏ស្មុគស្មាញ ដ៏ច្រើនសម្រាប់សហគមន៍តំបន់ ហើយក៏ បានធ្វើអន្តរកម្ម ខាងនយោបាយ និងសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ឡើងៗ ក្នុងចំណោម សមាជិក (ពិសេសសមាជិកអាស៊ានចាស់ទាំង៦)។

ទន្ទឹមនឹងនេះវិស័យយោធាក្នុងអាស៊ាន ក៏ចាប់ផ្តើមមានការប្រែប្រួល យ៉ាងខ្លាំងនិងវិវត្តន៏តាំងពីការផ្លាស់ប្តូរពតិមានយោធាទៅមក ដូចជាមានការរៀបចំប្រជុំដាច់ដោយឡែករវាងមន្ត្រីយោធាថ្នាក់ខ្ពស់អាស៊ានតាំង ពីឆ្នាំ ២០០២ មក។ សហប្រតិបត្តិការរវាងកងទ័ពរបស់ប្រទេសនានាជា ទ្វេភាគី និងពហុភាគី ក៏ជាមាគ៌ាឆ្ពោះទៅមុខមួយសម្រាប់សហគមន៍សន្តិសុខអាស៊ានផងដែរ។

រដ្ឋនីមួយៗមានវិធានការ និងការអនុវត្តន៍របស់ខ្លួនច្បាស់លាស់ តាម លក្ខណៈច្បាប់ជាតិ តំបន់អន្តរជាតិ។ ទន្ទឹមនេះក៏មាននយោបាយការបរទេស ច្បាស់លាស់ក្នុងគោលបំណងពង្រឹងស្ថេរភាព សន្តិភាព និងសហប្រតិបត្តិការ ការអភិវឌ្ឍន៍។ គោលនយោបាយការបរទេសរបស់សមាជិកអាស៊ាននីមួយៗ គឺ ការប្រកាន់យក ដំណោះស្រាយដោយសន្តិវិធី។ ទន្ទឹមនឹងនេះដំណើរការនៃ វិធានការកសាងទំនុកចិត្ត កំពុង ប្រព្រឹត្តទៅយ៉ាងសកម្ម រវាងការងារការទូត និង យោធា។

- ការកសាងតម្លាភាពលើវិស័យនយោបាយការពារជាតិ ក៏កំពុងក្លាយជារបៀប វារៈជាអាទិភាពនៃកិច្ចការអាស៊ាន និងវេទិកាតំបន់អាស៊ាន (ARF)
- ឆ្លងកាត់ប្រវត្តិ ៣៦ ឆ្នាំរបស់ខ្លួន សមាគមអាស៊ានក៏បានផ្តល់បទពិសោធន៍ ដល់សមាជិក (ពិសេសសមាជិកអាស៊ានចាស់) នូវការយល់ គ្នាទៅវិញទៅមក យ៉ាងធំធេងផងដែរ។ ពេលថ្មីៗនេះប្រទេសទាំង ៤ កម្ពុជា ឡាវ ភូមា និងប្រទេសថៃដែលមានព្រំដែនជិតខាងគ្នា បានសម្រេចបង្កើតឡើងនូវ កិច្ចសហប្រតិបត្តិការចែករំលែកឱ្យគ្នាទៅវិញទៅមកលើវិស័យសំខាន់ៗ ដែលក្នុងនោះ មានវិស័យពាណិជ្ជកម្ម វិនិយោគ វិស័យកសិកម្ម ឧស្សាហកម្ម វិស័យហេដ្ឋា រចនាសម្ព័ន្ធគមនាគមន៍ផ្លូវថ្នល់ វិស័យទេសចរណ៍ និងវិស័យបណ្តុះបណ្តាលធនធានមនុស្ស។ មេដឹកនាំប្រទេសទាំង ៤ បានចុះហត្ថលេខា លើសេចក្តីថ្លែងការណ៍បាហ្គាន ដែលនិយាយអំពីយុទ្ធសាស្ត្រសហប្រតិបត្តិការ សេដ្ឋកិច្ចរវាង ប្រទេសទាំង ៤ និងការដាក់ចេញនូវផែនការសកម្មភាព សម្រាប់កិច្ច សហប្រតិបត្តិការទាំងអស់ផងដែរ។

នៅក្នុងកិច្ចសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្ម ប្រទេសទាំង៤ បានយល់ព្រមជាមួយគ្នាក្នុងការបង្កើត នូវផ្សារណាត់ពាណិជ្ជកម្មរវាង ប្រទេសទាំង៤ ក្នុង ១ ឆ្នាំម្តងៗ ដើម្បីឱ្យមានការផ្លាស់ប្តូរផលិតកម្មទៅវិញទៅមករវាងប្រទេសទាំង ៤ និងបង្កើតឱ្យមានទីផ្សារនៅតាមព្រំដែនរវាង ប្រទេសនីមួយៗ គឺច្រកចេញចូលតែមួយសម្រាប់ទេសចរណ៍ និងពាណិជ្ជកម្មតាមបណ្តោយព្រំដែន។

លើកិច្ចសហប្រតិបត្តិការកសិកម្ម និងឧស្សាហកម្ម មានការជួយប្រមូល លក់ទិញកសិផលរបស់ប្រទេសជិតខាងគ្នាទៅវិញទៅមក ឱ្យបានច្រើនជាងគេបំផុត និងជំរុញឱ្យឯកជនជួយបង្កើនការវិនិយោគកសិកម្ម។

លើផ្នែកឧស្សាហកម្ម ប្រទេសទាំង ៤ ក៏បានបង្កើតនូវមជ្ឈមណ្ឌលអភិវឌ្ឍសមត្ថភាពខាងការងារហើយក៏បានសម្រេចសិក្សា និងការកសាងវារីអគ្គិសនីទៅតាមព្រំដែន។

លើវិស័យទេសចរណ៍ប្រទេសទាំង ៤ ក៏បានសម្រេចធ្វើការសម្រួល ទិដ្ឋាការ (ដោយសម្រេចថា ទេសចរណ៍ដែលបានទទួលទិដ្ឋាការពីប្រទេសណាមួយ ក្នុងចំណោមប្រទេសទាំង ៤ ហើយនោះ អាចចូលទៅទស្សនា ប្រទេស ៣ ផ្សេងទៀតបាន) ចំណុចនេះ ប្រទេសទាំង ៤ កំពុងតែពិភាក្សា លម្អិតបន្ថែមទៀត ហើយក៏បានពង្រឹងកិច្ចសហប្រតិបត្តិការ លើវិស័យអាកាសចរណ៍រវាងប្រទេស ទាំង ៤ ។ ដែលប្រទេសទាំង ៤ មានបំណងធ្វើ យ៉ាងណា ដើម្បីវេញបញ្ចូលគ្នាឱ្យទៅជា (ប្រទេស៤គោលដៅ តែមួយ)។

ប៉ុន្តែ កត្តាវិជ្ជមានដែលអាចជំរុញឱ្យមានការបង្កើត នូវសហគមន៍ សន្តិសុខយើងឃើញនៅមានបញ្ហាប្រឈមខ្លះដូចតទៅ :

- ទស្សនទាននៃសន្តិសុខ សង្គ្រាម ឧក្រិដ្ឋកម្ម មានភាពផ្លាស់ប្តូរយ៉ាងគំហុក នាពេលបច្ចុប្បន្នដែលជំរុញឱ្យរដ្ឋសមាជិកនីមួយៗ ផ្តល់អត្ថន័យខុសៗគ្នា ចំពោះការវាយតំលៃទៅនឹងវិធានការលើការគំរាមកំហែង និងសន្តិសុខជាតិនីមួយៗ ។
- អធិបតេយ្យភាព បូរណភាពគឺជាកត្តាសំខាន់បំផុតរបស់រដ្ឋនីមួយៗ។ សមាជិកអាស៊ាន ប្រហែលជាជួបការលំបាក កាលបើត្រូវឈានដល់តំណាក់កាលណាមួយដែលត្រូវដំណើរការរំលងពីគោលការណ៏មិនជ្រៀតជ្រែក និងមិនអន្តរាគមន៏។ ទំនាក់ទំនង ពាណិជ្ជកម្មផ្ទៃក្នុងរវាងសមាជិកក្នុងអាស៊ានមាន កម្រិតតិចជាងជាមួយប្រទេសក្រៅអាស៊ាន ជាពិសេសទំនាក់ទំនងទ្វេភាគីជា មួយមហាអំណាចនៅក្រៅតំបន់ ទោះបីពេលថ្មីៗនេះ មានការលើកឡើងនូវការបង្កើតនូវយុទ្ធសាស្ត្រ សហប្រតិបត្តិការ សេដ្ឋកិច្ចជាមួយប្រទេសជិតខាងគ្នាក្តី។ ដោយរដ្ឋនីមួយៗ ក៏នៅផ្តោតខ្លាំង និងផ្អែកលើគោលការណ៏ អធិបតេយ្យដោយផ្ទាល់របស់ខ្លួន។

ចំពោះការអនុវត្តន៏គោលកាណ៏ឯកច្ឆន្ទ (Consensus) ក្នុងសហគមន៏សម្រាប់ដំណើរការ ដើម្បីសម្រេចដំណោះស្រាយណាមួយ ក៏មិនមែនជាការ ងាយស្រួល និងសាមញ្ញពេកសម្រាប់សសហគមន៏ដែរ។ បច្ចុប្បន្ននេះ និងតទៅអនាគត កិច្ចការចាំបាច់ដ៏ច្រើនសម្រាប់ដោះស្រាយ គឺទាក់ទងនិងសន្តិសុខឆ្លងដែន ដែលពិតជាមានវិធានការខុសៗ គ្នារវាងប្រទេសនីមួយៗ ដោយយោងទៅតាម ស្ថេរភាព វប្បធមិ សេដ្ឋកិច្ច នយោបាយ និងសមត្ថភាព ប្រសិទ្ធិភាពរបស់ អាជ្ញាធរ។

នៅមានប្រមូលផ្ដុំលើការពង្រឹង ផ្នែកយោធាតាមប្រទេសក្នុងសហគមន៍ពិសេស ក្នុងទិសដៅប្រឆាំងភេរវកម្ម និងនៅមានបញ្ហាចំពោះព្រំដែន ខ្លះៗនៅ ឡើយរវាងប្រទេសខ្លះ។

គម្លាតគ្នារវាងសមាជិកអាស៊ានចាស់ និងថ្មីទាមទារឱ្យមានការពុះពារ ក្រោមប្រសិទ្ធិភាពខ្ពស់ ដើម្បីសមាជិកមានកម្រិតមួយប្រហាក់ប្រហែលគ្នា។ កត្តា ទាំងនេះបានចោទជាសំណួរចំពោះដំណើរការឆ្ពោះទៅរក ការកសាងសមាគម សន្តិសុខមួយប្រកបដោយតុល្យភាព។

បញ្ហាដ៏ធំមួយទៀត ដែលត្រូវតែឋិតនៅក្នុងការគិតគូរដែរនោះគឺ សហគមន៍សន្តិសុខអាស៊ានត្រូវមានភារកិច្ច កិច្ចការសមស្របបែបណាឱ្យស៊ីសង្វាក់គ្នានិង ក្របខ័ណ្ឌ (យន្តការ) ខ្លះដែលអាស៊ានបានបង្កើតឡើងហើយ ដូចជា អាស៊ានត្រៃយកា ឬក៏កិច្ចព្រមព្រៀងដែលកំពុងមានដូចជាកិច្ចព្រមព្រៀង ស្ដីពី មិត្តភាព និងសហប្រតិបត្តិការជាដើម។ ចំណែកបញ្ហាពាក់ព័ន្ធដំណើរការប្រតិបត្តិវិញ តើត្រូវបង្កបង្កើតរៀបចំប្រភពធនធានសម្រាប់ចំណាយឬប្រើប្រាស់យ៉ាងដូចម្ដេច?

បច្ចុប្បន្ននេះសូម្បីតែស្ថាប័នអាស៊ានខ្លះ ដូចជាលេខាធិការដ្ឋានអាស៊ាន ក៏កំពុងដំណើរការក្នុងស្ថានភាពថវិកាមានកម្រិតបំផុត និងជួបប្រទះនូវកង្វះខាត ប្រភពធនធានព្រមទាំងសមត្ថភាពនៅឡើយ។

យើងឃើញហើយថា ផ្អែកតាមទិដ្ឋភាពនយោបាយ សេដ្ឋកិច្ចក្នុងតំបន់ បច្ចុប្បន្ននេះ ប្រភពហិរញ្ញវត្ថុ និងធនធានសម្រាប់រកបន្ថែមមកធានា ហាក់ដូចជា នៅឆ្ងាយនៅឡើយ។

បញ្ហាទី ២ ដែលទាក់ទង និងដំណើរការប្រតិបត្តិនេះដែរគឺ សិទ្ធិអំណាច បំពេញកាតព្វកិច្ចរបស់សហគមន៍។ ក្នុងវេទិកាសន្ទនា ដើម្បីកសាងសន្តិសុខ ក្នុងតំបន់ពហុភាគីនៅមានកម្រិតមួយដែលទាមទារការជំរុញរហូត ដល់បានក្លាយជា ស្ថាប័ន ឬរចនាសម្ព័ន្ធមួយសម្រាប់ដោះស្រាយជម្លោះ ឱ្យមានប្រសិទ្ធិភាព។ ដើម្បីឱ្យមាន ប្រសិទ្ធិភាព និងមានជំនឿជឿជាក់ យន្តការសហគមន៍សន្តិសុខនេះ ក៏គួរតែមាន សិទ្ធិអំណាច និងតួនាទី ដើម្បីចាត់ការ ឬផ្តួចផ្តើមដាក់គោលការណ៍ ដំណោះ ស្រាយណាមួយក្រោមស្ថានការណ៍ជាយថាហេតុ ដើម្បីកុំឱ្យក្លាយជា យន្តការដែលគ្មានធ្មេញ។ សំណួរចោទឡើងថា តើសមាជិកភាគច្រើននៃអាស៊ាន អាចអនុវត្តដោយមានការកៀបសង្កត់ ឬក្រោមឥទ្ធិពលពីខាងក្រៅដែរឬទេ?

## សេចក្តីសន្និដ្ឋាន

ឆ្លុះបញ្ចាំងទៅលើលក្ខខ័ណ្ឌខ្លះដូចខាងលើយើងមើលឃើញថា ប្រសិនបើត្រូវការ រៀបចំសហគមន៍សន្តិសុខនៅអាស៊ាន អាចនឹងមានអំណោយផលផង បញ្ហា ប្រឈមផង។ នោះគឺបញ្ហាពាក់ព័ន្ធនឹង :

១- បញ្ញត្តិកម្មជាប្រពៃណី ស្តីពីអធិបតេយ្យភាព និងបូរណភាពដែនដី ដែលរដ្ឋនិមួយៗមានអំណាចដាច់ខាត និងរូបមន្តស្វ័យយ័តក្នុងការត្រួតត្រា គ្រប់គ្រង ដែនខ័ណ្ឌសីមារបស់ខ្លួនតាមភូមិសាស្ត្រកំណត់មក។

២- ត្រូវការបង្កើតនូវជំនឿជឿជាក់ថា ការបង្កើតឡើងនូវសហគមន៍សន្តិសុខនេះ ត្រូវតែជំរុញលើកកំពស់រក្សានូវសន្តិភាព ស្ថេរភាព រដ្ឋជាសមាជិក ក្នុងសហគមន៍។

គំនិតនៃការបង្កើតសហគមន៍សន្តិសុខអាស៊ាននេះគឺ ជាទស្សនទានថ្មីមួយសម្រាប់ការស្វែងរកយន្តការរក្សាស្ថេរភាព សន្តិភាព និងការអភិវឌ្ឍន៍ ក្នុងតំបន់តាមសន្តិវិធី ដើម្បីផលប្រយោជន៍របស់តំបន់ និងប្រទេសជាសមាជិក។ ទោះបីជាដំណើរការនេះអាចមានឧបសគ្គខ្លះក្តី ហើយការវិវត្តន៍អាចត្រូវការពេលវេលាតទៅមុខទៀត ដើម្បីរៀបចំក្តី ក៏ប្រវត្តិសាស្រ្តនៃការបង្កបង្កើត សហគមន៍សន្តិសុខ នៅអឺរ៉ុប នៃបណ្តាប្រទេសខ្លះ គឺជាបទពិសោធន៍សម្រាប់ ពិចារណា និងផ្តល់នូវសុទិដ្ឋិនិយម មួយចំនួនសម្រាប់អនាគតសហគមន៍សន្តិសុខ នៅអាស៊ីភាគអាគ្នេយ៍ផងដែរ ពីព្រោះថា អ្វីដែលជាសេចក្តីត្រូវការធំបំផុតរបស់ តំបន់អាស៊ាន គឺការបញ្ចៀសសង្គ្រាម និងតម្រូវការអភិវឌ្ឍ។

# កម្ពុជានិងសហគមន៍សេដ្ឋកិច្ចអាស៊ានៈ ផលប៉ះពាល់លើសេដ្ឋកិច្ចកម្ពុជា

**ដោយបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី**

*ប្រធាននាយកដ្ឋានត្រួតពិនិត្យគម្រោង គណៈកម្មការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អម វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព*

## សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយតូច មានទីតាំងភូមិសាស្ត្រស្ថិតនៅចំកណ្តាលតំបន់អាស៊ីអាគ្នេយ៍ ដែលកំពុងមានសកម្មភាពមមាញឹកយ៉ាងខ្លាំង នៃសេដ្ឋកិច្ចពិភពលោកអស់រយៈពេលជាច្រើនទសវត្ស។ នៅឆ្នាំ១៩៩៩ កម្ពុជាបានចូលជា សមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ដែលប្រមូលផ្តុំប្រទេសចំនួន ១០ ហើយមានប្រជាពលរដ្ឋសរុបប្រមាណ ៥៥០ លាននាក់ និងមានផលិតផលក្នុងស្រុក សរុប (GDP) ប្រមាណ ៦០០ ពាន់លានដុល្លារ។ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) និងកាត់បន្ថយតារាងពន្ធគយភាគច្រើនបំផុត លើទំនិញទៅកាន់ប្រទេសជិត ខាងរបស់ខ្លួននៅត្រឹមចន្លោះ ០ និង ៥% ត្រឹមឆ្នាំ ២០១០ និងលុបបំបាត់ពន្ធគយទាំង ស្រុងនៅឆ្នាំ ២០១៨។

តំបន់ពាណិជ្ជកម្មសេរី អាស៊ាន-ចិន (CFTA) ដែលចូលជាធរមាននៅឆ្នាំ ២០១០ និងបង្កើតបានប្លុកពាណិជ្ជកម្ម មានប្រជាពលរដ្ឋ ១,៧ ពាន់លាននាក់។ ការពិភាក្សាកំពុងតែប្រព្រឹត្ត ទៅរវាងឥណ្ឌា និងអាស៊ានអាចបង្កើតបានប្លុកមួយទៀត ដែលមិនតូចជាងប្លុកមុនទេ។ លើសពីនេះទៅទៀត ក្នុងឋានៈជាប្រទេស មានការអភិវឌ្ឍន៍តិចតួច (LDC) កម្ពុជាបាន ទទួលភាពអនុគ្រោះ ក្នុងការនាំផលិតផលច្រើនប្រភេទ ចូលទៅកាន់ទីផ្សារប្រទេសអ្នកមាននានានៃពិភពលោក។

កម្ពុជាមានសេដ្ឋកិច្ចបើកចំហបំផុត នៅក្នុងតំបន់សេដ្ឋកិច្ច ដែលបើកចំហជាបង្គួរ។ សន្ទស្សន៍នៃសេរីភាពសេដ្ឋកិច្ច ដែលចងក្រងប្រចាំឆ្នាំ ដោយអង្គការ មូលនិធិមរតក នៅសហរដ្ឋអាមេរិច បានដាក់កម្ពុជាក្នុងចំណាត់ថ្នាក់ទី ៣៥ ក្នុងចំណោម ១៧០ ប្រទេសក្នុងឆ្នាំ ២០០៣។ នេះបានធ្វើឱ្យកម្ពុជាមានចំណាត់ថ្នាក់ ប្រហាក់ប្រហែលប្រទេសជប៉ុន ហើយបាននាំមុខប្រទេសថៃបន្តិច (ចំណាត់ថ្នាក់ ទី៤០) និងបាននាំមុខប្រទេសជិតខាងជាច្រើនរបស់ខ្លួនយ៉ាងខ្លាំង (ម៉ាឡេស៊ី ទី ៧២ ឥណ្ឌូនេស៊ី ទី៩៩ វៀតណាម ទី១៣៥ និងសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ទី១៥៣)។ ក្នុងចំណោមកត្តាទាំងនេះ សន្ទស្សន៍បានឆ្លុះបញ្ចាំង នូវអត្ថប្រយោជន៍ល្អៗជាច្រើនដល់វិនិយោគិន ដែលមានសក្តានុពល ដូចជា បន្ទុក សារពើពន្ធ ឧបសគ្គផ្នែកច្បាប់ទំលាប់ ភាពមានកម្រិតនៃទីផ្សារពលកម្ម គោលនយោបាយពាណិជ្ជកម្ម។ កម្ពុជាមានបញ្ហាដូចប្រទេសក្រីក្រកំពុងអភិវឌ្ឍ ឧទាហរណ៍ បញ្ហាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ប៉ុន្តែ យ៉ាងហោចណាស់ ក៏ជាកន្លែងដែលគោលនយោបាយរបស់រដ្ឋាភិបាល បានយកចិត្តទុកដាក់ចំពោះវិនិយោគិន ដែលអាចទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅ និងមានសេរីភាព។ ក្នុងចំណោម ប្រទេសមានការអភិវឌ្ឍន៍តិចតួច (LDCs) នៅលើពិភពលោក ដែល

បានសិក្សាខាងលើ សន្ទស្សន៍បានបង្ហាញថា កម្ពុជាទទួលបានចំណាត់ថ្នាក់ខ្ពស់ ជាងគេក្នុងន័យនៃមិត្តភាពផ្នែកទីផ្សារ។

ការបោះឆ្នោតជាតិលើកទី ៣ នៅខែកក្កដា ឆ្នាំ២០០៣ ត្រូវបានគេរំពឹងថា ជាការពង្រឹងស្ថេរភាពនយោបាយ។ ក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ រដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងជាប្រចាំ ដើម្បីបង្កើតបរិយាកាសទីផ្សារប្រកបដោយមិត្តភាព។ ក្នុងខែមីនា និងមេសា ២០០៣ កម្ពុជាបានអនុម័តច្បាប់ និងធ្វើវិសោធនកម្មលើច្បាប់ស្តីពីការវិនិយោគ និងច្បាប់ស្តីពីសារពើពន្ធ ដែលបានធានាបើកចំហ ចំពោះវិនិយោគផ្ទាល់ពីបរទេស (FDI)។ អ្នកវិនិយោគដែលបានបោះទីតាំង ក្នុងប្រទេសរួចជាស្រេចហើយនោះ មានសេចក្តីរីករាយជាខ្លាំងជាមួយនិងលក្ខណភាពនៃច្បាប់ថ្មីនេះ ជាពិសេសទាក់ទងនឹងការលើកទឹកចិត្តពន្ធអាករ គេពុំមានការសង្ស័យទេថា កម្ពុជានៅតែជាទីតាំងល្អ ដែលមានការទាក់ទាញផ្នែកសារពើពន្ធជាមួយនឹងអត្រា ២០% នៃពន្ធលើប្រាក់ចំណេញសំរាប់ស្ទើរគ្រប់សកម្មភាព។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ជាមួយតំណាងក្រសួងនិងនាយកដ្ឋានមួយ ចំនួនបាននឹងកំពុងកែលម្អសេវាកម្មសំរបសំរួលរបស់ខ្លួន ជាបណ្តើរៗសំរាប់អ្នកវិនិយោគ។ វិនិយោគផ្ទាល់ពីបរទេស ដែលមាននៅក្នុងប្រទេសរួចជាស្រេចបាន គ្របដណ្តប់លើសកម្មភាពជាច្រើនចាប់តាំងពីវិស័យទេសចរណ៍ កម្មន្តសាល រហូតដល់សេវាកម្មហិរញ្ញវត្ថុ ហើយអ្នកវិនិយោគអាចបញ្ចេញមតិប្រកបដោយប្រសិទ្ធភាព ក្នុងការធ្វើសេចក្តីសំរេច តាមរយៈវេទិកា រដ្ឋាភិបាល វិស័យឯកជន និងក្លិប ធុរកិច្ចអន្តរជាតិ (IBC)។

ប្រទេសកម្ពុជាមានទីផ្សារធំ បៀវត្សរ៍ទាប សេដ្ឋកិច្ចសេរី និងប្រទេសមួយមានសម្បត្តិវប្បធម៌ដ៏អស្ចារ្យលើពិភពលោក សំរាប់វិស័យទេសចរណ៍។ ទីផ្សារធំ គឺមុខងារនៃទីតាំងភូមិសាស្ត្រ មិនមែនត្រឹមតែជាទីផ្សារក្នុងស្រុក នៃប្រទេសកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែជាទីផ្សារនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN)។ អាស៊ាន ១០ ប្រទេសនេះមានប្រជាជនសរុបប្រមាណ ៥៥០លាន នាក់ និងបានចូលរួមក្នុងតំបន់ ពាណិជ្ជកម្មសេរី (AFTA) ដែលជាតំបន់នឹងមានសកម្មភាពពាណិជ្ជកម្ម សេរីពេញលេញនៅឆ្នាំ ២០១០ ជាមួយនឹងអត្រាពន្ធគយពី ០-៥%។ អាស៊ានក៏កំពុងចរចារអំពី តំបន់ពាណិជ្ជកម្មសេរីជាមួយប្រទេសចិនផងដែរ ការចរចារនេះអាចនឹងធ្វើចប់សព្វគ្រប់នៅត្រឹមឆ្នាំ ២០១០ ហើយការចរចារ ជាមួយឥណ្ឌាអាចនឹងប្រព្រឹត្តទៅក្នុងពេលយ៉ាងឆាប់ខាងមុខនេះ។ម្យ៉ាងវិញទៀត កម្ពុជាសមនឹងពាក្យគេនិយាយថា ជាប្រទេសសំបូរទីផ្សារនៅអឺរ៉ុប និងអាមេរិចខាងជើង ដោយសារកម្ពុជាជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច (LDC) ទទួលបានភាពអនុគ្រោះសំរាប់ទីផ្សារទាំងនេះ។

ដោយសារជាសេដ្ឋកិច្ចទីផ្សារសេរី កម្ពុជាមានសេដ្ឋកិច្ចបើកចំហរបំផុតនៅ ក្នុងតំបន់អាស៊ី ដែលមានចំណាត់ថ្នាក់ ស្មើនឹងប្រទេសជប៉ុន និងជាសេដ្ឋកិច្ចបើកចំហបំផុតក្នុងចំណោម៤៩ប្រទេស ដែលមានការអភិវឌ្ឍន៍តិចតួចនៅលើពិភពលោក។ ប្រាក់បៀវត្សរ៍ទាប និងកំលាំងពលកម្មអាចហ្វឹកហ្វឺនបាន គឺជាសម្បត្តិដ៏ប្រពៃ ក្នុងសេដ្ឋកិច្ចពិភពលោក ដែលកំពុងប្រកួតប្រជែងកាន់តែខ្លាំងឡើង។ នៅពេលដែលគេ និយាយដល់វិស័យ ទេសចរណ៍ ប្រាសាទអង្គរវត្តដ៏អស្ចារ្យនៅខេត្តសៀមរាប បានធានា រួចជាស្រេចថាកម្ពុជាកំពុងទាក់ទាញភ្ញៀវទេសចរណ៍ ជាមួយអត្រាកំណើនប្រចាំឆ្នាំជាង ៣០%។

ទេសចរណ៍ជាវិស័យ ដែលកម្ពុជាចង់ទាក់ទាញវិនិយោគបរទេសឱ្យបាន ច្រើនបំផុត។ ក្នុងវិស័យនេះវាសឹងតែមានលក្ខណៈពិសេសមួយ។ មិនដូចប្រទេស ជាច្រើនដ៏ទៃទៀត កម្ពុជាមានលក្ខណៈសម្បត្តិវប្បធម៌គួរឱ្យភ្ញាក់ផ្អើល ដូចជាមាន ប្រាសាទអង្គរ ប្រាសាទនានា អាចទទួលភ្ញៀវទេសចរណ៍ប្រមាណ ១ លាននាក់ ក្នុងប៉ុន្មាន ឆ្នាំខាងមុខនេះ និងសក្តានុពលនៅទីនេះអាចមានធំធេង។ សម្បត្តិមួយប្រភេទទៀត ដែលមានការខុសដាច់ពីសម្បត្តិខាងលើគឺពលកម្ម។ បច្ចុប្បន្នវិនិយោគិន និងរដ្ឋាភិបាលទទួលស្គាល់ថា កម្មករកម្ពុជាមិនទាន់ត្រូវបាន គេហ្វឹកហ្វឺនឱ្យល្អប្រសើរនៅឡើយ ប៉ុន្តែ បញ្ហានេះអាចនឹងដោះស្រាយបានក្នុងរយៈពេលដ៏ខ្លីខាងមុខ។ ស្ទើរតែគ្រប់ៗគ្នា បានឯកភាពថា កម្មករកម្ពុជាមានឆន្ទៈ និងអាចរៀនសូត្របាន និងប្រាកដជាងនេះទៅទៀត គឺមានការឧស្សាហ៍ព្យាយាម។ គេអាចនិយាយបន្ថែមទៀតថា ប្រាក់បៀវត្សរ៍របស់កម្មករកម្ពុជាស្មើនឹងពាក់កណ្តាល នៃប្រាក់បៀវត្សរ៍ថ្នាក់ទាបបំផុត នៅប្រទេសថៃនេះ បង្ហាញច្បាស់ថាយើង នឹងមានជោគជ័យនៅផ្នែកនេះ ជាភស្តុតាងឧស្សាហកម្មនាំចេញសំលៀកបំពាក់មានកំណើន គួចាប់ឱ្យចាប់អារម្មក្នុងទស្សវត្សរ៍កន្លងទៅនេះ។

តាមពិតទេសចរណ៍ជាវិស័យ ដែលមានការទាក់ទាញបំផុតសំរាប់ការវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជា។ ខណៈដែលគេយល់ថា ទេសចរណ៍ភាគច្រើន បំផុតបានចាប់អារម្មណ៍លើប្រាង្គប្រាសាទអង្គរ កម្ពុជាមានសម្បត្តិទេសចរណ៍ដទៃទៀតផងដែរ ឧទាហរណ៍ ឆ្នេរសមុទ្រក្រុងព្រះសីហនុ សម្រស់ទីក្រុងភ្នំពេញដែលជាអតីតទីក្រុងអាណានិគម។ ក្នុងចំណោមកាលានុវត្តភាពនានានៃវិស័យនេះមាន ដូចជា ទេសចរណ៍ធម្មជាតិ វប្បធម៌ ទីលានវាយកូនគោល និងសណ្ឋាគារ។ ភ្ជាប់ទៅនឹងវិស័យទេសចរណ៍ គឺជាកាលានុវត្តភាពមួយក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ។ សង្គ្រាមស៊ីវិល និង

ភាពឯកោបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធស្ទើរតែទាំងស្រុង ផ្លូវដែក ផ្លូវថ្នល់ និងស្ពាន ត្រូវការស្តារ និងកសាងឡើងវិញ។ គ្រោងការសង់-ប្រតិបត្តិ-ផ្ទេរ (BOT) បាននឹងកំពុងដំណើរការ ឧទាហរណ៍ : ព្រលានយន្តហោះ អន្តរជាតិភ្នំពេញ។ ហិរញ្ញប្បទានអាចទទួលបានពីប្រភពផ្សេងៗរួមមាន ធនាគារ អភិវឌ្ឍន៍អាស៊ី (ADB) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងប្រទេសម្ចាស់ជំនួយ ដូចជាប្រទេសជប៉ុន។ ថាមពលធារាសាស្ត្រ ក៏ជាសក្តានុពលផងដែរ ប៉ុន្តែគេត្រូវតែធ្វើការសិក្សាសមិទ្ធិភាពលទ្ធភាព។ កំលាំងពលកម្ម ដែលមានតំលៃថោករបស់កម្ពុជា បានទាក់ទាញវិនិយោគដ៏ច្រើនលើសលប់ក្នុងឧស្សាហកម្មសំលៀកបំពាក់។ ទោះបីជា កំលាំងជំរុញដំបូងៗ កើតចេញពីកូតាដែលមិនទាន់បានប្រើប្រាស់ក្រោមកិច្ចព្រមព្រៀង ផ្នែកសំលៀកបំពាក់ (Multi-fiber Arrangement) អ្នកវិនិយោគជឿជាក់ថា ឧស្សាហកម្មកម្ពុជានឹងនៅតែមានភាពប្រកួតប្រជែងបន្ទាប់ពី MFA នឹងបាត់បង់ នៅចុងឆ្នាំ ២០០៤។ កសិកម្មជាវិស័យមួយទៀតដែលមានកាលានុវត្តភាពដែរ ជាពិសេស ក្នុងផ្នែកកែច្នៃផលិតផលកសិកម្ម។ លក្ខណៈចាំបាច់ធម្មជាតិជាមូលដ្ឋាន គឺសម្បូរណ៍ដីមានជីជាតិ និងសម្បូរទឹក ប៉ុន្តែ អ្វីដែលខ្វះគឺដើមទុន និងចំណេះធ្វើ។ ទោះបីជា អ្នកវិនិយោគបរទេសមិនអាចមានកម្មសិទ្ធិលើដីធ្លីក៏ដោយ ប៉ុន្តែ គេអាចទទួលបានសិទ្ធិប្រើប្រាស់ដីរយៈពេលវែង តាមរយៈការជួលមានរយៈពេលរហូត ដល់៩៩ឆ្នាំ និងអាចទទួលបានកម្មសិទ្ធិផ្នែកខ្លះ ដោយសហការយកអ្នករស់នៅក្នុងស្រុក ដែលមានភាគ ហ៊ុន ៥១% ធ្វើជាដៃគូ។ ក្នុងពេលនោះដែរកាលានុវត្តភាពដែលចង្អុលបង្ហាញដោយរដ្ឋាភិបាលមានជលផល ការចិញ្ចឹមសត្វ ការស្លប្រេងដូង ការកែច្នៃម្ហូបអាហារ និងការកែច្នៃដើមក្រចៅ និងស្ករ។

## បញ្ហាប្រឈមសំរាប់សេដ្ឋកិច្ចកម្ពុជា

បញ្ហាជាទូទៅចំពោះប្រទេសស្ថិតក្នុងដំណាក់កាលដំបូងៗ នៃការអភិវឌ្ឍន៍សេដ្ឋកិច្ចក្រោយពេលសង្គ្រាម និងវិនាសកម្ម ដោយសារជម្លោះ និងអស្ថេរ ភាពនៅដើមទសវត្ស ៧0 និង ៨0។ ជាពិសេស របបគ្រប់គ្រង ខ្មែរក្រហមប្រឡាក់ឈាម (១៩៧៥-៧៩)។ អ្នកដែលមានកិរិតវប្បធម៌ជំនាញ គឺជាសម្បត្តិកម្រកបាន។ អត្រាអ្នកចេះអក្សរមានកម្រិតទាប បើប្រៀបធៀបនឹងប្រទេសជិតខាង : មានតែ ៦៨% បើធៀបនឹងវៀតណាមមាន ៩៤% និងថៃមាន ៩៦%។ អាយុកាលរស់នៅជាមធ្យមក៏មានកម្រិតទាប ៥៤ ឆ្នាំ បើប្រៀបធៀបនឹងវៀតណាម និងថៃគឺ ៦៩ ឆ្នាំ។ ក្នុងឆ្នាំ ២00១ ជនកម្ពុជាម្នាក់ក្នុងចំណោម ៤00 នាក់មានទូរស័ព្ទលើតុ បើប្រៀបធៀប នឹងឡាវមានមួយក្នុងចំណោម ១00 នាក់ វៀតណាមម្នាក់ក្នុងចំណោម ២៥ នាក់។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅមានកម្រិត និងមានលក្ខខ័ណ្ឌមិនល្អ ជាពិសេសនៅតំបន់ជនបទ។ អត្រាប្រើប្រាស់ថាមពលមានកម្រិតទាបបំផុត បើប្រៀបធៀបនឹងស្តង់ដាក្នុងតំបន់ និងអគ្គសនីមានតម្លៃខ្ពស់។ ប៉ុន្តែគេត្រូវនិយាយថា និន្នាការនៃវិស័យទាំងអស់នេះ គឺមានលក្ខណៈជាវិជ្ជមាន។ អ្នកវិនិយោគនៅ ក្នុងប្រទេសបានកត់សំគាល់ឃើញថា មានភាពល្អប្រសើរឡើង ច្រើនក្នុងវិស័យទូរ គមនាគមន៍ និងបណ្តាញផ្លូវថ្នល់ ទោះបីជាទាំងអស់នេះ មាននៅតែទីក្រុងធំៗ ដូចជា ភ្នំពេញក្រុងព្រះសីហនុ និងសៀមរាបក៏ដោយ។

អ្នកវិនិយោគក៏បានកត់សំគាល់ឃើញដែរថា មានផ្នែកដទៃទៀតដែលអំពាវនាវឱ្យរដ្ឋាភិបាលយកចិត្តទុកដាក់ជាបន្ទាន់ ដូចជា ភាពទន់ខ្សោយនៃរដ្ឋាភិបាល ដែលមានទូទាំងប្រទេស ភាពយឺតយ៉ាវដោយសារការិយាធិបតេយ្យ និងអំពើពុករលួយដែល

កើតមានគ្រប់ទីកន្លែង ពាសវាលពាសកាល។ បញ្ហាទាំងអស់បានបង្កើនការចំណាយដ៏សន្ធឹកបន្ទាប់ ក្នុងការធ្វើជំនួញនៅកម្ពុជា។ ភាពមិនគ្រប់គ្រាន់នៃក្របខ័ណ្ឌច្បាប់សម្រាប់ធ្វើវិនិ យោគគឺជាឧបសគ្គមួយទៀត និងការផ្លាស់ប្តូរច្បាប់ ទំលាប់យ៉ាងឆាប់រហ័សហាក់ដូចជា បានធ្វើឱ្យបញ្ហាកាន់តែធ្ងន់ធ្ងរឡើង ទោះបីជាការផ្លាស់ប្តូរនេះ មានសារៈសំខាន់សម្រាប់ការកសាងបរិយាកាសទីផ្សារប្រកបដោយមិត្តភាពក៏ដោយ។

## <u>**ការវិវឌ្ឍន៍វិស័យវិនិយោគ**</u>

វិនិយោគផ្ទាល់ពីបរទេស (FDI) បានកើនឡើងពីស្ទើរតែគ្មានអ្វីសោះនៅចុងទសវត្សរ៍ ៨០ ដល់ ៦១ លានដុល្លារជាមធ្យមក្នុង ១ ឆ្នាំនៅដើមទសវត្ស ៩០ និងដល់២១៧ លានដុល្លារ នៅចុងទសវត្សរ៍ ៩០។ នេះជាវិភាគទានមួយ ដែលកម្ពុជាអាចរៀបចំស្តារខ្លួនឯងឡើងវិញ បន្ទាប់ពីមានអស្ថេរភាពយូរអង្វែង។ ចំណុចពីរទៀតគួរឱ្យកត់សំគាល់ *ទីមួយ* នេះមិនមែនបណ្តាលមកពីការវិនិយោគផ្ទាល់ពីបរទេសចូលទៅក្នុងវិស័យធនធានធម្មជាតិ ដូចដែលធ្លាប់បានកើតមានឡើងជាញឹកញាប់ ក្នុងកាលៈទេសៈបែបនេះ។ ការបែងចែកតាមវិស័យនៃការវិនិយោគផ្ទាល់ពីបរទេស ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានបញ្ជាក់ថា ការវិនិយោគផ្ទាល់ពីបរទេសភាគច្រើនចូលទៅក្នុងផ្នែកទេសចរណ៍និងកម្មន្តសាល ហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ ដែលអាចទទួលបានលំដាប់ថ្នាក់លេខ៣។ *ទីពីរ* ក្នុងទសវត្សចុងក្រោយប្រទេសកម្ពុជា បានទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ច្រើនជាងបណ្តាប្រទេសជិតខាង និងគូប្រកួតប្រជែងរបស់ខ្លួន បើធៀបទៅនឹងសមាមាត្រនៃផលិតផលក្នុងស្រុកសរុប (GDP)។ សូម្បីតែក្នុងឆ្នាំ ២០០១ កម្ពុជាទាក់ទាញបានការវិនិយោគផ្ទាល់

ពីបរទេសច្រើនជាងប្រទេសជិតខាង ព្រមទាំងប្រទេសចិន បើសិនជាគិតតាមសមាមាត្រ ១,០០០ ដុល្លារ នៃផ.ស.ស។ នៅពេលដែលយើងដាក់ករណី ទាំងនេះបញ្ចូលគ្នា គុណសម្បត្តិ និងនិន្នាការវិជ្ជមាន ដែលបានពោលខាងលើបង្ហាញថា ការវិនិយោគរបស់កម្ពុជា ទំនងជាបន្តកើនឡើងយ៉ាងខ្លាំង នាពេលអនាគតដ៏ខ្លីខាងមុខ។

កម្ពុជាបានឆ្លងកាត់ផ្លូវដ៏វែងឆ្ងាយ ក្នុងរយៈពេលដ៏ខ្លី។ នេះជាចំណុចសំខាន់ដែលកម្ពុជាបានបង្ហាញថា សង្គមរបស់ខ្លួនបានជាសះស្បើយយ៉ាងឆាប់រហ័ស។ កន្លងទៅមិនយូរណាស់ណាទេ ដែលខ្មែរក្រហមបានត្រួតត្រាផ្នែកខ្លះនៃទឹកដីកម្ពុជា សុវត្ថិភាព និងសន្តិសុខ គឺជាបញ្ហាចាំបាច់។ សព្វថ្ងៃនេះ នៅពេលដែលគេសួរវិស័យឯកជន អំពីការព្រួយបារម្ភរបស់គាត់ បញ្ហាសន្តិសុខមិនត្រូវបាន គេលើកឡើងទេ ហើយអ្នកទេសចរអាចចូលទៅក្នុងបរិវេណប្រាសាទអង្គរវត្តដ៏ អស្ចារ្យគ្រប់ទីកន្លែង និងប្រកបដោយសុវត្ថិភាព។ ទោះបីជាកាលពីអតីតកាលជា សេដ្ឋកិច្ចបិទជិតក៏ដោយតែបច្ចុប្បន្ន នេះគឺជាសេដ្ឋកិច្ចទីផ្សារសេរី។ កម្ពុជាបានធ្វើការកែទម្រង់សេដ្ឋកិច្ចប្រកបដោយការវិភាគថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយ។ ក្នុងប្រទេសមួយដែលមានទី តាំងចំបេះដូងនៃតំបន់កំពុងអភិវឌ្ឍ រដ្ឋាភិបាលមានភាពជិតស្និតជាមួយធុរកិច្ចបង្ហាញការសន្យាច្បាស់លាស់ ក្នុងការផ្តល់យ៉ាងច្រើនឱ្យអ្នកវិនិយោគដែលមាន សេចក្តីក្លាហានជំនះ នូវឧបសគ្គទាំងឡាយ និងហ៊ានធ្វើការវិនិយោគក្នុងសេដ្ឋកិច្ច ដែលមិនទាន់មានការអភិវឌ្ឍន៍នៅឡើយ។

សម្រាប់ករណីកម្ពុជា បញ្ហាប្រឈមចម្បងមិនមែនពិបាករកឱ្យឃើញទេ បញ្ហាសំខាន់បំផុតនោះ អាចជាការអភិវឌ្ឍន៍ធនធានមនុស្ស។ គុណសម្បត្តិដែលមានទីតាំងភូមិសាស្ត្រស្ថិតក្នុងតំបន់ប្រកបដោយសក្តានុពលខ្លាំងក្លា ត្រូវប្រឈមមុខនឹង

ភាព ប្រកួតប្រជែងជាមួយប្រទេសជិតខាងដែលផ្តល់ឱ្យដូចគ្នា។ សមត្ថភាព ពីកំណើត នៃប្រជាជនកម្ពុជា បានបង្ហាញនូវប្រាង្គប្រាសាទអង្គរ អស់រយៈពេលរាប់ពាន់ ឆ្នាំមក ហើយ។ ការអភិវឌ្ឍន៍ឱ្យទៅជាជំនាញសម្រាប់កសាងសេដ្ឋកិច្ច ទំនើបមួយគឺមិនទាន់ បានចប់នៅឡើយទេ។ ពិតមែនតែអ្នកវិនិយោគបាននិយាយ ដោយវិជ្ជមានអំពីភាពអាច ហ្វឹកហ្វឺនបាន និងភាពឧស្សាហ៍ព្យាយាមនៃ កំលាំងពលកម្មរបស់កម្ពុជា គេក៏បានបញ្ជាក់ ម្តងហើយម្តងទៀតថា ការហ្វឹកហ្វឺនដែលគេទទួលបាន គឺមិនទាន់មានលក្ខណៈ គ្រប់គ្រាន់។

ការថែទាំសុខភាពក៏ជាអាទិភាពផងដែរ។ ទោះបីជាអត្រាឆ្លងមេរោគហ៊ីវ (HIV)កំពុងតែធ្លាក់ចុះ វានៅតែជាការព្រួយបារម្ភក្នុងប្រទេសក្រីក្រ ដែលមានសេវា ថែទាំសុខភាពតិចតួច។ ក្រៅតែពីការអប់រំ និងសុខភាព ហេដ្ឋារចនា សម្ព័ន្ធក៏ជាបញ្ហា។ ទោះបីជាអ្នកវិនិយោគ បានសំគាល់ឃើញថា មានភាពប្រសើរ ឡើងនៅក្នុងទីក្រុង និងនៅក្បែរទីប្រជុំជន ប៉ុន្តែភាគច្រើននៃប្រជាជន គឺរស់នៅទីជនបទ ហើយលទ្ធភាពចូល ទៅតំបន់ជនបទជាបញ្ហាធ្ងន់ធ្ងរ ជាពិសេស បើសិនជាគេរំពឹងថា ទៅធ្វើការវិនិយោគ ទាក់ទងនឹងវិស័យកសិកម្ម។

មានបញ្ហាប្រឈមមុខមួយចំនួនមិនសូវគំរាមកំហែង ប៉ុន្តែវាជាបញ្ហា គ្រឹះដែរ គឺកង្វះក្របខ័ណ្ឌច្បាប់ និងស្ថាប័ន។ ទីនេះគេពិតជានិយាយថា រដ្ឋាភិបាលបានខិតខំ ប្រឹងប្រែងជាប្រចាំ ជាពិសេស ជាមួយនឹងទស្សនៈនៃការចូលជាសមាជិកអង្គការ ពាណិជ្ជកម្មពិភពលោករបស់កម្ពុជា ដើម្បីបំពេញច្បាប់ទម្លាប់ដែល នៅខ្វះចន្លោះ។

បញ្ហាពីរដែលតំរូវឱ្យយកចិត្តទុកដាក់ជាចាំបាច់គឺ "ភាពចន្លោះប្រហោងនៅតាមច្រកព្រំដែន និងអភិបាលកិច្ចមិនមានតម្លាភាព"។

ប៉ុន្តែ នៅពេលអ្វីដែលបានកើតឡើងខាងលើត្រូវបានដោះស្រាយចប់ សព្វគ្រប់ កម្ពុជានឹងមានកាលានុវត្តភាពដ៏ច្រើនលើសលប់ ហើយពេលនោះការ វិនិយោគផ្ទាល់ពីបរទេស អាចនឹងទទួលផលចំណេញច្រើនក្នុងប្រទេសនេះ ហើយនេះមិនមែនជាការសង្ឃឹមទុកទេ តែវាជាការពិត។

**<u>កំណើនសេដ្ឋកិច្ច</u>**

ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) បានកើនឡើងយ៉ាងល្អប្រសើរក្នុង ឆ្នាំ ១៩៩៥ និង ១៩៩៦ ប៉ុន្តែ បានធ្លាក់ចុះវិញក្នុងឆ្នាំ ១៩៩៧ និង ១៩៩៨។ បន្ទាប់មក ផលិតផលក្នុងស្រុកសរុប បានកើនខ្លាំងឡើងវិញម្តងទៀត ផ.ស.ស បានកើនឡើងដល់ ៦.៣% ក្នុងឆ្នាំ ២០០១ និង ៥.៥% ក្នុងឆ្នាំ ២០០២ និងត្រូវ បានរំពឹងថានឹងកើនឡើងដល់ ៦% ក្នុងឆ្នាំ ២០០៣។ ប្រទេសនេះកំពុងតែមាន ដំណើរការងាកចេញជាបណ្តើរៗ ពីសេដ្ឋកិច្ចកសិកម្មនៃទសវត្សរ៍ ៨០ ឆ្ពោះយ៉ាងច្រើនទៅរកវាយនភ័ណ្ឌ ទេសចរណ៍ និងសេវាកម្ម។ កសិកម្មដែលនៅតែជាវិស័យចម្បងបានរួមចំណែក ៤៨.៤% ដល់ GDP ក្នុងឆ្នាំ ២០០១ និងផ្តល់ការងារ ៨០% ក្នុងចំណោមប្រជាពលរដ្ឋក្នុងវ័យធ្វើការងារ។ យ៉ាងណាក៏ដោយវិស័យដទៃទៀត ឧទាហរណ៍វិស័យកម្មន្តសាល ទេសចរណ៍ និងសេវាកម្មបានកើនឡើងជាលំដាប់។

# តារាង ផលិតផលក្នុងស្រុកសរុប(GDP) និងផលិតផលក្នុងស្រុកសរុបសំរាប់មនុស្សម្នាក់

## Table Gross Domestic Product (GDP) and Per Capital GDP

| | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 |
|---|---|---|---|---|---|---|---|---|---|---|
| GDP គិតជាពាន់រៀល | 8,594 | 9,371 | 10,017 | 10,514 | 11,231 | 11,647 | 12,903 | 13,810 | 14,593 | 15,392 |
| អត្រាកំណើន គិតជា (%) | | 9.0% | 6.9% | 5.0% | 6.8% | 3.7% | 10.8% | 7.0% | 5.7% | 5.5% |
| GDPសំរាប់ មនុស្ស ម្នាក់ គិតជា 000រៀល | 907 | 941 | 957 | 953 | 965 | 956 | 1,032 | 1,077 | 1,110 | 1,142 |
| អត្រាកំណើន គិតជា (%) | | 3.8% | 1.6% | -0.4% | 1.3% | -0.9% | 8.0% | 4.3% | 3.1% | 2.9% |
| GDP គិតជា លានដុល្លារ | 3,128 | 3,646 | 4,060 | 3,983 | 3,755 | 3,086 | 3,383 | 3,579 | 3,719 | 3,926 |
| អត្រាកំណើន គិតជា (%) | | 16.6% | 11.4% | -1.9% | -5.7% | -17.8% | 9.6% | 5.8% | 3.9% | 5.6% |
| GDP សំរាប់ មនុស្សម្នាក់ គិតជាដុល្លារ អាមេរិច | 330 | 336 | 388 | 361 | 323 | 253 | 271 | 279 | 283 | 219 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| អត្រាកំណើន គិតជា (%) | | 10.9% | 5.9% | -6.9% | -10.6% | -21.5% | 6.8% | 3.1% | 1.4% | 3.0% |
| ការចំណាយប្រើប្រាស់ចុងក្រោយ របស់គ្រួសារ (HFCE) | 8,087 | 8,476 | 9,328 | 9,993 | 9,927 | 10,797 | 11,490 | 11,838 | 11,868 | 12,090 |
| HFCE សំរាប់មនុស្សម្នាក់ គិតជា 000រៀល | 854 | 851 | 891 | 906 | 853 | 886 | 919 | 923 | 903 | 897 |
| HFCE សំរាប់ មនុស្សម្នាក់ប្រចាំ ខែ គិតជារៀល | 71,131 | 70,956 | 74,244 | 75,466 | 71,072 | 73,834 | 76,581 | 76,919 | 75,224 | 74,778 |

ការប៉ាន់ស្មានចំនួនប្រជាពលរដ្ឋ ( នៅខែកក្កដា គិតជាលាននាក់ Population Estimate (As of July, in million)¦

(Estimated based on NIS polupation count as of January 1999)

ការប៉ាន់ស្មានផ្អែកទៅលើចំនួនប្រជារាស្ត្រ របស់វិទ្យាស្ថានជាតិស្ថិតិ នៅខែ មករា ឆ្នាំ ១៩៩៩

9,474 9,954 10,470 11,034 11,640 12,186 12,503 12,825 13,148 13,473

អត្រាប្តូរប្រាក់ជាផ្លូវការ (រៀល/ដុល្លារអាមេរិច)

Official Exchange rate (Riels/US$) (Average mid-point buying and selling rate)

(មធ្យមកណ្តាលថ្លៃលក់ និងថ្លៃទិញ)

2747 2570 2467 2640 2991 3774 3814 3859 3924 3921

ផលិតផលក្នុងស្រុកសរុប (GDP) តាមសកម្មភាពសេដ្ឋកិច្ច

អត្រាកំណើនគិតជាភាគរយ

Gross Domestic Product (GDP) by Economic Activity

| | តាមថ្លៃស្ថេរ ឆ្នាំ ២០០០ (in constant 2000 prices) | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | 93-94 r/ | 94-95 r/ | 95-96 r/ | 96-97 r/ | 97-98 r/ | 98-99 r/ | 99-00 r/ | 00-01 r/ | 01-02 p/ |
| កសិកម្មនេសាទ និង ព្រៃឈើ | 11.2% | 3.3% | 1.0% | 6.4% | 5.8% | 3.4% | -1.5% | 2.2% | -2.7% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ដំណាំ | 2.6% | 11.3% | 3.1% | -1.5% | 8.6% | 15.1% | 3.0% | 0.5% | -5.8% |
| បសុសត្វនិងបសុបក្សី | 2.6% | 11.3% | 1.5% | 0.5% | 6.3% | -1.2% | -9.4% | 11.6% | 1.2% |
| នេសាទ | -3.1% | 8.2% | 4.6% | 5.6% | 3.9% | -1.6% | 5.9% | 6.8% | 1.3% |
| ព្រៃឈើ និងអាជីវកម្មឈើ | 95.7% | 8.2% | -15.7% | 52.3% | 1.8% | -13.8% | -25.6% | -18.9% | -9.3% |
| ឧស្សាហកម្ម | 17.2% | 23.2% | 5.2% | 19.6% | -2.5% | 19.3% | 30.7% | 12.9% | 17.7% |
| ការរុករករ៉ែ | 29.4% | 20.0% | -13.7% | -1.8% | -13.7% | 32.8% | 24.8% | 13.4% | 18.7% |
| កម្មន្តសាល | 13.8% | 24.3% | 13.8% | 30.9% | 2.1% | 17.3% | 29.5% | 14.2% | 15.1% |
| ម្ហូបអាហារ ភេសជ្ជៈនិង ថ្នាំជក់ | -2.6% | 18.2% | -0.4% | 2.3% | 8.6% | 4.7% | -5.4% | 4.5% | -2.0% |
| តម្បាញ សំ លៀកបំពាក់ និងស្បែកជើង | 25.8% | 77.4% | 69.6% | 89.9% | 30.0% | 34.6% | 63.4% | 22.7% | 21.0% |
| ឈើ ក្រដាស់ និងបោះពុម្ព | 75.5% | 30.0% | 5.3% | 45.1% | -55.4% | -16.1% | -11.9% | -31.9% | 13.3% |
| ការផលិត កៅស៊ូ | -8.5% | 19.5% | 21.4% | 3.7% | 76.4% | 14.8% | 10.0% | 0.8% | -0.7% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ការផលិត ដទៃទៀត | 10.5% | 7.1% | 10.9% | 6.0% | 9.5% | 18.9% | 14.0% | 11.7% | 14.0% |
| អគ្គិសនី-ឧស្ម័ន និងទឹកស្អាត | 8.6% | 36.2% | 0.8% | 1.3% | 3.7% | 3.8% | 4.0% | 2.5% | 2.5% |
| សំណង់ | 23.4% | 20.8% | -8.5% | -2.5% | -15.7% | 27.4% | 36.8% | 9.6% | 26.8% |
| សេវាកម្ម | -2.0% | 8.4% | 7.8% | 3.4% | 4.8% | 10.9% | 5.7% | 4.2% | 4.5% |
| ពាណិជ្ជកម្ម | -11.5% | 5.1% | 2.2% | 9.1% | 2.4% | 1.8% | -2.1% | 0.9% | 0.8% |
| សណ្ឋាគារនិង ភោជនីយដ្ឋាន | 18.1% | 42.5% | 0.6% | 3.3% | -1.3% | 18.5% | 14.4% | 18.1% | 11.4% |
| ដឹកជញ្ជូន និង គមនាគមន៍ | 11.4% | 7.1% | 11.6% | -6.6% | 1.5% | 23.0% | 4.2% | 9.9% | 0.8% |
| ហិរញ្ញវត្ថុ | 21.5% | 138.9% | 6.7% | 3.6% | -9.5% | 19.7% | 24.4% | -8.2% | -5.7% |
| រដ្ឋាបាលសាធារណៈ | 71.3% | -6.4% | 23.9% | 4.2% | 10.8% | -1.2% | -0.8% | -2.4% | 1.6% |
| អចលនទ្រព្យ និង ជំនួញ | -22.5% | 3.9% | 6.5% | 6.7% | 10.1% | 8.0% | 3.8% | 3.1% | 3.2% |
| សេវាកម្មដទៃទៀត | 8.8% | -0.5% | 18.8% | -2.9% | 16.1% | 28.8% | 24.0% | 2.3% | 16.8% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ពន្ធលើផលិតផល ដកឧបត្ថម្ភធន | 80.8% | 1.8% | 14.3% | 5.3% | -2.4% | 39.2% | 4.5% | 7.1% | 10.6% |
| ដក : ឧបត្ថម្ភធន | 104.7% | 128.1% | 90.6% | -61.6% | 93.6% | -24.6% | 171.7% | 5.5% | 57.1% |
| ដក : ប្រាក់កំរៃ ធនាគារ | 21.5% | 269.1% | -19.8% | 65.6% | -6.4% | -11.3% | 23.1% | -4.7% | -5.3% |
| ផលិតផលក្នុង ស្រុកសរុប (GDP) | 9.0% | 6.9% | 5.0% | 6.8% | 3.7% | 10.8% | 7.0% | 5.7% | 5.3% |

r/ ការប៉ាន់ស្មានកែតំរូវឡើងវិញ — r/- revised estimates

p/ ការប៉ាន់ស្មានដំបូង — p/- preliminary estimates

Growth Rate in Percent

ប្រភព : វិទ្យាស្ថានជាតិស្ថិតិ (2002) និង CDRI (2002)

បន្ទាប់ពីរដ្ឋាភិបាលថ្មីត្រូវបង្កើតឡើងក្នុងឆ្នាំ ១៩៩៣ ដោយប្រកាន់ខ្ជាប់នូវកម្មវិធីកែតម្រូវរចនាសម្ព័ន្ធ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រទេសកម្ពុជាសំរេចបានជោគជ័យជាប្រវត្តិសាស្ត្រ។ អតិផរណាត្រូវបានកាត់បន្ថយពី ក៏រិតជាង ១00% នៅចុងទសវត្សរ៍ ៩0 រហូតដល់តិចជាង ៥% ក្នុងរយៈពេល ៧ ឆ្នាំចុងក្រោយនេះ។

## ពាណិជ្ជកម្ម និងការវិនិយោគ

គ្រប់ការដាក់កំហិតលើបរិមាណត្រូវបានដកចេញស្ទើរតែទាំងស្រុង ។ ការដាក់កំហិតធ្វើឱ្យសមត្ថភាព ក្រុមហ៊ុន និងបុគ្គលមានក៏រិត ក្នុងការធ្វើពាណិជ្ជកម្ម អន្តរជាតិ។ ក្នុងពេលថ្មីៗនេះ របបតារាងពន្ធគយត្រូវបានកែសំរួលយ៉ាងច្រើន ប្រភេទ អត្រាពន្ធគយបានកាត់បន្ថយពី១២ ក្រុមមកដល់ ត្រឹមតែ៤ ក្រុម និងទំនិញដែលមានអត្រាពន្ធគយខ្ពស់បំផុត ត្រូវកាត់បន្ថយមកត្រឹម ៣៥%។

ទំនិញនាំចេញសំខាន់ៗរបស់កម្ពុជា គឺសំលៀកបំពាក់ ស្បែកជើង ផលិតផលឈើ និងកៅស៊ូ។ ផលិតកម្មសំលៀកបំពាក់ គឺជាផលិតកម្មសំរាប់ការនាំចេញស្ទើរតែទាំងស្រុង។ ទីផ្សារសំខាន់ៗ សំរាប់សំលៀកបំពាក់ គឺសហរដ្ឋអាមេរិចនិងសហភាពអឺរ៉ុប។ ក្នុងឆ្នាំ ២000 កម្ពុជាបាននាំចេញ ៧៦% នៃផលិតផលរបស់ខ្លួនទៅកាន់សហរដ្ឋអាមេរិច និង២៣% ទៅកាន់សហភាពអឺរ៉ុប។ ទំនិញស្បែកជើងរបស់កម្ពុជាបាននាំចេញទៅកាន់អឺរ៉ុប ៦0% និងទៅជប៉ុន ៣៥% (ក្រសួងពាណិជ្ជកម្ម ២00២)។

កំណើនប្រចាំឆ្នាំនៃទំនិញនាំចេញមានជាមធ្យម ១៩.៧% ក្នុងអំឡុងឆ្នាំ ១៩៩៥-២០០១ ដែលក្នុងនោះទំនិញនាំចេញក្នុងស្រុក បានកើនឡើង ២៦,៨% និងទំនិញនាំចេញបានកើនឡើង ៨.៨%។ ទំនិញនាំចូលក៏បានកើនឡើងយ៉ាងឆាប់រហ័សផងដែរ ដោយមានអត្រាកំណើនប្រចាំឆ្នាំ ១៣.៥% ក្នុងរយៈពេលដូចគ្នា។ ទំនិញនាំចេញស្ថិតក្រោម ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម (GSP) ភាគច្រើនជា សំលៀកបំពាក់ បានគ្របដណ្តប់លើបរិមាណទំនិញនាំចេញ និងបានកើនឡើងពី ២ លានដុល្លារ ក្នុងឆ្នាំ ១៩៩៤ ដល់ជាង ១១៤១ លានដុល្លារ ក្នុងឆ្នាំ ២០០១ ដែលមានអត្រាកំណើនជាមធ្យម ២៧0% ក្នុងមួយឆ្នាំ។

កម្ពុជាបានទាក់ទាញ ការវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលមានចំនួនទឹកប្រាក់កើនឡើងនៅទសវត្សរ៍ឆ្នាំ ១៩៩0។ ដូចតារាងនេះបានបង្ហាញ ច្បាស់ថា បើគិតជាសមាមាត្រកម្ពុជាទាក់ទាញបានការវិនិយោគផ្ទាល់ពីបរទេស ច្រើនជាងប្រទេសដទៃទៀត ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩0 រហូតដល់ ឆ្នាំ ២០០១ (កូលោនទឹកប្រាក់វិនិយោគជាដុល្លារ សំរាប់រាល់ $១000 នៃ ផ.ស.ស)។ សូម្បីតែក្នុងឆ្នាំ ២00២ ក្រៅពីប្រទេសចិន និងវៀតណាម កម្ពុជា ទាក់ទាញបាន ការវិនិយោគផ្ទាល់ពីបរទេសច្រើនជាងប្រទេសដទៃទៀត ដែលមាន ឈ្មោះនៅក្នុងតារាង បើធៀបទៅនឹងទំហំសេដ្ឋកិច្ចរបស់ខ្លួន ។ ភាពល្អប្រសើរឡើង នៃស្ថានភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងភាពបើកចំហនៃសេដ្ឋកិច្ច បានជួយសំរួលការងារនេះយ៉ាងច្រើន។

យោងទៅតាមតួលេខជាផ្លូវការ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប្រទេសម៉ាឡេស៊ី គឺជាអ្នកវិនិយោគធំជាងគេបំផុត ក្នុងអំឡុងឆ្នាំ ១៩៩៤-២០០១ ដោយមាន

ចំណែក ៣១,២% នៃវិនិយោគទាំងអស់ និង ៧៩% ទៀត ជាវិនិយោគមក ពីប្រទេសអាស៊ានក្នុងរយៈកាលដូចគ្នា។ ម៉ាឡេស៊ី ជាប្រទេសទីមួយដែលបាន ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ការលើកលែងទិដ្ឋាការទ្វេភាគីជាមួយកម្ពុជានៅឆ្នាំ ១៩៩២ និងអ្នកវិនិយោគម៉ាឡេស៊ី ជាអ្នកចូលមកកម្ពុជាលើកដំបូងគេ ដូចនេះហើយពួកគេទទួលបានសម្បទានវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់ រួមមានសម្បទានក្នុងផ្នែករ៉ែ និងព្រៃឈើ។ ប្រភពនៃការវិនិយោគផ្ទាល់ ពីបរទេសដ៏សំខាន់ដទៃទៀតគឺ តៃវ៉ាន់ខេត្តនៃប្រទេសចិន (៨,២៧%) សហរដ្ឋអាមេរិច (៧,២៨%) និងប្រទេសចិន (៤,៤៧%)។

## <u>**សេចក្ដីសន្និដ្ឋាន**</u>

ការចូលជាសមាជិកអាស៊ាន ជាពិសេសសហគមន៍សេដ្ឋកិច្ចអាស៊ាន បានជះឥទ្ធិពលល្អ យ៉ាងខ្លាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចកម្ពុជា។

សំរាប់សភាពការណ៍សេដ្ឋកិច្ចបច្ចុប្បន្ន កម្ពុជាត្រូវខិតខំពង្រឹងបរិស្ថានវិនិយោគរបស់ខ្លួនឱ្យបានល្អ និងអំណោយផល ជាការជំរុញវិស័យវិនិយោគឯកជនឱ្យ លូតលាស់បានឆាប់រហ័ស ជួយទ្រទ្រង់សាជីវកម្មឯកជន សហគ្រាស ធុនមធ្យម-ធុនតូច ដែលជាប្រការសំខាន់ណាស់សំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ព្រោះថា វិស័យនេះជាដៃគូមួយនៃកំលាំងចលករ សំរាប់លើកស្ទួយកំណើនសេដ្ឋកិច្ច និងជួយតំរែតំរង់ទិស សេដ្ឋកិច្ចឱ្យដើរចំទៅតាមមាគ៌ាត្រឹមត្រូវពិតប្រាកដ។ កម្ពុជាត្រូវខិតខំទាញ យកផលប្រយោជន៍ឱ្យបានជាអតិបរមាពី សមាហរណកម្មសេដ្ឋកិច្ចផង និងពីពាណិជ្ជកម្មអន្តរជាតិផង ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក នេះជាប្រការ ដែលអាចជួយជំរុញឱ្យកម្ពុជាធ្វើសមាហរណកម្ម កាន់តែសុក្រិត និងស៊ីជំរៅទៅក្នុងសេដ្ឋកិច្ច ពិភពលោក បាន។

ការអនុវត្តន៍ត្រឹមត្រូវបែបនេះបានធ្វើឱ្យសង្គមកម្ពុជា ទទួលបាននូវភាពរីកចំរើនជឿនលឿនសម្បូណ៍ សប្បាយសុខដុមរមនា ប្រជាជនមានជីវភាពរស់នៅសមរម្យមានសុភមង្គល។ ក៏រិតក្រីក្រនៃប្រជាជនត្រូវបានកាត់បន្ថយ ហើយប្រទេសជាតិនឹង មានដំណើរអភិវឌ្ឍទៅមុខ កាន់តែឆាប់រហ័សដែលអាចតាមទាន់អារ្យប្រទេសនានា ក្នុងសាកលលោកបាន។

# កម្ពុជា និង សហគមន៍សង្គមវប្បធម៌អាស៊ាន

**ដោយឯកឧត្តមបណ្ឌិត ឆយ យីហ៊ាង**

*ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកវិស័យអប់រំ ប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ*

*សមាជិករាជបណ្ឌិត្យសភាកម្ពុជា និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អម*

*វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព*

## ក_សេចក្តីផ្តើម

កម្ពុជាបានឆ្លងកាត់មាគ៌ាដ៏ច្រើននៅក្នុងជីវិតរបស់ខ្លួន ដូចដែលប្រវត្តិសាស្ត្របានបញ្ជាក់ស្រាប់។ នៅក្នុងសម័យរុងរឿងប្រជាជនមានសេចក្តីថ្លៃថ្នូរ និងមានវឌ្ឍនភាពដូចក្នុងសម័យមហានគរជាឧទាហរណ៍។ ផ្ទុយទៅវិញនៅក្នុង សម័យអាប់ឱនប្រជាជនបាត់បង់កិត្តិយស និងអំណាចរបស់ខ្លួន ដោយឆ្លងកាត់សង្គ្រាមយ៉ាងជូរចត់ខ្លោចផ្សា។ នោះជាមេរៀន ដែលគ្រប់ប្រទេសនៅក្នុងពិភពលោកសុទ្ធតែបានបញ្ជាក់ថា សង្គ្រាមជាប្រភពនៃគ្រប់គ្រោះមហន្តរាយ។

នៅពេលនេះ ប្រទេសទាំងអស់នៅក្នុងពិភពលោករួបរួមសហការ និងកសាងមូលដ្ឋានសន្តិភាព ភាតរភាព និងមិត្តភាព។ គំនិតឈ្លានពានលុកលុយពីប្រទេសមួយទៅប្រទេសមួយជាគំនិតអន់ថយ។ នៅចំពោះមុខស្ថានការណ៍នេះ ប្រជាជនកម្ពុជា

ដ៏អង់អាចក្លាហានត្រូវតែតស៊ូយ៉ាងប្អូរផ្តាច់សម្រាប់អត្តិភាពរបស់ខ្លួន ក្នុងពេលសព្វថ្ងៃផង និងសម្រាប់មនុស្សជំនាន់ក្រោយផង។ ប្រជាជនកម្ពុជា ត្រូវតែគិតពិចារណាអំពីឱកាស ការប្រលងប្រណាំង និងចក្ខុវិស័យអនាគត ដែលត្រូវចាប់ផ្តើមដោះស្រាយដោយមិនគ្រាន់តែនៅក្នុងចំណោមខ្មែរទាំងអស់គ្នាទេ តែត្រូវពិចារណាដោះ ស្រាយជាមួយប្រជាជនដទៃទៀត។ ការពង្រឹង និងពង្រីកអត្តិភាពរបស់ខ្លួន ជាមួយប្រជាជាតិដទៃ ដើម្បីសន្តិសហវិជ្ជមាន គឺជាកត្តា ចាំបាច់មិនអាចខ្វះបានឡើយ។

ក្នុងឋានៈជាប្រទេសមួយស្ថិតនៅក្នុងក្រុមប្រទេសតតិយលោក កម្ពុជាត្រូវខិតខំចងមិត្តជាមួយប្រជាជាតិដទៃទៀត ជាពិសេសជាមួយប្រទេសជាសមាជិកនៃអាស៊ាន (ASEAN)។ យោងតាមកំណែទម្រង់គ្រប់វិស័យ យើងចង់កសាងកម្ពុជាមួយប្រកបដោយសណ្តាប់ធ្នាប់ល្អ។ ការផ្តួចផ្តើមមតិ ដើម្បីបង្កើតសណ្តាប់ធ្នាប់កម្ពុជា ថ្មីនេះអាចនឹងត្រូវវាយតម្លៃថាជាអ្វី ដែលប្រជាជនកម្ពុជារួមចំណែកពង្រឹង ពង្រីកសិទ្ធិមនុស្ស សេរីភាព និងប្រជាធិបតេយ្យ។ គំនិតនេះអាចទទួលជោគជ័យបានដោយ អវត្តមាននៃហិង្សា ឬដោយវត្តមាននៃការអត់ឱន និងយុត្តិធម៌។ ការបណ្តុះស្មារតីអត់ឱនយោគយល់គ្នាទៅវិញទៅមកនៅក្នុងសង្គមជាតិរបស់យើងជាកត្តាកំណត់ ក្នុងការពង្រឹងអត្តសញ្ញាណជាតិឡើងវិញ បន្ទាប់ពីយើងបែកបាក់គ្នាអស់រយៈពេលជាច្រើនមក។

ពេលនេះជាពេលដែលយើងត្រូវចោទសួរពីអ្វី ដែលយើងត្រូវធ្វើដើម្បីមាតុភូមិរបស់យើងនៅចំពោះមុខទិសដៅរួមនៃសាកលលោក។ ពិតណាស់យើង មិនអាចរស់នៅឯកោបានឡើយ។ ប្រសិនបើយើងបិទទ្វារយើងនឹងស្លាប់។ យើងត្រូវបើកទ្វារចំហគ្រប់ទិសទី។ ប៉ុន្តែនៅពេលដែលយើងបើកទ្វារចំហជ្រុងទាំងពីរ ល្អ និងអាក្រក់នៃសាកលភាវូបនីយកម្ម ពិតជាឈានជើងចូលមកដល់សង្គមយើង។ យើងត្រូវក្លាហាន

និងតស៊ូដើម្បីកាត់បន្ថយជ្រុងអវិជ្ជមាននៃសាកលភាវូបនីយកម្ម ដោយសារការប្រើប្រាស់វិចារណញាណរបស់យើង។ ក្នុងករណីនេះ បើយើងមិនបើកទ្វារចំហ ក៏យើងស្លាប់តែបើយើងបើកទ្វារចំហដោយខ្វះការ ពិចារណាក៏យើងស្លាប់ដែរ។

## ខ_បរិបទពិភពលោក សាកលភាវូបនីយកម្ម សាកលនិយម និង ការចំណុះគ្នាទៅវិញទៅមក

### ១-បរិបទពិភពលោក

ភាពឯកោដែលធ្លាប់មាននៅក្នុងសង្គមបុព្វកាល ឬនៅក្នុងសង្គមទាសភាព ត្រូវរលាយបាត់បង់តាំងពីយូរយាណាស់មកហើយ។ ទំនាក់ទំនងសាកល បាននឹងកំពុងរីករាលដាល។ ពិភពលោកមានទំនោរទៅរកលក្ខណៈរួមមួយ ពោលគឺទៅរកទំនាក់ទំនងទៅវិញទៅមក និងសាកលភាវូបនីយកម្ម ស្ដីពីលក្ខខណ្ឌ សេដ្ឋកិច្ច បច្ចេកវិទ្យា សង្គម និងវប្បធម៌។ ទិដ្ឋភាពដ៏សំខាន់នៃបំរែបំរួលខាង បច្ចេកវិទ្យា គឺជាបដិវត្តន៍ខាងទូរគមនាគមន៍។ គឺបដិវត្តន៍ទូរគមនាគមន៍នេះ ហើយដែលធ្វើឱ្យផែនដីរបស់យើងហាក់ដូចជា នៅរួញតូចត្រឹមតែជាភូមិមួយ ប៉ុណ្ណោះ។ លោក **សាពួរ រ៉ាសិច** (Shapour Rassekh) បានសរសេរថា" *ទិដ្ឋភាពដ៏សំខាន់នៃបំរែបំរួលខាងបច្ចេកវិទ្យាដែលកំពុងចោទឡើង គឺបដិវត្តន៍ ទូរគមនាគមន៍ ដែលធ្វើឱ្យពិភពលោកមានទំហំត្រឹមតែជាភូមិធំមួយប៉ុណ្ណោះ" (ទំព័រទី ១១)* ។

ក្នុងករណីនេះ ប្រជាជាតិនីមួយៗអាចទទួលពតិមានយ៉ាងឆាប់រហ័ស ដោយសារមធ្យោបាយទូរគមនាគមន៍ផ្សេងៗ ដូចជា ផ្កាយរណប (Satellites) កុំព្យូទ័រ (Computers) វិទ្យុ (Radios) ទូរទស្សន៍ (Televisions) ហ្វាក់ និង អ៊ីមែល

(Fax and E-mail) ទូរស័ព្ទចល័ត (Mobile Phones) និង បណ្ដាញអ៊ីនធឺណេត (Internet) ជាដើម។ ឧបករណ៍ទាំងនេះ កំពុងជំរុញឱ្យមនុស្សក្នុងពិភពលោកមានទំនាក់ទំនងជាមួយគ្នាយ៉ាងឆាប់រហ័ស ដោយឥតគិតអំពីជាតិសាសន៍ និងពណ៌សម្បុរឡើយ។

ដើម្បីគូសបញ្ជាក់បញ្ហានេះ លោក **អង់តូនី ហ្គីដិន** (Anthony Giddens) អះអាងថា *"ផ្កាយរណបពាណិជ្ជកម្មទី ១ ត្រូវបាន បង្ហោះនៅក្នុងឆ្នាំ ១៩៦៨។ ឥឡូវនេះ មានផ្កាយរណបបែបនោះជាង ២០០ នៅលើផែនដី ហើយផ្កាយរណបនីមួយៗកំពុងទទួលពតិមានយ៉ាងច្រើន"* (ទំព័រទី 11)។ នោះជាទំរង់ មួយនៃសាកលភាវូបនីយកម្ម។ វាគូសបញ្ជាក់អំពីការរីកចម្រើននៃបច្ចេកវិទ្យា ដែលធ្វើឱ្យមនុស្សកាន់តែឈានទៅធ្វើជាម្ចាស់លើធម្មជាតិ និងលើសង្គម។

**២-សាកលភាវូបនីយកម្ម សាកលនិយម និងការចំណុះគ្នា ទៅវិញទៅមក**

យើងគួរបែងចែកថា ទៅអ្វីដែលហៅថា សាកលភាវូបនីយកម្ម សាកលនិយម និងការចំណុះគ្នាទៅវិញទៅមក។

នៅក្នុងបណ្ដាប្រទេសខាងលិច ការកើតឡើងនៃបញ្ញត្តិ *"សាកលភាវូបនីយកម្ម"* (Globalization) មានជាយូរមកហើយ។ ដូចនេះ ពាក្យនេះមិនមែនទើបនឹងកើតឡើងទេ។ **រ៉ូប៊ែរ គីអូហាន** (Robert Keohane) និង **ហ្សូហ្សិប ណាយ** (Joseph Nye) អះអាងថា *"សព្វថ្ងៃនៅពេលគេជជែកគ្នា អំពីសាកលភាវូបនីយកម្ម គេតែងតែយល់ថា សាកលភាវូបនីយកម្ម គឺជាបញ្ហាមួយថ្មី"* (ទំព័រទី ២ ដល់៨)។ លោកទាំងពីរបានផ្ដល់ ឧទាហរណ៍ថា "The Silk Road" ដែលធានាអះអាងអំពី

ទំនាក់ទំនងវប្បធម៌ និងសេដ្ឋកិច្ចរវាងពាណិជ្ជករអឺរ៉ុប និងពាណិជ្ជករអាស៊ី គឺជាសាកលភាវូបនីយកម្ម ដែលទើបនឹងចាប់ផ្ដើមមុនដំបូង (thin globalization)។ ឯសហប្រតិបត្តិការខាងទីផ្សារហិរញ្ញវត្ថុរួមសព្វថ្ងៃគឺជាសាកលភាវូបនីយកម្ម ដែលមានដំណើរពេញលេញ (thick globalization)។

*"សាកលភាវូបនីយកម្ម"* ជាពាក្យមួយដែលទើបនឹងលេចឡើងខ្ទរខ្ទារ នៅទសវត្ស ១៩៩០ ដូចពាក្យ *"ការចំណុះគ្នាទៅវិញទៅមក"* (Interdependence) ដែលលេចឡើងនៅទសវត្ស ១៩៧០ ដែរ ។ ដូច្នេះ បាតុភូតនៃសាកលភាវូបនីយកម្ម មិនមែន ថ្មីទាំងស្រុងឡើយ។

លោកទាំងពីបានបែកចែកច្បាស់លាស់នូវពាក្យទាំងបីគឺ : សាកលភាវូបនីយកម្ម សាកលនិយម និងការចំណុះគ្នាទៅវិញទៅមក។ លោកបង្ហាញឱ្យ ឃើញថា ពាក្យទាំងបីមានន័យខុសគ្នា។ លោកពោលថា *"សាកលភាវូបនីយកម្ម និងការចំណុះគ្នាទៅវិញទៅមកមិនមែនស្របគ្នាទាំងស្រុងទេ។ ការចំណុះគ្នា សំដៅលើលក្ខខ័ណ្ឌ និងសភាពនៃកិច្ចការ។ វាអាចកើនឡើង ឬថយចុះដោយ យោងទៅតាមកាលៈទេសៈ។ សាកលភាវូបនីយកម្មសំដៅទៅលើអ្វីដែលកំពុង កើនឡើង។ ចំណែកឯ សាកល-និយមវិញ (Globalism) វាជាសភាពមួយនៃ ពិភពលោកដែល ក្នុងនោះមានបណ្ដាញនៃការចំណុះគ្នាទៅវិញទៅមក នៅក្នុងចំងាយពហុទ្វីបដោយមានទំនាក់ទំនងដែលកើតឡើង ដោយឆ្លងកាត់បណ្ដូរសង្គម និងសេដ្ឋកិច្ច។ ប៉ុន្តែ ការចំណុះគ្នា សំដៅលើស្ថានការណ៍ដែលកត់សំគាល់ ដោយ ផលដែលមានទៅវិញទៅមក រវាងប្រទេសនានា ឬរវាងតួអង្គទាំងឡាយនៅក្នុងប្រទេសផ្សេងៗ (ខ-ទំព័រទី១នៃ៨)*។

បើតាមសំដីខាងលើនេះ យើងឃើញថា ពាក្យទាំងបីមានទំនាក់ទំនងបដិសំយោគ ជាមួយគ្នា និងជះឥទ្ធិពលទៅវិញទៅ មក។

**ហ្វីលីព ស៊ីរស៊ី** *(Philip Cersy)* ពោលថា *"សាកលភាវូបនីកម្មមិនមែនសុទ្ធតែជាការប៉ះទង្គិច ដែលបង្កឡើងដោយការចំណុះគ្នាខាងសេដ្ឋកិច្ចជាមួយនឹងប្រព័ន្ធនយោបាយក្នុងស្រុក និងអន្តរកម្មរបស់រដ្ឋនានាឡើយ។ វាជាការធ្វើឱ្យយល់ឡើងវិញនូវវិទ្យាសាស្ត្រនយោបាយ និយាយរួម (និងវិទ្យាសាស្ត្រ សង្គមដ៏ទូលំទូលាយផងដែរ) នៅលើមាត្រា ដែលបានពន្យល់ទាំងខាងអំណាច ប្រវត្តិសាស្ត្ររបស់រដ្ឋទាំងខាងការបញ្ជាក់ឱ្យឃើញច្បាស់នូវចរន្តនាដកម្មនៃ បណ្តាញសេដ្ឋកិច្ច នយោបាយ និងសង្គមដ៏ស្មុគស្មាញ ដែលមានប្រព័ន្ធពិភពលោក ពោរពេញទៅដោយការផ្លាស់ប្តូរសព្វថ្ងៃនេះ"* (ខ-ទំព័រទី៦២៤ International Journal)។ បើតាម **ស៊ីរស៊ី** (Cersy) ការចំណុះគ្នាខាងសេដ្ឋកិច្ចគ្រាន់តែជា កត្តាមួយប៉ុណ្ណោះ។ នៅមានកត្តាជាច្រើនទៀត ដែលធ្វើសាកលភាវូបនីយកម្ម លេចធ្លោឡើង។

**អង់តូនី ហ្គីដិន** (Anthony Giddens) អះអាងថា *"គឺជាការខុសឆ្គងមួយក្នុងការគិតថា សាកលភាវូបនីយកម្មទាក់ទងតែនឹងប្រព័ន្ធធំៗ ដូចជាទាក់ទងនឹងសណ្តាប់ធ្នាប់ហិរញ្ញវត្ថុពិភពលោកជាដើម។ សាកលភាវូបនីយកម្មមិន គ្រាន់តែជាអ្វីដែល "ស្ថិតនៅខាងក្រៅ" ដែលស្ថិតនៅឆ្ងាយពីបុគ្គលទេ។ សាកលភាវូបនីយកម្មគឺជាបាតុភូតដែល "ស្ថិតនៅក្នុងទីនេះ" ផងដែរ ដែលកំពុងជះឥទ្ធិពលយ៉ាងខ្លាំងដល់ទិដ្ឋភាពបុគ្គលក្នុងជីវិតរបស់យើង* (ទំព័រទី១២)។ លោកបានបន្ថែមថា "សាកល-ភាវូបនីយកម្មមានលក្ខណៈនយោបាយ បច្ចេកទេស និងវប្បធម៌ ដូចលក្ខណៈសេដ្ឋកិច្ច

ដែរ។ វាត្រូវបានទទួលឥទ្ធិពលមុនបង្អស់ដោយសារការអភិវឌ្ឍន៍ នៅក្នុងប្រព័ន្ធទូរគមនាគមន៍ ចាប់តាំងពីចុងទសវត្ស ១៩៦០ មក ម្លេះ (១-ទំព័រទី១០)។ លោកបានបញ្ជាក់អំពីវិសាលភាពនៃសាកលភាវូបនីយកម្មថា "សាកលភាវូបនីយកម្មកំពុងតាត់តែងរចនាសម្ព័ន្ធមាត្រា ដែលយើងកំពុងរស់នៅ និងឈានចូល ជ្រៅទៅក្នុងរបៀបរបបរបស់យើង។ វាធ្វើដំណើរមកពីលោក ខាងលិច វាមានស្នាម ដ៏ធំនៃអំណាចសេដ្ឋកិច្ច និងអំណាចនយោបាយនៃសហរដ្ឋ អាមេរិចនិងបន្សល់ទុកនូវផលវិបាកដ៏ច្រើន។ ប៉ុន្តែ សាកលភាវូបនីយកម្មមិនមែន គ្រាន់តែជាការគ្របសង្កត់ នៃលោកខាងលិចទៅលើប្រទេសដទៃប៉ុណ្ណោះទេ។ វាធ្វើឱ្យប៉ះពាល់ដល់សហរដ្ឋអាមេរិច ដូចដែលសហរដ្ឋអាមេរិចធ្វើឱ្យប៉ះពាល់ដល់ប្រទេសដទៃដែរ (១-ទំព័រទី៤)។

បើតាមទស្សនៈខាងលើនេះ យើងឃើញថា គ្មានរដ្ឋណាមួយដែលស្ថិតនៅក្រៅប្រព័ន្ធសាកលភាវូបនីយកម្មឡើយ។ ប្រជាជាតិទាំង អស់ទោះចង់ក្តី ឬ មិនចង់ក្តី ត្រូវតែមានទំនាក់ទំនងគ្នាខាងវិស័យសេដ្ឋកិច្ច បរិស្ថាន និងវប្បធម៌ ។ល។ ហេតុនេះ យើងមិនអាចទប់ដំណើរ សាកលភាវូបនីយកម្មនេះបានឡើយ។ វាកំពុងតែជ្រៀតចូលមកក្នុងជីវភាពប្រចាំថ្ងៃរបស់យើង ធ្វើឱ្យយើងឃ្លាតចេញបន្តិចម្តងៗ ពីក្របខ័ណ្ឌជាតិទៅដល់ប្រកខ័ណ្ឌអន្តរជាតិ ដែលមិនមានប្រទេសណាមួយជៀសផុតបានឡើយ។

## គ-ដំណើរវប្បធម៌ខ្មែរក្នុងយុគសម័យសាកលភាវូបនីយកម្ម

សមាសភាគនៃវប្បធម៌ខ្មែរ (The components of Khmer Culture) រួមមានអ្វីៗដែលទាក់ទងនឹងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរនិយាយដោយ ឡែក និងប្រជាជនកម្ពុជានិយាយរួម។ កាលណានិយាយអំពីវប្បធម៌ខ្មែរ យើង ច្រើនតែនឹកដល់

ស្ថាបត្យកម្មសម័យមហានគរ និងរបៀបរបបរស់នៅសម័យអង្គរ សម័យលង្វែក សម័យឧត្តុង្គជាប៉ុណ្ណោះ។ តាមពិត វប្បធម៌ខ្មែរ គឺជារបៀបរស់នៅ និងអ្វីៗដែលទាក់ទងនឹងការរស់នៅរបស់ប្រជាជនខ្មែរ តាំងពីខ្មែរបានចាប់កំណើតឡើងរហូតមកដល់សព្វថ្ងៃនេះ។

សង្គមកម្ពុជាធ្វើដំណើរទៅមុខរាល់វិនាទី។ សមាជិកសង្គមនេះក៏កំពុង បោះជំហានទៅមុខរៀងរាល់វិនាទីដែរ។ ហេតុនេះ វប្បធម៌ដែលជាជីវិតស្មារតីនៃប្រជាជនខ្មែរតែងធ្វើចលនា ប្រែប្រួល និងរីកចំរើន ឬថយក្រោយតាមដំណើររុងរឿង ឬដំណើរអន់ថយនៃសង្គមកម្ពុជា។

ក្នុងយុគសម័យនៃអន្តរកម្មពហុវប្បធម៌សព្វថ្ងៃនេះ ដែលកើតឡើង ដោយសារសាកលភាវូបនីយកម្ម សេដ្ឋកិច្ច វប្បធម៌ខ្មែរកំពុងតែប្រឈមមុខយ៉ាង ស្វិតស្វាញជាមួយវប្បធម៌បរទេស ជាពិសេសជាមួយវប្បធម៌លោខាងលិច ដែលកំពុងហូរចូលមកកម្ពុជា ដើម្បីអត្ថិភាពរបស់ខ្លួន។ ប៉ុន្តែ នៅក្នុងនិម្មិត្តកម្ម សេដ្ឋកិច្ច-សង្គមកម្ពុជា វិស័យសេដ្ឋកិច្ចដែលជាកត្តាកំណត់លើគ្រប់វិស័យទាំងអស់ កំពុងតែទទួលឥទ្ធិពលយ៉ាងខ្លាំង ពីសំណាក់សាកលភាវូបនីយកម្មសេដ្ឋកិច្ចពិភពលោក។ រីឯ វិស័យវប្បធម៌ដែលចំណុះវិស័យសេដ្ឋកិច្ចក៏មិនអាចជៀសផុត ពីសំពាធនៃសាកលភាវូបនីយកម្មនេះដែរ។

នៅក្នុងប្រទេសកម្ពុជា មានហាងលក់ទំនិញធំៗដែលក្នុងនោះមានសុទ្ធ តែទំនិញបរទេស។ យើងអាចឱ្យឈ្មោះថា នោះជាផ្សារវប្បធម៌រួម។ ផ្សារវប្បធម៌ រួមតែងលើកតំកើងសញ្ញាណនៃតម្លៃវប្បធម៌រួម និងសញ្ញាណនៃផលិតផល ណាមួយដែលមានលក់ពាសពេញពិភពលោក។ គំនិតនេះជះឥទ្ធិពលទៅលើ មនុស្សខ្មែររាប់ម៉ឺននាក់ ដោយធ្វើឱ្យចំណូលចិត្ត និងអាកប្បកិរិយារបស់ខ្មែរមាន លក្ខណៈប្រហាក់ប្រហែលគ្នា

ឆ្ពោះទៅរករបៀបរស់នៅតាមអំពើចិត្តដែលគេចង់ ពោលគឺ ម្នាក់ៗចង់រស់នៅតាមទំនើងចិត្តរបស់ខ្លួន។ ការកើនឡើងដោយគ្មាន លំអានជាមុន នៅក្នុងពាណិជ្ជកម្មរួម ការទិញនិងការលក់វត្ថុ និងសេវាផ្សេងៗ នៅក្នុងប្រទេសកម្ពុជាបានបង្កើតឱ្យមានហាងទំនិញធំៗជាច្រើន ដែលមានទំនាក់ ទំនងជិតស្និទ្ធ ជាមួយហាងទំនិញធំៗក្នុងពិភពលោក។ ការទិញនិងការលក់ប្រទាក់គ្នាដោយ ឆ្លងតាមរយៈមធ្យោបាយផ្សាយពាណិជ្ជកម្ម។ ទូរទស្សន៍ វិទ្យុ ទូរស័ព្ទ កាសែត ទស្សនាវដ្ដី សុទ្ធតែជាមធ្យោបាយដែលបានបម្រើការងារផ្សព្វផ្សាយ នេះ។ តាមពិត សាកលភាវូបនីយកម្មនៃសេដ្ឋកិច្ចបានបង្កើត សាកលភាវូប-នីយកម្មនៃការផ្សាយ។ ទោះច្រើនឬតិច ការផ្សព្វផ្សាយតែងផ្អែកលើអំណាច និងវប្បធម៌នៃប្រទេសអ្នកមាន។ ទីផ្សារហិរញ្ញវត្ថុរួម បានបង្កើតបរិយាកាសថ្មីមួយ ក្នុងការស្វែងរកផលចំណេញឱ្យបានឆាប់រហ័ស។ ទីផ្សារប្ដូរប្រាក់កំពុងមានទំនាក់ទំនងជាមួយការកេងកំរៃរូបិយវត្ថុ ដោយធ្វើយ៉ាងណាឱ្យបានចំណេញច្រើនជាអតិបរមា។

ភាពមិនទៀងទាត់នៅក្នុងការបង្កើនមុខរបរ ដូចជា មុខរបរកសិកម្មជាដើមបានជំរុញឱ្យមានកន្លែងធ្វើការងាររួម ហើយបញ្ហានេះ បណ្ដាលឱ្យមានការ ផ្លាស់លំនៅស្ថាននៃពលករ ស្ទើរពាសពេញប្រទេសកម្ពុជា ជាពិសេស ការផ្លាស់ លំនៅស្ថាន របស់យុវវ័យ។ គេធ្វើដំណើរពីជនបទមករស់នៅទីក្រុង និងធ្វើដំណើរ ពីទីក្រុងទៅរស់នៅឯបរទេស ដើម្បីលក់កម្លាំងពលកម្មក្នុងពេលដែលកម្ពុជានៅមានផ្ទៃដីទំនេរជាច្រើន។

កំណែទម្រង់សេដ្ឋកិច្ចតម្រង់ទៅរកទីផ្សារ តែងជំរុញឱ្យក្រុមហ៊ុនអន្តរជាតិ នៅកម្ពុជាកាន់តែមានអានុភាពខ្លាំងឡើងៗ។ ការណ៍នេះ កំពុងជំរុញឱ្យពលករខ្មែរជាច្រើនស្វែងរកការងារនៅក្នុងប្រទេស ឬស្វែងរកការងារនៅឯបរទេស ដោយបំភ្លេចចោលតាមបែបអចេតនានូវវប្បធម៌របស់ខ្លួន។ នៅក្នុងលក្ខខណ្ឌមួយចំនួនម្ចាស់កម្មន្តសាល

បង្ខំឱ្យពលករខ្មែរទាំងនោះធ្វើការ ក្នុងសភាពអនុស្សធម៌ដោយបានទទួលបៀវត្សតិចតួចប៉ុណ្ណោះ។

យើងអាចនិយាយថា នៅក្នុងសម័យសាកលភាវូបនីយកម្ម មនុស្សជាតិ អាចឈានទៅរកវាសនារួម ដែលកើតឡើងដោយសារបដិវត្តបច្ចេកទេសខាងពតិមាន និងគមនាគមន៍។ គួរចងចាំថា ក្រុមហ៊ុនអន្តរជាតិជាចំណុចសំខាន់នៃសាកលភាវូបនីយកម្ម។ គឺក្រុមហ៊ុនអន្តរជាតិនេះហើយ ដែលក្លាយជាអ្នកគ្រប់គ្រង សេដ្ឋកិច្ច និងក្លាយជា កម្លាំងនយោបាយនៅក្នុងសេដ្ឋកិច្ចពិភពលោក។ ក្រុមហ៊ុន អន្តរជាតិតែង បង្កើនការប្រណាំងប្រជែង និងបង្កើនការកៀបសង្កត់លើគ្នាទៅ វិញទៅមក ដើម្បី ការពារអត្ថិភាពនិងប្រាក់ចំណេញរបស់ខ្លួន។ ការណ៍នេះជំរុញ ឱ្យពួកគេស្វែងរកយ៉ាងទទូចនូវទីផ្សារពលកម្មដែលមានតម្លៃថោក។ នៅក្នុងចំណោមទីផ្សារពលកម្ម ដែលមានតម្លៃថោកនោះកម្ពុជាមានតួនាទីមួយយ៉ាង សំខាន់។ ក្រុមហ៊ុនអន្តរជាតិ ជាច្រើនបាន បង្កើតកម្មន្តសាលនិងសេវាឧស្សាហកម្ម របស់ខ្លួននៅប្រទេសកម្ពុជា។ ជួនកាល គេពុំយកផលិតកម្មទាំងនោះបំរើឱ្យប្រជា ជនកម្ពុជាទេ។ ឧទាហរណ៍ សំលៀកបំពាក់ ជាច្រើន ដែលបានផលិតនៅកម្ពុជាត្រូវបានគេបញ្ជូនទៅលក់នៅឯបរទេស។ ចំណែកប្រជាជនកម្ពុជាបែរជានិយមស្លៀកពាក់ "សំលៀកបំពាក់ជជុះ" ដែលនាំចូលពីបរទេសវិញ។

មានអង្គការក្រៅរដ្ឋាភិបាលមួយអះអាងថា កម្មវិធីកែសំរួលរចនាសម្ពន្ធ័ The Structural Adjustment Programs (SAP) ក្នុងក្របខណ្ឌ័សាកលភាវូបនីយកម្មបានរួមចំណែកយ៉ាងធំក្នុងការបង្កើនបំណុល សេចក្តីក្រលំបាក និងវិបត្តិសេដ្ឋកិច្ច ក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ អង្គការនេះសង្កត់ធ្ងន់ថា ស្ថាប័នផ្តល់ឥណទានពិភពលោក (The Global Creditor Institutions) បាននឹង កំពុងបង្កើតបរិយាកាសដែល

ប៉ះពាល់យ៉ាងខ្លាំង ដល់បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍។ ប្រាក់ជាច្រើននៅក្នុង ប្រទេសកំពុង អភិវឌ្ឍន៍ត្រូវបានប្រើប្រាស់ទៅលើ ទិសដៅនាំចេញ។ សេដ្ឋកិច្ចក្នុងស្រុកចំណុះសេដ្ឋកិច្ចពិភពលោកទាំងស្រុង។ ស្ថាប័នដែលមានអំណាចខ្លាំង ដូចជា The International Monetary Fund, The World Bank, The World Trade Organization ជាដើមតែង ផ្ដល់ទឡ្ហីករណ៍ថា "គ្មានផ្លូវណា ផ្សេងទៀត" ឡើយ (There Is No Alternative)។ ផលវិបាកដែលប្រទេស កំពុងអភិវឌ្ឍន៍បានទទួលគឺធ្លាក់ទៅលើ ផលិតករក្នុងស្រុក ដូចជា វណ្ណៈកម្មករ និងកសិករជាដើម។ ដូចនេះផលិតករកម្ពុជាក៏កំពុង ទទួលផលវិបាកនេះដែរ។

គឺពិតជាត្រឹមត្រូវនៅពេលដែលគេអះអាងថា ប្រជាជនមួយចំនួន ដែលស្ថិតនៅក្នុងវណ្ណៈកណ្ដាល និងវណ្ណៈអ្នកមាន មានការរីកចំរើននៅក្នុងសង្គម ដែល មានការឆ្លងកាត់ទៅរកប្រព័ន្ធផ្សារសេរី។ វណ្ណៈកណ្ដាល និងវណ្ណៈអ្នកមានថ្មីនេះ ពិតជាលទ្ធផលនៃសាកលភាវូបនីយកម្ម។ ពួកគេធានាបង្កើតទីផ្សារ ដើម្បីនាំ ផលិតផល ចូលមកក្នុងស្រុក។ បើគេនាំផលិតផលបរទេសចូលក្នុងស្រុកកាន់តែ ច្រើន សេដ្ឋកិច្ច នៃប្រទេសអភិវឌ្ឍន៍ដែលជាម្ចាស់ផលិតផល ក៏កាន់តែរីក ចំរើនដែរ។

ជាការណ៍ដែលគួរឱ្យឆ្ងល់ណាស់នៅពេលដែលគេនិយាយថា ផលិតផល ខ្មែរមិនមានស្ដង់ដារអន្តរជាតិ! នៅពេលណាក៏គេលើកតំកើង ផលិតផលបរទេស ដែរ។ នេះមកពីខ្មែរបាត់បង់ជំនឿលើខ្លួនឯង បាត់បង់ជំនឿលើសង្គមរបស់ខ្លួនពី ជំនាន់មួយទៅជំនាន់មួយ។

យើងមានផ្សារទំនើបសម្រាប់ផលិតផលបច្ចឹមប្រទេសតាំងពី ជីដាក់ស្រែ និងម្ហូបកំប៉ុងជាដើម។ កសិករទាំងអស់ស្ទើរតែបោះបង់ចោល ការផ្សាំជីធម្មជាតិ ដែលមាន

គុណភាពខ្ពស់ ហើយស្រវាចាប់យកជីគីមីដែលមានគ្រោះថ្នាក់ដល់អាយុ ជីវិតរបស់ខ្លួន និងអាយុជីវិតនៃអ្នកប្រើប្រាស់ផលិតផលកសិកម្ម។ សំលៀក បំពាក់ Levis Jeans និងស្បែកជើង Nike athletic ជាដើម បានឈានជើង មកដល់កម្ពុជា។ សំលៀកបំពាក់មួយសំរាប់មានតម្លៃខ្ពស់ជាងច្រើនដង បើ ប្រៀបធៀបនឹងប្រៀវត្សដែលរកបានក្នុងមួយខែ។ រីឯ ការដើរចូលសណ្ឋាគារខារ៉ាអូខេ ឬផ្ទះសំណាក់បានក្លាយទៅជាបញ្ហាសាមញ្ញនៅតាមទីក្រុង ជាយក្រុង និង ទីរួមខេត្តនានា។ ការភ្នាល់កីឡាប្រដាល់ និងកីឡាបាល់ទាត់ដែលមានទឹកប្រាក់ រាប់ម៉ឺនដុល្លារក្នុងមួយស្តប៉ាហ៍ត្រូវបាន ប្រព្រឹត្តទៅនៅក្នុងទីក្រុងភ្នំពេញ។

សភាពការណ៍នេះកំពុងជំរុញឱ្យប្រជាជនខ្មែរ បោះបង់ចោលបន្តិចម្តងៗ នូវវប្បធម៌បូរាណរបស់ខ្លួន ដោយឈោងចាប់ពហុវប្បធម៌ដែល កំពុងលុកលុយក្នុងសតិអារម្មណ៍របស់ជាតិ។ ប្រជាជនមួយចំនួនធំយល់ថា មានប្រាក់គឺមានអ្វីៗទាំងអស់។ សព្វថ្ងៃមានក្មេងជំទង់ និងយុវជនរាប់ម៉ឺននាក់ ដែលកំពុងរស់នៅក្នុងបរិស្ថាននៃអ្នកមានពហុប្រព័ន្ធផ្សព្វផ្សាយ។ ពួកគេមានលក្ខណៈរួមដូចគ្នាមាន ចំណង់ចំណូលចិត្តប្រហាក់ប្រហែលគ្នា និងមានជំនោរងាកចេញពីប្រពៃណីដូច គ្នា។ គេកំពុងតែច្រានចោលកត្តាសកម្មនៃប្រពៃណីជាតិ ហើយស្រវាយក ដោយសេចក្តីពេញចិត្តនូវកត្តាអកម្មនៃវប្បធម៌ដែលហូរចូលមកពីក្រៅដូចជា :

- ការលែងស្តាប់ដំបូន្មានឪពុកម្តាយ
- ការប្រើសំលៀកបំពាក់ហ៊ឺហាសិចស៊ីតាមទំនើងចិត្ត
- ការតុបតែងខ្លួន កែសម្ផស្ស

- ការស្វែងរកដៃគូដើរកំសាន្ត
- ការពន្លូតកូនមុនមានអាពាហ៍ពិពាហ៍ពេញច្បាប់
- ការផ្លាស់ប្តូរសង្សារពីមួយទៅមួយ
- ការចូលចិត្តរាំរែកចង្វាក់បរទេស
- ការបំរើក្នុងភោជនីយដ្ឋាន សណ្ឋាគារ ខារ៉ាអូខេ និងការបំរើសេវា ផ្លូវភេទ
- ពាក្យសំដីចំអេសចំអាសលេងសើចបែរតំរង់ទៅរកសេចក្តីស្នេហា ដើម្បីប្រាក់ ...... ។ល។ ......

កត្តាទាំងអស់នេះបង្ហាញឱ្យឃើញថា យើងកំពុងរត់តាមកម្លាំងសំភារៈ ដែលជាផលិតផលនៃសាកលភាវូបនីយកម្មផ្សព្វផ្សាយ ដោយឥតបានប្រើវិចារណញ្ញាណថា ត្រូវទទួលយកអ្វី និងត្រូវបដិសេធអ្វីឡើយ។ ការផ្សាយពាណិជ្ជកម្មបារី ជាឧទាហរណ៍មានលក្ខណៈផ្ទុយស្រឡះពីវេជ្ជបញ្ជា។ ដោយផ្អែកលើវិទ្យាសាស្ត្រ វេជ្ជបណ្ឌិតអះអាងថា បារីបណ្តាលឱ្យខូចសុខភាព។ ផ្ទុយទៅវិញ ដោយផ្អែកលើការបង់ពន្ធក្នុងការផ្សាយអ្នកនាំពាក្យអះអាងថា បារីនាំឱ្យមានបញ្ញាភ្លឺថ្លា។ ចំពោះបញ្ហាបារីតែមួយ ក្នុងពេលតែមួយមានការផ្សាយពីរបែបផ្ទុយគ្នា ពោលគឺ បារីបំផ្លាញសុខភាពផង និងបារីនាំឱ្យមានបញ្ញាភ្លឺថ្លាផង។ គំនិតទី២ ជាគំនិតក្បត់វិទ្យាសាស្ត្រ។ គេដឹង! តែគេនៅតែបំពាន ព្រោះគេលោភប្រាក់។ អ្នកមានខ្លះ គ្រាន់តែឃើញការផ្សាយម៉ូតសំលៀកបំពាក់នៅតាមទូរទស្សន៍នៃប្រទេសជិតខាងភ្លាម ក៏ប្រញាប់ប្រញាល់ ទៅឱ្យជាងកាត់ដេរ កាត់តាមម៉ូដសំលៀកបំពាក់នោះ តែក្នុងរយៈពេល ២ ឬ ៣ ម៉ោងប៉ុណ្ណោះ។ រីឯអ្នកក្រខ្លះក៏រត់តាមបញ្ហានេះដែរ ព្រោះកុំឱ្យចាញ់អ្នកមានពេក។ យុវជន នឹងក្មេងជំទង់នៅតាមទីក្រុង ក៏ដូចជានៅ

តាមជនបទដែរមិនមានចំណូលចិត្ត ចំពោះការរាំវង់រាំក្បាច់រាំសារ៉ាវ៉ាន់ទេ តែគេចូលចិត្ត អ្វីដែលហៅថា ការរាំញាក់មិនត្រូវជ្រុង មិនដូចប្រភពដើមរញ៉េរញ៉ៃ។ នេះជាការរត់តាមគ្នា ពីភូមិមួយទៅភូមិមួយ ពីស្រុកមួយទៅស្រុកមួយ ពីខេត្តមួយទៅខេត្តមួយ ដែលខ្វះចំណាត់តាំង ខ្វះការអប់រំ ដែលមានលក្ខណៈជាប្រព័ន្ធ។

ម្យ៉ាងទៀតក្នុងការអប់រំ និងការបណ្ដុះបណ្ដាលធនធានមនុស្ស គេច្រើនតែនិយាយាថា ត្រូវរត់តាមសេដ្ឋកិច្ចទីផ្សារសេរី។ ប៉ុន្តែ គេភ្លេចនិយាយាថា ត្រូវបង្កើនកត្តាសកម្មនៃសេដ្ឋកិច្ចទីផ្សារសេរី និងបន្ថយកត្តាអសកម្មរបស់វា។ ហេតុនេះ ធនធានមនុស្សដែលគេផលិតបានច្រើន ច្រើនតែជាអ្នកមានចំណេះវិទ្យាសាស្ត្រ ដែលខ្វះសីលធម៌។ ទស្សនវិទូបស្ចឹមប្រទេសម្នាក់បានពោលយូរមក ហើយថា *"វិទ្យាសាស្ត្រខ្វះមនសិការ ជាការបំផ្លិចបំផ្លាញព្រលឹងមនុស្ស"* (Science sans conscience n'est que rume de l'áme) ។ ការណ៍នេះ បានបង្កើតផលអាក្រក់ជាច្រើន ផ្សេងទៀត ដូចជា អំពើពុករលួយ ការកេងប្រវ័ញ្ច ការជេរប្រមាថ ការប្រើអំពើហឹង្សា ការប្រើអាកប្បកិរិយាច្រងេងច្រងាង ដែលក្នុងគ្រួសារខ្លះស្ទើរតែក្លាយទៅជាវប្បធម៌ទៅហើយ។

អង្គការ តាមរបាយការណ៍នៃអភិវឌ្ឍមនុស្ស (Human Development Report) នៅឆ្នាំ ១៩៩៧ បានបញ្ជាក់ថា សាកលភាវូបនីយកម្មបានលើកគំរូនៃការប្រើប្រាស់សំភារៈផ្សេងៗ ដូចជា រថយន្តប្រណីត និងភេសជ្ជៈជាដើម កំពុងតែក្លាយជាជំនក់ចិត្តនៅក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សទូទៅ។ គំរូនេះកំពុងតែបំផ្លាញផលិតផល ក្នុងស្រុក ដែលប្រជាជនក្រីក្រ កំពុងពឹងពាក់។ លោក **រ៉ូបែរតូ វេរហ្សូឡា** (Roberto Verzola) សង្គមវិទូហ្វីលីពីនបានពោលថា ក្នុងរយៈពេល ១០០ ឆ្នាំ មុនមាន

អាណានិគមនិយម តែឥឡូវមានសាកលភាវូបនីយកម្ម។ សព្វថ្ងៃសាជីវកម្មពហុជាតិបានចូលមកជំនួស អំណាចអាណានិគមនិយម។ លោកគូសបញ្ជាក់ថា នៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ សាជីវកម្មរួមត្រូវបានអនុញ្ញាត ឱ្យប្រើប្រាស់ធនធានធម្មជាតិ ធនធានមនុស្ស និងទ្រព្យសម្បត្តិជាតិ។ ពួកគេប្ដូរទីកន្លែងកសិករពីដីស្រែប្ដូរទីកន្លែងកម្មករពីមុខរបរ និងប្ដូរទីកន្លែងសហគមន៍ពីឫសគល់របស់វា។ ពួកគេត្រូវទទួលខុសត្រូវចំពោះការបែកបាក់សហគមន៍ និងការបំផ្លិចបំផ្លាញបរិស្ថាន ដើម្បីបម្រើដល់តម្រូវការសភារៈដើម និងមនុស្សដែលជាផលិតផលសម្រាប់ផ្សាររួម។ ផលវិបាកដែលប្រជាជនក្រីក្របានទទួល គឺសន្តិសុខខាងម្ហូបអាហារ និងវិបត្តិបរិស្ថាន ដែលថ្ងៃក្រោយអាចអាក្រក់ ជាងរបបអាណានិគម និយមទៀតផង។

ការរៀបរាប់ខាងលើនេះ មិនមែនជាការបដិសេធចំណុចល្អនៃ សាកលភាវូបនីយកម្មទេ។ សាកលភាវូបនីយកម្មក៏មានចំណុចល្អរបស់វាដែរ។ សាកលភាវូបនីយកម្មបច្ចេកវិទ្យាពិតជាធ្វើឱ្យពិភពលោករីកចំរើន។ ប៉ុន្តែ របបបច្ចេកាធិបតេយ្យ ដែលយកបច្ចេកទេសទៅធ្វើនយោបាយ មិនបានបម្រើឱ្យសង្គមមនុស្សឡើយ។ វាគ្រាន់តែជារបបមួយដែលបម្រើអ្នកមានមួយចំនួនតូចប៉ុណ្ណោះ។

នៅចំពោះមុខសភាពការណ៍បែបនេះ ដើម្បីរក្សាតម្លៃដើមរបស់ខ្លួន វប្បធម៌ខ្មែរត្រូវស្ថិតនៅក្នុងសតិអារម្មណ៍ប្រជាជនកម្ពុជាគ្រប់រូប។ វាត្រូវតែ ស្ដែងឡើងតាមរយៈសកម្មភាពប្រចាំថ្ងៃ ដូចជាតាមរយៈពាក្យសំដី ឥរិយាបថ ពិធីបុណ្យ និងសម្លៀកបំពាក់ជាដើម។ សម្លេងខ្លុយអាចពិរោះដល់ត្រចៀក មនុស្សចាស់ តែអាចមិនពិរោះដល់ត្រចៀកយុវជនទេ។ ប៉ុន្តែ ទោះជាពិរោះក្តី ឬមិនពិរោះក្តី ក៏គួរតែក្រអៅបេះដូងរបស់មនុស្សខ្មែរ ត្រូវបានជ្រួតជ្រាបដោយ សម្លេងខ្លុយខ្មែរ ប្រសិនបើមិនចង់ឱ្យ

សម្លេងខ្លួយនោះរលាយសាបសូន្យ។ យើង នឹងបាត់បង់សម្បត្តិវប្បធម៌ហូល ជ្រលក់ល័ក្ខ ខ្មែរ ដែលខ្មែរបានធ្វើសំភារៈដើមដោយខ្លួនឯង ប្រសិនបើយើងមិនរិះរក មធ្យោបាយ ឧបត្ថម្ភអ្នកត្បាញហូលទេ។

## ឃ_ការប្រឡងប្រណាំងដើម្បីជោគជ័យទាំងអស់គ្នា

យើងបានរស់នៅរាប់សតវត្សមកហើយ ដែលមុជចូលជ្រៅទៅក្នុង វប្បធម៌ សង្គ្រាម ក្នុងវប្បធម៌ដែលហេតុផលនៃកំលាំងបាយ ឈ្នះលើកម្លាំងនៃហេតុផល។ គឺមិន មែនជាការពន្យល់ឱ្យយល់ទេ តែជាការយកឈ្នះ។ ឈ្នះដោយសារយើងប្រើគ្រប់ មធ្យោបាយ។ តើយើងទទួលផលចំណេញអ្វីខ្លះ? តាមការពិត នោះជាហេតុផលមួយ ដែលបញ្ជាក់ថា យើងទាំងអស់គ្នាសុទ្ធតែខាតបង់។

យើងបានចំណេញរាប់សតវត្សមកហើយនូវ ថ្លៃសង្គ្រាម និងជីវិតមនុស្ស ដែល ជាតម្លៃខ្ពស់បំផុត។ ឥឡូវនេះ យើងត្រូវតែចេះចំណាយថ្លៃសន្តិភាពម្តងវិញ។ ប៉ុន្តែ តើយើងត្រូវធ្វើយ៉ាងណានៅចំពោះមុខសាកលភាវូបនីយកម្មនេះ?

ពិតណាស់ សាកលភាវូបនីយកម្ម និងទំនើបភាវូបនីយកម្ម បានធ្វើឱ្យ ពិភពលោកមានការរីកចំរើន។ វាបានរួមចំណែកលើកតំកើងស្តង់ដារួម សំរាប់មនុស្ស ជាច្រើនលើកតំកើងការប្រើប្រាស់ធនធានមនុស្ស ប្រកបដោយប្រសិទ្ធិភាព។ ប៉ុន្តែ នៅក្នុងដំណើររបស់វា សាកលភាវូបនីយកម្ម និងទំនើបភាវូបនីយកម្មមាន ជ្រុងអាក្រក់ ជាច្រើន ដូចជាការ ចុះថយខាងសីលធម៌ជាដើម។ ឯប្រព័ន្ធ សង្គមដែលធ្លាប់មាន របៀបរៀបរយកំពុងក្លាយជា ប្រព័ន្ធសង្គមដែលខ្វះរបៀបរៀបរយវិញ។ ចលាចល សង្គម និងអំពើពុករលួយ ដែលរត់តាមកម្លាំងសំភារៈ សុទ្ធសឹងជាកូនបង្កើតរបស់វា។

នៅក្នុងស្ថានភាពបែបនេះ យើងត្រូវប្រឡងប្រណាំង ដើម្បីឆ្លើយតប ចំពោះឱកាសថ្មីសម្រាប់ការលេចឡើងនៃវប្បធមិរបស់ប្រជាជាតិនានា លើសកលលោក។ ដោយសារការលេចឡើងនៃវប្បធមិនោះ អត្តសញ្ញាណនៃប្រជា ជាតិនានាអាចត្រូវធានាខាងផ្លូវកាយ និងត្រូវបានលើកកម្ពស់ខាងសោភ័ណភាព ទាំងបុគ្គល និងសង្គម ទាំងនៅក្នុងប្រទេស និងក្នុងពិភពលោក។ យើងប្រឡង ប្រណាំង ដើម្បីធ្វើឱ្យន័យនៃអត្តសញ្ញាណសីលធមិមានវឌ្ឍនភាព ដោយស្ថិតនៅ ក្នុងបរិបទពហុវប្បធមិ ដែលក្នុងនោះភាពផ្សេងគ្នា និងពហុភាពមានកម្លាំងច្រើន ហើយពន្លឺ សហប្រតិបត្តិការមានកម្លាំងជាងការអុជអាលឱ្យមានជម្លោះ។ យើងប្រឡងប្រណាំងដើម្បីឱ្យបុគ្គល និងប្រជាជាតិទាំងអស់ រីកចម្រើននៅក្នុងបរិបទ ពិភពលោកថ្មី និងជៀសវាងយ៉ាងណាកុំឱ្យមានសង្គ្រាមកើតឡើង។

លោក **សាន ហ្ស៊ីនហាន** (Sang Jin Han) ពោលថា *"សេដ្ឋកិច្ចនៅសតវត្សទី ២១ ត្រូវបានធ្វើនិទស្សន៍ទុកជាមុន ជាសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ។ គេបានទាយទុកមុនផងដែរថា សេដ្ឋកិច្ចផ្អែកលើពុទ្ធិនោះមានស្ថេរភាព មានលក្ខណៈរស់រវើក"* (1-ទំព័រទី១៤)។ ទិដ្ឋភាពនៃសេដ្ឋកិច្ចផ្អែកលើពុទ្ធិ គឺការពង្រឹងសារៈប្រយោជន៍នៃមូលធនមនុស្ស។ អ្វីដែលមានលក្ខណៈសារវន្ត ដើម្បីការរីកចម្រើននៃសេដ្ឋកិច្ចនាសតវត្សទី ២១ គឺមិនមែនមូលធនមនុស្ស ដែលមានអំណាចខាងកម្លាំងបាយទេ តែជាមូលធនមនុស្ស ដែលមានបញ្ញាច្នៃប្រឌិត។

ទន្ទឹមនោះដែរ យើងគួររំលឹកឡើងវិញនូវគ្រោះថ្នាក់ដែលគួរជៀសវាង។ គ្រោះថ្នាក់នោះធ្វើឱ្យសង្គមមួយឃ្លាតឆ្ងាយពីអតីតកាលរបស់ខ្លួន គឺខុសពីលក្ខណៈពិសេសដំបូង នៅក្នុងអរិយធមិឧស្សាហកម្មទំនើប។ គ្រោះថ្នាក់មានពីរបែប សំខាន់គឺ

គ្រោះថ្នាក់ដែលកើតឡើងដោយធម្មជាតិ និងគ្រោះថ្នាក់ដែលកើតឡើង ដោយមនុស្សផ្ទាល់។ ការខុសគ្នារវាងគ្រោះថ្នាក់ទាំងពីរបែបនេះ មានដូចខាងក្រោម :

- នៅក្នុងវប្បធម៌បុរាណ និងនៅក្នុងសង្គមឧស្សាហកម្មដំបូង មនុស្សមានការភ័យព្រួយចំពោះគ្រោះថ្នាក់ដែលកើតឡើងដោយធម្មជាតិក្រៅ ដូចជា ការមិនបានប្រមូលផលទឹកជំនន់ ជំងឺរាតត្បាត និងទុរភិក្សជាដើម។ នេះហើយ ដែលគេហៅថា គ្រោះថ្នាក់ដែលធម្មជាតិខាងក្រៅបានប្រព្រឹត្តមកលើសង្គមមនុស្ស។
- សព្វថ្ងៃ នៅក្នុងករណីមួយចំនួន យើងមិនសូវព្រួយបារម្ភអំពីអ្វីដែលធម្មជាតិ បានប្រព្រឹត្តមកលើយើងទេ តែយើងគួរព្រួយបារម្ភយ៉ាងខ្លាំង អំពីអ្វីដែលយើងបានប្រព្រឹត្តទៅលើធម្មជាតិវិញ។ នេះហើយហៅថា គ្រោះថ្នាក់ដែលមនុស្សបានប្រព្រឹត្តទៅលើធម្មជាតិ។

ក្នុងការប្រៀបធៀបនេះ យើងឃើញថាសព្វថ្ងៃមានការឆ្លងកាត់ពី ឧត្តមានុភាពនៃគ្រោះថ្នាក់ ដែលបង្កឡើងដោយធម្មជាតិមកលើធម្មជាតិវិញ។ គ្រោះថ្នាក់ទី ២ នេះតែងធ្វើឱ្យវប្បធម៌នៃប្រទេសនីមួយៗរង្គោះរង្គើ រហូតដល់បាត់បង់ សញ្ញាណដើមរបស់ខ្លួន ប្រសិនបើយើងមិនប្រុងប្រយ័ត្ន។

នៅចំពោះមុខគ្រោះថ្នាក់ខាងលើ យើងដែលជាប្រជាពលរដ្ឋកម្ពុជា គួរពង្រឹងពង្រីកបន្ថែមទៀតនូវសហប្រតិបត្តិការ ដើម្បីអភិវឌ្ឍវិស័យវប្បធម៌នៃ ប្រទេសនីមួយៗដោយរក្សាធាតុដើមរបស់ខ្លួនផង និងអាចរស់នៅក្នុងពហុវប្ប ធម៌ផង។ ការប្រើឆន្ទៈអត្តនោម័ត និងប្រើអំណាចទាំងកំរោល ដើម្បីលុបបំបាត់ កត្តាអសកម្មនៃវប្បធម៌បរទេស ឬ *"វប្បធម៌ពាលាអាវ៉ាសែ"* មិនអាចប្រព្រឹត្ត ទៅបានទេ។ បញ្ហា

សំខាន់គឺការអប់រំឱ្យខ្មែរភ្ញាក់រលឹកឡើងវិញ តាមរយៈការពង្រឹងវិន័យសីលធម៌ តាមរយៈការសម្ដែងសិល្បៈ តាមរយៈប្រលោមលោក ជាដើម។

ការទប់ស្កាត់ចំណូលចិត្តដែលមិនសមស្រប ដែលបំផ្លិចបំផ្លាញប្រពៃណីជាតិ ដូចជាគំនិតដែលអះអាងថា "កូនធំហើយ ម៉ែឪមិនបាច់ណែនាំច្រើនពេកទេ" "កុំទូលផែនដីម្នាក់ឯង" "សម័យនេះជាសម័យយន្តហោះ មិនមែនជាសម័យរទេះ គោទេ" "មានលុយគឺមានអ្វីៗទាំងអស់" "បើមាត់ហោប៉ៅបែទៅខាងលើលុយជាបញ្ហាចម្បងបំផុត" ... មានអត្ថន័យយ៉ាងសំខាន់ សម្រាប់ឱ្យវប្បធម៌របស់យើងមានអត្ថិភាពរឹងមាំជាមួយនឹងពហុ-វប្បធម៌ដែលឈានចូលមកពីខាងក្រៅ។ កូនធំ កូន តូចសុទ្ធតែត្រូវមានសិទ្ធិសេរីភាព តែការប្រើសិទ្ធិសេរីភាពមិនអាចឃ្លាតឆ្ងាយពី ការទូន្មាន ការណែនាំ របស់ម៉ែឪឡើយ។ របៀបរស់នៅតាមសម័យយន្តហោះ ជាកត្តាសំខាន់ តែក៏មិនគួរ បំភ្លេចរបៀបរស់នៅតាមរទេះគោដែរ។ ប្រាក់ជាកត្តា ចាំបាច់សម្រាប់ជីវិតប្រចាំថ្ងៃ តែមិនគួរចាត់ទុកប្រាក់ជាចៅហ្វាយនាយរបស់ខ្លួនឡើយ។

## ង_សេចក្តីសន្និដ្ឋាន

ប្រទេសនីមួយៗមានវប្បធម៌ដោយឡែករបស់ខ្លួន។ ជនជាតិនីមួយៗ មានវប្បធម៌ដោយឡែករបស់ខ្លួន។ នៅក្នុងប្រទេសមួយ ដែលមានសញ្ជាតិច្រើន ក៏មានវប្បធម៌ច្រើនដែរ។ ដើម្បីរួមរស់ជាមួយគ្នាបាន ជនជាតិទាំងនោះត្រូវ ទទួលស្គាល់ភាពដោយឡែកផង និងភាពរួមផង។

នៅក្នុងពិភពលោកដែលមានប្រជាជាតិដ៏ច្រើន ពហុវប្បធម៌កំពុងតែឆ្លងកាត់គ្នាទៅវិញទៅមក។ វប្បធម៌បស្ចិមប្រទេសកំពុងទន្ទ្រានចូលមកក្នុងប្រទេសដទៃ ទៀត

តែទោះបីតិច ឬច្រើន បស្ចឹមប្រទេសក៏ទទួលឥទ្ធិពលវប្បធម៌នៃ ប្រទេស ដទៃវិញដែរ។ ការឆ្លងគ្នារវាងវប្បធម៌ និងវប្បធម៌ ជាកត្តាបរានុម័តនៅក្នុងយុគសម័យសាកល-ភាវូបនីយកម្មនេះ។

ដំណើរសាកលភាវូបនីយកម្ម ដែលកំពុងមានវិសាលភាពទូលំទូលាយ តែងមានជ្រុងល្អ និងជ្រុងអាក្រក់របស់វា ពិតជាធ្វើឱ្យវប្បធម៌របស់ខ្លួនរស់នៅប្រកបដោយលក្ខណៈថ្មៃប្រឌិត។ ប៉ុន្តែ ការបន្ថយឥទ្ធិពលនៃជ្រុងអាក្រក់នោះ ត្រូវតែប្រព្រឹត្តទៅក្រោមវិចារណញ្ញាណប្រកបដោយវិធីសាស្ត្រ។ កង្វះវិធីវិទ្យាសាស្ត្រ កង្វះបញ្ញាប្រមូលផ្តុំសំរាប់ដោះស្រាយតាមជំហាននីមួយៗ អាចបណ្តាល ឱ្យវប្បធម៌ខ្មែរលិចបាត់បន្តិចម្តងៗ។

ពលរដ្ឋម្នាក់ៗត្រូវមានស្មារតីទទួលខុសត្រូវ ដូចដែល ហ្សង់ ប៉ូលសាត្រ (Jean Paul Sartre) បានអះអាងថា : "មនុស្សទទួលខុសត្រូវគ្រប់នាទី។ មនុស្សទទួលខុសត្រូវអ្វីៗទាំងអស់ នៅចំពោះមុខអ្នកទាំងអស់គ្នា។ គេរែកពុនពិភពលោកទាំងមូលនៅលើស្មារបស់គេ" (L’homme est responsable á tout minute II est responsable de tout devant tous II porte le poids du monde entire sur ses épaules)។

# កម្ពុជា និង ដៃគូពិភាក្សាអាស៊ាន

**ដោយលោក អ៊ុំ ស៊ីផុល**

*ប្រធានការិយាល័យអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី*

ថ្ងៃនេះខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងមានសេចក្តីសោមនស្សរីករាយក្នុងការចូលរួមធ្វើបទអន្តរាគមន៍ ស្តីពីដៃគូចរចាអាស៊ាន។ ខ្ញុំសូមឆ្លៀតឱកាសនេះ សំដែងសេចក្តីអបអរសាទរ ចំពោះវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ក្នុងការរៀបចំវេទិកាកម្ពុជា និងដៃគូពិភាក្សាអាស៊ាន ដោយបានចូលរួម ឧបត្ថម្ភដោយមូលនិធិហ្វ្រីឌ្រិចអេប៊ែត (Friedrich-Ebert-Stiftung)។ វេទិកា នេះរៀបចំឡើងនៅខណៈពេលដែលអាស៊ានកំពុងតែមានដំណើរការយ៉ាងជាក់ច្បាស់ក្នុងកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងរបស់ខ្លួនចំពោះដៃគូចរចារបស់ខ្លួន ជាពិសេសចំពោះសេចក្តីសំរេចដែលមានលក្ខណៈជាប្រវត្តិសាស្ត្រដែលធ្វើឡើង ដោយប្រមុខរដ្ឋ-ប្រមុខរដ្ឋាភិបាល នៅកិច្ចប្រជុំកំពូលនៅបាលីនាពេលថ្មីៗនេះ។

ទំនាក់ទំនងរបស់អាស៊ានជាមួយពិភពខាងក្រៅ បានបោះជំហានយ៉ាងខ្លាំងក្លានៅឆ្នាំ ១៩៧៦ គឺរយៈពេលមួយទសវត្ស បន្ទាប់ពីការបង្កើតអាស៊ាននៅ ខែសីហា ឆ្នាំ

១៩៦៧។ នៅក្នុងរយៈពេល ១០ ឆ្នាំដំបូងនៃការបង្កើតអាស៊ាន អាស៊ានមានសេចក្តីខ្វល់ខ្វាយ ក្នុងការធ្វើឱ្យមានសមាគមថ្មីមួយនេះ ជំរុញការជឿ ជាក់គ្នាទៅវិញទៅមក ហើយនិងការរក្សាតំបន់នេះឱ្យស្ថិតនៅក្រៅសៃវៀននៃជំលោះសង្គ្រាមត្រជាក់។ គោលបំណងសំខាន់គឺ ត្រូវធ្វើឱ្យមានសាមគ្គីភាពស្អិត រមួតក្នុងតំបន់ និងការអភិវឌ្ឍន៍ដែលត្រូវបានធ្វើឡើង ដោយប្រទេសអាស៊ាន ដែលទើបបានទទួលឯករាជ្យថ្មីៗ ដើម្បីកែលំអជីវភាពរស់នៅរបស់ប្រជាជនរបស់ខ្លួន។ សមាជិកស្ថាបនិកមានប្រវត្តិសាស្ត្រ ធ្លាប់មានជំលោះជាមួយគ្នា ដូច្នេះ សំខាន់គឺសិក្សា ដើម្បីឈ្វេងយល់នូវភាពមិនចុះសំរុងគ្នារបស់ពួកគេ និងដើម្បីឱ្យការជឿជាក់ក្នុងការធ្វើការចរចា និងការធ្វើកិច្ចសហប្រតិបត្តិការគ្នាជាក្រុម។ ក្រៅពីប្រទេសរបស់ពួកគេ អាស៊ានបានសំលឹងឃើញនូវតំបន់មួយ និងសហគមន៍ពិភពលោកមួយ ដែលត្រូវបានបែងចែកពីគ្នាដោយមនោគមវិជ្ជា និងសង្គ្រាមត្រជាក់។

ទំនាក់ទំនងអាស៊ានជាមួយដៃគូចរចាររបស់ខ្លួន ធ្វើឡើងតាមរយៈកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយប្រទេសដៃគូ (Post-Ministerial Conference-PMC) ។ កិច្ចប្រជុំ PMC មាន PMC+10 និង PMC+1។ ចំពោះ PMC+10 គឺប្រទេសអាស៊ានទាំង ១០ ចូលរួមកិច្ចប្រជុំនេះជាមួយដៃគូ ទាំង ១០ ឯកិច្ចប្រជុំ PMC+1 គឺប្រទេសអាស៊ានទាំង ១០ ចូលរួមប្រជុំជាមួយ ប្រទេស មួយៗនៃដៃគូ។ ចាប់ពីឆ្នាំនេះតទៅ អាស៊ានបានសំរេចឱ្យមានកិច្ចប្រជុំ PMC+1 ជាមួយតែប្រទេសចំនួន ៦ ប៉ុណ្ណោះគឺ ប្រទេសអូស្ត្រាលី កាណាដា សហភាពអឺរ៉ុប ញូហ្សេឡែន សហព័ន្ធរុស្ស៊ី និងសហរដ្ឋអាមេរិច។ រីឯ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ការបរទេសអាស៊ាន ជាមួយ

ប្រទេសដៃគូបួនទៀតគឺ ប្រទេសចិន ជប៉ុន សាធារណៈរដ្ឋកូរេ និងឥណ្ឌា នឹងត្រូវធ្វើឡើងជាប់គ្នាទៅនឹងកិច្ចប្រជុំកំពូលអាស៊ាន។

គោលបំណងសំខាន់ នៃទំនាក់ទំនងជាមួយពិភពខាងក្រៅរបស់អាស៊ាន មានបីគឺ : ១-ធានាឱ្យមានជំនួយបច្ចេកទេសសំរាប់គម្រោងសហប្រតិបត្តិការ តំបន់ ២-បង្កើតទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្ម និង ៣-ពង្រឹងទំនាក់ទំនង នយោបាយជាមួយប្រទេសខាងក្រៅ និងការប្រមូលផ្តុំគ្នាជាក្រុមនៃតំបន់នេះ។ ដៃគូចរចាសំខាន់ទីមួយរបស់អាស៊ានមាន សហភាពអឺរ៉ុប ជប៉ុន និងសហរដ្ឋអា មេរិច ដែលជាប្រទេសដៃគូពាណិជ្ជកម្មធំៗ។

បច្ចុប្បន្នដៃគូចរចាអាស៊ានមាន : ប្រទេសអូស្ត្រាលី (ជាដៃគូចរចាពេញលេញនៅឆ្នាំ១៩៧៤) កាដាណា (ជាដៃគូចរចារពេញលេញនៅឆ្នាំ១៩៧៧) ចិន (ជាដៃគូចរចាពេញលេញនៅឆ្នាំ១៩៩៦) សហភាពអឺរ៉ុប (ជាដៃគូចរចា ពេញលេញ នៅឆ្នាំ១៩៧២) ឥណ្ឌា (ជាដៃគូចរចាពេញលេញនៅឆ្នាំ១៩៩៥) ជប៉ុន (ជាដៃគូចរចាពេញលេញនៅឆ្នាំ១៩៧៧) សាធារណៈរដ្ឋកូរ៉េ(ជាដៃគូចរចាពេញលេញនៅឆ្នាំ ១៩៩១) ញូហ្សេឡេនដ៍ (ជាដៃគូចរចាពេញលេញនៅឆ្នាំ ១៩៧៥) រុស្សី (ជាដៃគូចរចា ពេញលេញនៅឆ្នាំ ១៩៩៧) សហរដ្ឋអាមេរិច (ជា ដៃគូចរចាពេញលេញ នៅឆ្នាំ១៩៧៧) និង UNDP (ជាដៃគូចរចាពេញលេញ នៅឆ្នាំ១៩៧៧)។

## ដំណើរការផ្លាស់ប្តូរយុទ្ធសាស្ត្រផ្ទៃក្នុងរបស់អាស៊ាន

នៅពេលដែលអាស៊ានមានការវិវត្តិ និងមានការជឿជាក់កាន់តែខ្លាំងថា ជាអង្គការតំបន់មួយនោះ អាស៊ានបានពង្រីកសមាជិកភាពរបស់ខ្លួន ដើម្បីឱ្យប្រទេស

ប្រ៊ុយណេ វៀតណាម ឡាវ ភូមា និងកម្ពុជា តាមរយៈការផ្លាស់ប្តូរក្នុងសតវត្សចុងក្រោយ ដើម្បីបំពេញតំរូវការរបស់ប្រទេសស្ថាបនិក ក្នុងការបង្រួប បង្រួមអាស៊ានមួយដែលរួមមានគ្រប់ប្រទេសនៅអាស៊ីអាគ្នេយ៍។ នៅពេលជាមួយគ្នានេះ អាស៊ានទទួលប្រទេសឥណ្ឌា ចិន និងសហព័ន្ធរុស្ស៊ី ជាដៃគូចរចានៅ ក្នុងយុទ្ធសាស្ត្រមួយឆ្ពោះទៅរកការធានាឱ្យមានសន្តិភាព និងសន្តិសុខតំបន់នៅក្នុងយុគសម័យក្រោយសង្គ្រាមត្រជាក់ថាតើដៃគូចរចាទាំងឡាយ នឹងក្លាយទៅជាដៃគូចរចាពិតប្រាកដដែរឬទេ?

ការខិតខំប្រឹងប្រែងដើម្បីជំរុញឱ្យមាន សន្តិភាព និងវិបុលភាពនៅក្នុងតំបន់តាមរយៈកិច្ចសហប្រតិបត្តិការតំបន់ និងទំនាក់ទំនងខាងក្រៅ អាស៊ានត្រូវបានទទួលស្គាល់ថា ជាកំលាំងដើម្បីសន្តិភាព ស្ថិរភាព និងជាគន្លឹះមួយសំរាប់ស្ថេរភាពក្នុងតំបន់អាស៊ីប៉ាស៊ីភិច ហើយប្រើប្រាស់យុទ្ធវិធីរបស់អាស៊ាន ក្នុងការដើរតួជាចម្បងក្នុងសកម្មភាពចរចា និងសហប្រតិបត្តិការនៃពិភពលោក តាមរយៈវេទិកាតំបន់អាស៊ាន (ARF) ក៏ដូចជា យន្តការនៃតំបន់ផ្សេងៗទៀត ដែលអាស៊ាន បានជួយបង្កើត និងជំរុញដូចជាដំណើរការ ASEAN+3 សហប្រតិបត្តិការសេដ្ឋ កិច្ចអាស៊ីប៉ាស៊ីភិច (APEC) កិច្ចប្រជុំអាស៊ីអឺរ៉ុប (ASEM) និងការចរចា ស្តីពី សហប្រតិបត្តិការអាស៊ាន (ACD)។

## ដំណើរការផ្លាស់ប្តូរយុទ្ធសាស្ត្រទំនាក់ទំនងខាងក្រៅ

រយៈពេលជាង ២៥ ឆ្នាំចុងក្រោយ យុទ្ធសាស្ត្រផ្នែកទំនាក់ទំនងផ្នែកខាងក្រៅមានដំណើរការ ដើម្បីផលប្រយោជន៍របស់អាស៊ាន និងបរិដ្ឋានអន្តរជាតិ និងតំបន់ប្រកបដោយភាពស្វាហាប់។

ទំនាក់ទំនងរវាងអាស៊ាន និងដៃគូចរចាររបស់ខ្លួនមានភាពស្មើភាពគ្នា មិនមែនដូចជាទំនាក់ទំនងរវាងអតិថិជននិងអ្នកផ្តល់ជំនួយ ដែលដៃគូចរចារមាន ឥទ្ធិពលខ្លាំងជាង ក្នុងសកម្មភាពសហប្រតិបត្តិការនោះទេ។ ពេលនេះកិច្ចសហប្រតិបត្តិការឈរលើមូលដ្ឋានការសំរេចរួមគ្នា ការអនុវត្តន៍ និងការធ្វើផែនការរួមគ្នា ក្នុងសកម្មភាពសហប្រតិបត្តិ។ អាស៊ាន និងដៃគូចរចាររបស់ខ្លួន កំពុងប្រើផែនការរួមគ្នាក្នុងការអនុវត្តន៍គំរោងទាំងឡាយ ដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើប្រទេសសមាជិកអាស៊ានថ្មី។ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ផ្តោតជាសំខាន់ទៅលើកម្មវិធី ដែលមានប្រយោជន៍ទៅវិញទៅមក និងដែលមានផលប្រយោជន៍សំរាប់ការអភិវឌ្ឍន៍តំបន់ និងទំនាក់ទំនងជាដៃគូ។

ទំនាក់ទំងជាមួយប្រទេសខាងក្រៅ អាស៊ានទទួលបាននូវច្រកចូលទីផ្សារ កាន់តែធំជាងការធានាវិនិយោគទុន ការសំរួលដល់ផ្នែកសេវាកម្ម ជំរុញទេសចរណ៍ និងជួយអាស៊ានក្នុងការកាត់បន្ថយគំលាតនៃការអភិវឌ្ឍន៍ក្នុងយុទ្ធសាស្រ្ត សមាហរណកម្មតំបន់។

ការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចត្រូវបានឆ្លុះបញ្ចាំងច្បាស់ តាមរយៈភាព ជាដៃគូសេដ្ឋកិច្ចទូលំទូលាយ (Comprehensive Economic Partnerships CEPs) ដែលអាស៊ានបានចូលរួមជាមួយដៃគូចរចាររបស់ខ្លួន។ ប្រទេស ចិន ឥណ្ឌា និងជប៉ុនបានអនុវត្ត ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយ (CEPs) ជាមួយអាស៊ាន និងកំពុងធ្វើការឆ្ពោះទៅរកតំបន់ពាណិជ្ជកម្មសេរី (FTAs) ក្នុងរយៈពេលមួយទសវត្ស ឬច្រើនជាងនេះ ដែលមិនត្រឹមតែអនុវត្តលើទំនិញ ប៉ុណ្ណោះទេ តែថែមទាំងទៅលើពាណិជ្ជកម្មផ្នែកសេវាកម្ម វិនិយោគទុន និង ការលុបបំបាត់របាំងគយទៀតផង។ សហរដ្ឋអាមេរិច

សហភាពអឺរ៉ុប អូស្ត្រាលី នូវែលហ្សេឡង់ ក៏កំពុងធ្វើការជាមួយអាស៊ានកាន់តែជិតស្និត ស្តីពី ទំនាក់ទំនងសេដ្ឋកិច្ច។

ដោយមានការអនុម័ត ទស្សនទានសហគមន៍អាស៊ាន (ASEAN Community) ដែលរួមមានសហគមន៍ ៣ គឺ សហគមន៍សន្តិសុខអាស៊ាន (ASC) សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និង សហគមន៍វប្បធម៌សង្គម អាស៊ាន (ASCC) ដើម្បីបង្កើនការយកចិត្តទុកដាក់ទៅលើសមាហរណកម្មរបស់ខ្លួន។ សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ត្រូវបានគេរំពឹងថានឹងដឹកនាំ ដំណើរការសហគមន៍នេះ តាំងពីពេលដែលប្លុកនេះត្រូវបានដាក់ ឱ្យដំណើរការតាមរយៈ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) តំបន់វិនិយោគអាស៊ាន (AIA) និងកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម (AFAS)។ ដៃគូចរចាអាស៊ាននឹងដើរតួនាទីជាអ្នកផ្តល់វិភាគទាន ក្នុងការជួយអាស៊ាននៅក្នុងសហគមន៍សេដ្ឋកិច្ច តាមរយៈភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយ (CEPs) និងគំនិតផ្តួចផ្តើមសហប្រតិបត្តិការផ្សេងៗ។

តំបន់ពាណិជ្ជកម្មសេរី ជាយន្តការមួយចំពោះសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) គឺអាស៊ានធ្វើការបើកទីផ្សារចំពោះដៃគូចរចារបស់ខ្លួន និងប្រទេសដៃគូបើកទីផ្សារ ចំពោះប្រទេសអាស៊ានវិញ។ ប្រទេសអាស៊ាននឹងត្រូវការកែលំអភាពប្រកួតប្រជែង របស់ខ្លួន ដើម្បីជំរុញការនាំចេញក្នុងទីផ្សារអាស៊ាន និងទីផ្សារដៃគូរបស់ខ្លួន។

ក្នុងកិច្ចសហប្រតិបត្តិការក្នុងវិស័យសន្តិសុខ នយោបាយ អាស៊ានបានទទួលជោគជ័យក្នុងការបង្រួបបង្រួមនៅក្នុងវេទិកាតំបន់អាស៊ាន (ARF) ដោយ បានទទួលតួនាទីធំក្នុងពិភពលោក និងរក្សាបានផលប្រយោជន៍របស់ខ្លួនក្នុង តំបន់។ ដំណើរការ

ផ្សេងទៀតដូចជា អាស៊ាន+3, APEC, ASEM និង ACD ក៏បានជំរុញឱ្យមានសន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់ថែមទៀត។

ចំណុចរួមផ្សេងទៀតដែលអាស៊ានលើកឡើង ដើម្បីធានាសន្តិភាព និងសន្តិសុខអាស៊ីអគ្នេយ៍គឺ ការបើកចំហរសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិ ការអាស៊ាន (TAC) នៅក្នុងអាស៊ីអគ្នេយ៍ចំពោះដៃគូចរចាររបស់ខ្លួន។ ប្រទេសចិនបានក្លាយ ជាដៃគូចរចាទីមួយ ដែលបានចុះហត្ថលេខាលើ TAC បន្ទាប់មក ប្រទេសឥណ្ឌា នៅក្នុងកិច្ចប្រជុំកំពូលនៅបាលីថ្មីៗនេះ។ សហព័ន្ធ រុស្ស៊ីត្រូវគេរំពឹងថា នឹងចុះ ហត្ថលេខាលើ TAC នៅឆ្នាំបន្ទាប់នេះ។ អាស៊ាន កំពុងជំរុញដៃគូអាស៊ាន+3 របស់ខ្លួនពីរ ប្រទេសគឺ ប្រទេសជប៉ុន និងសាធារណៈរដ្ឋកូរ៉េ ក្នុងការចុះហត្ថលេខាលើ TAC ឱ្យបានកាន់តែឆាប់ ដើម្បីធ្វើជា ក្រមសីលធម៌មួយ (Code of conduct) សំរាប់ទំនាក់ទំនងអាស៊ីបូព៌ា។ នៅពេលដំណាលគ្នានេះដែរ អាស៊ាននឹងជំរុញឱ្យមាន អំណាច នុយក្លេអ៊ែរទាំងប្រាំចូលរួមសន្ធិសញ្ញាតំបន់គ្មានអាវុធនុយក្លេអ៊ែរអាស៊ីអគ្នេយ៍ (Treaty of Southeast Asia Nuclear Weapon Free Zone, SEANWFZ)។

ដោយមានការវាយប្រហារនៅថ្ងៃទី១១ ខែកញ្ញា លើសហរដ្ឋអាមេរិច និងការកើនឡើងភេរវកម្មអន្តរជាតិ អាស៊ានបានធ្វើការយ៉ាងសកម្មជាមួយ ដៃគូចរចារបស់ខ្លួនក្នុងកំរិតពហុភាគីតំបន់ និងទ្វេរភាគី ក្នុងការដោះស្រាយបញ្ហានេះ។ អាស៊ានបានអនុវត្តកតិការសញ្ញាជាច្រើនជាមួយដៃគូចរចារបស់ខ្លួន ដើម្បីដោះស្រាយរួមគ្នាបញ្ហាភេរវកម្ម និងបទឧក្រិដ្ឋឆ្លងដែន។ ដៃគូទាំងនោះរួមមាន សហរដ្ឋអាមេរិច សហភាពអឺរ៉ុបប្រទេសចិន រុស្ស៊ី និង ឥណ្ឌា។ សហប្រតិបត្តិការនឹងផ្តោតលើវិស័យដូចជា ការរួមចំណែកផ្លាស់ប្តូរ ពតិមាន ការកសាងសមត្ថភាព ការធ្វើការរួមគ្នាយ៉ាងជិតស្និត

លើឆាកអន្តរជាតិ និងការចុះហត្ថលេខាលើការប្រទានសច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពី ភេរវកម្ម និងបទឧក្រិដ្ឋឆ្លងដែនដែលពាក់ព័ន្ធ។ កិច្ចសហប្រតិបត្តិការបែបនេះមានសារៈសំខាន់សំរាប់អាស៊ាន ដើម្បីលុបបំបាត់ ទស្សនៈដែលថាអាស៊ានជាប្រភពសំរាប់ភេរវករ ។

ក្នុងបរិបទបច្ចុប្បន្ននេះ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្លាយទៅជាផ្នែកសមាហរណកម្មមួយនៃទំនាក់ទំនងខាងក្រៅ។ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ជាមួយដៃគូចរចារបស់ខ្លួនផ្តោតទៅលើទិដ្ឋភាពបួន : ទី១-បង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ទី២-គាំទ្រសមាហរណកម្មអាស៊ាន ទី៣-ការកាត់ បន្ថយគំលាតអភិវឌ្ឍន៍តាមរយៈទំនាក់ទំនងជារូបវន្ត និងការកសាងសមត្ថភាព និងដោះស្រាយបញ្ហាអន្តរជាតិ ទី៤-ជំរុញទំនាក់ទំនងរវាងប្រជាជន។

ដៃគូចរចាដឹងច្បាស់ថា កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយអាស៊ាននឹងពឹងផ្អែកយ៉ាងខ្លាំង លើល្បឿនរីកចំរើននៃប្រទេសអាស៊ានថ្មី ដែលជាកត្តាជំរុញឱ្យអាស៊ានអនុវត្ត CEPs និង FTAs ជាមួយដៃគូចរចារបស់ខ្លួន និងសំរេចបានការកំណត់ពេលវេលាសំរាប់កិច្ចការនេះ។ អាស៊ាន និងដៃគូចរចារបស់ខ្លួនផ្តោតការ យកចិត្តទុកដាក់លើការផ្តល់ជំនួយដល់ប្រទេសអាស៊ានថ្មី តាមរយៈកម្មវិធី អភិវឌ្ឍន៍អនុតំបន់ផ្សេងៗ ជាពិសេស នៅតំបន់អាងទន្លេមេគង្គ។ ប្រទេសចិន ឥណ្ឌា ជប៉ុន និងសាធារណៈរដ្ឋកូរ៉េកំពុងជួយអាស៊ាន ដើម្បីអនុវត្តគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (IAI) កិច្ចសហប្រតិបត្តិការអនុតំបន់នៅក្នុង តំបន់អាងទន្លេមេគង្គ។ តំបន់ផ្សេងទៀតដែលទទួលបានជំនួយរបស់ដៃគូចរចាអាស៊ានខាងកើត (BIMP-EAGA) ដែលរួមមានប្រទេសប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និង ហ្វីលីពីន។

ដើម្បីបង្កើនល្បឿនធ្វើសមាហរណកម្មសេដ្ឋកិច្ច ប្រទេសអាស៊ានចាស់ ទាំង ៦ សន្យាជួយប្រទេសអាស៊ានថ្មី ក្នុងបំណងជំរុញឱ្យប្រទេសដៃគូចរចាមើលឃើញអំពីតំលៃក្នុងការ ផ្តល់ជំនួយបន្ថែមទៀត។

*ចំណុចចុងក្រោយ* យុទ្ធសាស្រ្តទំនាក់ទំនងខាងក្រៅរបស់អាស៊ានត្រូវ បែរទៅរកអាស៊ីបូព៌ា ដោយសារតែការផ្លាស់ប្តូរឥទ្ធិពលតំបន់ និងពិភពលោក។ វិបត្តិសេដ្ឋកិច្ចឆ្នាំ ១៩៩៧-១៩៩៨ ជាសក្ខីភាពទំនាក់ទំនងអាស៊ាន និងដៃគូអាស៊ីបូព៌ា ដូចជាប្រទេសចិន ជប៉ុន និងសាធារណៈរដ្ឋកូរ៉េ ដែលតំបន់នេះត្រូវធ្វើ ការឱ្យកាន់តែជិតស្និទថែមទៀត ដើម្បីធានាស្ថេរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច ដើម្បីបង្កើនការកើនឡើងសារជាថ្មី នៃវិបត្តិផ្សេងទៀត។ បញ្ហានេះធ្វើឱ្យ ដំណើរការអាស៊ាន+3 ដែលត្រូវបានផ្តួចផ្តើមឡើងក្នុងឆ្នាំ ១៩៩៧ ក្លាយជាផ្លូវការនៅឆ្នាំ ១៩៩៩ ដែលបង្កើតជាយន្តការចាំបាច់ ដើម្បីធានាសន្តិភាព និងវិបុលភាពថែមទៀតនៃតំបន់អាស៊ីបូព៌ា។

នៅក្នុងអំឡុងពេល ៥ ឆ្នាំចុងក្រោយនេះ សហប្រតិបត្តិការអាស៊ីខាងកើតបានរីកដុះដាលគ្របដណ្តប់លើវិស័យសេដ្ឋកិច្ច រូបិយវត្ថុ និងហិរញ្ញវត្ថុ វិទ្យាសាស្រ្ត និងបច្ចេកទេស សុខាភិបាល ពលកម្ម កសិកម្ម និងការអភិវឌ្ឍន៍ ហើយ និងទំនាក់ទំនងរវាងប្រជាជន។ ការប្រឆាំងនឹងភេរវកម្មជាវិស័យមួយផ្សេងទៀត ដែលបង្កើនកិច្ចសហប្រតិបត្តិការអាស៊ាន+3 តាំងពីមានការកើនឡើងភេរវកម្ម និងបទល្មើសឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដែលតំរូវឱ្យមានការប្តេជ្ញាចិត្ត ការធានាសន្តិសុខ និងនយោបាយនៅក្នុងអាស៊ីបូព៌ា។ តាមរយៈកិច្ចប្រជុំរដ្ឋមន្រ្តីការបរទេសអាស៊ាន+3 លើកទី ៥ បានពិភាក្សាលើទិសដៅឈានទៅរកការបង្កើត **សហគមន៍អាស៊ីបូព៌ា** នៅពេលអនាគត និងមានការរៀបចំឱ្យមាន **កិច្ចប្រជុំកំពូលអាស៊ីបូព៌ា**។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គប្រជុំបាន

ឯកភាពថា កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី ១ ត្រូវបានធ្វើឡើង នៅប្រទេសអាស៊ាន គឺប្រទេសម៉ាឡេស៊ី នៅឆ្នាំ ២០០៥ ហើយកិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី ២ នឹងប្រព្រឹត្តទៅនៅអាស៊ាន+3 ។

ចំពោះដៃគូចរចាអាស៊ានផ្សេងទៀតនោះ ក៏មានការវិវត្តិទៅរកភាពវិជ្ជមានដោយប្រទេសអាស៊ានទាំងអស់បានឯកភាពគ្នាឱ្យមាន **កិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលី និងញូហ្សេឡេនដ៏** ធ្វើឡើងភ្ជាប់ទៅនឹងកិច្ចប្រជុំកំពូល អាស៊ានលើកទី ១០ នៅថ្ងៃទី ៣០ វិច្ឆិកា ២០០៤ ខាងមុខនេះនៅប្រទេសឡាវ ។

## ការប្រឈមផ្សេងៗទៀត

នៅក្នុងឆាកនយោបាយ អាស៊ានត្រូវសំលឹងមើលទៅរកការរៀបចំ ទំនាក់ទំនងរបស់ខ្លួនជាមួយនឹងដៃគូយុទ្ធសាស្ត្ររបស់ខ្លួន ដូចជា ប្រទេសចិន និង ឥណ្ឌាដែលជាភាគីហត្ថលេខីនៃ TAC និងប្រទេសរុស្ស៊ីក្នុងពេលឆាប់ៗនេះ។ នៅ ខណៈដែលពួកគេជាសមាជិក TAC នឹងមានការកើនឡើងនូវជំនឿជឿជាក់ និង ការទុកចិត្តគ្នាទៅវិញទៅមកជាពិសេស តាំងពីពេលដែលពួកគេមានសមត្ថភាពនុយក្លេអ៊ែរ។ អាស៊ានត្រូវជំរុញពួកគេ ដើម្បីបន្តផ្តល់ជាមធ្យោបាយសំរាប់អាស៊ានក្នុងការស្វែងរកការដោះស្រាយបញ្ហា ការគោរពគោលការណ៍មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងគ្នា ការគោរពអធិប-តេយ្យភាពជាតិ និងការគោរពគ្នាទៅវិញទៅមកនៅក្នុង TAC ។

អាស៊ាននឹងត្រូវធ្វើកិច្ចការច្រើនជាងនេះ ជាមួយដៃគូចរចារបស់ខ្លួនដើម្បីដោះស្រាយបញ្ហាភេរវកម្ម និងការព្រួយបារម្ភផ្សេងៗទៀតរបស់អន្តរជាតិ។ អាស៊ាននឹងត្រូវប្រមើលមើលទៅរកការចុះហត្ថលេខា និងការផ្តល់សច្ចាប័នដល់ អនុសញ្ញាអង្គការ

សហប្រជាជាតិស្តីពី ភេរវកម្ម និងបទឧក្រិដ្ឋអន្តរជាតិពាក់ព័ន្ធ។ អាស៊ានធ្វើការជាមួយ ចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េ លើបញ្ហាចោរកម្មតាម សមុទ្រក្នុងច្រកម៉ាឡាកា ដើម្បីធានាសុវត្ថិភាពក្នុងផ្នែកនាវាចរ នៅក្នុងផ្លូវនាវា ចរមួយក្នុងចំណោមផ្លូវនាវាចរដ៏មមាញឹកបំផុតរបស់ពិភពលោក និងជាមួយ អូស្ត្រាលី សហភាពអឺរ៉ុប នៅលើការជួញដូរមនុស្ស ជាមួយឥណ្ឌាលើការជួញដូរ គ្រឿងញៀន ហើយជាមួយសហរដ្ឋអាមេរិច ក្នុងការប្រឆាំងភេរវកម្ម។

ក្នុងវិស័យសេដ្ឋកិច្ច អាស៊ានធ្វើការប្តេជ្ញាចិត្តក្រោមល័ក្ខខ័ណ្ឌដៃគូសេដ្ឋកិច្ចទូលំទូលាយ (CEP) និងកំណត់គោលដៅសំរាប់ដៃសេដ្ឋកិច្ចទូលំទូលាយ និងតំបន់ពាណិជ្ជកម្មសេរី ដើម្បីអាចទទួលបានដូចផែនការគ្រោងទុក។ កិច្ចការទាំងនេះនឹងជួយបង្កើនល្បឿន ក្នុងការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (ACE) នា ឆ្នាំ ២០២០ ឬក៏អាចលឿនជាងនេះ។

ក្នុងវិស័យសហប្រតិបត្តិការអភិវឌ្ឍន៏អាស៊ាន នឹងត្រូវរក្សាទុកគោលការណ៏នៃភាពជាដៃគូស្មើភាព និងការមិនប្រកាន់សមាជិកណាមួយក្នុងសកម្មភាពអភិវឌ្ឍន៏។ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៏គួរត្រូវគេប្រើជាឧបករណ៏ប្រកប ដោយប្រសិទ្ធិភាព ដើម្បីកាត់បន្ថយគំលាតអភិវឌ្ឍន៏ ដើម្បីពង្រឹងទំនាក់ទំនង នយោបាយ និងសេដ្ឋកិច្ច ជាមួយដៃគូចរចារបស់ខ្លួន។

អាស៊ានត្រូវប្រមើលមើលទៅរកយុទ្ធសាស្ត្រគៀងគរប្រភពថ្មីៗ ដើម្បី បំពេញជំនួយរបស់ដៃគូចរចា។ គោលដៅមួយដែលត្រូវទទួលបានរូបិយវត្ថុនោះ គឺការអនុវត្តន៏សកម្មភាពរួមគ្នារវាងដៃគូចរចា និងប្រទេសអាស៊ានចាស់ទាំង ៦ តាមរយៈគំនិតផ្តួចផ្តើម

សមាហរណកម្មអាស៊ាន (IAI) ។ ការធ្វើសមាហរណកម្ម អាស៊ានកាន់តែឆាប់ អាស៊ានកាន់តែមានភាពងាយស្រួលក្នុងការឆ្ពោះទៅរក កិច្ចសហប្រតិបត្តិការអាស៊ីខាងកើតកាន់តែប្រសើរឡើង ។

## សេចក្តីសន្និដ្ឋាន

ទំនាក់ទំនងខាងក្រៅរបស់អាស៊ាន នឹងបន្តធ្វើជាប៉ូលមួយនៅក្នុងកិច្ចសហប្រតិបត្តិការអាស៊ាន ហើយវានឹងបន្តផ្តល់ផលប្រយោជន៍ដល់អាស៊ាន ជាអង្គការតំបន់មួយដែលចង់សំរេចគោលដៅរបស់ខ្លួន ធ្វើជាកំលាំងសន្តិភាពវិបុលភាព និងភាពសុខសាន្តនៅក្នុងអាស៊ីអគ្នេយ៍ ។ ទោះជាយ៉ាងណាក្តី ទិសដៅសំរាប់អនាគតត្រូវពឹងផ្អែកយ៉ាងខ្លាំងលើទិដ្ឋភាព ជាច្រើនដែលរួមមានការផ្លាស់ប្តូរយុទ្ធសាស្ត្រ សមាហរណកម្ម និងការវិវត្តឆ្ពោះទៅរកសហគមន៍អាស៊ាន និងប្រសិទ្ធិភាព ក្នុងការដោះស្រាយបញ្ហាប្រឈម ទាំងនៅក្នុងតំបន់ទាំងក៏រិតទំនាក់ទំនង ខាងក្រៅ ។

# កម្ពុជា ក្នុងអាស៊ាន៖ ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍កម្ពុជា

**ឯកឧត្តម ធុត និនជឿន**

*រដ្ឋលេខាធិការនៃក្រសួងទេសចរណ៍*

## ក_សេចក្តីផ្តើម

ក្នុងនាមក្រសួងទេសចរណ៍និងក្នុងនាមខ្ញុំផ្ទាល់ សូមសំដែងនូវអំណរ សារទរ និងកោតសរសើរយ៉ាងក្រៃលែងចំពោះ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិ បត្តិការ និងសន្តិភាព ដែលបានបង្កើតនូវវេទិកានេះឡើង ជាពិសេស ថ្វាយចំពោះ **សម្តេច នរោត្តម សិរីវុឌ្ឍ** ជាព្រះប្រធាន ក្រុមប្រឹក្សាភិបាល។

វេទិកានេះមានលក្ខណៈសំខាន់ណាស់ សំរាប់ព្រះរាជាណាចក្រកម្ពុជា ដែលជាសមាជិកអាស៊ាន។ វេទិការតំបន់អាស៊ាន ជាវេទិកា ដែលទាក់ទងនឹង សន្តិសុខតំបន់ និងជាឧបករណ៏មួយដែលធ្វើឱ្យតំបន់អាស៊ីយើង មានកិច្ចសហប្រតិបត្តិការ ជាមួយនឹងតំបន់ឯទៀត ក្នុងពិភពលោក ដែលរួមគ្នាដោះស្រាយវិបត្តិនានា ដើម្បីធានាឱ្យពិភពលោកយើង កាន់តែមានសន្តិភាព និងសហប្រតិបត្តិការ។

ទេសចរណ៍អាស៊ានគឺជាទេសចរណ៍សហការ និង ជាការប្រកួតប្រជែងរវាងប្រទេស ជាសមាជិក ក្នុងការទាក់ទាញភ្ញៀវឱ្យមកទស្សនកិច្ចក្នុងប្រទេសខ្លួន ដើម្បីសេដ្ឋកិច្ច និងផ្តល់ការងារជូនប្រជាពលរដ្ឋ យ៉ាងទូលំទូលាយ ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ នៃប្រទេសនីមួយៗ ដែលជាសមាជិក។ ដូចនេះ ការជួបពិភាក្សារវាងស្ថាប័នរដ្ឋ-នីតិប្រតិបត្តិ នីតិបញ្ញត្តិ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជនមានសារៈសំខាន់ណាស់ ដើម្បីយើងទាំងអស់គ្នាធ្វើការស្រាវជ្រាវ សិក្សាទីផ្សារ បង្កើនសមត្ថភាពការយល់ដឹង និងការរៀនសូត្រ ដកស្រង់ការពិសោធន៍ ពីសមាជិកដទៃទៀតនៃអាស៊ាន។

តើកម្ពុជាត្រូវធ្វើអ្វីខ្លះលើវិស័យទេសចរណ៍? វិស័យទេសចរណ៍នៃ ព្រះរាជាណាចក្រកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលកំណត់ថា ជាទេសចរណ៍ វប្បធម៌ និងធម្មជាតិ។ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៣ បានបន្តកំណត់នូវយុទ្ធសាស្ត្រចតុកោណទី៣ ក្នុងការអភិវឌ្ឍន៍ផ្នែកឯកជន និងការងារមុំទី ១ គឺការពង្រីកវិស័យឯកជន និងការទាក់ទាញវិនិយោគ (ដកស្រង់ពីសុន្ទរកថាសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា "ស្តីពីយុទ្ធសាស្ត្រចតុកោណ" ថ្លែងក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើក ទី ១ សម្រាប់អាណត្តិទី ៣ នៃរដ្ឋសភា នៅទីស្តីការគណៈរដ្ឋ មន្ត្រី នៅរាជធានី ភ្នំពេញ ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៤។)

## សភាពការណ៍ទេសចរណ៍

តាមរបាយការណ៍របស់អង្គការទេសចរណ៍ពិភពលោក (WTO) បាន បង្ហាញឱ្យដឹងថាក្នុងឆ្នាំ ២០០៣ ទេសចរណ៍បានធ្វើដំណើរមានចំនួន ៦៩៤ លាននាក់។ តួលេខ

បង្ហាញពីការធ្លាក់ចុះ ១២% បើប្រៀបធៀបទៅនឹងឆ្នាំ ២០០២ ដែលមានចំនួន ៧១៥ លាននាក់ ហើយទទួលបានចំណូល ៤៦៨ ពាន់ លានដុល្លា មានការថយចុះ ៣.២% បើប្រៀបធៀបទៅនឹងឆ្នាំ ២០០២។

តាមរបាយការណ៍របស់សមាគមអាស៊ានបានឱ្យដឹងថា ក្នុងឆ្នាំ ២០០៣ ទេសចរណ៍ បានធ្វើដំណើរកំសាន្តនៅអាស៊ានមាន ៣៧.៤៩៣.៨៨៣ នាក់ មានការធ្លាក់ចុះ ១៤.៧៧% បើប្រៀបធៀបទៅនឹងឆ្នាំ ២០០២ ដែលមានចំនួន ៤៣.៩៨៩.០១០ នាក់។

ព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ ២០០៣ បានទទួលទេសចរណ៍ចំនួន ៧០១.០១៤ នាក់ មានការធ្លាក់ចុះចំនួន ១០.៨៧% បើប្រៀបធៀបទៅនឹងឆ្នាំ ២០០២ ដែលមានភ្ញៀវចំនួន ៧៨៦.៥២៤ នាក់ នឹងទទួលបានចំណូល ៣៤៦ លានដុល្លា តាមប្រភពក្រសួងទេសចរណ៍។

សភាពការណ៍ធ្លាក់ចុះនៃទេសចរណ៍នៅឆ្នាំ ២០០៣ គឺដោយសារឥទ្ធិពលអវិជ្ជមានពីភេរវកម្ម សង្គ្រាមនៅអ៊ីរ៉ាក់ ជំងឺ SARS និងជំងឺគ្រុនបក្សីដែលកើតមានឡើងនៅតំបន់អាស៊ី និងនៅប្រទេសជិតខាងយើងដូចជា ប្រទេសថៃ និងប្រទេសវៀតណាម។ តាមប្រភពអង្គភាពទេសចរណ៍ពិភពលោក បានផ្តល់ពតិមានថា សភាពការណ៍ទេសចរណ៍ឆ្នាំ ២០០៤ មកដល់ខែ កក្កដា ព្រះរាជាណាចក្រកម្ពុជា បានទទួលភ្ញៀវចំនួន ៥២៥.៨៧៩ នាក់ គឺមានការកើនឡើងចំនួន ៤៦.២៨% បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៣។ ក្រសួងនៅតែវាយតម្លៃថា ឆ្នាំ ២០០៤ នេះ ភ្ញៀវទេសចរណ៍នឹងមានចំនួន ១ លាននាក់។

នៅឆ្នាំ ២០០៣ ៨០% នៃទេសចរណ៍ ៦៩៤ លាននាក់ គឺធ្វើដំណើរនៅតំបន់របស់ខ្លួន (៥៥៥ លាននាក់) និង២០% ធ្វើដំណើរទស្សនកិច្ចឆ្ងាយ (Long Land Travel)។ សភាពការណ៍បែបនេះ បានជំរុញឱ្យប្រទេសជាសមាជិក អាស៊ានខិតខំរិះរកមធ្យោបាយ ដើម្បីទាក់ទាញទេសចរណ៍ដែលនៅតំបន់ខ្លួនឱ្យធ្វើទស្សនកិច្ចក្នុងប្រទេសខ្លួន។ ដូចនេះដើម្បីទាក់ទាញភ្ញៀវតំបន់ឱ្យមកទស្សនា ប្រទេសយើងកម្ពុជា ត្រូវរិះរកមធ្យោបាយនិងបានកំណត់នូវយុទ្ធសាស្ត្រ ដូចខាងក្រោម :

១- បន្តកិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន ដែលប្រមុខរាជរដ្ឋាភិបាលអាស៊ាន បានចុះហត្ថលេខានៅទីក្រុងភ្នំពេញ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០២ និង ទទួលឯកភាពដោយរដ្ឋមន្ត្រីទេសចរណ៍អាស៊ានបូក៣ ក្នុងវេទិកាទេសចរណ៍ អាស៊ាន ២០០៣ នៅភ្នំពេញ កាលពីថ្ងៃទី ២០-២៨ មករា ដើម្បីសហប្រតិ បត្តិការទ្វេភាគី ត្រីភាគី និង ពហុភាគី។ ក្នុងនោះប្រទេសជាសមាជិកបាន ឯកភាពធ្វើការលើកលែងទិដ្ឋាការជូនប្រជាពលរដ្ឋទៅវិញទៅមកតាម ការពិភាក្សា ទ្វេភាគី និងពហុភាគី ឱ្យបានជោគជ័យនៅឆ្នាំ ២០០៥។

២- បង្កើន និងធានាសន្តិសុខ សុវត្ថិភាពគ្រប់គ្រាន់ទូទាំងប្រទេសជូនភ្ញៀវទេសចរណ៍

៣- កសាងច្បាប់ និងបទដ្ឋាននានា ដើម្បីគ្រប់គ្រងវិស័យទេសចរណ៍ និង សំដៅធានាគុណភាពដល់សេវាកម្ម និងផលិតផលទេសចរណ៍។

៤- កសាងផែនការថ្នាក់ជាតិ និងថ្នាក់តំបន់ :

- តំបន់ភ្នំពេញ
- តំបន់សៀមរាប

- តំបន់កំពង់សោម (ដោយយកចិត្តទុកដាក់លើការការពារបរិស្ថាន ឆ្នេរ និងសំណង់អាណាធិបតេយ្យ)

- តំបន់ភូមិភាគឥសាន្ត អេកូទេសចរណ៍

- តំបន់ផ្សេងៗទៀតតាមអាទិភាព

- បន្តសហការការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម តំបន់ត្រីកោណមរកតកម្ពុជា-ឡាវ-ថៃ និងតំបន់ កម្ពុជា-ឡាវ-ភូមា-ថៃ។

៥- ទប់ស្កាត់ការកេងប្រវ័ញ្ច និងធ្វើអាជីវកម្មលើផ្លូវភេទកុមារ និងការប្រយុទ្ធ ប្រឆាំងជំងឺអេដស៍ ពេស្យាកម្ម ព្រមទាំងបទឧក្រិដ្ឋកម្មផ្សេងៗ ក្នុងវិស័យ ទេសចរណ៍។

៦- ជំរុញកិច្ចសហការតំបន់អាស៊ានលើវិស័យទេសចរណ៍ និងកិច្ចសហការ អន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងអាស៊ីប៉ាស៊ីហ្វិក (ឧទាហរណ៍ ជប៉ុន ចិន សាធារណរដ្ឋកូរ៉េ ឥណ្ឌា អូស្ត្រាលី ញូវហ្ស៊ីឡែន) ដោយចូលរួមប្រជុំ និងធ្វើជាម្ចាស់ផ្ទះ ដើម្បីបញ្ជាក់ថា កម្ពុជាមានសមត្ថភាព និងលទ្ធភាព។

៧- គាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងយុទ្ធនាការ "ទស្សនាអាស៊ាន" (Visit ASEAN Campaign-VAC) ដូចជា ការចូលរួមតាំងពិពណ៌ជាមួយ ASEAN ។

- ខិតខំពង្រីកកម្មវិធី សិក្សាទីផ្សារ និងការផ្សព្វផ្សាយ ដោយសហការជាមួយដៃគូផ្នែកឯកជន ដូចជាការបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយ ដើម្បីតំរង់ទិសទីផ្សារ និងផ្សព្វផ្សាយមានប្រសិទ្ធិភាពខ្ពស់។

- សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីបង្កើតកុងស៊ុល ជាពិសេស ក្នុងប្រទេសជាទិសដៅទីផ្សារទេសចរណ៍។

៨- ពង្រឹង និងបង្កើនគុណភាពផលិតផលទេសចរណ៍ ដើម្បីប្រកួតទីផ្សារតំបន់ និងពិភពលោកជាមួយដៃគូឯកជន ជាពិសេសការធ្វើឱ្យកញ្ចប់ទស្សនកិច្ច មានតំលៃអាចប្រកួតជាមួយប្រទេសក្នុងតំបន់ (សំបុត្រយន្តហោះ សេវាកម្មស្នាក់នៅ សេវាកម្ម ម្ហូបអាហារ សេវាកម្មមគ្គុទេសក៏ និងសេវាកម្មផ្សេងៗ ទៀត ដែលបំរើឱ្យវិស័យទេសចរណ៏)។

៩- បង្រៀន និងណែនាំកសិករឱ្យចេះផលិតផលិតផលកសិកម្ម សាច់ បន្លែ ផ្លែឈើ និងផ្កាសំរាប់ផ្គត់ផ្គង់ឱ្យឯកជនសំរាប់បំរើទេសចរណ៏ឱ្យមានគុណភាព និងអនាម័យ ដើម្បីកាត់បន្ថយការនាំចូល និងដើម្បីផ្តល់ការងារជូនប្រជាពលរដ្ឋ ដែលរស់នៅតាមជនបទ ក្នុងន័យកាត់បន្ថយភាពក្រីក្រ។ ករណីនេះប្រទេសអាស៊ានបានខិតខំយ៉ាងខ្លាំង ដើម្បីផ្តល់ផលប្រយោជន៏លើវិស័យទេសចរណ៏ជូនដល់ពលរដ្ឋគេវិញ។

១០- បន្តការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីភ្ជាប់ជាមួយសមាជិកអាស៊ានសំរាប់លំហូរទេសចរណ៏ តំបន់តាមមធ្យោបាយដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក និងផ្លូវដែក។ល។ ជាមួយគ្នានេះយើងត្រូវបន្តការសាងសង់ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវស្រុក និងផ្លូវលំ ដើម្បីទេសចរណ៏ អាចធ្វើដំណើរពីរមណីយដ្ឋានមួយទៅ មួយទៀតទៅតាមគំរោងផែនការមេរបស់កម្ពុជា។

១១- សំរួលដល់ការធ្វើដំណើររបស់ទេសចរណ៍ ដោយបន្តការផ្តល់ទិដ្ឋាការពេលមកដល់ (Visa on Arrival) នៅគ្រប់ច្រកព្រំដែនអន្តរជាតិ និងធ្វើអាគារសំរាប់ភ្ញៀវរង់ចាំឱ្យបានគ្រប់កន្លែង។

១២- បន្តជំរុញការលើកទឹកចិត្តដល់ការវិនិយោគជាតិ និងអន្តរជាតិ ដោយផ្អែកលើច្បាប់វិនិយោគ និងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាពិសេស លើការសាងសង់ សាលប្រជុំ និងពិពណ៌ (Convention Center) ។

១៣- ត្រូវធ្វើផែនការលើកកំពស់ការយល់ដឹង ដល់ផ្នែកសាធារណៈ ដល់ប្រជាពលរដ្ឋ និងឯកជនក្នុងការរួមចំណែក ដល់ការអភិវឌ្ឍន៍ទេសចរណ៍មួយ ប្រកបដោយនិរន្តភាព ដោយធ្វើឱ្យភាគីទាំងអស់យល់ថា វិស័យទេសចរណ៍ ជាការងារ និងការរកចំណូលរបស់យើងទាំងអស់គ្នា។

១៤- បន្តអនុវត្តផែនការបណ្តុះបណ្តាលធនធានមនុស្ស (សាធារណៈ និង ឯកជន) ដោយបន្តសហការជាមួយប្រទេសអាស៊ាន អង្គការអន្តរជាតិ (ADB, GMS) លើគ្រប់ផ្នែកដែលបំរើឱ្យទេសចរណ៍។

១៥- បង្កើតសាលាបណ្តុះបណ្តាលទេសចរណ៍ជាតិ និងមជ្ឈមណ្ឌលជាតិទេសចរណ៍ ដើម្បីពង្រឹងសមត្ថភាពមន្ត្រី និងបុគ្គលិកជំនាញដែលរំរើសេវាការងារ ផ្ទាល់ និងប្រយោលជាមួយវិស័យទេសចរណ៍ (មគ្គុទ្ទេសក៏អ្នកគ្រប់គ្រង អ្នកទទួល ភ្ញៀវ អ្នករៀបចំបន្ទប់ ...... ) ។

**សន្និដ្ឋាន**

ចំណុចទាំងនេះ គឺជាយុទ្ធសាស្ត្រដ៏សំខាន់ដែលក្រសួងទេសចរណ៍បាន និងបន្តអនុវត្តសំរាប់ការអភិវឌ្ឍន៍វិស័យទេសចរណ៍ ឱ្យទៅជាក្បាលរទេះភ្លើងសំរាប់ទាញសេដ្ឋកិច្ច និងការប្រកួតប្រជែង ក្នុងតំបន់អាស៊ានប្រកបដោយជោគជ័យខ្ពស់។

ក្រោយពីយើងបានចូលជាសមាជិកអាស៊ាន វិស័យទេសចរណ៍កម្ពុជាបានឈានឡើងដល់ចំណុចអភិវឌ្ឍន៍មួយគួរជាទីមោទនៈ ដោយសារយើងមានកិច្ចសហប្រតិបត្តិការល្អ និងមានការបន្ធូរបន្ថយផ្នែកទិដ្ឋាការ ជាពិសេសរវាងប្រទេសជាសមាជិកអាស៊ាន។ នេះគឺជាផលប៉ះពាល់ដ៏វិជ្ជមានមួយ។ យើងត្រូវខិតខំយកឱកាសដ៏ល្អនេះ ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមា ពីសមាហរណកម្មនេះ។

# កម្ពុជា និងអាស៊ានបូក ៣

**ដោយលោក កេត សុផាន់**

*ប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី*

*និងជាអ្នកស្រាវជ្រាវ វិទ្យាស្ថានខ្មែរដើម្បីសហប្រតិបត្តិការ និងសន្តិភាព*

ក្រុមអាស៊ានបូក បី បានកើតឡើងក្នុងពេលមានវិបត្តិហិរញ្ញវត្ថុអាស៊ីនៅ ឆ្នាំ ១៩៩៧-៩៨។ ក្នុងពេលនោះប្រទេសអាស៊ានទាំងដប់ បានផ្តួចផ្តើមគំនិត ឱ្យមាននូវកិច្ចប្រជុំជាប្រចាំមួយ ថ្នាក់រដ្ឋមន្ត្រី និងថ្នាក់ប្រមុខរដ្ឋាភិបាល ជាមួយសមភាគីរបស់ខ្លួនមកពីប្រទេសជប៉ុន ចិន និងសាធារណរដ្ឋកូរ៉េ។ កិច្ចប្រជុំទាំងនេះរួមមានទាំងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន រដ្ឋមន្ត្រីពាណិជ្ជកម្ម និងរដ្ឋមន្ត្រីហិរញ្ញវត្ថុជាមួយសមភាគីមកពី ប្រទេសបីក្នុងអាស៊ីឦសាន្ត។ លើសពីនោះទៅទៀត ប្រមុខរដ្ឋាភិបាលមកពីប្រទេសទាំង ១៣ (អាស៊ីបូពា៌) បានជួបជុំគ្នាក្នុងកំឡុងពេល កិច្ចប្រជុំកំពូលប្រចាំឆ្នាំរបស់អាស៊ាន។

បច្ចុប្បន្ននេះ អាស៊ីបូពា៌ត្រូវបានចាត់ទុកជាប៉ូលសេដ្ឋកិច្ចនយោបាយដ៏សំខាន់នៅក្នុងពិភពលោក។ ចាប់តាំងពីការធ្វើស្ថាប័ននីយកម្មសំរាប់កិច្ចសហប្រតិបត្តិការរបស់ខ្លួននៅឆ្នាំ ១៩៩៧ មក តំបន់នេះបានបោះជំហានទៅមុខ យ៉ាងលឿនដោយសំរេច

បាននូវជោគជ័យជាបន្តបន្ទាប់ និងធ្វើឱ្យកិច្ចសហប្រតិបត្តិការកាន់តែស៊ីជំរៅ ក្នុងបណ្ដាឆ្នាំកន្លងមក។ ដោយហេតុថា សហប្រតិបត្តិការអាស៊ាន+៣ នេះបានកើតឡើងក្នុងពេលដែលតំបន់អាស៊ីប្រឈមមុខនឹង វិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរ និងផលប៉ះពាល់នៃចរន្ត សាកលភាវូបនីយកម្មនោះ យើងអាចមើលឃើញថា គោលការណ៍ នៃកិច្ចសហប្រតិបត្តិការនេះ បានឈានចេញ ពីការប្ដេជ្ញាចិត្តនយោបាយមួយដ៏ខ្ពង់ខ្ពស់របស់អ្នកដឹកនាំអាស៊ាន+៣ ដែលបានចាក់គ្រោលជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយ សំរាប់សហប្រតិបត្តិការអាស៊ីបូពាបច្ចុប្បន្ន។

កិច្ចប្រជុំនៅឆ្នាំ ១៩៩៧ ក្នុងពេលមានវិបត្តិហិរញ្ញវត្ថុ បានផ្ដោតការពិភាក្សាលើទំនាក់ទំនងជាមិត្តភាព និងភាពជាបងប្អូនជាមួយប្រទេសចិន និង យន្តការចរចាផ្សេងៗទៀត។ កិច្ចប្រជុំក្រោយមកទៀតផ្ដោតលើវិបត្តិហិរញ្ញវត្ថុដែលកំពុងបន្ត និងផលវិបាកនៃវិបត្តិនេះ ព្រមទាំងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់អាស៊ាន។ ពេលនោះ ប្រទេសជប៉ុនបានប្រកាសនូវកញ្ចប់ជំនួយ ហិរញ្ញវត្ថុយ៉ាងច្រើនសន្ធឹកសន្ធាប់ ព្រមទាំងកម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសមានតំលៃសាមសិបពាន់លានដុល្លា សំរាប់កំចី និងជំនួយឥតសំណង ដែលមានឈ្មោះថា "ផែនការ Miyazawa"។

ក្រុមចក្ខុវិស័យអាស៊ីបូពាត្រូវបានបង្កើតឡើង នៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន+៣ នៅហាណូយឆ្នាំ ១៩៩៨។ សេចក្ដីថ្លែងការណ៍រួមមួយ ស្ដីពីអនាគតអាស៊ីបូពាត្រូវបានប្រកាសឡើង ដែលក្នុងនោះប្រទេសទាំងបីបានសន្យា សហប្រតិបត្តិការ លើផ្នែកសេដ្ឋកិច្ចនិងសង្គម នយោបាយនិងសន្តិសុខ ដើម្បីបង្កើនកំណើនតំបន់ និងបង្កើនសហប្រតិបត្តិការលើផ្នែករូបិយវត្ថុ និងហិរញ្ញវត្ថុ និងពង្រឹងការសំរបសំរួល និងកិច្ចសហ-

ប្រតិបត្តិការជាមួយអង្គការតំបន់ និងអន្តរជាតិផ្សេងៗទៀតដូចជា UN, WTO, APEC, ASEM, ARF ។

នៅក្នុងកិច្ចប្រជុំកំពូលនៅឆ្នាំ ២000 មេដឹកនាំអាស៊ានបានដាក់ចេញ នូវគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន សំដៅធ្វើសហប្រតិបត្តិការមួយដែល ប្រទេសមានការអភិវឌ្ឍន៍ច្រើន ជួយដល់ប្រទេសដែលមានការអភិវឌ្ឍតិចទៅលើវិស័យដូចជា អប់រំជំនាញ និងការបណ្តុះបណ្តាល ។

ផ្នែកលើសមិទ្ធផលសេដ្ឋកិច្ច និងនយោបាយរបស់អាស៊ាន+៣ សហប្រតិបត្តិការនេះកាន់តែមានទំងន់យុទ្ធសាស្ត្រ និងនយោបាយបន្ថែមទៀតក្នុង ពេលដែលអ្នកដឹកនាំអាស៊ាន បានចាប់ផ្តើមធ្វើសហប្រតិបត្តិការ ក្រោមបដា "សហប្រតិបត្តិការអាស៊ីបូព៌ា" ដែលត្រូវបានអនុម័តនៅឆ្នាំ ១៩៩៩ ដោយបាន ដាក់ចេញ នូវទស្សនៈនិងគោលដៅយុទ្ធសាស្ត្រនៃសហប្រតិបត្តិការអាស៊ាន+៣ ក៏ដូចជា សហប្រតិបត្តិការអាស៊ីបូព៌ាទាំងមូល ។

នៅក្នុងសម័យប្រជុំកំពូលអាស៊ាន+៣ ចុងក្រោយនៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ឆ្នាំ ២00៣ ថ្នាក់ដឹកនាំបណ្តាប្រទេសនេះបានគូសបញ្ជាក់ឡើង វិញថាសហប្រតិបត្តិការអាចនឹងពង្រឹងបន្ថែមទៀត តាមរយៈសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ដើម្បីលើកស្ទួយភាពជាដៃគូរបស់អាស៊ាន+៣។ សហប្រតិបត្តិការអាស៊ាន+៣ នាពេលបច្ចុប្បន្នកំពុងបន្តគ្របដណ្តប់ ជាចម្បងទៅលើវិស័យនយោបាយ សន្តិសុខសេដ្ឋកិច្ច និងសហប្រតិបត្តិការផ្សេងទៀតដែល មានអត្ថប្រយោជន៍ ។

ព្រឹត្តការណ៍មួយដែលគួរឱ្យកត់សំគាល់នោះគឺ ប្រទេសចិនបានចូលជាភាគីនៃសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការអាស៊ីអគ្នេយ៍ ព្រមទាំង បានសន្យាថានឹងសំរេចឱ្យបាននូវតំបន់ពាណិជ្ជកម្មសេរីអាស៊ាន + ចិន នៅឆ្នាំ ២០១០ ។

ទោះបីជាយ៉ាងណាក៏ដោយសហប្រតិបត្តិការនៅមានបញ្ហាប្រឈម មុខជាច្រើនដែលត្រូវដោះស្រាយ :

- គំលាតនៃការអភិវឌ្ឍន៍នៅក្នុងតំបន់អាស៊ាន និងរវាងអាស៊ាន និងប្រទេស + ៣។ កត្តាសំខាន់នោះគឺត្រូវបែងចែកការអភិវឌ្ឍន៍រវាងអាស៊ាន និងបណ្តាប្រទេសកំពុងអភិវឌ្ឍក្នុងអាស៊ាន ពោលគឺប្រទេសក្រីក្រទាំងនេះគួរត្រូវបានលើកទឹកចិត្ត ជាពិសេស តាមរយៈគំរោងកម្មវិធីគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន និងផែនការអាស៊ានជាច្រើនទៀត។
- ការប្រឈមមុខនឹងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម និងបញ្ហាឆ្លងដែននានាដូចជាការជួញដូរមនុស្ស និងការរត់ពន្ធគ្រឿងញៀន ជាពិសេសចាប់តាំងពីព្រឹត្តិការណ៍ថ្ងៃទី១១ កញ្ញា មកដែលកំពុងតែគំរាមកំហែងតំបន់ទាំងមូល។
- សន្តិសុខខាងផ្នែកថាមពល ក្នុងខណៈពេលដែលតំលៃប្រេងឥន្ធនៈបន្តកើនឡើងខ្ពស់។ ហើយផលប៉ះពាល់នេះ បានជះឥទ្ធិពលខ្លាំងមកលើប្រទេសក្រីក្រ។
- ទិដ្ឋភាពប្រវត្តិសាស្ត្រនៃប្រទេស+៣ ដែលមានផលប៉ះពាល់ទៅលើកិច្ចសហប្រតិបត្តិការអាស៊ីបូពា៌។

- វិបត្តិឧបទ្វីបកូរ៉េ និងច្រកតៃវ៉ាន់។

ឆ្លងតាមអ្វីដែលខ្ញុំបានលើកឡើងខាងលើ បានបង្ហាញឱ្យឃើញទាំងចំណុចជាសក្តានុពល និងអវិជ្ជមាន នៅក្នុងកិច្ចសហប្រតិបត្តិការអាស៊ាន+៣ នេះ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ អាស៊ានគួរប្រកាន់យកនូវជំហររួមមួយ ដើម្បីកំណត់យុទ្ធសាស្ត្រសំខាន់ៗរបស់ខ្លួន ពោលគឺអាស៊ានត្រូវតែបន្តស្ថិតនៅក្នុង លំដាប់ដឹកនាំជួរមុខនៅក្នុងដំណើរការអាស៊ាន+៣។ ការប្រកាន់ជំហររួមរបស់អាស៊ាននេះ អាចនឹងបានជាសំលេងមួយដែលកាន់តែមានទំងន់ រួមចំណែកដល់ការដោះស្រាយវិបត្តិនៅក្នុងតំបន់ ក៏ដូចជាអន្តរជាតិ។ ក្នុងន័យនេះ អាស៊ានអាចដឹកនាំកិច្ចប្រជុំកំពូលអាស៊ីបូព៌ា តាមរូបមន្តសហប្រធាន។

ដោយឡែកក្នុងនាមប្រទេសកម្ពុជា ជាសមាជិកម្នាក់ក្នុងអាស៊ានកម្ពុជា ក៏នឹងទទួលបានផលប្រយោជន៍យ៉ាងច្រើនពីកិច្ចសហប្រតិបត្តិការនេះដែរ ដូចជា :

- សំលេងរបស់កម្ពុជានៅក្នុងសហគមន៍អន្តរជាតិកាន់តែមានទំងន់។
- កំណើនទេសចរណ៍មកកម្ពុជាបន្ថែមទៀត ដោយកម្ពុជាមានសក្តានុពលសំបូរបែបផ្នែកទេសចរណ៍បុរាណ វត្ថុវិទ្យា និងធម្មជាតិ។
- ការបណ្តុះបណ្តាលធនធានមនុស្ស ដែលត្រូវបានផ្តល់ជូនពីប្រទេសអាស៊ាន ក៏ដូចជាប្រទេស+៣។
- កម្ពុជាអាចនឹងទាក់ទាញវិនិយោគមកកម្ពុជាបន្ថែមទៀត។
- ការផ្ទេរបច្ចេកវិទ្យា។

ជាសន្និដ្ឋាន ដោយផ្អែកលើពេលវេលា នៃកំណើតកិច្ចសហប្រតិបត្តិការអាស៊ាន+៣ និងសមិទ្ធផលដែលសំរេចបានកន្លងមក សហប្រតិបត្តិការនេះគឺជាដំណើរការដ៏មានសារៈសំខាន់មិនអាចខ្វះបាន និងស្របតាមចរន្តនៃតំបន់និយម និងសាកលភាវូបនីយកម្ម ដើម្បីសំរេចឱ្យបាននូវគោលគំនិតនៃសហគមន៍អាស៊ីបូព៌ានៅក្នុងអនាគត។ សារៈសំខាន់នេះ តែងតែត្រូវបានអះអាងដោយថ្នាក់ដឹកនាំ អាស៊ាន+៣ នៅក្នុងរាល់កិច្ចប្រជុំនីមួយៗ។ ដោយឡែកកម្ពុជាខ្លួនឯង ត្រូវតែខិតខំពង្រឹងសមត្ថភាពរបស់ខ្លួនថែមទៀត ដើម្បីអាចទទួលបានផលប្រយោជន៍ពីចរន្ត នៃតំបន់និយមនេះនិយាយជារួម និងដោយឡែកសហប្រតិបត្តិការអាស៊ាន + ៣។

# កម្ពុជា និង អាស៊ាន: សហប្រតិបត្តិការផ្នែកនគរបាល

**ដោយឯកឧត្តមឧត្តមសេនីយ៍ឯក ខៀវ សុភ័ក្រ**

*ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី អគ្គលេខាធិការរងក្រសួងមហាផ្ទៃ និងអាជ្ញាធរជាតិ*
*ប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ខ្ញុំរីករាយខ្លាំងណាស់ ដោយបានមកចូលរួមជាមួយអស់លោកនៅទីនេះ ក្នុងថ្ងៃនេះ ដើម្បីពិនិត្យមើលឡើងវិញ ក៏ដូចជាប្រារព្ធ សមាជិកភាព ៥ ឆ្នាំរបស់ប្រទេសកម្ពុជាក្នុងអាស៊ាន។ ឯកឧត្តម លោក លោកស្រី ពិតជាយល់ស្របតាមខ្ញុំ ថា អាស៊ានបានពង្រីកខ្លួនពីអង្គការតូចមួយ ចាប់តាំងពីឆ្នាំ ១៩៦៧ ទៅអង្គការតំបន់មួយដែលបានបង្កើតឡើងយ៉ាងល្អ ដែលជំរុញស្មារតីនៃសមភាព និងភាពជាដៃគូឆ្ពោះទៅរកសន្តិភាព ភាពរីកចំរើន និងវិបុលសុខទាំងនៅក្នុងតំបន់ និងក្នុងពិភពលោក។

ដោយមានការអនុញ្ញាតពីអស់លោក ដែលឱ្យខ្ញុំរំលឹកពីការខិតខំរបស់យើងជាផ្នែកមួយនៃអាស៊ាន អស់លោកនៅតែរំលឹកឡើងវិញ នៅខែកក្កដា ឆ្នាំ ១៩៩៣ ពេលដែលប្រទេសកម្ពុជាបានចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានលើកទី ២៦ ក្នុងនាមជាភ្ញៀវផ្លូវការជាលើកដំបូង។ នៅឆ្នាំបន្ទាប់មកទៀត ប្រទេសកម្ពុជាបានចូលរួមម្តងទៀត

ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ក្នុងនាមជាភ្ញៀវ ហើយនៅ ខែតុលា ឆ្នាំ១៩៩៥ ប្រទេសកម្ពុជា បានដាក់ពាក្យសុំឋានៈជាអ្នកសង្កេតការណ៍។ ពាក្យសុំធ្វើជាអ្នកសង្កេតការណ៍ របស់កម្ពុជាបានត្រូវយល់ព្រម បន្ទាប់ពីប្រទេសរបស់យើងបានយល់ព្រមទទួលយកសន្ធិសញ្ញានៃមិត្តភាព និងសហប្រតិបត្តិការ។ ការប្រឹងប្រែង និងការតាំងចិត្ត ដោយឥតនឿយហត់របស់រដ្ឋាភិបាលកម្ពុជាដើម្បី កែលម្អសេដ្ឋកិច្ច និងកែទម្រង់នយោបាយ តាមរយៈការលើកជំហរសេដ្ឋកិច្ចទីផ្សារ និងប្រជាធិបតេយ្យនីយកម្ម។ នៅទីបញ្ចប់ ប្រទេសកម្ពុជាបានត្រូវគេទទួលឱ្យ ចូលជាសមាជិកគ្រួសារនៅក្នុង អង្គការអាស៊ាន នៅថ្ងៃទី៣០ មេសា ១៩៩៩។ នៅឆ្នាំបន្តបន្ទាប់មក យើងបាន ធ្វើជាម្ចាស់ផ្ទះ ដោយរៀបចំកិច្ចប្រជុំអាស៊ានដ៏មានសារៈសំខាន់ជាច្រើន រួមមានកិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ទិវាទេសចរណ៍អាស៊ាន កិច្ចប្រជុំអង្គការអន្តរសភាអាស៊ាន (AIPO) និង ASEANAPOL ជាដើម។

ដូចយើងបានដឹងហើយ សមាជិកភាពនៅក្នុងអង្គការណាមួយ ក៏ដោយ មិនត្រឹមតែតម្រូវឱ្យយើងមានការតាំងចិត្ត ខិតខំប្រឹងប្រែងប៉ុណ្ណោះទេ។ ក៏ប៉ុន្តែតម្រូវឱ្យយើងទទួលយកនូវការចាំបាច់នានា ដូចជាច្បាប់ នីតិវិធី និងសហប្រតិបត្តិការពហុភាគី។ នៅក្នុងន័យនេះ និងក្នុងនាមជាសមាជិកថ្មីជាងគេ នៅក្នុងអាស៊ាន កម្ពុជាបានជំនះរាល់ការប្រឈមធំៗ ដើម្បីចែករំលែកជាមួយអាស៊ាន និងរៀនពីការអនុវត្តន៍ និងឧទាហរណ៍ល្អបំផុតរបស់អាស៊ាន។ ទោះបីជារយៈពេល ៥ ឆ្នាំ ហាក់ដូចជាខ្លីសម្រាប់យើង ក៏ប៉ុន្តែ យើងបានទទួលជោគជ័យធំធេងខ្លះ នៅក្នុងអង្គការនេះ ឬនៅក្នុងរដ្ឋាភិបាលតាមរយៈសហប្រតិបត្តិការទ្វេភាគី ពហុភាគី ផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម ទេសចរណ៍ ការផ្លាស់ប្តូរវប្បធម៌ និង សន្តិសុខ ជាដើម។

ជាថ្មីម្តងទៀត ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់ អំពីសមាជិកភាពរបស់កម្ពុជាក្នុងអាស៊ាននៅក្នុងបរិបទសន្តិសុខ ជាផ្នែកមួយដែលខ្ញុំបានយល់ដឹង ច្បាស់លាស់បំផុត ចាប់តាំងពីបានកើត អាស៊ានតែងតែគូសបញ្ជាក់នូវស្មារតីនៃ សមធម៌ និងភាពជាដៃគូឆ្ពោះទៅរកសន្តិភាព និងការមិនជ្រៀតជ្រែកដែលមាន ន័យថា សមាជិកភាព នៅក្នុងអាស៊ាន ពង្រឹងដល់សន្តិសុខទាំងមូល ជាពិសេសតាមព្រំដែននៃប្រទេសនីមួយៗ។ ដើម្បីពង្រឹងសន្តិសុខ និងសុវត្ថិភាពសម្រាប់ ប្រជាជនអាស៊ាន ស្ថាប័នអនុវត្តន៍ច្បាប់នៃរដ្ឋជាសមាជិកបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការនាំប្រទេសនីមួយៗ ចូលទៅក្នុងការចរចាតាមរយៈសន្និសីទ សិក្ខាសាលា ការបណ្តុះបណ្តាល និងកិច្ចប្រជុំនានាដែលអនុញ្ញាតឱ្យស្ថាប័ននីមួយៗ បានផ្លាស់ប្តូរបទពិសោធន៍គ្នា និងបង្កើតជាច្រកសម្រាប់ធ្វើទំនាក់ទំនងគ្នា ជារៀងរាល់ថ្ងៃ។ ឧទាហរណ៍ដ៏ល្អមួយ នៃសហប្រតិបត្តិការទៅវិញទៅមកនោះគឺ ការប្រយុទ្ធប្រឆាំងនឹងក្រុម*ជេរអាយ* (JI)។ ស្ថាប័ននីមួយៗក្នុតំបន់បានសហការ គ្នាទៅវិញទៅមក ដោយចែករំលែកពត៌មាន និងការស៊ើបការណ៍ដែលនាំទៅរកការចាប់ខ្លួន និងការបង្អាក់សកម្មភាពរបស់សមាជិក នៃអង្គការភេរវកម្មនេះ។

ASEANAPOL គឺជាវេទិកាមួយ ដែលនគរបាលជាតិកម្ពុជាបានស្ថិតនៅជាផ្នែកមួយ។ វេទិកាបាលផ្តល់ឱកាសសម្រាប់ស្ថាប័នអនុវត្តន៍ច្បាប់ នៃរដ្ឋជាសមាជិកអាស៊ានក្នុងការពិនិត្យមើលឡើងវិញនូវសហប្រតិបត្តិការរបស់ខ្លួន លើកឡើងពីសភាពការណ៍ឧក្រិដ្ឋកម្ម ដែលប៉ះពាល់ដល់តំបន់ និងពិភពលោក ហើយដើម្បីលើកយុទ្ធសាស្ត្ររួមប្រកបដោយប្រសិទ្ធិភាព និងល្អប្រសើរជាងមុន ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មទាំងនោះ។ វេទិកាបានពិភាក្សាពីបញ្ហានៃឧក្រិដ្ឋកម្មឆ្លងដែន អំពើភេរវកម្ម

ថ្នាំញៀន ការរត់ពន្ធអាវុធ ការជួញដូរមនុស្ស ចោរសមុទ្រ ឧក្រិដ្ឋកម្ម ការលាងលុយកខ្វក់ និងឧក្រិដ្ឋកម្មសេដ្ឋកិច្ចជាដើម។ ទម្រង់ នៃការអនុវត្តន៍នេះ មិនត្រឹមតែធ្វើឱ្យស្ថាប័នអនុវត្តច្បាប់របស់យើង ក្លាយជាអង្គការដែលទទួលពតិមានគ្រប់ជ្រុងជ្រោយប៉ុណ្ណោះទេ តែថែមទាំងពង្រីកបណ្តាញប្រតិបត្តិការរបស់យើង ដែលជាលក្ខណៈសម្បត្តិចាំបាច់ក្នុងការប្រយុទ្ធ ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែននៅក្នុងយុគសម័យទំនើបនេះ។

ការកើតឡើងនៃឧក្រិដ្ឋកម្មឆ្លងដែន រួមមានភេរវកម្មមិនបានគេចពីការយកចិត្តទុកដាក់របស់ស្ថាប័នអនុវត្តច្បាប់ នៃរដ្ឋជាសមាជិកអាស៊ាននោះទេ។ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ ស្តីអំពី ឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) បានបង្កើតឡើងដើម្បីពិភាក្សាបញ្ហាឧក្រិដ្ឋកម្មឆ្លងដែនជារៀងរាល់ឆ្នាំ។ តាមរយៈកិច្ចប្រជុំនេះ ស្ថាប័ន អនុវត្តច្បាប់របស់យើង បានដឹងយ៉ាងច្រើនពីសារជាតិ និងសភាពការណ៍នៃឧក្រិដ្ឋកម្ម ឆ្លងដែនដែលធ្វើឱ្យយើងមានលទ្ធភាពរៀបចំខ្លួនឱ្យបានល្អប្រសើរ ដើម្បីទប់ទល់នឹងវា។ កិច្ចប្រជុំបែបនេះធ្វើឱ្យយើងមានឱកាសលើកកំពស់ "*តម្រូវការចង់ ដឹង*" ទៅរក "*តម្រូវការចែករំលែក*" ការសំងាត់រវាងស្ថាប័ននានាផងដែរ។

ជាទីបញ្ចប់ ខ្ញុំសូមបញ្ជាក់ថា យើងទទួលបានចំណេញច្រើនណាស់ ពីការចូលអាស៊ាន ក្នុងរយៈពេល ៥ ឆ្នាំ នេះ ជាពិសេស សហប្រតិបត្តិការផ្នែកនគរបាល។ យើងបានចូលរួមប្រជុំ និងអនុវត្តការងាររួមគ្នា ក្នុងតំបន់ជាច្រើន នគរបាលជាតិកម្ពុជាបានបញ្ជូនមន្ត្រីរបស់ខ្លួនមួយចំនួនធំទៅ ចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាល ដែលបានផ្តល់ដោយស្ថាប័នអនុវត្តច្បាប់នៃរដ្ឋជាសមាជិកអាស៊ាន។ ជំនាញ និងបទពិសោធន៍ដែលពួកគេបានទទួលពីវគ្គបណ្តុះបណ្តាល ធ្វើឱ្យពួកគេអាចឆ្លើយតបបានភ្លាមៗ ទៅនឹងការ

ប្រែប្រួលដ៏រហ័ស និងភាពស្មុគ្រស្មាញ នៃឧក្រិដ្ឋកម្មឆ្លងដែន និងសភាពការណ៍នៃឧក្រិដ្ឋកម្ម។

ខ្ញុំសូមដកស្រង់ទស្សនៈនៅក្នុង ទស្សនាទានអាស៊ានឆ្នាំ ២០២០ ដែលបានប្រកាសដោយប្រមុខរដ្ឋ/ប្រមុខរដ្ឋាភិបាលនៃសមាគមប្រជាជាតិអាស៊ី អាគ្នេយ៍ នៅក្នុងក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ីថា "ទស្សនាទានរបស់អាស៊ាន គឺជាប្រជាជាតិអាស៊ីអាគ្នេយ៍រួបរួមគ្នា សំលឹងទៅមុខរស់នៅដោយសន្តិភាព ស្ថេរភាព និងវិបុលសុខចងបាច់គ្នាជាដៃគូ នៅក្នុងការអភិវឌ្ឍន៍ជាថាមពល និងក្នុងសហគម ដែលនាំគ្នាថែទាំសង្គម"។ ការធ្វើឱ្យសម្រេចបាននូវគោលដៅសំខាន់បួន ដែលបានចែង គឺជាគំនិតរបស់អាស៊ាន ហើយកម្ពុជាចង់ស្ថិតនៅជាផ្នែកមួយនៃក្រុមនេះ ដើម្បីអនុវត្តន៍ និងធ្វើឱ្យទស្សនាទាននេះលេចចេញជារូបរាង។

ការដែលនិយាយបែបនេះ គឺជាភាពជូរចត់ចំពោះយើង ក្នុងនាមជាសមាជិកថ្មីរបស់អាស៊ាន និងជាប្រទេសដែលឆ្លងកាត់សង្គ្រាម និងភាពវឹកវរជាច្រើន ទសវត្សរ៍ យើងនៅមានបន្ទុក និងឧបសគ្គជាច្រើននៅចំពោះមុខយើង ក្នុងការព្យាយាមឱ្យក្លាយជាដៃគូតំបន់ដ៏ល្អ ជាមួយមិត្តភ័ក្តអាស៊ីរបស់យើង ដើម្បីធ្វើឱ្យសម្រេចទស្សនាទានអាស៊ានឆ្នាំ ២០២០។ ទោះជាយ៉ាងនេះក៏ដោយ ខ្ញុំសូមសង្កត់ធ្ងន់លើការតាំងចិត្ត និងបំណងប្រាថ្នាចំពោះអាស៊ាននៅតែខ្លាំងក្លា។ ជាមួយការគាំទ្រ និងជំនួយពីសមាជិកអាស៊ានចាស់ យើងអាចសម្រេចបាននូវការរំពឹងទុករបស់យើង ចំពោះអនាគតត្រចះត្រចង់របស់អាស៊ាន។

# កម្ពុជា និង អាស៊ាន ៥ ឆ្នាំ : ការអភិវឌ្ឍន៍វិស័យឥណទានជនបទនៅកម្ពុជា

**ដោយឯកឧត្តម សុន គន្ធរ**

*ប្រធានអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*

ថ្ងៃនេះ ទូលបង្គំខ្ញុំ សូមសំដែងនូវបីតិសោមនស្ស ដោយមានកិត្តិយសបាន ទទួលការអញ្ជើញចូលរួម ជាវាគ្មិនសម័យប្រជុំទី ៤, ស្តីពី កម្ពុជា និងទស្សនវិស័យរបស់ អាស៊ានក្នុងឆ្នាំ ២០២០ : សហគមន៍សន្តិសុខសេដ្ឋកិច្ច និងវប្បធមិសង្គម នៅក្នុង សន្និសីទជាតិដ៏មានសារៈសំខាន់នេះ ។

ប្រទេសកម្ពុជា មានសេដ្ឋកិច្ចស្ថិតក្នុងកម្រិតប្រទេសកំពុងអភិវឌ្ឍន៍ ទទួលបាន ភាពអនុគ្រោះទីផ្សារពីបណ្តាប្រទេសជាច្រើន ជាពិសេសលើប្រព័ន្ធកូតាក្រោម កិច្ចព្រម ព្រៀងសំលៀកបំពាក់ វាយនភណ្ឌហើយដែលនឹងត្រូវបញ្ចប់ នៅចុងឆ្នាំ ២០០៤ នេះ សេដ្ឋកិច្ចកម្ពុជានឹងត្រូវប្រឈមមុខនឹងបញ្ហា ប្រកួតប្រជែងក្នុងតំបន់ ក្នុងតំបន់ក្របខ័ណ្ឌ AFTA ផង និងនៅក្នុង WTO ផង ព្រមទាំងបញ្ហាមួយចំនួន ទៀតដែលនឹងកើត ឡើងនៅពេលអនាគត ។

ក្រៅអំពីវិស័យទេសចរណ៍ កសិកម្មជាវិស័យមួយដែលមានអាទិភាព ចំបង ក្នុងកំណើនសេដ្ឋកិច្ច ជាពិសេសក្នុងផ្នែកកែច្នៃផលិតផលកសិកម្ម។ បញ្ហាចោទ ចំពោះវិស័យនេះគឺ កង្វះដើមទុន និងបច្ចេកទេសដាំដុះទំនើប។ អនុវត្តន៍តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលបន្តលើស្ទួយវិស័យឥណទានជនបទ យើងមានភារកិច្ចផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាកសិករក្រីក្រ ដោយផ្តល់ការឱ្យ ខ្ចីដើមទុនយកការប្រាក់ទាបសមរម្យ និងគាំទ្រវិស័យសហគ្រាសខ្នាតតូច និងមធ្យមព្រមទាំងជំរុញចលនាភូមិមួយផលិតផលមួយផង។

ជាមួយនឹងជោគជ័យដែលកម្ពុជាយើងទទួលបានកន្លងមក ក្នុងនាមជា សមាជិកពៅគេនៃសមាគមអាស៊ាន យើងនៅមានភារកិច្ចរាប់មិនអស់ជាច្រើនទៀត ដែលត្រូវពុះពារ និងប្រឈមដើម្បីជាប្រយោជន៍សំរាប់ប្រជាជាតិយើង។ ជាបន្តទៅនេះ ទូលបង្គំខ្ញុំសូមចែកបទអន្តរាគមន៍នេះជាពីរផ្នែកគឺ : (១)- សមិទ្ធផលទទួលបានកន្លងមក និង (២)-ទស្សនវិស័យក្នុងឆ្នាំ ២០២០ ជាពិសេសលើវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

## ១. សមិទ្ធផលទទួលបានកន្លងមក :

ទន្ទឹមនឹងជោគជ័យដែលរាជរដ្ឋាភិបាល ទទួលបានលើគ្រប់វិស័យក្នុង អាណត្តិមុនៗ ក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ សេវាមីក្រូហិរញ្ញវត្ថុបាន ចូលជ្រៅទៅក្នុងតំបន់ជនបទ ហើយដើរតួជាសំខាន់ក្នុងការចូលរួមដោះស្រាយ រកការងារធ្វើសម្រាប់ប្រជាជនក្រីក្រ ជួយពួកគាត់ឱ្យចេះធ្វើអាជីវកម្ម ដើម្បីបង្កើនចំណូលគ្រួសារ។ ជាមួយនឹងការផ្តល់ឥណទានដោយអត្រាការប្រាក់ទាបជាងពេលមុន ដើម្បីគាំទ្រការប្រកប របរប្រចាំថ្ងៃ សេវាមីក្រូហិរញ្ញវត្ថុនៅបានជួយប្រជាជនក្រីក្រជនបទ ឱ្យយល់ដឹងបាន ពី

អត្ថប្រយោជន៍នៃការសន្សំប្រាក់ ក្នុងប្រព័ន្ធធនាគារ ដូចជាការដាក់ផ្ញើប្រាក់សន្សំ នៅតាមស្ថាប័នមីក្រូហិរញ្ញវត្ថុ នានាជាដើម ។

ជាឧទាហរណ៍ជាក់ស្តែង សេវាមីក្រូហិរញ្ញវត្ថុបានជួយលើកកំពស់ជីវភាពប្រជាជនបានមួយកម្រិតនៅតាមជនបទដាច់ស្រយាលក្នុងទូទាំងប្រទេស ទោះបី មិនទាន់បានជាទីពេញចិត្តយ៉ាងណាក៏ដោយ ជាពិសេសតាមតំបន់ព្រំដែន ភាគពាយព្យនៃប្រទេសដែលជាអតីតសមរភូមិប្រយុទ្ធ ធ្វើឱ្យតំបន់ទាំងនោះ ប្រែក្លាយទៅជាតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចដ៏ឆាប់រហ័ស ជាមួយនឹងសក្តានុពល សេដ្ឋកិច្ចដែលមានស្រាប់ ។ ជីវភាពរបស់ប្រជាជននៅតំបន់ទាំងនោះបាន ប្រែប្រួលជាវិជ្ជមានគួរឱ្យកត់សំគាល់ ក្នុងពេលវេលាមួយដ៏ខ្លី ។ សំរាប់ទូទាំងប្រទេស ទុនឥណទានសរុបគិតតាំងពីថ្ងៃដំបូង ដែលបានផ្តល់ដល់ប្រជាកសិករ និងប្រជាជននៅជនបទមកដល់ថ្ងៃនេះកើនដល់ ៨០ លានដុល្លារអាមេរិច ។

ប្រការដែលទូលបង្គំខ្ញុំ លើកឡើងខាងលើថា មិនទាន់បានជាទីពេញចិត្តនៅឡើយនោះ គឺស្ថិតនៅត្រង់ថា ក្រៅពីសេវារបស់ប្រតិបត្តិការឥណទានតូចតាច មានប្រាក់បុរេប្រទាន នៃប្រព័ន្ធធនាគារពាណិជ្ជសរុបតែ ៦% ប៉ុណ្ណោះដែលផ្តល់ទៅឱ្យវិស័យកសិកម្ម ឬផ្តល់ទៅឱ្យបណ្តាសកម្មភាពពាក់ព័ន្ធ ជាពិសេសគឺការឱ្យខ្ចីចងការជាប្រាក់ដុល្លារអាមេរិចសំរាប់រយៈពេលខ្លី ។ ជាងនេះទៅទៀត ចលនាសន្សំប្រាក់ក្នុងប្រព័ន្ធធនាគារ ទើបតែបានរីកចំរើនមួយកំរិតតូច គឺកេណ្ឌ ប្រមូលបានប្រមាណតែ ៥% នៃផលប័ត្រឥណទាន (Loan Portfolio) សរុបតែប៉ុណ្ណោះ ។ ពិនិត្យលើក្របខ័ណ្ឌតំបន់នៅមានប្រជាជនរស់នៅក្នុងប្រទេសសមាជិកអាស៊ានច្រើនរយពាន់នាក់ ទៀតត្រូវការចាំបាច់សេវាមីក្រូឥណទាន ។ ដោយឡែកនៅកម្ពុជា តំរូវការទុនឥណទាន នៅជនបទមានប្រមាណ ១០០ លានដុល្លារអាមេរិចទៀតសំរាប់ ៨០% គ្រួសារក្រីក្រនៅជនបទ ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏យើងមានមោទនភាព ដោយមាន ច្បាប់ សំរាប់ប្រព័ន្ធធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ។

យើងពិនិត្យឃើញទាំងអស់គ្នាថា សេវាមីក្រូហិរញ្ញវត្ថុជនបទមានការប្រទាក់គ្នាយ៉ាងជិតស្និទ្ធជាមួយនឹងសេវារបស់សហគ្រាសខ្នាតតូច និងមធ្យម ហើយមានទំនាក់ទំនងគ្នា រហូតដល់វិស័យកសិ-ឧស្សាហកម្មទៀត ហើយនេះជាទំនាក់ទំនងដែលមិនអាចមើលរំលងបានឡើយ។

## ២. ទស្សនវិស័យក្នុងឆ្នាំ ២០២០

ជាការពិតណាស់ ការព្យាករណ៍សំរាប់រយៈពេលវែងប្រកបដោយ លក្ខណៈវិទ្យាសាស្ត្រមិនជាការងារងាយស្រួលទេ។ ចក្ខុវិស័យសំរាប់រយៈពេល ១៥ ឆ្នាំខាងមុខនេះ ទាមទារឱ្យមានភាពប្រាកដនិយម។ ជាទិសដៅសំរាប់រយៈពេល ១៥ ឆ្នាំខាងមុខ រាជរដ្ឋាភិបាលកម្ពុជា មានផែនការកាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាល ពោលគឺអត្រាអ្នកស្ថិតក្រោមបន្ទាត់ក្រីក្រ នឹងថយចុះពី ៣៦% មកក្រោម២០%។ ដែលស្របតាមគោលដៅអភិវឌ្ឍន៍ សហសវត្សរ៍តទៅនេះ ទូលបង្គំខ្ញុំ សូមអនុញ្ញាតលើកយកតែចំណុចសំខាន់មួយចំនួនមកធ្វើការពិនិត្យពិចារណាដូចខាង ក្រោម :

*ក.ទិដ្ឋភាពផ្នែកច្បាប់*-ច្រកចូលធំបំផុតរបស់ឥណទានជនបទ ដើម្បីទៅឱ្យដល់ដៃប្រជាកសិករគឺតាមរយៈសមាគមន៍ សហគមន៍ សហភាពឥណទាននានា ដែលបំរើឱ្យផលប្រយោជន៍ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ។ ប្រព័ន្ធច្បាប់ ស្តីពី សមាគមន៍ សហគមន៍ សហភាពឥណទាន គឺសំរាប់ធានាភាពកក់ក្តៅ ដល់សមា-ជិកសមាគម សហគមន៍ សហភាពទាំងមូលមិនទាន់មាននៅឡើយទេ។ តាមរយៈសមាគម សហគមន៍

សមាជិក អាចទទួលយកបានឥណទាន ដែលមានការប្រាក់ទាប ជាងសព្វថ្ងៃ។ លើសពីនេះ ការឱ្យខ្ចីតាមរយៈ សមាគមន៍ សហគមន៍ ធានាបាន ភាពជឿទុកចិត្ត បន្ថយបានហានិភ័យឥណទាន និងមិនទាមទារត្រូវតែមាន វត្ថុកក់បញ្ចាំនោះឡើយ។ សូមជំរាបជាពតិមានថា អត្រាការប្រាក់ឱ្យខ្ចីអនុវត្តនៅប្រទេសជា សមាជិកអាស៊ានជិតខាងយើងមានកំរិតទាប ដែលអាចជួយប្រជាពលរដ្ឋគេ មានលទ្ធភាពរក្សាចំណូលបានមួយចំណែកសមរម្យ។ ឧទាហរណ៏ ប្រទេសឡាវ អត្រាការប្រាក់ខ្ពស់បំផុតគឺ ១៦% ក្នុង មួយឆ្នាំ ប្រទេសថៃឡង់ មិនលើសពី ១៩% ហើយប្រទេសវៀតណាមក្នុងរង្វង់ ១២%។ ក្រៅពីត្រូវមានច្បាប់សមាគម សហគមន៍ ច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ក៏ត្រូវតែបង្កើត ឱ្យបានឆាប់រហ័ស ដើម្បីធានាបរិស្ថានអាជីវកម្ម និងវិនិយោគល្អប្រសើរ ដូចជាច្បាប់ក្ស័យធនជាដើម។

***ខ.អភិវឌ្ឍន៍ធនធានមនុស្ស-*** ការបង្កើនសមត្ថភាពការងារ នៅតែជាកត្តាចាំបាច់មិនអាចខ្វះបាន។ ការបំពាក់បំប៉ន ហ្វឹកហ្វឺនការដាក់បញ្ចូលបច្ចេកវិទ្យាទំនើប ទៅក្នុងជីវភាពការងារប្រចាំថ្ងៃ គឺនៅតែជាប្រការដែលត្រូវយកចិត្តទុកដាក់ជាទីបំផុត។ ខ្វះបច្ចេកវិទ្យាទំនើបមានន័យថាដើរថយក្រោយ បើប្រៀបធៀបទៅនឹងការអភិវឌ្ឍន៍របស់បណ្តាប្រទេសសមាជិកអាស៊ានផ្សេងទៀត។

***គ.សាជីវកម្មធានាឥណទាន*** (Credit Guarantee Corporation)- កម្ពុជា ជាប្រទេសសមាជិកអាស៊ានមួយ ដែលមិនទាន់មានសាជីវកម្មធានា ឥណទាននេះនៅឡើយ។ ស្ថាប័នហិរញ្ញវត្ថុទាំងអស់គួរតែរៀបចំខ្លួន ដើម្បីបង្កើតជាបេឡាមួយសម្រាប់ជាមូលនិធិធានាឥណទាន។ នៅពេលមានមូលនិធិនេះ ទាំងអ្នកខ្ចី ទាំងអ្នកឱ្យខ្ចីលែងខ្វល់ខ្វាយពីវត្ថុកក់បញ្ចាំធានា បំណុលទៀតហើយ។ ហានិភ័យឥណទាន ថយចុះ

មកនៅក៏រិតទាបបំផុត។ ជាមួយគ្នានេះដែរ ការគិតគូរទៅដល់ការធានារ៉ាប់រង សេវាមីក្រូហិរញ្ញវត្ថុ ក៏ជាអាទិភាពមួយដែរ។ សមាជិកសមាគម សហគមន៍ សហភាព ឥណទានមានភាពកក់ក្ដៅ ហើយនឹងក្នុងចិត្តនៅពេលដែលអាជីវកម្មរបស់ខ្លួន ក៏ដូចជា ជីវភាពរស់នៅរបស់ខ្លួនមាន ការធានារ៉ាប់រងមួយដ៏ជាក់លាក់។ នៅពេលជួបលំបាក ឬគ្រោះអាសន្នផ្សេងៗជាយថាហេតុ ពួកគាត់នឹងមិនបាត់បង់ក្ដីសង្ឃឹម នៅចំពោះ មុខឧបសគ្គទាំងនោះឡើយ។

ក្រោយពីការចូលអាស៊ាន ក្នុងរយៈពេល ៥ ឆ្នាំ នេះ យើងបានចំណេញពីការ ទទួលបានចំណេះដឹងថ្មីៗ រួមទាំងវិស័យឥណទានជនបទផងដែរ។ ដោយឡែករាជ រដ្ឋាភិបាលកម្ពុជា ក៏បាននឹងកំពុងជួយជំរុញឱ្យវិស័យឥណទានជនបទនេះ ឱ្យមានការរីក ចំរើន និងរួមចំណែកដល់ការអភិវឌ្ឍន៏សេដ្ឋកិច្ចជាតិ ជាពិសេសការអភិវឌ្ឍន៏សហគ្រាស តូច និងមធ្យម ព្រមទាំងការកាត់បន្ថយភាពក្រីក្រផងដែរ។

ទូលបង្គំ-ខ្ញុំ សូមបញ្ចប់បទអន្តរាគមន៍ដោយសង្ខេបត្រឹមនេះ ហើយសូមថ្លែង អំណរគុណដ៏ជ្រាលជ្រៅ ចំពោះការយកចិត្តទុកស្ដាប់របស់ សម្ដេច ព្រះអង្គម្ចាស់ ព្រះអង្គ ម្ចាស់ក្សត្រី អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសទាំងអស់។ ទូលបង្គំ ខ្ញុំ សូមគោរពជូនព្រះពរ ដល់សមាជិកអង្គសន្និសីទ សូមទទួលបាននូវជោគជ័យ ក្នុងគ្រប់ភារកិច្ច។

# ការអភិវឌ្ឍក្នុងសហប្រតិបត្តិការវិស័យទេសចរណ៍អាស៊ាន

**ដោយលោក ច្រឡឹង សុមេធា**

*អនុប្រធាននាយកដ្ឋានអាស៊ាន ក្រសួងទេសចរណ៍*

## សេចក្តីផ្តើម :

វិស័យទេសចរណ៍នៃប្រទេសកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលកំណត់ថា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិ។ បុព្វបទនេះត្រូវផ្អែកទៅលើធនធានវប្បធម៌ និងធម្មជាតិដ៏សំបូរស្តុកស្តម្ភដែលយើងមាន។ ហេតុដូច្នេះហើយ បានជាការអភិវឌ្ឍន៍នូវវិស័យទេសចរណ៍ ទោះបីជាប្រទេសនៅក្រីក្រ និងទន់ខ្សោយ ប៉ុន្តែយើងមិនសូវជួបប្រទះនូវការលំបាកខ្លាំងក្លាហួសប្រមាណដូចប្រទេសដទៃទៀតឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏យើងត្រូវតែអភិវឌ្ឍនូវធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនទៀតដែរ ដើម្បីជំនួយដល់ទេសចណ៍ក្នុងការធ្វើដំណើរកំសាន្តក្នុងប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះដែរ របត់នយោបាយ និងសេដ្ឋកិច្ចបានកំណត់ឱ្យកម្ពុជា ចូលជាសមាគមន៍អាស៊ានដើម្បីបំបាត់ភាពឯកោនៅលើពិភពលោក ក៏ដូចជាការបើកច្រកទូលាយផ្នែកសេដ្ឋកិច្ច និងសហប្រតិបត្តិការក្នុងតំបន់។

## សភាពការណ៍ទេសចរណ៍អាស៊ាន

ផ្អែកលើមូលដ្ឋានទិន្នន័យទេសចរណ៍អាស៊ាន នៅឆ្នាំ២០០២ ទេសចរណ៍អន្តរជាតិមកទស្សនាអាស៊ាន មានចំនួន៤៣,៨០៥,៣៤២ នាក់ និងទទួលបានចំណូល

២៧,៦៨ ពាន់ លានដុល្លារអាមេរិក ហើយចំណូលនេះស្មើនឹង ៤,៨១% នៃផលទុនជាតិសរុបនៃ ប្រទេសអាស៊ាន។

**ចំនួនទេសចរណ៍អន្តរជាតិចូលមកប្រទេសកម្ពុជា និងអាស៊ាន ក្នុងឆ្នាំ១៩៩៩-២០០៣**

| ប្រទេស | ១៩៩៩ | ២000 | ២001 | ២00២ | ២00៣ | ២00៤ |
|---|---|---|---|---|---|---|
| កម្ពុជា | ៣៦៧,៧៤៣ | ៤៦៦,៣៦៥ | ៦0៤,៩១៩ | ៧៨៦,៥២៤ | ៧0១,0១៤ | ៨៦៧,0៨២ |
| អាស៊ាន | - | - | ៤២,២0២,២៦៦ | ៤៣,៩៨៩,0១0 | ៣៧,៤៩៣,៨៨៣ | - |

ទេសសចរណ៍អាស៊ានក្នុងឆ្នាំ ២00៣ កន្លងមកបានប្រឈមនឹងបញ្ហាជាអវិជ្ជមានមួយចំនួនបណ្តាលមកពីជំងឺ SARS និងសង្គ្រាមអ៊ីរ៉ាក់។ បច្ចុប្បន្ននេះទេសចរណ៍អាស៊ានបានវិលមករកប្រក្រតីភាព និងប្រសើរឡើងវិញបណ្តើរៗ ហើយក្រោមការខិតខំរបស់ប្រទេសសមាជិកអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការ ជាមួយប្រទេសផ្សេងៗ មាន ចិន ជប៉ុន កូរ៉េ និងអង្គការអន្តរជាតិនានា ដើម្បីកាត់បន្ថយឥទ្ធិពលអវិជ្ជមានទាំងឡាយ លើវិស័យទេសចរណ៍ឱ្យថយចុះមកនៅកម្រិតអប្បបរមា។ ចំពោះបញ្ហាជំងឺគ្រុនផ្តាសាយបក្សី ដោយសារការខិតខំប្រឹងប្រែងរបស់ប្រទេសសមាជិកអាស៊ានបានពង្រឹងនូវសហប្រតិបត្តិការជាមួយប្រទេសផ្សេងៗ និងអង្គការអន្តរជាតិនានាជំនះលើបញ្ហាប្រឈមនេះ។

តើបន្ទាប់ពីកម្ពុជាចូលអាស៊ានវិស័យទេសចរណ៍មានការរីកចម្រើនដូចម្តេច?

១- **កិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន** (ASEAN Tourism Agreement)

កិច្ចព្រមព្រៀងទេសចរណ៍អាស៊ានកំណត់នូវសហប្រតិបត្តិការ ក្នុងការសំរួលការធ្វើដំណើរចូលមក នៅក្នុងអាស៊ានពង្រឹងកិច្ចសហប្រតិបត្តិការក្នុងឧស្សាហកម្ម

ទេសចរណ៍រវាងប្រទេសសមាជិកអាស៊ាន ដើម្បីធ្វើឱ្យប្រសើរឡើង នូវសមត្ថភាព និងភាពប្រកួតប្រជែងរបស់ខ្លួន។ គោលបំណងកិច្ចព្រមព្រៀង នេះគឺបង្កើតជាប្រព័ន្ធរួមបញ្ចូលគ្នានៃសេវាកម្មទេសចរណ៍ និងការធ្វើដំណើរ សំដៅធ្វើឱ្យបានជាអតិបរមា លើការប្រើប្រាស់ ធម្មជាតិរបស់តំបន់ជាការទាក់ទាញទេសចរ បង្កើនការអភិវឌ្ឍ និងផ្សព្វផ្សាយតំបន់អាស៊ានជាគោលដៅទេសចរណ៍តែមួយ ប្រកបដោយស្តង់ដាថ្នាក់ពិភពលោក នៃសណ្ឋាការសេវាកម្ម និងកន្លែងទាក់ទាញ។

កិច្ចព្រមព្រៀងនេះ នៅមានការសំរួលការធ្វើដំណើរក្នុងអាស៊ាន និងការធ្វើដំណើរជាអន្តរជាតិ ដោយប្រទេសសមាជិកនឹងសំរួលការធ្វើដំណើរនៅក្នុង និងចូលមកតំបន់អាស៊ាន ដោយបន្តការរៀបចំលើកលែងទិដ្ឋាការសម្រាប់ប្រជាជាតិ សមាជិកអាស៊ាន។ ប្រជាជនអាស៊ាននឹងធ្វើដំណើរនៅក្នុងតំបន់ដោយឈរលើមូលដ្ឋាននៃកិច្ចព្រមព្រៀងលើកលែងទិដ្ឋាការទ្វេភាគី រវាងប្រទេសសមាជិកដែលត្រៀមខ្លួនជាស្រេចដើម្បីអនុវត្ត និងការធ្វើឱ្យមានភាពស្របគ្នាចំពោះបែបបទផ្តល់ទិដ្ឋាការ សម្រាប់ទេសចរណ៍អន្តរជាតិ។

នៅកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ានលើកទី ៧ កាលពីថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០០៤ នាទីក្រុងវៀង ច័ន្ទ ប្រទេសឡាវ ការពិភាក្សាបានផ្តោតលើ របៀបវារៈសំខាន់មាន : ការអនុវត្តន៏កិច្ចព្រមព្រៀងទេសចរណ៍អាស៊ានការបន្ត ផ្សព្វផ្សាយយុទ្ធនាការទស្សនាអាស៊ាន ការជំរុញល្បឿននៃការធ្វើសេរីភាវូបនីយកម្មសេវាកម្មទេសចរណ៍អាស៊ាន ការផ្សព្វផ្សាយវិនិយោគទុនទេសចរណ៍ ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសផ្សេងៗ និងអង្គការអន្តរជាតិ។ រដ្ឋមន្ត្រីទេសចរណ៍អាស៊ានក៏បានចេញសេចក្តីប្រកាសទីក្រុងវៀងច័ន្ទស្តីពីការធ្វើឱ្យប្រសើរឡើង នៃកិច្ចសហប្រតិ

បត្តិការទេសចរណ៍អាស៊ាន ដោយបានប្រកាន់យកវិធានការណ៍ជំរុញល្បឿន នៃការអនុវត្តន៏ កិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន និងការលើកជាផែនការកម្មវិធីអនុវត្តលំអិតជាក់ស្តែងក្នុងនោះ រួមមានការជំរុញ ការលើកលែងទិដ្ឋាការក្នុងប្រទេសអាស៊ានឱ្យបានមុន ឆ្នាំ ២០០៥។ សេចក្តី ប្រកាសក៏គូសបញ្ជាក់ផងដែរ អំពីការធ្វើសមាហរណកម្មតាមរយៈគោលដៅទស្សនៈផែនទីបង្ហាញផ្លូវ (Roadmap) របស់ប្រមុខរដ្ឋាភិបាលអាស៊ាន ដែលបានត្រួសត្រាយដោយមានការជួយដល់សមាជិកថ្មី នូវជំនួយបច្ចេកទេសក្នុងការអភិវឌ្ឍធនធានមនុស្ស ជំរុញការវិនិយោគទុនទេសចរណ៍ ព្រមទាំងសហការឱ្យកាន់តែជិតស្និទ្ធជាមួយស្ថាប័នទីភ្នាក់ងាររបស់ប្រទេសសមាជិក ការពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន និងក្រុមសមាគមឧស្សាហកម្មទេសចរណ៍អាស៊ាន។

## ២- **វេទិកាទេសចរណ៍អាស៊ាន** (ASEAN Tourism Forum)

វេទិកាទេសចរណ៍អាស៊ាន ត្រូវបានប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំតាមលំដាប់អក្ខរាវិរុទ្ធ (Alphabetical Order) ឈ្មោះប្រទេសជាសមាជិក។ វេទិកាទេសចរណ៍អាស៊ានជាព្រឹត្តិការណ៍ទេសចរណ៍ដ៏ធំមួយក្នុងតំបន់ នៃប្រទេសអាស៊ាន ចូលរួមដោយអ្នកកំណត់គោលនយោបាយឧស្សាហកម្មទេសចរណ៍ (Tourism Industry Policy Makers) អ្នកប្រកបអាជីវកម្មទេសចរណ៍ សណ្ឋាគារ អាកាសចរណ៍ អ្នកសារពត៌មានក្រុមហ៊ុនផ្គត់ផ្គង់សេវា និងអតិថិជន ដោយផ្អែកលើមូលដ្ឋានសេវា និងផលិតផលទេសចរណ៍។ ព្រឹត្តិការណ៍សំខាន់បំផុតនៅវេទិកាទេសចរណ៍អាស៊ាន គឺការតាំងពិពរណ៍ទេសចរណ៍ (Travel Expo, TRAVEX) ដែល ជាឱកាសទីផ្សារពាណិជ្ជកម្មទេសចរណ៍សម្រាប់ធ្វើទំនាក់ទំនងពាណិជ្ជកម្ម និងផ្សព្វផ្សាយទេសចរណ៍ ក្នុងការទាក់

ទាញអ្នកចូលរួមពីក្រៅប្រទេសចំនួន ១៥០០ នាក់ ទៅ ២០០០ នាក់មកពីពាសពេញពិភពលោក ។

ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការទេសចរណ៍អាស៊ាននា ឆ្នាំ ២០០៣ នេះ យើងមានកិត្តិយស និងប្រកបដោយមោទនភាពជាតិខ្ពស់ ដោយបានទទួលធ្វើជាម្ចាស់ផ្ទះសម្រាប់វេទិកាទេសចរណ៍អាស៊ាន ឆ្នាំ ២០០០៣ សម្រេចដោយជោគជ័យ និងធ្វើការប្រកាសបើកឆ្នាំទស្សនាកម្ពុជា (Visit Cambodia Year)។ ជាមួយនេះ យើងនៅមានសកម្មភាពមួយចំនួនទៀត ដូចជា : រៀបចំកិច្ចប្រជុំ រដ្ឋមន្ត្រីទេសចរណ៍អាស៊ានលើកទី៦ កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន ចិន ជប៉ុន និងកូរ៉េ លើកទី២ កិច្ចប្រជុំស្ថាប័នទេសចរណ៍ជាតិអាស៊ានលើកទី ១៧ ដែលក្នុងនោះមានការប្រជុំក្រុមការងារអភិវឌ្ឍន៍ធនធានមនុស្ស ទេសចរណ៍អាស៊ាន ក្រុមការងារវិនិយោគទុន អាស៊ាន ក្រុមការងារផ្សព្វផ្សាយទីផ្សារទេសចរណ៍អាស៊ាន និងក្រុមការងារទំនាក់ទំនងពតិមានទេសចរណ៍អាស៊ាន ដែលផ្តោតលើបញ្ហាសុវត្ថិភាព សន្តិសុខទេសចរណ៍ ។

### ៣- **គណៈកម្មាធិការសម្របសម្រួលផ្នែកសេវាកម្មអាស៊ាន** (The Coordinating Committee on Services)

ក្រសួងទេសចរណ៍ក៏បានចូលរួមជាមួយ គណៈប្រតិភូអន្តរក្រសួងក្នុង កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល សេវាកម្មអាស៊ាន ក្នុងការជំរុញល្បឿន សេរីភាវូបនីកម្មសេវាកម្មទេសចរណ៍អាស៊ាន ក្នុងបំណងលើកកំពស់ កិច្ចសហប្រតិបត្តិការ ផ្នែកសេវាកម្មរវាងប្រទេសជាសមាជិកអាស៊ាន ដើម្បីបង្កើននូវប្រសិទ្ធិភាព និងភាពប្រកួត ប្រជែងក្នុងការពង្រីកសមត្ថភាពផលិតកម្ម ការផ្គត់ផ្គង់ និងការបែងចែកសេវាកម្ម របស់

អ្នកផ្គត់ផ្គង់ សេវាទាំងក្នុង និងក្រៅតំបន់ អាស៊ាន ព្រមទាំងការលុបបំបាត់នូវការរិតត្បិត ចំពោះការធ្វើពាណិជ្ជកម្មផ្នែក សេវាកម្មរវាងប្រទេសសមាជិកអាស៊ាន ហើយ អត្ថប្រយោជន៍ដែលយើងទទួលបានពីការអនុវត្តន៍កិច្ចព្រមព្រៀងនេះ មានដូចជាការបើក ច្រកទីផ្សារក្នុងស្រុកខ្មែរ និងការស្រូបទាញបានការវិនិយោគបរទេសជាច្រើន ការទទួល បានការហូរចូល នូវបច្ចេកវិទ្យាទំនើបទាន់សម័យ។

បន្ថែមលើនោះក្រសួងទេសចរណ៍ បានសហការយ៉ាងល្អប្រសើរជាមួយ មជ្ឈមណ្ឌល អាស៊ាន-ជប៉ុន ដើម្បីការបណ្តុះបណ្តាលអប់រំ និងផ្សព្វផ្សាយ ទាក់ទាញ ទេសចរណ៍មកពីទីផ្សារជប៉ុនឱ្យកាន់តែច្រើនថែមទៀត។

ក្រៅពីកិច្ចសហប្រតិបត្តិការ ក្នុងក្របខ័ណ្ឌសមាគមអាស៊ានយើងមាន កិច្ច សហប្រតិបត្តិការទេសចរណ៍ទ្វេភាគី ជាមួយប្រទេសក្នុងតំបន់ ដើម្បីផ្លាស់ ប្តូរទស្សនកិច្ច បទពិសោធន៍ ការអភិវឌ្ឍន៍ទេសចរណ៍ ការផ្សព្វផ្សាយទីផ្សារ ការបណ្តុះបណ្តាល ធនធានមនុស្ស តាមរយៈការផ្តល់អាហារូបករណ៍ពីភាគីមិត្តជាដើម។ ជាមួយគ្នានេះដែរ កិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងក្របខ័ណ្ឌ ជាយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការ បងប្អូនប្រទេសកម្ពុជា ឡាវ មីយ៉ានម៉ា ថៃ ដែលប្រមុខរដ្ឋាភិបាល បានចុះហត្ថលេខា កាលពីថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៣ នៅទីក្រុង បាហ្គាន់ ប្រទេសមីយ៉ានម៉ា នឹងជំរុញគំរោងទេសចរណ៍ក្នុងតំបន់ឈាន ទៅសម្រេចបានលទ្ធផលដ៏ប្រសើរ លើកិច្ច សហប្រតិបត្តិការក្នុងវិស័យទេសចរណ៍។

# សុន្ទរកថាគន្លឹះបិទសន្និសីទជាតិ

## ឯកឧត្តមបណ្ឌិត កៅ គឹមហួន

*រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ.*

១- តាងនាមឱ្យឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួងកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ខ្ញុំសូមកោតសរសើរចំពោះវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព និងមូលនិធិ Friedrich-Ebert-Stiftung ដែលបានអញ្ជើញលោកឧបនាយករដ្ឋមន្ត្រីមកថ្លែងសុន្ទរកថាបិទនៅក្នុងសន្និសីទជាតិ ស្តីពី "**ប្រទេសកម្ពុជា និងសមាគមអាស៊ានក្នុងរយៈពេល ៥ ឆ្នាំក្រោយមក**"។ ដោយសារតែកម្មវិធីរបស់លោកមមាញឹក ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** មិនអាចអញ្ជើញចូលរួមបានក្នុងសន្និសីទនេះ ហេតុដូចនេះហើយ បានជាលោកសុំឱ្យខ្ញុំធ្វើជាតំណាង លោកនៅក្នុងសម័យប្រជុំបិទអង្គសន្និសីទនេះ។

២- ជាបឋមខ្ញុំសូមអបអរសាទរទាំង CICP និង មូលនិធិ FES ដែលបានរៀបចំសន្និសីទនេះក្នុងពេលវេលាដ៏ចាំបាច់មួយ ដើម្បីពិនិត្យមើលឡើងវិញ វាយតម្លៃ និង

ពិភាក្សាពីសមាជិកភាពរបស់ប្រទេសកម្ពុជា និងសមាគមអាស៊ាន ក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ។ ដូចនេះសន្និសីទជាតិនេះ មានបំណង ពិនិត្យមើលសមិទ្ធផលអ្វីដែលប្រទេសកម្ពុជាបានសម្រេច ក៏ដូចជា តើអ្វីខ្លះ ដែលប្រទេសកម្ពុជា ត្រូវប្រកាន់យកពីពេលនេះ ក៏ដូចជាក្នុងអនាគត ដើម្បីពង្រីកផលប្រយោជន៍ យូរអង្វែងរបស់ខ្លួន ទៅក្នុងសង្គមបើកចំហធំធេងនៃសាកលភាវូបនីយកម្ម និងតំបន់នាពេលបច្ចុប្បន្ននេះ។

៣- ក្នុងន័យនេះ ខ្ញុំសូមចែករំលែកទស្សនទានរបស់ខ្ញុំ អំពីការដែលខ្ញុំបានពិនិត្យឃើញភាពជាដៃគូ និងសហប្រតិបត្តិការកម្ពុជា និងអាស៊ានក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ ដោយសំលឹងទៅមុខឆ្ពោះទៅរកអនាគតកាល នៃការចូល រួមដ៏សកម្មឥតងាករេ របស់កម្ពុជាជាមួយក្រុមក្នុងតំបន់ ដែលរួមមានការចូល រួមដ៏ទូលំទូលាយរបស់កម្ពុជា ដូចជា ប្រទេសកម្ពុជានិងកិច្ចប្រជុំអាស៊ីអឺរ៉ុប ដែលប្រទេសយើងទើបតែចូលរួមនៅដើមខែ តុលាឆ្នាំនេះ និងតួនាទីរបស់ កម្ពុជានៅក្នុង ការពិភាក្សាសហប្រតិបត្តិការអាស៊ី (ACD)។

៤- ជាការជាក់ច្បាស់ណាស់ដែលថា ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងពេញទំហឹងក្នុងនាមជាសមាជិកអាស៊ាន ចាប់តាំងពីខ្លួនបានក្លាជាសមាជិកនៃសមាគមនេះ ក្នុងខែមេសា ឆ្នាំ១៩៩៩ មកម្ល៉េះ បន្ទាប់ពីមានការរៀបចំ និងការចរចា ដ៏ស្រួចស្រាវអស់រយៈពេលជាច្រើនឆ្នាំ។ នៅពេលដែលគេលើកឡើងថា ប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជា តាមរយៈអាជ្ញាធរ បណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិ(UNTAC) បានចូលរួមចំណែកក្នុងការបញ្ចប់ភាពឯកោជាអន្តរជាតិរបស់ប្រទេសកម្ពុជា។ ការទទួលយកកម្ពុជាចូលទៅក្នុង

អាស៊ាន អាចដើរតួនាទីដ៏មាន សារៈសំខាន់នៅ ក្នុងការបញ្ចប់ ភាពឯកោជាលក្ខណៈតំបន់របស់កម្ពុជា ក្នុងន័យនេះការបញ្ចប់នៃភាពឯកោរបស់កម្ពុជាក្នុងកម្រិតតំបន់ អាចរួមចំណែក ជាវិជ្ជមានដល់ការផ្សះផ្សារ និងការអភិវឌ្ឍន៏នយោបាយនៅក្នុងតំបន់។ និយាយម្យ៉ាងទៀត គឺតំបន់របស់យើង លែងត្រូវបែងចែកដូចកាលពីអតីតកាលទៀតហើយ។ ក្នុងនាមជាសមាជិកទី ១០ របស់អាស៊ាន កម្ពុជា បានចូលរួមដោយស្មើភាព ក្នុងអង្គការតំបន់ដោយពេញសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន។ ដូចនេះ កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងគ្រប់វិស័យនៃ សហប្រតិបត្តិការពីនយោបាយទៅសន្តិសុខ ពីសេដ្ឋកិច្ចទៅសហប្រតិបត្តិការមុខងារ។

៥- នៅពេលដែលសមាគមអាស៊ាន ចូលរួមសហប្រតិបត្តិការគ្រប់វិស័យ វាមានសារៈសំខាន់ ដូចជាសមាជិកនីមួយៗត្រូវសហប្រតិបត្តិការ ឱ្យកាន់តែជិតស្និទ្ធថែមទៀត ទាំងជាបុគ្គល និងសមូហភាព ដើម្បីធានាថា កិច្ចសហប្រតិបត្តិការតំបន់អាចផ្តល់ផលប្រយោជន៏ដល់ប្រទេសជាសមាជិកទាំងអស់។ សមាគមអាស៊ាន ក្នុងនាមជាអង្គការតំបន់ប្រកបដោយថាមពល ដើរតួនាទីជាពិសេស ទាំងក្នុងកិច្ចការតំបន់ និងពិភពលោកទាំងនៅក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត។ បើគ្មានអាស៊ានទេ នោះប្រទេសតូច និងមធ្យមនៅក្នុងអាស៊ីអាគ្នេយ៏ ដែលអាចមានឥទ្ធិពល ឬតួនាទីបន្តិចបន្តួចប៉ុណ្ណោះ នៅក្នុងកិច្ចការអន្តរជាតិ និងតំបន់ នៅពេលដែលមាននិន្នាការ ដ៏ពុះកញ្ជ្រោលពេញទំហឹងនៃតំបន់និយម និងសាកលភាវូបនីយកម្ម នាពេលបច្ចុប្បន្ននេះ។ ដូច្នេះ តួនាទីរបស់អាស៊ានកាន់តែមាន សារៈសំខាន់ខ្លាំងឡើងនៅក្នុងទំនាក់ទំនងតំបន់ និងអន្តរជាតិ។

៦- ប្រទេសកម្ពុជាចាប់តាំងពីបានចូលក្នុងសមាគមអាស៊ានរយៈពេល ៥ ឆ្នាំនេះ មានភាពសកម្ម និងមោទនភាពក្រៃលែង ដោយបានរៀបចំកិច្ចប្រជុំផ្សេងៗ ប្រកបដោយ ជោគជ័យរួមមានកិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ាន+៣ កិច្ចប្រជុំកំពូលអាសាន+១ ជាមួយចិន ជប៉ុន សាធារណរដ្ឋកូរ៉េ កិច្ចប្រជុំកំពូល លើកដំបូងអាស៊ានឥណ្ឌា និងកិច្ចប្រជុំផ្សេងៗ ទៀត នៅឆ្នាំ ២០០២ ដោយបានធ្វើជាប្រធានគណៈកម្មាធិការ នាយករបស់អាស៊ាន (ASC) ក្នុងឆ្នាំ ២០០២-២០០៣ រៀបចំកិច្ចប្រជុំ រដ្ឋមន្ត្រីអាស៊ាន (AMM) វេទិកាតំបន់អាស៊ាន (ARF) រៀបចំសន្និសីទ រដ្ឋមន្ត្រី (PMCS) ក៏ដូចជា រៀបចំកិច្ចប្រជុំអង្គការអន្តរសភាអាស៊ាន (AIPO) ក្នុងឆ្នាំ២០០៤ ដែលសភាជាតិរបស់យើងបាន ដើរតួនាទីស្នូល។ លើសពីនេះ ប្រទេសកម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុង ARF នៅពេលដែលខ្លួនបានធ្វើជាប្រធាននៃវេទិកាតំបន់អាស៊ានក្នុងឆ្នាំ២០០២-០៣ ក្នុងការជំរុញវិធានការកសាងទំនុកចិត្ត ក៏ដូចជា សន្តិភាព ស្ថេរភាព និងសន្តិសុខ តំបន់សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិកទាំងមូល។

៧- នៅពេលដែលនិយាយដល់បញ្ហាអាស៊ានមានសំណួរ អំពីផលប្រយោជន៍ និងការចំណាយ ដើម្បីចូលជាសមាជិកអាស៊ាន។ ម្យ៉ាងទៀត ពួកគេចង់ដឹងថាតើយើងពិតជាបានចំណេញ ពិតប្រាកដពីអង្គការនេះមែនឬ ហើយបើបានចំណេញពួកគេចង់ឱ្យយើងរាប់ពីផលប្រយោជន៍ពិតប្រាកដជាក់ស្តែង? តែនេះពុំមែនជាការងាយស្រួលនោះឡើយ។ ជាការពិតណាស់ នៅពេលដែលមានផលប្រយោជន៍ជាក់ច្បាស់ពេលនោះ ក៏មានផលប្រយោជន៍ ដែលយើងមើលដោយភ្នែកមិនឃើញ

ផងដែរ។ តាមទស្សនៈរបស់ខ្ញុំ ប្រទេសកម្ពុជាពិតជាបានទទួលផលប្រយោជន៍ពីសមាជិកភាពរបស់ខ្លួនក្នុងអង្គការអាស៊ាន ដែលរួមមានដូចខាងក្រោមនេះ :

*ទី១-ការបណ្តុះបណ្តាលៈ* ជារៀងរាល់ឆ្នាំប្រទេសកម្ពុជាបានបញ្ជូនមន្ត្រីមួយចំនួន ក៏ដូចជាអ្នកមិនមែនជាមន្ត្រីរាជការទៅកាន់កម្មវិធីបណ្តុះបណ្តាលផ្សេងៗនៅក្នុងប្រទេសជាសមាជិកអាស៊ាន ឬប្រទេសដៃគូពិភាក្សាអាស៊ាន។ ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ធនធានមនុស្សមានសារៈសំខាន់ណាស់ សម្រាប់ប្រទេសរបស់យើង ពីព្រោះយើងកំពុងស្វះស្វែងរកការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ធនធានមនុស្សរបស់យើងគ្រប់វិស័យ។

*ទី២-ជំនួយតាមរយៈគំរោងរបស់អាស៊ាន* : នេះមានន័យថា ប្រទេសកម្ពុជាអាចទទួលបាននូវផលប្រយោជន៍ដោយផ្ទាល់ ពីគំរោងទ្វេភាគី ឬពហុភាគី ដែលដៃគូចរចាអាស៊ានបានផ្តល់មូលនិធិ ដូចជា ប្រទេស+3 ចិន ជប៉ុន និង សាធារណរដ្ឋកូរ៉េ ឬប្រទេសដទៃទៀត។ ឧទាហរណ៍ដូចជា គំរោងក្រោមគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ានឬ IAI មានសារៈសំខាន់ដើម្បីគាំទ្រសមាជិកថ្មី នៃអាស៊ានដែលពង្រឹងដល់ការធ្វើសមាហរណកម្មអាស៊ាន។

*ទី៣-ការវិនិយោគទុន និងការជំរុញពាណិជ្ជកម្ម តាមរយៈកម្មវិធី ផ្សេងៗ ជាបន្ថែមទៅលើកិច្ចព្រមព្រៀងទ្វេភាគី ប្រទេសកម្ពុជា បានខិតខំប្រឹងប្រែង តាមរយៈ ក្របខ័ណ្ឌតំបន់ ដើម្បីជំរុញសហប្រតិបត្តិការពាណិជ្ជកម្ម វិនិយោគ និងសេដ្ឋកិច្ច។* នៅក្នុងក្របខ័ណ្ឌអាស៊ាន និងតាមរយៈក្របខ័ណ្ឌ ទំនាក់ទំនងការចរចាអាស៊ាន ប្រទេសកម្ពុជាអាចចូលទៅដល់ទីផ្សារ និងវិនិយោគផ្សេងៗ។ នេះជា ហេតុផលដែលសហប្រតិបត្តិការរបស់យើង ជាមួយអាស៊ានកាន់តែមាន

សារៈសំខាន់នៅក្នុងឆ្នាំថ្មីៗ ពីព្រោះតែដំណើរ នៃការធ្វើសមាហរណកម្ម អាស៊ាននាពេលបច្ចុប្បន្ន និងសហប្រតិបត្តិការស៊ីជំរៅ និងធំធេងដែលយើងមាន ជាមួយដៃគូចរចារបស់អាស៊ានបច្ចុប្បន្ន ពិសេសជាមួយប្រទេស+3 និង ប្រទេសឥណ្ឌា។

*ទី៤-ការជំរុញវិស័យទេសចរណ៍* : វិស័យទេសចរណ៍ជាវិស័យដ៏មានសារៈសំខាន់ ដែលប្រទេសកម្ពុជាអាចធ្វើការជាមួយអាស៊ានរាប់សិបឆ្នាំ។ ទេសចរណ៍តំបន់មានសភាពខ្លាំងក្លា និងកាន់តែមានសារៈសំខាន់ ទោះបីជាមានឧបសគ្គដែលបណ្តាលមកពីផលប៉ះពាល់នៃជំងឺសារ និងគ្រុនផ្តាសាយបក្សី។ ប្រទេស កម្ពុជាក៏ដូចជា ប្រទេសសមាជិកដទៃទៀត ក្នុងអង្គការអាស៊ាន គឺត្រូវបង្កើតជាក្រុម និងធ្វើការយ៉ាងជិតស្និទ្ធនៅក្នុងអាស៊ាន ហើយទន្ទឹមនឹងនោះ គឺជាមួយដៃគូចរចាអាស៊ាន ដើម្បីជំរុញវិស័យទេសចរណ៍ ដើម្បីទទួលបានផលប្រយោជន៍ទាំងគ្រប់ប្រទេស ពិសេសប្រទេសដែលមានការអភិវឌ្ឍន៍ទាបជាងគេ ដូចជា ប្រទេសកម្ពុជា។

*ទី៥-ការកើនឡើង នៃសហប្រតិបត្តិការអនុតំបន់កំណើន និងការអភិវឌ្ឍក្នុងអាស៊ានជាកត្តាដ៏មានសារៈសំខាន់សម្រាប់ជំរុញ ការអភិវឌ្ឍ ដែលប្រទេសកម្ពុជា បានសហការជាមួយប្រទេសដទៃ ដើម្បីពន្លឿន ការអភិវឌ្ឍរបស់ខ្លួន*។ បច្ចុប្បន្ននេះ មានកិច្ចព្រមព្រៀង និងកម្មវិធីសហប្រតិបត្តិការ អនុតំបន់ មួយចំនួនដែលរួមមាន មហាអនុតំបន់ទន្លេមេគង្គ (GMS) និងសហប្រតិបត្តិការអាងទន្លេមេគង្គអាស៊ាន (AMBDC) ការអភិវឌ្ឍន៍ត្រីកោណ និងយុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ច ទន្លេអាយេយ៉ាវ៉ាឌី Ayeyawady និងទន្លេចៅផ្រាយ៉ា (ACMECS) និងទន្លេមេគង្គ។

៨- ខ្ញុំបានរ៉ាយរ៉ាប់វិស័យមួយចំនួននៃសហប្រតិបត្តិការ ដែលប្រទេសកម្ពុជាបាន ចូលរួម និងបានទទួលផលប្រយោជន៍ពីនេះ។ ទោះជាយ៉ាងនេះក៏ដោយវិស័យ នៃសហ-ប្រតិបត្តិការខាងលើ មិនបានរាប់បញ្ចូលផលប្រយោជន៍ជាយុទ្ធសាស្ត្រ និងទូលំទូលាយដែលកម្ពុជាបានទទួលនោះទេ។ វិស័យមួយដែលខ្ញុំចង់បញ្ជាក់នៅទីនេះគឺ ការពង្រឹងតួនាទីរបស់កម្ពុជាក្នុងកិច្ចការតំបន់ និងអន្តរជាតិក្នុងរយៈពេល ៥ឆ្នាំកន្លងមក មិនមែនតែការទូតទ្វេភាគី ប៉ុណ្ណោះទេ តែថែមទាំងតាមរយៈការទូតពហុភាគីអាស៊ានថែមទៀតផង។ គឺតាម រយៈការទូតពហុភាគីអាស៊ាននេះហើយដែលប្រទេសកម្ពុជាអាចចូលរួមយ៉ាងសកម្ម នៅក្នុងវេទិកាដ៏មានសារៈសំខាន់ផ្សេងៗ ដូចជាកិច្ចចរចាសហប្រតិបត្តិការអាស៊ី (ACD) កិច្ចប្រជុំអាស៊ីអឺរ៉ុប (ASEM) និងវេទិកា សម្រាប់អាស៊ីបូព៌ា និងសហប្រតិបត្តិការ អាមេរិកឡាទីន (FEALAC)។

៩- ឥឡូវនេះ ខ្ញុំសូមនិយាយអំពីវិស័យដែលខ្ញុំយល់ថា ប្រទេសកម្ពុជាកំពុងប្រឈមមុខក្នុងសមាគមអាស៊ាន ក៏ដូចជាសម្រាប់សមាគមអាស៊ានជាទូទៅ។ ជាដំបូង ដោយហេតុថា ជាប្រទេសអភិវឌ្ឍន៍ទាបបំផុតនៅក្នុងតំបន់ ប្រទេសកម្ពុជា នឹងត្រូវបន្តខិតខំប្រឹងប្រែង ដើម្បីដើរឱ្យទាន់សមាជិកដទៃទៀត របស់សមាគមអាស៊ាន ពិសេសជាមួយសមាជិកចាស់ៗ។ នៅទីនេះ ប្រទេសកម្ពុជានឹងត្រូវធ្វើអ្វីៗ តាមដែលគេអាចធ្វើទៅបានដោយខ្លួនឯង ដូចដែលខ្លួនបានធ្វើក្នុងឆ្នាំកន្លងមក។ គំលាតអភិវឌ្ឍរវាងប្រទេសកម្ពុជា និងសមាជិកដទៃទៀតរបស់អាស៊ាននឹងត្រូវតែ បង្រួញតូចទៅៗ ដើម្បីឱ្យស៊ីសង្វាក់គ្នា។ ខ្ញុំជឿថា យើងត្រូវតែប្រឹងប្រែងថែមទៀត ក្នុងការផ្តោតទៅលើ ការធ្វើសមាហរណកម្មអាស៊ាន ពិសេសតាមរយៈគម្រោងគំនិត

ផ្តួចផ្តើម សម្រាប់សមាហរណកម្មអាស៊ាន (IAI) កម្មវិធីសកម្មភាពទីក្រុងវៀងច័ន្ទ (VAP) និងគំរោងអភិវឌ្ឍអនុតំបន់ ដើម្បីធានាថា សមាជិកនៃប្រទេសអភិវឌ្ឍទាបបំផុតរបស់អាស៊ាន អាចធ្វើសកម្មភាពពេញលេញ ចូលទៅក្នុងសហគមន៍តំបន់ និងពិភពលោក។ ក្នុងន័យនេះប្រទេសដៃគូសន្ទនា ក៏ដូចជាភាគីពាក់ព័ន្ធទី ៣ អាចជួយអាស៊ានក្នុងការជំរុញការធ្វើសមាហរណកម្ម របស់ខ្លួនពិសេស នៅពេលដែលអាស៊ានឥឡូវនេះ កំពុងផ្តោតការយកចិត្ត ទុកដាក់ដ៏ធំធេងរបស់ខ្លួន ក្នុងការបង្កើតសមាគមរបស់ខ្លួន ដែលមាន សហគមន៍ ៣ គឺសហគមន៍សេដ្ឋកិច្ច នយោបាយនិងសន្តិសុខ និងវប្បធម៌ សង្គម។

១០- ដើម្បីឱ្យអាស៊ាននៅតែជាអង្គការដ៏ចាំបាច់ និងអាចសម្រេចបាននូវ សមិទ្ធិផលរបស់ខ្លួននៅក្នុងតំបន់ និងពិភពលោក ខ្ញុំជឿថា អាស៊ាននឹង ត្រូវបន្តផ្តោតលើវិស័យគន្លឹះ ដែលជាអាទិភាពធំធេងមួយចំនួន ដើម្បីពង្រឹងឯកភាព និងសាមគ្គីភាពអាស៊ាន ជំរុញការធ្វើសមាហរណកម្មរបស់ខ្លួន និង ការកសាងសហគមន៍ និងរក្សាការប្រមើលមើលទៅខាងក្រៅ និងការចូល រួមដ៏សកម្មជាមួយដៃគូ សន្ទនារបស់ខ្លួន និងភាគីដទៃទៀត។

១១- ការពង្រឹងឯកភាព និងសាមគ្គីភាពអាស៊ាន : ដូចយើងដឹងស្រាប់ហើយ ថាកម្លាំង និងការទាក់ទាញរបស់អាស៊ានត្រូវតែធ្វើឡើង ជាសមូហភាព ទាំងអស់គ្នាក្នុងឯកភាព និងសាមគ្គីភាព។ ជាន័យនយោបាយប្រទេសទាំង ១០ របស់អាស៊ានអាចចងបាច់គ្នាក្រោមដំបូលអាស៊ានតែមួយ ដែលមិនអាចត្រូវបាន បំបែកបំបាក់ដោយងាយស្រួលនោះឡើយ។ ក្នុងន័យសេដ្ឋកិច្ច អាស៊ានដែល មានទីផ្សាររួមនៃប្រជាជនជាងប្រាំរយលាននាក់ បានផ្តល់ឱកាសសេដ្ឋកិច្ចដ៏ ធំធេង ដូចនេះហើយ

បានជាមានការទាក់ទាញអ្នកវិនិយោគទុន ពិសេស បើសិនជាទីផ្សារអាស៊ានអាចរួមបញ្ចូលគ្នា ជាទីផ្សារតែមួយនៅពេលអនាគត។ ដូច្នេះ វាមានសារៈសំខាន់ សម្រាប់អាស៊ានក្នុងការរក្សាស្មារតីដ៏ ពិតប្រាកដរបស់ខ្លួននៃឯកភាព និងសាមគ្គីភាព ពីព្រោះតែខ្លួនមានមហិច្ឆតា ជាប្រវត្តិសាស្ត្រចង់បង្កើតសហគមន៍អាស៊ាន។

១២- អាស៊ានត្រូវបន្តជំរុញសមាហរណកម្ម និងការកសាងសង្គមរបស់ខ្លួន ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនៅបាលី (Bali Concord II)។ កម្មវិធីសកម្មភាពទីក្រុងវៀងច័ន្ទ គឺជាផ្លូវផែនទីដ៏ស៊ីជម្រៅបំផុតសម្រាប់ការធ្វើសមាហរកម្មអាស៊ាន និងការអនុវត្តន៏សហគមន៍អាស៊ានទាំង៣ ដែល នឹងរួមចំណែកដល់ការធ្វើឱ្យសម្រេចនូវទស្សនាទានអាស៊ាន ឆ្នាំ២០២០ ហើយទន្ទឹមនឹងនោះនឹង ជួយរួមចំណែកដល់ការកសាងសហគមន៏អាស៊ីនៅ ក្នុងរយៈពេលយូរអង្វែង ពីព្រោះអាស៊ានបច្ចុប្បន្នកំពុងផ្តោតលើកិច្ចប្រជុំ កំពូលអាស៊ីបូព៌ា នៅក្នុងទីក្រុងកូឡាឡាំពួរក្នុងឆ្នាំ ២០០៥។ ដូចនេះ ដើម្បី ជំរុញសមាហរណកម្មតំបន់ និងការកសាងសហគមន៏អាស៊ានត្រូវប្រមូលផ្តុំធនធាន និងការគាំទ្រពិសេស១ ដ៏ទៃទៀត ដើម្បីធានាឱ្យមានការអនុវត្តន៏ ប្រកបដោយប្រសិទ្ធិភាព និងទាន់ពេលវេលានូវគម្រោង និងសកម្មភាព ផ្សេងទៀត ដែលបានដាក់ចេញដោយ VAP។

១៣- ដើម្បីរក្សាឱ្យបាននូវការប្រមើលមើលទៅខាងក្រៅរបស់អាស៊ាន និងពង្រឹងទំនាក់ទំនងជាមួយដៃគូសន្ទនាមិត្តភក្តិ និងប្រទេសដទៃទៀត ជាអន្តរជាតិ អាស៊ានត្រូវរក្សាវិធីរបស់ខ្លួន នៃការចូលរួមជាមួយគ្រប់ភាគី និងតួអង្គសំខាន់១ ទាំងអស់នៅលើឆាកតំបន់ និងពិភពលោក ពិសេសជាមួយ ដៃគូជិតស្និទទាំងអស់ ដែលអាស៊ានកំពុងធ្វើការយ៉ាងជិតស្និទ្ធ ដូចជាប្រទេសបូកបីប្រទេសឥណ្ឌា ក៏ដូចជា

ប្រទេសអូស្ត្រាលី និងញូហ្សេឡេន។ លើសពីនេះ ការចូលរួមរបស់អាស៊ានជាមួយដៃគូធំៗ ដទៃទៀតរួមមានប្រទេសរុស្ស៊ី (ដែលអាស៊ាន នឹងរៀបចំកិច្ចប្រជុំកំពូលនៅឆ្នាំក្រោយ) និងអង្គការសហប្រជាជាតិ នឹងមានលក្ខណៈជាយុទ្ធសាស្ត្រ និងវិជ្ជមាន។ ក្នុងន័យនេះ ដើម្បីផលប្រយោជន៍មធ្យម និងយូរអង្វែង អាស៊ានត្រូវរក្សាយុទ្ធសាស្ត្ររបស់ខ្លួន នៃការចូលរួមដ៏សកម្មបំផុត និងការសំលឹងទៅខាងក្រៅ។

១៤- ទាំងអស់នេះ នឹងជួយឱ្យអាស៊ានគិតគូរអំពីជំហររបស់ខ្លួនឡើងវិញ នៅក្នុងកិច្ចការតំបន់ និងអន្តរជាតិ។ នៅក្នុងការវិវត្តឥតឈប់ឈររបស់អាស៊ាននេះ ប្រទេសកម្ពុជានឹងត្រូវប្រឹងប្រែងចូលរួមយ៉ាងពេញទំហឹងជាមួយអាស៊ាន នៅគ្រប់កម្រិតចាប់តាំងពីកម្រិតទ្វេភាគីទៅដល់អនុតំបន់ និងពីកម្រិតតំបន់ ទៅដល់កម្រិតពិភពលោក។ វាជាការពិតណាស់ដែលថា អនាគតរបស់កម្ពុជានឹងស្ថិតនៅជាមួយអាស៊ានច្រើនថែមទៀត ពីព្រោះសមាគមតំបន់ប្រកបដោយថាមពលនេះ កំពុងបន្តរីកចម្រើននៅពេលបច្ចុប្បន្ន និងអនាគត។

១៥- ជាសេចក្តីសន្និដ្ឋាន ខ្ញុំជឿថា រយៈពេល ៥ ឆ្នាំ នៃសមាជិកភាព និងការចូលរួមយ៉ាងសកម្មជាមួយអាស៊ានមានផលប្រយោជន៍ទៅវិញទៅមក ២ យ៉ាងគឺ ប្រទេសកម្ពុជា ពិតជាបានទទួលផលប្រយោជន៍ដ៏សំខាន់ពី អាស៊ាន ហើយ អាស៊ានក៏បានទទួលផលប្រយោជន៍ ពីការរួមចំណែករបស់កម្ពុជាវិញដែរ។ ដោយមានជោគជ័យ និងសមិទ្ធផលក្នុងអតីតកាលរបស់ខ្លួន តំបន់អាស៊ាននឹងបន្តរីកចម្រើនរឹងមាំ និងរុងរឿង ដែលសមាជិកទាំងអស់នៃ សហគមន៍តំបន់នេះ នឹងទទួលបាននូវផលប្រយោជន៍ពីសន្តិភាព ស្ថេរភាព ការអភិវឌ្ឍ សន្តិសុខ និងភាពរុងរឿង។

# ឧបសម្ព័ន្ធ១ របាយការណ៍នៃអង្គសន្និសីទជាតិ ស្តីពី "ប្រទេសកម្ពុជា ក្នុងអាស៊ាន : ប្រាំឆ្នាំក្រោយមក"

## ក_សេចក្តីផ្តើម

អស់រយៈពេល ០២ ថ្ងៃ សម័យប្រជុំទាំង ៦ នៃសន្និសីទជាតិស្តីពី "**ប្រទេសកម្ពុជា ក្នុងអាស៊ាន : ប្រាំឆ្នាំក្រោយមក**" បានប្រព្រឹត្តទៅយ៉ាងមមាញឹក ដោយមានសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានសភាជាតិ ដែលព្រះអង្គបានផ្តល់កិត្តិយសយាងមកបើក ដោយមាន ការចូលរួមពីឥស្សរជនជាន់ខ្ពស់ ថ្នាក់ដឹកនាំសំខាន់ៗ នៃរាជរដ្ឋាភិបាល រួមទាំងសមាជិក សមាជិការដ្ឋសភាជាតិ ព្រឹទ្ធសភា តំណាងអង្គទូត មន្ត្រីរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និស្សិត បញ្ញវន្ត និងប្រព័ន្ធពតិមានផង ។

អង្គសន្និសីទជាតិ បានលើកយកលទ្ធផលនៃកិច្ចប្រជុំពិភាក្សាទាំង ១០ លើកនៃវេទិកា **កម្ពុជា_អាស៊ាន** ដែលបានរៀបចំឡើងដោយ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព មកពិនិត្យពិចារណា និងផ្តល់មតិបំពេញបន្ថែម ដោយបានទទួលលទ្ធផលដូចខាងក្រោម :

**ខ_ទស្សនៈរួម :**

សមាជិកភាពរបស់កម្ពុជាក្នុងអាស៊ាន មានសារៈសំខាន់ជាចាំបាច់ដល់ការស្ថាបនា និងការអភិវឌ្ឍប្រទេសកម្ពុជា ក្រោយសម័យសង្គ្រាម ដោយហេតុថា: ភាពនៅដាច់ឆ្ងាយពីតំបន់ និងក្រៅប្រព័ន្ធសេដ្ឋកិច្ច ពិភពលោក និងសាកលភាវូបនីយកម្ម នឹងនាំឱ្យប្រទេសកម្ពុជា ស្ថិតក្នុងភាពឱនថយ។

ការចូលជាសមាជិកអាស៊ានរបស់កម្ពុជា ពិតជាបានទទួលនូវផលប្រយោជន៍ជាច្រើន។ ផលប្រយោជន៍ជាក់ស្តែងគឺ ការបញ្ចប់ភាពឯកោក្នុងសម័យសង្គ្រាម ការអភិវឌ្ឍ សេដ្ឋកិច្ចជាតិ ការពង្រឹងសន្តិសុខ និងសន្តិភាព ការទប់ស្កាត់ ភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរមនុស្ស និងគ្រឿងញៀន ការទទួលបានចំណេះដឹងថ្មី ទីផ្សារធំទូលាយ និងការវិនិយោគទុនបរទេស ពិសេសការពង្រីកទំនាក់ទំនងការទូត ដែលជាកត្តាកំណត់ មិនអាចខ្វះបាន ។ល។

ក៏ប៉ុន្តែ សមាជិកភាពរបស់កម្ពុជាក្នុងអាស៊ានក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ពិតជាមានបញ្ហាប្រឈមមុខជាច្រើន។ ប្រសិនបើពុំមានវិធានការ ទប់ស្កាត់ ឬកែលំអទេ សមាជិកភាពនេះនឹងមានការលំបាក។ បញ្ហាប្រឈមមុខ ទាំងនោះគឺ : កម្រិតនៃការយល់ដឹងអំពីគុណប្រយោជន៍ ដែលបានមកពីអាស៊ាននៅទាប ភាពទន់ខ្សោយ នៃហេដ្ឋារចនា សម្ព័ន្ធសេដ្ឋកិច្ច នៅតាមជនបទ កង្វះខាតធនធានមនុស្ស ការគ្រប់គ្រង និងសមត្ថភាព ផលិតកម្មនៅទន់ខ្សោយ នាំឱ្យមានការលំបាក ក្នុងការប្រកួតប្រជែង ដណ្តើមទីផ្សារ អាស៊ាន។

ជាទិសដៅទៅអនាគត ដើម្បីឱ្យសមាជិកភាព កម្ពុជា-អាស៊ានកាន់តែរឹងមាំ ប្រទេស កម្ពុជាគួរតែ :

- *លើកស្ទួយការយល់ដឹង និងការផ្សព្វផ្សាយអំពីគុណប្រយោជន៍កម្ពុជាក្នុង អាស៊ាន*
- *លើកស្ទួយស្ថេរភាពនយោបាយផ្ទៃក្នុង សន្តិសុខ សីលធម៌សង្គម សន្តិភាព និង ការអភិវឌ្ឍន៍*
- *លើកស្ទួយការអភិវឌ្ឍន៍ធនធានមនុស្ស ទាំងសមត្ថភាពយល់ដឹង និង គុណធម៌ វិជ្ជាជីវៈ*
- *លើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ប្រសិទ្ធិភាពនៃការគោរពច្បាប់ ពង្រឹងអភិបាលកិច្ចល្អ ការស្ថាបនានីតិរដ្ឋ វប្បធម៌នៃសហប្រតិបត្តិការ ការពិភាក្សា ភាពជាដៃគូ និងសេចក្តី យោគយល់រវាងគ្នានិងគ្នា*
- *ជំរុញការគាំទ្រ និងលើកទឹកចិត្តដល់វិនិយោគឯកជន ដើម្បីផ្តល់ការងារ និងធានា បាន នូវការប្រកួតប្រជែងដោយសេរី និង យុត្តិធម៌ ។*

ការអប់រំផ្សព្វផ្សាយ និងការលើកស្ទួយចំណេះដឹងអំពីប្រទេសកម្ពុជា និង អាស៊ានមានគុណប្រយោជន៍ជាសំខាន់ដល់ការស្ថាបនាប្រទេសកម្ពុជា ឱ្យទៅជាសមាជិក អាស៊ាន ដ៏សកម្មមួយ ។

បើគ្មានចំណេះដឹងអំពីអាស៊ានទេ កុំសង្ឃឹមថាប្រទេសជាតិយើង នឹងអាចក្លាយ ជាសមាជិកដ៏ល្អ និងទទួលបានផលប្រយោជន៍ពិតប្រាកដ ពីសមាគមក្នុងតំបន់នេះ ។

កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គឺជាយុទ្ធសាស្ត្រដ៏សំខាន់ដល់ការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈកាធានាយុត្តិធម៌សង្គមសន្តិភាព ការទាក់ទាញការវិនិយោគទុនបរទេស និងមុខរបរ ដើម្បីលើកស្ទួយគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។

រាជរដ្ឋាភិបាលមានឆន្ទៈនយោបាយ និងយុទ្ធសាស្ត្រពិតប្រាកដក្នុងការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក៏ប៉ុន្តែ កង្វះមធ្យោបាយនិងធនធានក្នុងការធ្វើឱ្យសម្រេចឆន្ទៈនយោបាយ និងយុទ្ធសាស្ត្រនេះ គឺជាបញ្ហាប្រឈមមុខដែលចាំបាច់ត្រូវដោះស្រាយ។ ដូច្នេះ ប្រសិនបើពុំមានការឧបត្ថម្ភគាំទ្រ និងការផ្តល់មធ្យោបាយនិងធនធាន ដើម្បីកំណែទម្រង់ទេនោះ យើងនឹងមានការលំបាក។

ក្នុងរយៈពេល ៣៧ ឆ្នាំ នេះ អាស៊ានបានវិវត្តរីកចម្រើនយ៉ាងខ្លាំងក្លា ពី សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ រហូតដល់ចក្ខុវិស័យស្ថាបនាសហគមន៍ អាស៊ានដ៏ធំបី នៅឆ្នាំ ២០២០ និងសហគមន៍អាស៊ីបូព៌ាមួយ ទៅអានាគត។

នៅក្នុងឋានៈជាសមាជិករបស់អាស៊ានមួយ ប្រទេសកម្ពុជាមានតួនាទី សំខាន់ណាស់ ក្នុងការប្រែក្លាយខ្លួន ឱ្យទៅជាសមាជិកដ៏សកម្មមួយ របស់សហគមន៍ អាស៊ាន ដោយត្រូវលើកស្ទួយការអភិវឌ្ឍធនធានមនុស្ស និងត្រូវធ្វើឱ្យសម្រេច ជោគជ័យនៃកំណែទម្រង់ទ្រង់ទ្រាយធំទាំងបួនរបស់ជាតិ ពិសេសគឺ យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល ការពង្រឹងសន្តិភាព និងការអភិវឌ្ឍន៍ និងបង្កើតសមត្ថភាពផលិត ដើម្បីធ្វើការនាំចេញ។

## ត_លទ្ធផលនៃអង្គសន្និសីទជាតិ :

### ១- ប្រទេសកម្ពុជានិងតំបន់ពាណិជ្ជកម្មសេរីអាស៊ានៈ ការអនុវត្តន៍និងផលប៉ះពាល់

ទស្សនទាននៃការបង្កើត តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) គឺមានឡើងចាប់តាំងពីឆ្នាំ ១៩៩០ មកម្ល៉េះ។ ក៏ប៉ុន្តែ ការសម្រេចបាន ជារូបរាងពិតប្រាកដនៃ AFTA នេះគឺនៅ ខែមករា ឆ្នាំ ១៩៩២ តាមរយៈការចុះកិច្ចព្រមព្រៀងមួយ ឈ្មោះ **គម្រោងអនុគ្រោះពន្ធគយរួម** (Common Effective Preferential Tariff Scheme) ដែលហៅកាត់ថា CEPT ដោយថ្នាក់ដឹកនាំអាស៊ានប្រាំមួយប្រទេស ។

គោលដៅសំខាន់នៃការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាននេះគឺ *ដើម្បី*ធ្វើសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្មសេរី និងប្រែក្លាយតំបន់អាស៊ាន ឱ្យទៅជាទីផ្សារដ៏ធំមួយសម្រាប់ប្រជាពលរដ្ឋអាស៊ានចំនួន ៥១៥ លាននាក់ និងដើម្បីបង្កើតឱ្យមានការប្រកួតប្រជែងលើវិស័យពាណិជ្ជកម្មសេរី ការវិនិយោគទុនក្នុងតំបន់ និងលើពិភពលោក។

ការចូលក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន គឺត្រូវអនុវត្តតាមកិច្ចព្រមព្រៀងគម្រោង អនុគ្រោះពន្ធគយរួមនេះ មិនឱ្យហួសពីរយៈពេល ១០ ឆ្នាំ តាមរយៈការលុបបំបាត់របាំងពន្ធគយ និងរបាំងពុំមែនពន្ធគយ។

ការអនុវត្តន៍គម្រោងអនុគ្រោះពន្ធគយរួម សម្រាប់ប្រទេសកម្ពុជានឹងត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ ២០០០ រហូតដល់ ឆ្នាំ ២០១០។ ពីដំបូងការកាត់បន្ថយពន្ធគយមានចំនួនតែ ០.៥% ទេ (ពីឆ្នាំ ២០០០ ដល់ ឆ្នាំ ២០១០) តែដល់ឆ្នាំ ២០១៥ ពន្ធគយនឹងត្រូវកាត់បន្ថយរហូតដល់ ០%។

ចំពោះប្រទេសកម្ពុជា ការអនុវត្តកិច្ចព្រមព្រៀងគម្រោងអនុគ្រោះពន្ធគយរួម អាចនឹងមានបញ្ហាប្រឈមមុខសំខាន់ពីរគឺ: (១)-ការបាត់បង់ថវិកាជាតិមួយភាគធំ ដែលបានមកពីពន្ធគយ និង (២)-ភាពធ្លាក់ចុះនៃការប្រើប្រាស់ទំនិញក្នុងស្រុក។ ក៏ប៉ុន្តែ ប្រទេសកម្ពុជាអាចនឹងបានទទួលផលចំណេញជាច្រើនពី AFTA នេះ ដូចជា គំនិតច្នៃប្រឌិតក្នុងការផលិត មុខទំនិញក្នុងស្រុក ការទទួលបានបច្ចេកវិជ្ជាថ្មី ផលិតផលថ្មី ការប្រកួតប្រជែងឯកទេសកម្ម និងផលិតកម្មមុខទំនិញក្នុងស្រុកស្របតាមស្តង់ដារតំបន់ និងអន្តរជាតិ ។

ជាអនុសាសន៍រួម អង្គសន្និសីទជាតិស្នើសុំឱ្យមានការលើកស្ទួយ ការអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យគយ និងរដ្ឋាករ ការអភិវឌ្ឍន៍ផ្នែកឯកជន ការពង្រីកមូលដ្ឋាននៃការប្រមូលពន្ធក្នុងស្រុក ការទប់ស្កាត់ការរត់ពន្ធ និងការគេចពន្ធ កំណែទម្រង់ច្បាប់ ជំរុញអភិបាលកិច្ចល្អ និងការអប់រំផ្សព្វផ្សាយ អំពីគម្រោងអនុគ្រោះពន្ធគយរួមដល់មហាជន ជាពិសេសគឺវិស័យឯកជន។

អង្គសន្និសីទជាតិ ក៏បានស្នើសុំឱ្យរាជរដ្ឋាភិបាល តាមដានពីករណីលក់បង្ខូចថ្លៃ (Dumping) ដែលប្រទេសជិតខាងបានធ្វើដើម្បីផលិតផលក្នុងស្រុក។ ហើយស្នើសុំឱ្យប្រជាពលរដ្ឋ និងអាជីវករក្នុងស្រុក ព្រមទាំងស្ថានអគ្គរាជទូតកម្ពុជា យើងនៅបរទេសចូលរួមតាមដាន និងរាយការណ៍ ប្រសិនបើមានករណីនាំចូលទំនិញខូចគុណភាព ឬទំនិញមានគ្រោះថ្នាក់ដល់សុខភាព និងទំនិញដែលគេចង់លក់បង្ខូចថ្លៃ ដែលបង្កគ្រោះថ្នាក់ដល់ប្រទេសយើង។

## ២- ប្រទេសកម្ពុជា និងចក្ខុវិស័យអាស៊ានឆ្នាំ ២០២០ : សហគមន៍សន្តិសុខ សេដ្ឋកិច្ច និងវប្បធម៌

*ជាចក្ខុវិស័យរួមឆ្ពោះទៅឆ្នាំ ២០២០ សមាគមអាស៊ានមើលឆ្ពោះទៅខាងក្រៅ (Outward Looking) ដើម្បីរស់ក្នុងសន្តិភាព ស្ថេរភាព និងវិបុលភាព ដោយចងបាច់គ្នាជាចង្កោម (Bonded together) ក្នុងភាពជាដៃគូ ក្នុងវឌ្ឍនភាពប្រកបដោយថាមវន្តនៅក្នុងសហគមន៍អាស៊ានដ៏ធំមួយ ដែលយកចិត្តទុកដាក់ដល់ការអភិវឌ្ឍន៍ និងសុខុមាលភាពសង្គមជាចម្បង (A Caring Society)។*

ដើម្បីធ្វើឱ្យសម្រេចចក្ខុវិស័យឆ្នាំ ២០២០ របស់ខ្លួនអាស៊ានត្រូវស្ថាបនាសហគមន៍ធំបី គឺ :

- សហគមន៍សន្តិសុខអាស៊ាន
- សហគមន៍សេដ្ឋកិច្ចអាស៊ាន និង
- សហគមន៍វប្បធម៌សង្គមអាស៊ាន។

សហគមន៍សន្តិសុខអាស៊ាន មានគោលដៅធានាសន្តិសុខ ស្ថេរភាព សុវត្ថិភាព និងសន្តិភាពរបស់អាស៊ាន តាមរយៈការអភិវឌ្ឍន៍ វិស័យនយោបាយ ការរួមចំណែកកសាងច្បាប់ទម្លាប់ ការបង្ការ និងដោះស្រាយទំនាស់ដោយសន្តិវិធី ការស្ថាបនាសន្តិភាព និងការអភិវឌ្ឍន៍។

សហគមន៍សេដ្ឋកិច្ចអាស៊ានមានគោលដៅធ្វើសមាហរណកម្មវិស័យសេដ្ឋកិច្ចរបស់បណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់ ឱ្យទៅជាសហគមន៍សេដ្ឋកិច្ចដ៏ធំមួយរបស់

អាស៊ាននៅឆ្នាំ ២០២០។ សហគមន៍នេះនឹងត្រូវធ្វើឡើង តាមរយៈការប្រែក្លាយអាស៊ានឱ្យទៅជាទីផ្សារផ្គត់ផ្គង់សេដ្ឋកិច្ចដ៏មានថាមពល មួយនៅក្នុងតំបន់ និងលើពិភពលោក ។

រីឯ សហគមន៍វប្បធម៌សង្គមអាស៊ាន មានគោលដៅលើកស្ទួយការអប់រំចំណេះដឹងដើម្បីអភិវឌ្ឍសង្គម តាមរយៈការលើកកំពស់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ ការហ្វឹកហ្វឺនកម្លាំងពលកម្ម ការលើកស្ទួយសុខភាពសាធារណៈ ការអប់រំឧបនិស្ស័យ និងភាពឈ្លាសវៃ ការផ្សព្វផ្សាយចំណេះដឹង ដើម្បីដោះស្រាយកំណើនប្រជាពលរដ្ឋ បញ្ហាការងារ ភាពរេចរិលនៃបរិស្ថាន និងការគ្រប់គ្រងគ្រោះមហន្តរាយក្នុងតំបន់ ។

សហគមន៍ទាំងបីនេះ គឺជាសសរគ្រឹះនៃការអភិវឌ្ឍន៍របស់សហគមន៍អាស៊ានក្នុងឆ្នាំ ២០២០។ ប្រទេសកម្ពុជាមានតួនាទី និងភារកិច្ចសំខាន់ណាស់ ក្នុងការស្ថាបនាសហគមន៍ទាំងបីនេះនៅកម្ពុជា ដើម្បីអភិវឌ្ឍប្រទេសជាតិ ឱ្យក្លាយជាសមាជិកអាស៊ានដ៏រុងរឿងមួយ។

## ៣- <u>ប្រទេសកម្ពុជា និងវេទិកាតំបន់អាស៊ាន</u> : មេរៀនជា បទពិសោធន៍ និងទស្សនវិស័យទៅអនាគត

ទស្សនាទាននៃការបង្កើតវេទិការនេះ ត្រូវបានផ្តួចផ្តើមឡើង នៅខែ កក្កដា ឆ្នាំ ១៩៩៤ នៅទីក្រុងបាងកក។ គោលដៅជាសក្តានុពលនៃវេទិកានេះគឺ ដើម្បីរក្សានិរន្តរភាព សន្តិសុខ និង ដើម្បីពង្រឹងសន្តិភាព វិបុលភាពនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ។

វេទិកាតំបន់អាស៊ាន (ASEAN Regional Forum) ដែលហៅ កាត់ថា ARF គឺជាវេទិកាពហុភាគីលើវិស័យនយោបាយសន្តិសុខនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ វេទិកានេះត្រូវបានចូលរួមដោយ រដ្ឋមន្ត្រីក្រសួងការបរទេស របស់ប្រទេសជាសមាជិក។

វេទិកានេះ មានសមាជិកចំនួន ២៤ រួមមាន ២៣ ប្រទេស និងសហគមន៍អឺរ៉ុបមួយ។ បណ្តាប្រទេសជាសមាជិកនៃវេទិកានេះ រួមមានបណ្តាប្រទេសជាសមាជិកអាស៊ានទាំង ១០ និងប្រទេសអូស្ត្រាលី ជប៉ុន សហគមន៍អឺរ៉ុប សហរដ្ឋអាមេរិក សាធារណរដ្ឋកូរ៉េ ចិន ញូវសេឡេន ឥណ្ឌា កាណាដា និងប៉ាគីស្ថាន ។ល។

វេទិកាតំបន់អាស៊ានមានកិច្ចប្រជុំរាល់ឆ្នាំ ជាប់គ្នាជាមួយ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ដោយផ្តោតលើការពិភាក្សាដោះស្រាយ ពិគ្រោះយោបល់លើបញ្ហាសន្តិសុខ ពិភពលោកធំៗ ដូចជាបញ្ហាកោះស្ប្រាតលី (សមុទ្រចិនខាងត្បូង) បញ្ហាបរិមាណូនៅ ឥណ្ឌា និងប៉ាគីស្ថាន បញ្ហាឧបទ្វីបកូរ៉េ ភេរវកម្មអន្តរជាតិ ឧក្រិដ្ឋកម្មឆ្លងដែនជាដើម ។

ប្រទេសកម្ពុជាយល់ថា វេទិកាតំបន់អាស៊ាន គឺជាវេទិកាដ៏សំខាន់មួយសម្រាប់ផ្លាស់ប្តូរទស្សនៈក្រៅផ្លូវការស្មើភាព អំពីបញ្ហានយោបាយសន្តិសុខ នៅអាស៊ីប៉ាស៊ីហ្វិក និងដើម្បីប្រើប្រាស់ជាវេទិកាពហុភាគីមួយ សម្រាប់លើកស្ទួយផលប្រយោជន៍ខាងនយោបាយ និងសន្តិសុខរបស់ខ្លួន។

ដើម្បីឱ្យបានទទួលផលប្រយោជន៍ជាក់ស្តែងពីវេទិកានេះ ប្រទេសកម្ពុជាគួរតែខិតខំលើកស្ទួយតួនាទី ការទូតរបស់ខ្លួនក្នុងតំបន់ និងស្ថាបនាក្រុមជំនាញការកម្ពុជាដែលសិក្សាពីសន្តិសុខ និងយុទ្ធសាស្ត្រអន្តរជាតិ ដើម្បីចូលរួមក្នុងវេទិកានេះ និងដើម្បីធ្វើការសិក្សាស្រាវជ្រាវ អំពីវេទិកាតំបន់អាស៊ាន សម្រាប់ជួយផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ពិនិត្យពិចារណា មុននឹងចូលរួមក្នុងវេទិកានេះ ។

## ៤- ប្រទេសកម្ពុជានិងអាស៊ាន+៣ : អនាគតនៃសហគមន៍អាស៊ីបូព៌ា

អាស៊ាន+3 គឺអាស៊ាន១០ + ប្រទេសចិន ជប៉ុន និងសាធារណរដ្ឋ កូរ៉េ ដែលត្រូវបានបង្កើតឡើង ដើម្បីពង្រឹងសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច និ ហិរញ្ញវត្ថុរវាងអាស៊ាន១០ និង អាស៊ាន +3 ។

គោលដៅជាយុទ្ធសាស្ត្រនៃការបង្កើតអាស៊ាន+៣ គឺដើម្បីស្ថាបនា "**សហគមន៍អាស៊ីបូព៌ាមួយ**" ដែលមានរូបភាព និងខ្លឹមសារស្រដៀងគ្នា នឹងសហគមន៍អឺរ៉ុបដែរ ពោលគឺមានទីផ្សាររួម មានរូបិយវត្ថុរួម និងមានសេដ្ឋកិច្ចរួម ។ល។ ក៏ប៉ុន្តែ ការបង្កើតសហគមន៍នេះ អាចនឹងមានបញ្ហាប្រឈមមុខជាច្រើន ក្នុងបញ្ហាដឹកនាំ (តួនាទី ដឹកនាំ) បញ្ហាភេរវកម្ម បញ្ហាសន្តិសុខ ភាពដោយឡែកនៃវប្បធម៌និងទំនុកចិត្ត និងការលូតដៃពីខាងក្រៅ ។

ប្រទេសកម្ពុជា ក៏អាចនឹងទទួលផលប្រយោជន៍ជាច្រើន អំពីអាស៊ាន + ៣ នេះ ដូចជាក្នុងការទាក់ទងជាមួយសហគមន៍អន្តរជាតិ ការទទួលបានកំណើន ទេសចរណ៍ ការអភិវឌ្ឍន៍ធនធានមនុស្ស និងមុខរបរ ការវិនិយោគទុនបរទេស និងចំណេះដឹងវិទ្យាសាស្ត្រ ។ ម្យ៉ាងទៀត កម្ពុជាប្រែក្លាយខ្លួនពីប្រទេសប្រើប្រាស់ ឱ្យទៅជាប្រទេសផ្គត់ផ្គង់ ទំនិញ តាមរយៈការជំរុញការផលិត និងការនាំចេញ ។

ជាអនុសាសន៍រួម ដើម្បីឱ្យបានផលប្រយោជន៍ពិតប្រាកដ ពីទំនាក់ទំនងអាស៊ាន +៣ ប្រទេស កម្ពុជាគួរតែខិតខំលើកស្ទួយការយល់ដឹងរបស់ខ្លួន អំពី អាស៊ាន+៣ អភិវឌ្ឍធនធានមនុស្ស បង្កើតឱ្យមានគោលនយោបាយដោយ ឡែកជាមួយអាស៊ាន +៣

ពង្រឹងស្ថេរភាពនយោបាយសន្តិសុខ សន្តិភាព និងការអភិវឌ្ឍអោយបានល្អ ដើម្បីផ្តល់ជំនឿអោយវិនិយោគិនអាស៊ាន +៣ ។

## ឃ_សេចក្តីសន្និដ្ឋាន

ជាសេចក្តីសន្និដ្ឋាន សន្និសីទជាតិស្តីពី "**ប្រទេសកម្ពុជា ក្នុងអាស៊ាន** : ប្រាំឆ្នាំក្រោយមក " បានទទួលលទ្ធផលល្អគួរជាទីមោទនៈ។ ចំណេះដឹង និងបទពិសោធន៍ក៏ដូចជា អនុសាសន៍ទាំងឡាយដែលអង្គសន្និសីទជាតិប្រមូលផ្តុំបាន គឺពិតជាមានគុណប្រយោជន៍ សំខាន់ណាស់ដល់ការពង្រឹង និងលើកស្ទួយប្រសិទ្ធិភាព នៃសមាជិកភាពរបស់កម្ពុជានៅក្នុងតំបន់។ ការចូលរួមក្នុងអាស៊ាន ក្នុងរយៈពេលប្រាំឆ្នាំនេះ យើងបានទទួលលទ្ធផល ធំធេងណាស់ លទ្ធផលខ្លះ យើងមើលឃើញជាទឹកប្រាក់ ដូចជាជំនួយនានាពីសមាជិក អាស៊ានចាស់ លទ្ធផលខ្លះ យើងមើលមិនឃើញ ដោយវាចេញជាប្រសិទ្ធិភាពការងារចំណេះដឹង និងពង្រឹងការរៀបចំច្បាប់នានា។ ក៏ប៉ុន្តែ ប្រសិនបើគ្មានការផ្សព្វផ្សាយ នូវចំណេះ ដឹងទាំង នោះឱ្យបានទូលំទូលាយដល់មជ្ឈដ្ឋាន មហាជននិងប្រជាពលរដ្ឋទេ នោះលទ្ធផល នេះគ្រាន់តែជាមនោគតិប៉ុណ្ណោះ។ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពនឹងចងក្រងផ្សព្វផ្សាយនូវចំណេះដឹង និងអនុសាសន៍ទាំងនេះ ឱ្យបានទូលំទូលាយ ដើម្បីជាគុណប្រយោជន៍ដល់ការលើកស្ទួយចំណេះដឹងកម្ពុជាអាស៊ាន និងការអនុវត្ត។

# ឧបសម្ព័ន្ធ២ : របាយការណ៍នៃវេទិកាទាំង ១០ លើក ក្នុងឆ្នាំ ២០០៤ ស្តីពី "កម្ពុជា និងអាស៊ាន"

## វេទិកា ទី ១: ប្រទេសកម្ពុជា ក្នុងអាស៊ាន : ទស្សនៈរួម

### ក_សេចក្តីផ្តើម

វេទិកាទី ១ ឆ្នាំ ២០០៤ ស្តីពី **"ប្រទេសកម្ពុជា ក្នុងអាស៊ាន : ទស្សនៈរួម"** ដែលបានរៀបចំឡើង កាលពីថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០០៤ នេះ បានប្រព្រឹត្តទៅនៅក្រោមអធិបតីភាពរបស់ **ឯកឧត្តម អ៊ុន នីង** សមាជិករដ្ឋសភា និងជាសមាជិកគណៈកម្មាធិការនាយកនៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព និងដោយមានការចូលរួម ពីគណៈវាគ្មិន កិត្តិយស ពីររូបគឺ : (១) **ឯកឧត្តមបណ្ឌិត កៅ គីមហួន** ទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទទួលបន្ទុកកិច្ចការអាស៊ាន និងជានាយកប្រតិបត្តិ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព និង (២) លោកបណ្ឌិត **ចាប សុថារិទ្ធ** ប្រធាន នាយកដ្ឋានអាស៊ានទីស្តីការគណៈរដ្ឋមន្ត្រី ទីប្រឹក្សាឯកឧត្តមទេសរដ្ឋមន្ត្រី ***សុខ អាន*** និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ។

វេទិកាទី ១ នេះ ត្រូវសម្របសម្រួលដោយ **លោក សំរ៉ាំង កំសាន្ត** អ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព និងចូលរួមជាសមាជិក សមាជិកានៃអង្គពិភាក្សា ដោយសមាជិក ព្រឹទ្ធសភា អ្នកតំណាងអង្គការសង្គមស៊ីវិល អ្នកតំណាងក្រសួង មន្ទីរ និងស្ថាប័នពាក់ព័ន្ធ មន្ត្រីរាជការផ្នែកឯកជន និស្សិត បញ្ញវន្ត និងអ្នកស្រាវជ្រាវ។ ដើម្បីជាកិច្ចចាប់ផ្តើមបើកវេទិកាទី១ ឯកឧត្តមប្រធានអង្គប្រជុំនេះបានថ្លែងអំណរគុណដល់គណៈវាគ្មិនកិត្តិយស និងសមាជិក សមាជិកា នៃអង្គប្រជុំទាំងមូល ព្រមទាំងជម្រាបពីគោលដៅ និងវត្ថុបំណងសំខាន់៧ នៃវេទិកាទី១នេះ។ បន្ទាប់មក ឯកឧត្តមប្រធានបានប្រគល់វេទិកាឱ្យលោក **សំរ៉ាំង កំសាន្ត** អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរសហប្រតិបត្តិការ និងសន្តិភាព ដឹកនាំ និងសម្របសម្រួលកម្មវិធី នៃវេទិកាប្រជុំពិភាក្សា លើកទី១ ស្តីពី **"ប្រទេសកម្ពុជា និងសមាគមអាស៊ាន: ទស្សនៈរួម"** នេះដូចមាន ខ្លឹមសារជាបន្តបន្ទាប់គ្នា ដូចតទៅ :

លោក **សំរ៉ាំង កំសាន្ត** បានមតិផ្តួចផ្តើមគំនិតសម្របសម្រួលសម្រួលវេទិកាទី ១ ដោយបានលើកឡើងនូវគោលដៅ និងបំណងសំខាន់៧ នៃវេទិកាទី១ នេះថា :

ទស្សនៈរួមនៃវេទិកាលើកទី ១ គឺជាទស្សនៈចំពោះអត្តិភាព (ការចូលរួម) ក្នុងពេលចំពោះមុខ និងទៅអនាគត នៃសមាជិកភាពនៃប្រទេសកម្ពុជា ក្នុងសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា Asean នេះ។ វេទិកាទី ១ ពុំគ្រាន់តែមានអត្ថន័យស្វែងយល់ពីបញ្ហាពិនិត្យ ហេតុផលរបស់បញ្ហា និងដោះស្រាយបញ្ហាប៉ុណ្ណោះទេ តែគឺមានចរិតអប់រំ និងផ្សព្វផ្សាយផង។ លោក **សំរ៉ាំង កំសាន្ត** បានស្នើសុំឱ្យ

អង្គពិភាក្សារំលឹកឡើងវិញខ្លះ នូវសញ្ញាណរបស់សមាគមអាស៊ាន ដូចជាថា តើអ្វីទៅជាអាស៊ាន? ហេតុដូចម្ដេច បានជាចាំបាច់មានសមាគមអាស៊ាន? តើសមាគមអាស៊ានមានសារៈសំខាន់ និងគុណប្រយោជន៍ដូចម្ដេច ដល់បណ្ដាប្រទេសជាសមាជិកក្នុងតំបន់? តើអាស៊ានមានគោលនយោបាយចំពោះមុខ និងទៅអនាគតដូចម្ដេច?

នេះគឺជាខ្លឹមសារដែលត្រូវពិភាក្សាក្នុងចំណុចទី១។ ការយល់ច្បាស់អំពីខ្លឹមសារនេះ នឹងនាំឱ្យយើងកាន់តែមានការយល់ដឹងជ្រាលជ្រៅថែមទៀតអំពីអាស៊ាន។ យល់ដឹងអំពីអាស៊ានច្បាស់ចូលអាស៊ានបានល្អ។ ចូលអាស៊ានបានល្អនឹងនាំមក នូវផលប្រយោជន៍ពិតប្រាកដដល់ប្រទេសជាតិ និងប្រជាពលរដ្ឋកម្ពុជា។ ផ្ទុយទៅវិញ បើយល់ពីអាស៊ានមិនបានច្បាស់លាស់ទេ ការចូលអាស៊ានក៏មិនបានផលល្អដែរ។ បើចូលអាស៊ានមិនបានល្អហើយ នោះកម្ពុជាពុំគ្រាន់តែមិនបានផលប្រយោជន៍ពីអាស៊ានទេ តែតឹថែមទាំងមានការខាតបង់ជាច្រើនទៀតផង ដូចជា ការខាតបង់ពេលវេលា សេចក្ដីខិតខំប្រឹងប្រែង និងថវិកាជាដើម ។ល។

ចំណុចទី ២ លោក **សំរាំង កំសាន្ដ** បានស្នើសុំឱ្យអង្គពិភាក្សាពិនិត្យ មើលមូលប្រវត្តិ នៃការចូលជាសមាជិករបស់ប្រទេសកម្ពុជាទៅក្នុងសមាគមអាស៊ាន។ តើប្រទេសកម្ពុជាមានប្រវត្តិដូចម្ដេច ក្នុងការចូលជាសមាជិកអាស៊ាន? តើការចូលអាស៊ានបានផ្ដល់នឹងផ្ដល់ផលប្រយោជន៍ដូចម្ដេច ដល់ប្រទេសកម្ពុជា ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត?

កិច្ចពិភាក្សាក្នុងចំណុចទី២នេះ នឹងជួយឱ្យយើងកាន់តែមានការយល់ដឹងច្បាស់អំពីការលំបាក និងសេចក្ដីខិតខំប្រឹងប្រែងរបស់យើង ក្នុងការចូលជាសមាជិកអាស៊ាន

ព្រមទាំងផលប្រយោជន៍ទាំងឡាយ ដែលយើងនឹងទទួលបានមកពីសមាជិកភាពនេះផង។ ការយល់ដឹងអំពីការលំបាក និងគុណប្រយោជន៍នេះ នឹងជួយឱ្យយើងកាន់តែមានជំនឿ និងការខិតខំប្រឹងប្រែងកាន់តែខ្លាំងក្លាថែមទៀត ដើម្បីជំរុញឱ្យសមាជិកភាពរបស់ប្រទេសកម្ពុជា ទៅក្នុងអាស៊ានកាន់តែមានសកម្មភាពខ្លាំងក្លារឹងមាំ និងទទួលបានផលប្រយោជន៍ពិតប្រាកដពីសមាគម នៃប្រជាជាតិអាស៊ីអាគ្នេយ៍នេះ។

ចំណុចទី៣ អង្គពិភាក្សាត្រូវបានស្នើសុំ ឱ្យយកចិត្តទុកដាក់ផ្លាស់ប្ដូរមតិយោបល់ទៅលើវិធីសាស្ត្រ ក្នុងការទាញយកផលប្រយោជន៍ ក៏ដូចជាតួនាទី និង ភារកិច្ចរបស់រាជរដ្ឋាភិបាលរបស់អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋកម្ពុជាទាំងមូលក្នុងការពង្រឹង និងពង្រីកនៃសមាជិកភាពរបស់ប្រទេសកម្ពុជានៅក្នុងសមាគមអាស៊ាន។

ចំណុចទាំងបីនេះ គឺជាបំណង និងជាគោលដៅដ៏សំខាន់ នៃវេទិកាទី១ ស្តីពី "ទស្សនៈរួមចំពោះសមាជិកភាពនៃប្រទេសកម្ពុជានៅក្នុងអាស៊ាន"។ កិច្ចពិភាក្សារួមត្រូវបានស្នើសុំឱ្យប្រមូលផ្ដុំការចាប់អារម្មណ៍ និងការផ្លាស់ប្ដូរមតិទៅលើចំណុចផ្ដួចផ្ដើមទាំងបីនេះ ដើម្បីឆ្លើយតបទៅនឹងសំណូមពរដែលវេទិកាចង់បាន។

បន្ទាប់មក **លោក សំរ៉ាំង កំសាន្ត** បានគោរពអញ្ជើញគណៈវាគ្មិនកិត្តិយសទាំងពីរ រូបឡើងមានមតិ និងបង្ហាញទស្សនៈរបស់លោកចំពោះប្រធានបទនៃ វេទិកាទី១ ស្ដីពី **"ប្រទេសកម្ពុជា ក្នុងអាស៊ាន : ទស្សនៈរួម"** នេះ។

## ខ_អំពីទស្សនៈរបស់គណៈវាគ្មិនកិត្តិយស :

### ឯកឧត្តមបណ្ឌិត កៅ គឹមហួន

ជាមូលប្រវត្តិ សមាគមអាស៊ានត្រូវបានស្ថាបនាឡើងនៅឆ្នាំ ១៩៦៧ នៅទីក្រុងបាងកក ដោយរដ្ឋមន្ត្រីការបរទេស នៃប្រទេសប្រាំដែលនៅក្នុងតំបន់អាស៊ីអាគ្នេយ៍គឺ : ប្រទេសថៃ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងសិង្ហបុរី។ ពីដំបូងសមាគមនេះមានគោលដៅបម្រើសកម្មភាពនយោបាយជាចម្បង។ ក៏ប៉ុន្តែ លុះមកដល់ ឆ្នាំ ១៩៩០-១៩៩៩ គោលដៅសន្តិសុខ និងសេដ្ឋកិច្ចក៏ត្រូវបានរៀបចំឡើង។

ក្នុងដំណើរការអភិវឌ្ឍន៍ជាង ៣០ ឆ្នាំ កន្លងមកនេះ សមាគមអាស៊ាន មានការរីកចម្រើនយ៉ាងខ្លាំងក្លាគឺ :

- បានស្ថាបនាសហគមន៍ជាច្រើនក្នុងតំបន់ សំដៅជំរុញកិច្ចពិភាក្សា ផ្លាស់ប្តូរមតិយោបល់ក្នុងតំបន់ ឱ្យទៅជាកិច្ចសហប្រតិបត្តិការរួមដ៏ជិតស្និទ្ធ ដែលគិតគូពីផលប្រយោជន៍របស់តំបន់ជាធំ
- បានបង្កើតអគ្គសញ្ញាណអាស៊ានក្នុងតំបន់ ការប្រជុំកំពូលរបស់អាស៊ាន អគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានថ្នាក់ជាតិនៅក្នុងបណ្តាប្រទេសជាសមាជិកនីមួយៗ
- បានជំរុញឱ្យមានភាពជាដៃគូក្រៅតំបន់
- បានស្ថាបនាបណ្តាញ សម្ព័ន្ធភាព និងការប្រជុំពិភាក្សាជាច្រើន (មិនតិចជាង៣០០ លើក ក្នុង ១ ឆ្នាំ)

- បានបង្កើតវេទិកាក្នុងតំបន់ ដើម្បីការពារសន្តិសុខរបស់ខ្លួន ។ល។ និង ។ល។
- សមាគមអាស៊ាន ក៏មានគោលដៅស្វែងរកជំនួយ និងពង្រឹងភាពជាដៃគូ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ខ្លួនដែរ ដូចជាការទទួលយកភាពជាដៃគូ ជាមួយប្រទេសជប៉ុន ចិន កូរ៉េ កាណាដា អូស្ត្រាលី សហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិកជាដើម ។ល។

ជាជោគជ័យក្នុងរយៈពេល ៣៧ ឆ្នាំ នៃការកកើតរបស់អាស៊ាន គេបានវាយតម្លៃថា ក្រៅពីសហគមន៍អឺរ៉ុប (EU) គ្មានអង្គការក្នុងតំបន់ណាមួយ ដែលនៅលើពិភពលោកនេះ បានទទួលជោគជ័យច្រើនជាង សមាគមអាស៊ានទេ។ អាស៊ានបានទទួលស្នាដៃល្អប្រសើរបំផុត ក្នុងការការពារ និងដោះស្រាយជម្លោះក្នុងតំបន់ (ដូចជា ជម្លោះខ្មែរ-ថៃ នាថ្ងៃ ទី២៩ ខែមករា ឆ្នាំ ២០០៣) តាមរយៈគោលនយោបាយដោះស្រាយទំនាស់ផ្ទៃក្នុងតំបន់ដោយអហិង្សាធម៌។ សមាគមអាស៊ាន បានដើរតួនាទីដ៏សំខាន់ ក្នុងសហគមន៍អន្តរជាតិកន្លងមក ដូចជាស្នាដៃក្នុងការដោះស្រាយជម្លោះនៃប្រទេសកម្ពុជា (សង្គ្រាមស៊ីវិលខ្មែរ) ដែលបង្កើតជាកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស ឆ្នាំ ១៩៩១ អាស៊ានមានស្នាដៃល្អក្នុងការកសាងសន្តិភាព ស្ថេរភាព និងវឌ្ឍនភាពក្នុងតំបន់របស់ខ្លួន អាស៊ានមានស្នាដៃល្អក្នុងការកសាង តំបន់របស់ខ្លួនឱ្យទៅជាតំបន់ប្រកួតប្រជែងមួយលើទីផ្សារអន្តរជាតិ។

អំពីបញ្ហាប្រឈមមុខ បញ្ហាប្រឈមមុខរបស់អាស៊ានគឺ អាស៊ានជាតំបន់អាស៊ីអាគ្នេយ៍ ធ្លាប់ជាទីលាននៃទំនាស់មនោគមន៍វិជ្ជា និងជម្លោះអាណានិគមនិយម។

សង្គ្រាមប្រឆាំងនឹងភេរវកម្ម ជាបញ្ហាប្រឈមមុខដ៏ចម្បង ការជួញដូរគ្រឿងញៀន ជំងឺសារ (SAR) ការជួញដូរមនុស្ស (ស្ត្រី និង កុមារ) ជំងឺអេដស៍ ឧក្រិដ្ឋកម្មឆ្លងដែន ។ល។ ក៏សុទ្ធតែជាបញ្ហាដែលត្រូវដោះស្រាយចំពោះមុខ និងទៅអនាគត បញ្ហាសមាហរណកម្មសមាជិកថ្មី ឱ្យទាន់សមាជិកចាស់នៅមានភាពអសកម្មខ្លះ ការបង្កើតសហគមន៍អាស៊ីបូព៌ារីកចម្រើន តែក៏មានបញ្ហាជាច្រើនទៀត ដែលត្រូវដោះស្រាយ ដើម្បីឱ្យក្លាយទៅជាបង្គោលសេដ្ឋកិច្ចទី ៣ ។

## *លោក បណ្ឌិត ចាប សុថារិទ្ធ*

សមាគមអាស៊ាន ដែលមានប្រវត្តិពាក់ព័ន្ធនឹងអង្គការ សេអាតូ (Seato) ត្រូវបានបង្កើតឡើង ៣៧ ឆ្នាំ ហើយ។ អង្គការក្នុងតំបន់ អាស៊ីភាគអាគ្នេយ៍នេះ មានគោលនយោបាយអព្យាក្រឹត។ ក្នុងសមាជិក ទាំង ១០ មានសមាជិកស្ថាបនិកតែប្រាំទេ។

នៅទសវត្សរ៍ ឆ្នាំ ទី ៦០និង ៧០ ប្រទេសកម្ពុជា គឺជាសមរភូមិក្តៅរវាងមនោគមន៍វិជ្ជាធំពីរ គឺមនោគមន៍វិជ្ជាមូលធននិយម និងសង្គមនិយម។ បំណងរបស់ប្រទេសកម្ពុជា ដែលចូលក្នុងអាស៊ាននេះគឺមិនចង់រស់នៅឯកោ។ ក្នុងចំណោមសមាជិកទាំង ១០ ប្រទេសកម្ពុជា គឺជាសមាជិកពៅគេ។ ក៏ប៉ុន្តែ តាមនិន្នាការថ្មី ប្រទេសទីម័រខាងកើត (East Timor) អាចនឹងចូលជាសមាជិកទី១១។

សមាគមអាស៊ានមានគោលនយោបាយពិភាក្សាជាចម្បង ពោលគឺការប្រជុំផ្លាស់ប្តូរមតិយោបល់រវាងសមាជិកក្នុងតំបន់ និងដៃគូក្រៅតំបន់ ដើម្បីស្វែងយល់គ្នាស្ថាបនាសហប្រតិបត្តិការ និងលើកស្ទួយភាពជាដៃគូ។ គឺផ្តើមចេញពីគោលនយោបាយនេះ

ហើយដែលនាំឱ្យសមាគម អាស៊ានដណ្តើមបានការឧបត្ថម្ភគាំទ្រ និងការចូលរួមពីបណ្តាប្រទេសជាសមាជិក និងដៃគូក្រៅតំបន់។

ប្រជាពលរដ្ឋអាស៊ានមានចំនួនប្រមាណ ៥១៥ លាន នាក់ មានផ្ទៃដី ៤ លាន ៥ សែន គីឡូម៉ែត្រក្រឡា មានផលិតផលក្នុងតំបន់សរុប ៧០០ ពាន់លានដុល្លារ និងមានទំហំពាណិជ្ជកម្មសរុបចំនួន ៧២០ ពាន់ លាន ដុល្លារ។

<u>អំពីប្រយោជន៍ និងការបង់ខាតរបស់ប្រទេសកម្ពុជាក្នុងអាស៊ាន</u>

<u>១- ផលប្រយោជន៍</u>

- ប្រទេសកម្ពុជា នឹងទទួលបានស្មារតីសហប្រតិបត្តិការ លើគ្រប់វិស័យអាចផ្លាស់ប្តូរកិច្ចពិភាក្សា ដែលជាប្រភពនៃស្ថេរភាព សន្តិភាព និងការអភិវឌ្ឍន៍។
- ប្រទេសកម្ពុជា អាចនឹងទទួលបានបច្ចេកវិជ្ជាថ្មី ដែលនាំឱ្យធនធានមនុស្សកម្ពុជា កាន់តែមានសមត្ថភាពបច្ចេកទេស និងការយល់ដឹង
- ជួយលើកស្ទួយមុខមាត់ និងកិត្តិយសរបស់ប្រទេសជាតិយើង (បានទទួលជំនួយបរទេស) និងអាចទទួលបានការឧបត្ថម្ភគាំទ្រ។
- ប្រទេសកម្ពុជា មានឱកាសបានធ្វើការកែទម្រង់ជាច្រើន ក្នុងការចូលជាសមាជិកសមាគមនេះ ដោយមានក្របខ័ណ្ឌច្បាប់ មានតម្លាភាពដែលនាំឱ្យវិនិយោគិនបរទេសមានជំនឿ និងមករកស៊ីនៅកម្ពុជា

- អាស៊ានអាចនាំមកនូវទេសចរណ៍បរទេសបានច្រើន ដែលអាចជួយលើកស្ទួយវិស័យទេសចរណ៍ជាតិឱ្យបានរុងរឿងទៅអនាគត។

## ២- ការបង់ខាត

- ជាការបង់ខាតនោះ គឺត្រូវធ្វើការចំណាយច្រើន ព្រោះមានកិច្ចប្រជុំ និងព្រឹត្តិការណ៍ ជាច្រើន មិនតិចជាង ៣០០ លើកក្នុងមួយឆ្នាំ។ បើគិតទាំងការប្រជុំលើផ្នែកជំនាញក្នុងប្រទេសផង កិច្ចប្រជុំនេះអាចនឹងកើនឡើងដល់ជាង ៦០០ លើក ក្នុងមួយឆ្នាំ។ បណ្តាប្រទេសជាសមាជិកអាស៊ានត្រូវធ្វើវិភាគទានមួយភាគដប់ នៃការចំណាយទាំងអស់របស់អាស៊ាន។
- សមាជិកអាស៊ានមានពីរប្រភេទគឺ សមាជិកថ្មី និងសមាជិកចាស់។ សមាជិកចាស់ជាប្រទេសអ្នកមាន រីឯសមាជិកថ្មីជាប្រទេសអ្នកក្រ។ បណ្តាប្រទេសជាសមាជិកទាំង ១០ អាចប្រកួតប្រជែងគ្នា ដើម្បីយកផលប្រយោជន៍ ពីអាស៊ានឱ្យជាតិគេរៀងៗខ្លួន។
- ពេលចូលរួមក្នុង តំបន់សេដ្ឋកិច្ចអាស៊ាន-AFTA ប្រទេសកម្ពុជាអាចនឹងត្រូវបាត់បង់ពន្ធគយ។
- តម្លៃនៃការចំណាយផ្សេងៗ មានចំនួនច្រើនណាស់។ ការចំណាយនេះអាចធ្វើឱ្យប៉ះពាល់ដល់ថវិកាជាតិ ដែលកំពុងមានការខ្វះខាត។

ជាតួនាទី និងភារកិច្ចប្រទេសកម្ពុជាគួរខិតខំរៀបចំគោលនយោបាយ ខាងក្នុង និងខាងក្រៅប្រទេសឱ្យមានតុល្យភាព និងស្របតាមគេឯងក្នុងតំបន់ដោយចាំបាច់ត្រូវ

ប្រមូលផ្តុំ ទៅលើការអភិវឌ្ឍន៍ធនធានមនុស្ស ការស្ថាបនាសេដ្ឋកិច្ចជាតិ ការស្តារហេដ្ឋារចនាសម្ព័ន្ធ ការលើកស្ទួយវិស័យអប់រំវប្បធម៌ សុខាភិបាល សង្គមកិច្ច និងសន្តិសុខជាតិ ស្ថេរភាពនយោបាយសង្គមសន្តិភាព និងការអភិវឌ្ឍន៍។

## គ_អំពីលទ្ធផលនៃកិច្ចពិភាក្សារួម: ចំណេះដឹង និងអនុសាសន៍

<u>ការយល់ដឹងអំពីសមាគមអាស៊ាន</u> :

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលហៅកាត់ថាអាស៊ាន (ASEAN) ត្រូវបាននបង្កើតឡើងនៅទីក្រុងបាងកក ក្នុងឆ្នាំ ១៩៦៧ ដោយស្ថាបិក ដែលជារដ្ឋមន្ត្រីការបរទេស នៃប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ប្រាំរូប។ បើគិតមកទល់នឹងឆ្នាំនេះ សមាគម អាស៊ានមានអាយុ ៣៧ ឆ្នាំហើយ។ ក៏ប៉ុន្តែ លុះរហូតដល់ ៣២ ឆ្នាំ ក្រោយមក គឺរហូតមកដល់ឆ្នាំ ១៩៩៩ ទើបបណ្តាប្រទេសទាំងប្រាំទៀត ដែលនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ បានចូលជាសមាជិក បង្គ្រប់បានជា ១០ ប្រទេស គឺប្រទេសប្រ៊ុយណេ (Brunei) បានចូលជាសមាជិកនៅឆ្នាំ ១៩៨៤ ប្រទេសវៀតណាម បានចូលជាសមាជិកនៅឆ្នាំ ១៩៩៥ ប្រទេសឡាវ និងភូមាបានចូលជាសមាជិក នៅឆ្នាំ ១៩៩៧ ហើយចុងក្រោយ គឺប្រទេសកម្ពុជា បានចូលជាសមាជិក ទី១០ នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៩។ ទៅអនាគតសមាគមអាស៊ានអាចមានសមាជិកថ្មីមួយទៀត បង្គ្រប់ឱ្យបានជាសមាជិកទី ១១ គឺប្រទេសទីម័រខាងកើត (East Timor)។

<u>អំពីគោលដៅរបស់សមាគមអាស៊ាន</u> :

ជាគោលដៅរួមរបស់សមាគមអាស៊ាន គឺដើម្បីប្រមូលផ្តុំបណ្តាប្រទេសក្នុង តំបន់អាស៊ីអាគ្នេយ៍ឱ្យចូលរួមធ្វើសហប្រតិបត្តិការ ដើម្បីធានាសន្តិភាព ស្ថេរភាពនិង

វឌ្ឍនភាព នៅក្នុងតំបន់របស់ខ្លួន។ គោលដៅចម្បងពីដំបូងនេះ អាចចែកចេញជាគោលដៅ សំខាន់ពីរគឺ : (១)-ដើម្បីបង្កើនវឌ្ឍនភាពលើវិស័យសេដ្ឋកិច្ច វិបុលភាពសង្គម និងភាពរុងរឿងលើវិស័យវប្បធម៌ក្នុងតំបន់ តាមរយៈការខិតខំប្រឹងប្រែងរួមគ្នាក្នុងស្មារតីស្មើភាព និងភាពជាដៃគូសំដៅពង្រឹងសហគមន៍ នៃប្រជាជាតិអាស៊ីអាគ្នេយ៍ឱ្យប្រកបដោយភាពរុងរឿង, (២)-ដើម្បីលើកស្ទួយសន្តិភាព ស្ថេរភាពក្នុងតំបន់តាមរយៈការគោរពយ៉ាងខ្ជាប់ខ្ជួននូវភាពយុត្តិធម៌ និងការគោរពច្បាប់ (នីតិរដ្ឋ) នៅក្នុងទំនាក់ទំនងរវាងបណ្តាប្រទេសជាសមាជិក ក្នុងតំបន់ដោយផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ។

ជាទស្សនៈរួម ឆ្ពោះទៅឆ្នាំ ២០២០ ដោយផ្តើមចេញពីកិច្ចព្រមព្រៀងប្រកបដោយសាមគ្គីភាពរបស់ខ្លួន សមាគមអាស៊ាននឹងមើលឆ្ពោះទៅខាងក្រៅ (Outward Looking) រស់ក្នុងសន្តិភាព ស្ថេរភាព វិបុលភាព ចងបាច់គ្នាជា ចង្កោមក្នុងភាពជាដៃគូ ក្នុងវឌ្ឍនភាពប្រកបដោយថាមវន្ត (Dynamic) នៅក្នុងសហគមន៍អាស៊ានរួមមួយ ដែលយកចិត្តទុកដាក់ដល់សុខុមាលភាពសង្គមជាចម្បង។

<u>អំពីផលប្រយោជន៍និងការបង់ខាតដែលបានមកពីការចូលអាស៊ាន</u> :

ការចូលជាសមាជិក នៃសមាគមអាស៊ានរបស់ប្រទេសកម្ពុជា នឹងផ្តល់នូវប្រយោជន៍ជាច្រើន ដូចជា

- រក្សាការពារ និងលើកស្ទួយនូវផលប្រយោជន៍ជាយុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជា ក្នុងការលុបបំបាត់សត្រូវ និងស្ថាបនាមិត្តក្នុងតំបន់ដើម្បីធានាឱ្យបានល្អប្រសើរនូវសន្តិសុខពីខាងក្រៅ។

- អភិវឌ្ឍសេដ្ឋកិច្ចជាតិក្រោយសម័យសង្គ្រាមឱ្យរួចផុតពីភាពក្រីក្រ តាមរយៈការចូលជាសមាជិកក្នុងតំបន់ពាណិជ្ជកម្មអាស៊ាន (AFTA) ដែលអាចបង្កើនបានជំនឿវិនិយោគិនបរទេស ព្រោះអាស៊ានមានទីផ្សារធំទូលាយ។ ចូលអាស៊ាន គឺដើម្បីឈានទៅចូលអង្គការពាណិជ្ជកម្មពិភពលោក។ អាស៊ានជាច្រកសេដ្ឋកិច្ចដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៏សេដ្ឋកិច្ចកម្ពុជា។

- លើកស្ទួយការទូត សហប្រតិបត្តិការអន្តរជាតិ និងស្តារឡើងវិញនូវកិត្យានុភាពជាតិដែលបាត់បង់ក្នុងសង្គ្រាម និងលុបបំបាត់ភាពឯកោ។

- ទទួលបានការទទួលស្គាល់តាមច្បាប់ និងពង្រឹងប្រព័ន្ធច្បាប់គ្រប់គ្រងរបស់ប្រទេសជាតិឱ្យកាន់តែមានភាពយុត្តិធម៌ សមភាព និងតម្លាភាពត្រឹមត្រូវតាមប្រព័ន្ធច្បាប់ក្នុងតំបន់។

- លើកស្ទួយវិស័យទេសចរណ៍ និងអភិវឌ្ឍន៏វិស័យវប្បធម៌ អប់រំ សង្គមកិច្ចយោធា និងសន្តិសុខ ប្រយុទ្ធនឹងភេរវកម្ម លុបបំបាត់វប្បធម៌និនថយ ការជួញដូរគ្រឿងញៀន ស្ត្រីភេទ និងកុមារ ឧក្រិដ្ឋកម្មឆ្លងដែន ជំងឺអេដស៍ និង SAR ។ល។

- ទទួលបានសហប្រតិបត្តិការ កិច្ចពិភាក្សា និងភាពជាដៃគូជាច្រើនក្នុងតំបន់ និងលើពិភពលោក ដើម្បីកសាង និងអភិវឌ្ឍប្រទេសជាតិ។

- រក្សាការពារបាននូវសន្តិសុខ ស្ថេរភាព សន្តិភាព និងវឌ្ឍនភាពរបស់ប្រទេសជាតិ និងការធ្វើសមាហរណកម្មទៅក្នុងតំបន់ និងលើពិភពលោក។

ក៏ប៉ុន្តែ ការចូលអាស៊ានរបស់ប្រទេសកម្ពុជា អាចជួបនឹងការខាតបង់ខ្លះ ក្នុងគ្រាដំបូង ដូចជាតម្លៃនៃការចំណាយផ្សេងៗ មានច្រើនឥតគណនា ដែលអាចធ្វើឱ្យប៉ះពាល់ដល់ថវិកាជាតិដែលកំពុងខ្វះខាត ការបាត់បង់ពន្ធគយក្នុងពេលចូល AFTA ដំបូង, ភាពស្រុតចុះនៃផលិតកម្ម សេដ្ឋកិច្ច ក្នុងស្រុកដែលបណ្ដាល មកពីបច្ចេកទេសផលិតទន់ខ្សោយការបាត់បង់ពលកម្ម អស្ថេរភាពដើមទុន និងបច្ចេកទេស, និងការមិននិយមប្រើប្រាស់ទំនិញក្នុងស្រុក ។ល។

ទោះជាដូចម្ដេចក្ដី, ការចូលជាសមាជិកអាស៊ាននៃប្រទេសកម្ពុជា អាចនឹងនាំមកនូវផលប្រយោជន៍ច្រើនជាងការខាតបង់។

<u>អំពីបញ្ហាប្រឈមមុខ</u> :

- អង្គពិភាក្សា និងគណៈវាគ្មិបានរកឃើញថា សមាជិកភាពរបស់ប្រទេសកម្ពុជាក្នុងសមាគមអាស៊ានក្នុងពេលបច្ចុប្បន្ន មានបញ្ហាជាច្រើន ដែលត្រូវប្រឈមមុខគឺ
- ការយល់ដឹងអំពីសារៈសំខាន់ និងផលប្រយោជន៍ដែលបានមកពីអាស៊ាននៅពុំទាន់បានល្អ និងទូលំទូលាយ
- ខឿនសេដ្ឋកិច្ចជាតិនៅមានភាពខ្ទេចខ្ទាំ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន នៅពុំទាន់ស្ដារបានទាំងស្រុង បច្ចេកទេសផលិតមុខទំនិញ ការគ្រប់គ្រងផ្នែកឯកជន សហគ្រាស ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម នៅពុំទាន់រឹងមាំ

- ការអភិវឌ្ឍន៍ធនធានមនុស្ស ពុំទាន់ឆ្លើយតបបានតាមសំណូមពរ នៃសមាជិកភាពនេះ, ចង្វាក់ និងសមត្ថភាពផលិតកម្ម ក៏ដូចជា ផលិតផលសេដ្ឋកិច្ចនៅពុំទាន់អាចប្រកួតប្រជែងបានជាមួយ ទីផ្សារក្នុងតំបន់,

អង្គពិភាក្សាបានសន្និដ្ឋានថា ប្រសិនបើប្រទេសកម្ពុជា ជំនះបាននូវបញ្ហាប្រឈមមុខ ក្នុងគ្រាដំបូងនេះ នោះផលចំណេញពិតជា នឹង បានមកប្រទេសកម្ពុជា ក៏ប៉ុន្តែ, បើគេមើលស្រាលចំពោះការខ្វះខាតនេះ នោះការចូលជាសមាជិកអាស៊ាននឹងផ្តល់នូវការលំបាក ។

<u>អំពីទិសដៅដែលត្រូវអនុវត្តន៍ទៅអនាគត និង សំណូមពរជា អនុសាសន៍</u> :

ដើម្បីជំនះបាននូវការបង់ខាត និងទទួលបានផលចំណេញពិតប្រាកដ ពីសមាជិក-ភាពរបស់ប្រទេសកម្ពុជានៅក្នុងអាស៊ាន អង្គពិភាក្សាបានរកឃើញទិស ដៅដែលត្រូវអនុវត្តចំពោះមុខ និងទៅអនាគត និងស្នើសុំរាជរដ្ឋាភិបាល សភា ជាតិ ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាអង្គការសង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋ ទាំងមូលខិតខំធ្វើឱ្យសម្រេចដូចខាងក្រោម :

- ស្នើសុំបន្តពង្រឹង សុវត្ថិភាពសង្គម និងការអភិវឌ្ឍន៍
- ស្នើសុំលើកស្ទួយការអភិវឌ្ឍន៍ធនធានមនុស្សគុណភាពអប់រំសិក្សា ការបង្កើនចំណេះដឹងវិទ្យាសាស្ត្របច្ចេកទេស អភិបាលកិច្ចល្អ និងគុណធម៌ផ្លូវចិត្ត ។

- ស្នើសុំបន្តការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន លើកស្ទួយផលិតផលកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ សិល្បៈវប្បធម៌អប់រំ សង្គមកិច្ច និង សុខាភិបាល។

- ស្នើសុំបន្តការស្ថាបនា និងកែលំអគោលនយោបាយបរទេស ឱ្យបាន ជឿនលឿន ទន់ភ្លន់ និងរស់រវើក។

- ស្នើសុំបន្តការអប់រំផ្សព្វផ្សាយ អំពីទស្សនាទាន និងគុណប្រយោជន៍ នៃការ ចូលជាសមាជិកអាស៊ាន នៃប្រទេសកម្ពុជា ឱ្យប្រជាពលរដ្ឋ គ្រប់រូបមាន ការយល់ដឹង ដើម្បីជួយកសាងកម្លាំងគាំទ្រដល់សមាជិកភាព នេះឱ្យកាន់ តែមានភាពខ្លាំងក្លា និងរឹងមាំទៅអនាគត។

- ស្នើសុំបន្តទប់ស្កាត់ ភាពអសន្តិសុខក្នុងប្រទេស ចំណុចខ្សោយដែល បណ្តាលឱ្យមានការជ្រៀតចូលនៃភេរវកម្ម ការជួញដូរមនុស្ស និង គ្រឿង ញៀនឧក្រិដ្ឋកម្មឆ្លងដែន និងជំងឺឆ្លង។

## ឃ_សេចក្តីសន្និដ្ឋាន :

ជាសេចក្តីសន្និដ្ឋាន វេទិកាទី១ ស្តីពី : ប្រទេសកម្ពុជា និងសមាគម អាស៊ានៈ ទស្សនៈរួម បានទទួលលទ្ធផលល្អ។ អង្គពិភាក្សាបានរកឃើញចំណេះដឹង បទពិសោធន៍ និងសំណូមពរជាច្រើន ដែលមានប្រយោជន៍ជាសំខាន់ដល់ ការលើកស្ទួយប្រសិទ្ធិភាព នៃភាពជាសមាជិកពេញសិទ្ធិរបស់ប្រទេសកម្ពុជាក្នុងសមាគមអាស៊ាន។

ទស្សនៈទាំងនេះ ឆ្លុះបញ្ចាំងឱ្យឃើញនូវការយល់ដឹងរបស់មហាជន បញ្ញវន្ត និងសង្គមស៊ីវិលខ្មែរចំពោះគុណប្រយោជន៍ និងការខាតបង់ដែលបានមកពីសមាជិកភាព

នេះ។ អង្គពិភាក្សាយល់ថា នោះគឺជាការយល់ដឹង និងជាមតិ ក៏ដូចជា សំណូមពររបស់ប្រជាពលរដ្ឋចំពោះរាជរដ្ឋាភិបាល និងសភាជាតិ ពិនិត្យពិចារណាក្រែងបានជាមូលដ្ឋានខ្លះ ដល់ការកែលំអគោលនយោបាយចាស់ និងស្ថាបនាគោលនយោបាយថ្មី ដើម្បីទាញយកផលប្រយោជន៍ពីអាស៊ានជូនប្រទេសជាតិ និងប្រជាពលរដ្ឋឱ្យបានពិតប្រាកដ។

ក៏ប៉ុន្តែ អ្វីដែលសំខាន់ជាងនោះគឺ បំណងនៃការអប់រំផ្សព្វផ្សាយអំពីចំណេះដឹង និងពតិមានប្លែកៗ ដែលកើតមានឡើងក្នុងសមាគមអាស៊ាន ដែលជាតិយើងបានចូលជាសមាជិកប្រាំឆ្នាំមកហើយនេះ ជូនប្រជាពលរដ្ឋបានយល់ដឹង និងជ្រួតជ្រាប ព្រោះថាការយល់ដឹងច្បាស់ ពីអាស៊ាននឹងបានទទួលផលច្រើនជូនប្រទេសជាតិ តែផ្ទុយទៅវិញបើពុំមាន ការយល់ដឹងពីអាស៊ានទេ កុំថាឡើយ ផលប្រយោជន៍ សូម្បីតែវេលា ការខិតខំប្រឹងប្រែង និងទ្រព្យសម្បត្តិជាតិក៏ត្រូវខាតបង់។

អង្គពិភាក្សា ស្នើសុំអំពាវនាវឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូប ជាពិសេសនិស្សិតដែលទើបតែរៀនចប់ត្រូវខិតខំស្វែងយល់រៀនសូត្រ ពីអាស៊ានដើម្បីមានឱកាសអាចចូលធ្វើការក្នុងសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍នេះ ។

# វេទិកា ទី ២ ប្រទេសកម្ពុជា និង សហគមន៍សន្តិសុខអាស៊ាន

## ក_សេចក្តីផ្តើម

វេទិកានេះត្រូវបានសំរបសំរួលដោយ **លោក សំរាំង កំសាន្ត** អ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ដោយមានការចូលរួម ពីគណៈវាគ្មិន កិត្តិយស ពីររូបគឺ : (១)_**ឯកឧត្តមបណ្ឌិត កៅ គឹមហួន** ទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទទួលបន្ទុកកិច្ចការអាស៊ាន និងជានាយកប្រតិបត្តិ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព និង **ឯកឧត្តមឧត្តមសេនីយ៍ទោ ណឹម សុវត្ថិ** អគ្គនាយករងនៃអគ្គនាយកដ្ឋាន យោធសេវា នាយក នាយកដ្ឋាននយោបាយ នៃក្រសួង ការពារជាតិ ។

មុននឹងចាប់ផ្តើមបើកកិច្ចប្រជុំពិភាក្សានៃវេទិកាទី២ ស្តីពី **ប្រទេស កម្ពុជា និងសហគមន៍សន្តិសុខអាស៊ាន** (Cambodia and ASEAN Security Community) **លោក សំរាំង កំសាន្ត** អ្នកសម្របសម្រួល នៃគម្រោងកម្មវិធីនេះ បានថ្លែងអំណរគុណ ដល់ការចូលរួមរបស់គណៈវាគ្មិន កិត្តិយស និងសមាជិកសមាជិកាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួម ក្នុងវេទិកាដ៏មានសារៈសំខាន់នេះ។ ដើម្បីបានជាមូលដ្ឋានដល់ កិច្ចប្រជុំពិភាក្សា នៃវេទិកាលើកទី២

**លោក សំរ៉ាំង កំសាន្ត** បានធ្វើរបាយការណ៍ដោយសង្ខេបមួយស្ដីពី វេទិកា លើកទី១ ដែលបានប្រមូលផ្ដុំកិច្ចប្រជុំ ពិភាក្សាទៅលើទស្សនៈរួម នៃសមាជិកភាពរបស់ប្រទេសកម្ពុជាក្នុងអាស៊ាន ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០០៤។

## គ_អំពីទស្សនៈ និងមតិរបស់គណៈវាគ្មិនកិត្តិយស

### *ឯកឧត្ដម បណ្ឌិត កៅ គីមហួន*

សហគមន៍សន្តិសុខអាស៊ាន (ASEAN Security Community) នៅតែជា (ទស្សនៈ និងជាចក្ខុវិស័យនៅឡើយទេ តែផែនការសកម្មភាពរបស់សហគមន៍នេះ បាននឹងកំពុងជជែកគ្នានៅក្នុងកម្រិតរដ្ឋ។

សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) មានសហគមន៍ធំ៣ បីគឺ (១)-សហគមន៍សន្តិសុខអាស៊ាន (២)-សហគមន៍សេដ្ឋកិច្ចអាស៊ាន និង (៣)-សហគមន៍វប្បធម៌សង្គមអាស៊ាន។ សហគមន៍សន្តិសុខអាស៊ាន ពុំអាចកាត់ផ្ដាច់ពីសហគមន៍សេដ្ឋកិច្ច និងសហគមន៍វប្បធម៌សង្គមអាស៊ានឡើយ។

ហេតុផលចម្បង ដែលអាស៊ានចង់បង្កើតសហគមន៍សន្តិសុខរបស់ខ្លួននោះ គឺដើម្បីឆ្លើយតបឱ្យបានរស់រវើកទៅនឹងការប្រែប្រួលឥតឈប់ឈរលើវិស័យសេដ្ឋកិច្ច និងសន្តិសុខលើពិភពលោក។ នៅក្នុងកិច្ចប្រជុំកំពូល (Bali Concord II) លើកទី២ ឆ្នាំ ២០០៣ នៅទីក្រុងបាលីនៃប្រទេសឥណ្ឌូណេស៊ី សមាគមអាស៊ានមានគោលដៅឆ្ពោះទៅបង្កើតសហគមន៍សន្តិសុខរបស់ខ្លួនហើយ។

សហគមន៍សន្តិសុខអាស៊ានមានទស្សនវិស័យ ១២ យ៉ាងគឺ :

- ជំរុញកិច្ចសហប្រតិបត្តិការសន្តិសុខ ក្នុងសហគមន៍អាស៊ានឱ្យកាន់តែខ្លាំងក្លាជាងលើកមុនៗ ដើម្បីធានាឱ្យបណ្តាប្រទេសជាសមាជិកក្នុងតំបន់បានរួមរស់ និងមានភាពសុខដុមរមនាក្នុងសន្តិភាព និងការអភិវឌ្ឍន៍។ រាល់បញ្ហាទាំងឡាយ ដែលកើតមានក្នុងតំបន់នេះ ត្រូវតែដោះស្រាយដោយសន្តិវិធី។

- ទទួលស្គាល់អធិបតេយ្យភាពរបស់បណ្តាប្រទេសជាសមាជិកនីមួយៗ បន្តអនុវត្តគោលនយោបាយបរទេសដោយឡែករបស់ខ្លួន។ អាស៊ានគ្មានបក្សសម្ព័ន្ធយោធា ឬគោលនយោបាយការបរទេសរួមគ្នាទេ។

- អាស៊ាននឹងបន្តលើកស្ទួយមិត្តភាពក្នុងតំបន់ និងសហប្រតិបត្តិការ។ ប្រទេសជាសមាជិកនីមួយៗ អាចនឹងប្រើសិទ្ធិរបស់ខ្លួន ក្នុងការដឹកនាំប្រទេសជាតិខ្លួន ដោយចៀសវាងការធ្វើអន្តរាគមន៍ និងការលូកដៃពីខាងក្រៅ។

- សហគមន៍សន្តិសុខអាស៊ាន គោរពតាមគោលនយោបាយ លក្ខន្តិកៈធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងធ្វើការសម្រេចរួម គោរពអធិបតេយ្យភាពមិនប្រើកម្លាំងគំរាមកំហែង តែដោះស្រាយបញ្ហាដោយសន្តិវិធី។

- សហគមន៍សន្តិសុខអាស៊ាន ធ្វើសហប្រតិបត្តិការព្រំដែនសមុទ្រ រវាងបណ្តាប្រទេសជាសមាជិក និងចូលរួមធ្វើវិភាគទាន ដើម្បីវិឌ្ឍនភាព នៃសហគមន៍សន្តិសុខនេះ។

- រាល់ឯកសារ ជាគោលការណ៍របស់អាស៊ានដែលមានស្រាប់ ដូចជាឯកសារ ZOPEAN (តំបន់សន្តិភាព សេរីភាព និងអព្យាក្រឹត) TAC និងសន្ធិសញ្ញា SEANWFZ ត្រូវបានយកធ្វើជាឯកសារសម្រាប់ប្រើប្រាស់រួមដើម្បីស្ថាបនាជំនឿទុកចិត្ត និងយកការងារទូតធ្វើជាវិធានការការពារ និងដោះស្រាយទំនាស់ ។

- ជំរុញការប្រើប្រាស់ក្រុមប្រឹក្សាជាន់ខ្ពស់ នៃសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ ជាសមាសធាតុសំខាន់នៅក្នុងសហគមន៍សន្តិសុខអាស៊ាន ដើម្បីឆ្លុះបញ្ចាំងឆន្ទៈរបស់អាស៊ានក្នុងការដោះស្រាយរាល់ជម្លោះ និងជំទាស់ដោយសន្តិវិធី ។

- ជំរុញការលើកស្ទួយសន្តិភាព និងសន្តិសុខនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ។ អាស៊ានចង់ក្លាយជាកម្លាំងនាំមុខមួយ ក្នុងការជំរុញវេទិកាអាស៊ានដើម្បីពិភាក្សាអំពីបញ្ហានយោបាយ និងសន្តិសុខ ។

- រក្សាឱ្យសហគមន៍សន្តិសុខអាស៊ាន ទៅជាសហគមន៍មួយបើកចំហមានទស្សនៈជឿនលឿនឆ្ពោះទៅមុខ ដើម្បីអូសទាញមិត្ត និងដៃគូដើម្បីសន្តិភាព ស្ថេរភាពក្នុងតំបន់ ។

- ប្រើប្រាស់រាល់យន្តការ និងរចនាសម្ព័ន្ធ ដើម្បីពង្រឹងសមត្ថភាព ប្រឆាំងនឹងភេរវកម្ម គ្រឿងញៀន ការជួញដូរមនុស្សនិងឧក្រិដ្ឋកម្ម ឆ្លងដែន ។ល ។

- ជំរុញឱ្យមានការពង្រឹងសហគមន៍សន្តិសុខអាស៊ាន ជាមួយនឹងអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងតំបន់ដើម្បីលើកស្ទួយសន្តិភាពអន្តរជាតិ និង សន្តិសុខ។
- ស្វែងរកមធ្យោបាយ និងមាគ៌ាដែលថ្មី និងប្លែក ដើម្បីលើកស្ទួយសន្តិសុខ និងស្ថាបនាយន្តការរបស់ខ្លួន ដើម្បីឱ្យអាស៊ានអាចអនុវត្ត ការដោះស្រាយ និងការបង្ការទំនាស់បានល្អជាងមុន ក៏ដូចជា ដើម្បីកសាងសន្តិភាព ក្រោយសម័យសង្គ្រាមឱ្យបានល្អប្រសើរ និងដើម្បីឱ្យអាស៊ានសម្រេចទស្សនៈឆ្នាំ ២០២០ របស់ខ្លួន។

**<u>អំពីផែនការសកម្មភាពរបស់សហគមន៍សន្តិសុខអាស៊ាន</u> :**

*ការអភិវឌ្ឍន៍ផ្នែកនយោបាយ* (Political Development) ជំរុញសហប្រតិបត្តិការ សន្តិសុខ នយោបាយអាស៊ានឱ្យខ្លាំងក្លាជាងមុន ដើម្បីឱ្យបណ្តាប្រទេសជាសមាជិក បានរួមរស់ក្នុងសន្តិភាព យុត្តិធម៌ ប្រជាធិបតេយ្យ និងការរួបរួមគ្នាជាធ្លុងមួយ។ បណ្តាប្រទេសសមាជិកទាំងអស់ត្រូវគាំទ្រថ្នាក់ដឹកនាំរបស់អាស៊ាន លើកស្ទួយលទ្ធិប្រជាធិបតេយ្យ លើកស្ទួយតម្លៃរួមគ្នាត្រូវមានទស្សនៈដូចគ្នា។ ឆន្ទៈនយោបាយ របស់បណ្តាប្រទេសជាសមាជិកទាំងអស់ មានសារៈសំខាន់ណាស់ ដើម្បីជំរុញឱ្យមានតម្លៃនយោបាយសង្គមរួមគ្នាមួយ។

ដើម្បីឆ្លើយតបឱ្យបានល្អប្រសើរទៅនឹងថាមវ័ន្តថ្មី នៅក្នុងបណ្តាប្រទេសជាសមាជិកនីមួយៗ អាស៊ានត្រូវអប់រំនូវតម្លៃនយោបាយសង្គមរួម និងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។ នៅក្នុងបរិបទនេះបណ្តាប្រទេសជា

សមាជិកមិនត្រូវអនុគ្រោះឱ្យមានការផ្លាស់ប្តូររដ្ឋាភិបាលណាមួយដែលផ្ទុយ ពីរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យឡើយ។

ជំរុញឱ្យមានស្ថេរភាព និងសន្តិភាពជាបន្តបន្ទាប់នៅក្នុងតំបន់។ បណ្តាប្រទេសជាសមាជិកនីមួយៗ ត្រូវអនុវត្តតាមមធ្យោបាយប្រកបដោយសន្តិវិធី ក្នុងការដោះស្រាយជម្លោះផ្ទៃក្នុងតំបន់ ហើយត្រូវចាត់ទុកសន្តិសុខក្នុងប្រទេសខ្លួនថា ជាសន្តិសុខរួមក្នុងព្រំដែនភូមិសាស្ត្រក្នុងទស្សនៈ និងគោលដៅរួម។ ដូច្នេះ អាស៊ានត្រូវបង្កើនសហប្រតិបត្តិការលើផ្នែកនយោបាយរវាងសមាជិករបស់ខ្លួនតាមរយៈ

- ការអភិវឌ្ឍន៍បរិស្ថាន នយោបាយ យុត្តិធម៌ ប្រជាធិបតេយ្យ និងប្រកបដោយភាពសុខដុមនៅក្នុងអាស៊ាន
- លើកស្ទួយសិទ្ធិមនុស្ស និងកាតព្វកិច្ចគោរពសិទ្ធិមនុស្ស
- លើកស្ទួយទំនាក់ទំនងរវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ
- ដោះស្រាយទំនាស់ ដែលកើតមានឡើងនៅលើព្រំដែនគោក ព្រំដែនទឹក និងព្រំដែនអាកាស។

*រួមចំណែកកសាងច្បាប់ទម្លាប់ :*

សហគមន៍អាស៊ាន ដោះស្រាយបញ្ហារបស់ខ្លួនដោយច្បាប់ទម្លាប់ ត្រូវមានទំនាក់ទំនងល្អ ពង្រឹងសាមគ្គីភាពលើកស្ទួយទស្សនៈរួមថា អាស៊ាន គឺជាតំបន់យើង (ជារបស់យើង) រួមចំណែកកសាងសហគមន៍អាស៊ានមួយ ដែលមានលក្ខណៈប្រជាធិបតេយ្យចូលរួម ដោយប្រជាពលរដ្ឋចម្រុះ និងបើកចំហ។

ការរួមចំណែកកសាង ឬចែករំលែកច្បាប់ទម្លាប់នេះ សង្កត់ធ្ងន់ទៅលើគោលការណ៍ ៤ យ៉ាង គឺ

- សម្រេចចិត្តដោយឯករាជ្យ
- ជំរុញសន្តិភាព
- ដោះស្រាយជម្លោះតាមរយៈមធ្យោបាយអហិង្សា
- បដិសេធអាវុធបរមាណូ និងអាវុធមហាប្រល័យដទៃទៀត និង ចៀសវាងការប្រកួតប្រជែងគ្រឿងសព្វាវុធនៅអាស៊ីអាគ្នេយ៍។

*ការបង្ការទំនាស់ :*

ដោយផ្អែកលើគោលការណ៍ ដែលមាននៅក្នុង TAC ដែលជាក្រមសីលធមិគន្លឹះ ក្នុងការគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋទាំងឡាយជាសមាជិក និងការប្រើប្រាស់ការទូត ដើម្បីលើកស្ទួយ សន្តិភាព និង ស្ថេរភាពនៅក្នុងតំបន់ការបង្ការទំនាស់មានគោលដៅដូចខាងក្រោម :

- បង្កើនជំនឿ និងទំនុកចិត្តកម្រិតខ្ពស់បំផុត ក្នុងតំបន់ដោយមិនមើលគ្នាជាការគំរាមកំហែង
- បង្ការកុំឱ្យជម្លោះកើនឡើង ក្នុងចំណោមបណ្តាប្រទេសជាសមាជិក និងពុំមែនជាសមាជិក
- បង្ការកុំឱ្យបញ្ហាបច្ចុប្បន្នក្លាយជាបញ្ហាធំដុំ គឺត្រូវគ្រប់គ្រងបញ្ហា
- ស្ថាបនាជំនឿខាងការងារទូត ជាបែបផែននៃសន្តិសុខថ្មី។

*ការដោះស្រាយទំនាស់ :*

ដោះស្រាយទំនាស់ដែលកើតមានដោយសន្តិវិធី ដោយប្រើប្រាស់អ្នកការទូតភាគីទីបី និងការចរចាជាមូលដ្ឋាន។

*ការស្ថាបនាសន្តិភាពក្រោយទំនាស់ :*

ត្រូវស្វែងរកការបង្កើតល័ក្ខខ័ណ្ឌចាំបាច់ ដើម្បីនិរន្តរភាព នៃ សន្តិភាពក្នុងសម័យក្រោយទំនាស់ និងការពារកុំឱ្យទំនាស់កើតឡើងវិញ។ ក្នុងឋានៈជា មហាគ្រួសារដ៏ធំមួយ, សមាគមអាស៊ានត្រូវរួមគ្នា ខិតខំជួយស្ថាបនាសន្តិភាព ក្រោយសម័យទំនាស់ឱ្យគ្នាទៅវិញទៅមក។ សកម្មភាពទាំងនោះ មានដូចជាការបង្កើត យន្តការជំនួយមនុស្សធម៌ ការកសាង និងស្ថាបនាឡើងវិញ ការប្រមូលផ្តុំធនធាន ក៏ដូចជាការជួយឃ្លាំមើល និងវាយតម្លៃនូវសកម្មភាពទាំងនោះ។

*យន្តការអនុវត្ត :*

ដើម្បីធានាប្រសិទ្ធិភាព នៃការអនុវត្តន៏នូវផែនការសកម្មភាពទាំងនេះ, ខាងក្រោមនេះ គឺជាវិធានការដែលត្រូវអនុវត្ត

- តាមដានសកម្មភាពអនុវត្តទាំង ០៥ ខាងលើតាមរយៈ ការពិគ្រោះគ្នា ការធ្វើការរួមគ្នា ការបង្កើតក្រុមការងារបណ្តោះអាសន្ន ដើម្បីរាយការណ៍ជាប្រចាំទៅថ្នាក់ដឹកនាំជាន់ខ្ពស់អាស៊ាន

- រដ្ឋមន្ត្រីការបរទេសអាស៊ានទាំង ១០ ត្រូវធ្វើការតាមដានរួម ថាតើផែនការទាំងនោះ ត្រូវបានអនុវត្តដូចម្ដេច? តើទិសដៅទៅឆ្នាំ ២០២០ នឹងត្រូវបានសម្រេចទេ?
- អគ្គលេខាធិការអាស៊ាន ត្រូវពិនិត្យមើលតួនាទី មុខងារ និងសមត្ថភាពរបស់លេខាធិការដ្ឋានអាស៊ានក្នុងការគាំទ្រ ការអនុវត្តនីផែនការសកម្មភាពនេះ។

## *ឯកឧត្តមឧត្តមសេនីយ៍ទោ ណឹម សុវត្ថិ*

តើអ្វីទៅសហគមន៍សន្តិសុខអាស៊ាន? តើសហគមន៍សន្តិសុខនេះ មានគុណប្រយោជន៍ ដូចម្ដេចដល់សមាគមអាស៊ាន និងបណ្ដាប្រទេសជាសមាជិក? **ឯកឧត្តមបណ្ឌិត កៅ គឹមហួន** បានបកស្រាយ និងមានមតិយ៉ាងច្បាស់ លាស់ហើយ។ ការពិតសហគមន៍សន្តិសុខអាស៊ាន គឺជារឿងថ្មីដែលទើបតែសម្រេចឱ្យបង្កើត : មានទស្សនៈធំចំនួន ១២ និងផែនការសកម្មភាព៦ យ៉ាងដូច **ឯកឧត្តមបណ្ឌិត កៅ គឹមហួន** បានជំរាបរួចហើយ។ ក៏ប៉ុន្តែផែនការសកម្មភាពទាំង ៦ យ៉ាងនោះ កំពុងត្រូវបានពិភាក្សាគ្នាក្នុងកម្រិតរដ្ឋនៅឡើយ។

សហគមន៍សន្តិសុខអាស៊ាន មានភាពខុសគ្នាពីបក្សសម្ព័ន្ធយោធា។ បក្សសម្ព័ន្ធយោធា គឺជាសម្ព័ន្ធភាពទ័ព ដើម្បីរួមគ្នាប្រយុទ្ធក្នុងសង្គ្រាម តែសហគមន៍សន្តិសុខអាស៊ាន គឺមានគោលដៅដើម្បីស្ថាបនាសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍន៍ក្នុងតំបន់។

គោលដៅចម្បងនៃសហគមន៍សន្តិសុខអាស៊ាន នោះគឺដើម្បីកាត់បន្ថយសង្គ្រាម ហើយស្ថាបនាសន្តិភាព និងការអភិវឌ្ឍន៍។

សហគមន៍សន្តិសុខអាស៊ានមានល័ក្ខខ័ណ្ឌ ៤ យ៉ាងគឺ :

១-មិនឱ្យមានទំនាស់ប្រដាប់អាវុធ (លើកស្ទួយសន្តិភាពក្នុងតំបន់)

២-មិនឱ្យមានការប្រកួតប្រជែងសព្វាវុធ (លើកស្ទួយតុល្យភាព នៃកំណែទម្រង់ទ័ព)

៣-បង្កើតស្ថាប័នបន្ទូរបន្ថយភាពតានតឹង និង

៤-ជំរុញសមាហរណកម្មលើគ្រប់វិស័យក្នុងតំបន់។

សមាគមអាស៊ាន បង្កើតសហគមន៍សន្តិសុខអាស៊ាន គឺជាមធ្យោបាយដ៏មានប្រសិទ្ធិភាពមួយដល់ការប្រឆាំងនឹងភេរវកម្មអន្តរជាតិ ការជួញដូរមនុស្ស និងគ្រឿងញៀន ឧក្រិដ្ឋកម្មឆ្លងដែន និងទំនាស់ដែលអាចឱ្យមានការបែកបាក់ក្នុងតំបន់។ មិនតែប៉ុណ្ណោះ ការបង្កើតសហគមន៍សន្តិសុខអាស៊ាន ក៏គឺដើម្បីលើកស្ទួយវឌ្ឍនភាព លើវិស័យសេដ្ឋកិច្ច និងទេសចរណ៍ផងដែរ។

ជារួម គោលទស្សនៈរបស់សហគមន៍សន្តិសុខអាស៊ាន ពិតជាមានទស្សនាទានល្អដល់ការកសាងសាមគ្គីភាព សហប្រតិបត្តិការភាពជាដៃគូ និងការចូលរួមដ៏ជិតស្និទ្ធដល់ការស្ថាបនាសន្តិភាពក្នុងតំបន់ ពិសេសគឺក្នុងបណ្តាប្រទេសជាសមាជិក ដើម្បីជាគ្រឹះនៃការអភិវឌ្ឍន៍ និងវិបុលភាពក្នុងតំបន់ ក៏ដូចជាក្រៅតំបន់។

គោលទស្សនៈដ៏ល្អប្រសើរបំផុតនៃសមាគមនេះ នោះគឺការបង្ការ និងការដោះស្រាយទំនាស់ ផ្ទៃក្នុងតំបន់ និងបណ្តាប្រទេសជាសមាជិកដោយសន្តិវិធី តាមរយៈការប្រើប្រាស់ទស្សនៈ និងយោបល់រួម និងមធ្យោបាយ ដែលប្រកបដោយសន្តិវិធី ការអត់ឱន និងភាតរភាព ។

**ឃ_អំពីលទ្ធផលនៃកិច្ចពិភាក្សារួម : ចំណេះដឹង និង អនុសាសន៍**

សហគមន៍សន្តិសុខអាស៊ាន មានគោលដៅលើកស្ទួយសន្តិសុខ សុវត្ថិភាព ស្ថេរភាព និងសន្តិភាពក្នុងតំបន់។ ការអភិវឌ្ឍន៍គោលនយោបាយសន្តិសុខនេះ ថ្វីបើមានផែនការ សកម្មភាពរួមសម្រាប់លើកស្ទួយសន្តិសុខក្នុងតំបន់ ក៏ប៉ុន្តែ បណ្តាប្រទេសជាសមាជិក ពុំអាចបាត់បង់នូវភាពម្ចាស់ការ និងស្មារតីទទួលខុសត្រូវរបស់ខ្លួនឡើយ។ ប្រទេសកម្ពុជា ដែលសព្វថ្ងៃមានបញ្ហាប្រឈមមុខមួយចំនួនក្នុងការទប់ស្កាត់ និងលុបបំបាត់ការជួញដូរមនុស្ស និងគ្រឿងញៀន ការរំលោភសិទ្ធិមនុស្ស និងបញ្ហាអន្តោប្រវេសន៍ គួរតែខិតខំរកវិធានការទប់ស្កាត់ ដោយខ្លួនឯងតាម ដែលអាចធ្វើបាន ក៏ប៉ុន្តែ ពុំអាចបោះបង់ចោលនូវសហប្រតិបត្តិការ និងការពឹងពាក់សហគមន៍ សន្តិសុខក្នុងតំបន់ឡើយ ។

អង្គពិភាក្សាស្នើសុំឱ្យរាជរដ្ឋាភិបាល និងសភាជាតិ ពិសេសគឺ ស្ថាប័នពាក់ព័ន្ធមេត្តាយកចិត្តទុកដាក់អំពីបញ្ហានេះ ។

សមាគមអាស៊ាន មានក្រុមប្រឹក្សាជាន់ខ្ពស់របស់ខ្លួន ចាប់តាំងពីឆ្នាំ ១៩៧៦ មកម្ល៉េះ, ក៏ប៉ុន្តែ ក្រុមប្រឹក្សានោះ ពុំទាន់បានធ្វើសកម្មភាពអ្វីឱ្យបានធំដុំនៅឡើយ ទើបតែក្នុងពេលបង្កើតសហគមន៍សន្តិសុខនេះទេ ដែលបានផ្តល់ តួនាទីចម្បងឱ្យក្រុម

ប្រឹក្សានេះ។ ដូច្នេះ ប្រទេសកម្ពុជា ត្រូវបានអង្គពិភាក្សាស្នើសុំឱ្យខិតខំត្រៀម ខ្លួនឱ្យបាន ល្អ ដើម្បីធ្វើសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាជាន់ខ្ពស់នេះ បន្ទាប់ពីផែនការសកម្មភាព នៃសហគមន៍សន្តិសុខអាស៊ានត្រូវបានចាត់តាំងឱ្យអនុវត្ត។

តើប្រទេសកម្ពុជា បានទទួលផលប្រយោជន៍ជាក់ស្ដែងអ្វីខ្លះ ពីសមាគម អាស៊ាន? គណៈវាគ្មិនបានលើកឡើងថា កន្លងមកប្រទេសកម្ពុជាបានទទួលផល ប្រយោជន៍សំខាន់ ០៤ យ៉ាងពីសមាគមអាស៊ាន។ ផលប្រយោជន៍ទាំងនោះគឺ

- ការអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈក្របខ័ណ្ឌអាស៊ាន (ជំនួយតាម រយៈអាស៊ាន)
- ការការពារផលប្រយោជន៍របស់ប្រទេសកម្ពុជា តាមរយៈវេទិកាក្នុង តំបន់អាស៊ាន
- ការប្រើប្រាស់ក្របខ័ណ្ឌទូតអាស៊ាន ដើម្បីតំណាងប្រទេសកម្ពុជា ក្នុងឋានៈ ជាសមាជិកពេញសិទ្ធិមួយ និង
- ការទប់ស្កាត់ (អ្វីបើពុំទាន់បានទាំងស្រុង តែអាចកាត់បន្ថយបាន) ការជួញដូរមនុស្ស និងគ្រឿងញៀន ឧក្រិដ្ឋកម្មឆ្លងដែន បញ្ហាអន្តោ ប្រវេសន៍ និងបញ្ហាព្រំដែន។

ប្រទេសកម្ពុជា ជាសមាជិកអាស៊ានពៅគេ តែបានរៀបចំការប្រជុំកំពូល និង វេទិកាក្នុងតំបន់បានល្អលើសគេ ក្នុងកាលៈទេសៈដែលមានក្ដីព្រួយបារម្ភជាខ្លាំង អំពី បញ្ហាភេរវកម្ម។

អង្គពិភាក្សាបានស្នើសុំឱ្យ សមាជិកសមាជិកានៃកិច្ចពិភាក្សា ពិសេសស្នើសុំឱ្យជនជាតិខ្មែរគ្រប់រូបមានជំនឿទៅលើជាតិយើង ថាពិតជាអាចទទួលបានផលប្រយោជន៍ពិតប្រាកដ ពីសមាគមក្នុងតំបន់នេះ។ បើមានជំនឿដូច្នោះនោះទើបយើងអាចខិតខំបន្តការប្រឹងប្រែង ដើម្បីប្រកួតប្រជែងយកផលប្រយោជន៍បានច្រើនទៀតទៅអនាគត។

អត្ថន័យរួមនៃសហគមន៍សន្តិសុខអាស៊ាននោះគឺសន្តិភាព ស្ថេរភាព និងសន្តិសុខពិតប្រាកដដែលត្រូវធ្វើឱ្យសម្រេចជាស្ថាពរតាមទស្សនៈ ឆ្នាំ ២០២០ របស់សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN)។

អង្គពិភាក្សាស្នើសុំឱ្យសមាជិក សមាជិកា ធ្វើការផ្លាស់ប្តូរមតិពិភាក្សា និងពិចារណាឱ្យបានល្អិតល្អន់ ដើម្បីកុំឱ្យមានការយល់ច្រឡំថា សហគមន៍ សន្តិសុខអាស៊ានគឺជាសហគមន៍យោធា។ គោលដៅតែមួយគត់នៃសហគមន៍នេះ នោះគឺ ដើម្បីសន្តិភាព និងការអភិវឌ្ឍន៍។

ជាអនុសាសន៍រួម អង្គពិភាក្សានៃវេទិកាទី ២ ស្តីពី "ប្រទេសកម្ពុជា និងសហគមន៍សន្តិសុខអាស៊ាន" បានស្នើសុំឱ្យរាជរដ្ឋាភិបាល រដ្ឋសភា និងសង្គមស៊ីវិលមេត្តាបន្តការខិតខំប្រឹងប្រែង :

- ពង្រឹងសន្តិសុខផ្ទៃក្នុង ស្ថេរភាពនយោបាយក្នុងប្រទេស លើកស្ទួយកំណែទម្រង់យោធា និងសន្តិសុខ ដើម្បីពង្រឹងសន្តិភាព និង ការអភិវឌ្ឍន៍
- បន្តការត្រៀមខ្លួនឱ្យបានល្អបន្ថែមទៀត ដើម្បីឱ្យបានទទួលផលប្រយោជន៍ពិតប្រាកដ ឱ្យបានច្រើនទៀតពីសមាគមក្នុងតំបន់នេះ

- អប់រំផ្សព្វផ្សាយអំពីសមាគមអាស៊ាន (គោលដៅ និងផលប្រយោជន៍ចំពោះប្រទេសកម្ពុជា) ដើម្បីឱ្យប្រជាពលរដ្ឋកាន់តែមានការយល់ដឹង និងចូលរួមឧបត្ថម្ភគាំទ្រ និងមានជំនឿលើសមាគមអាស៊ានថា ពិតជាបាននាំមកនូវផលប្រយោជន៍ជូន ប្រទេសជាតិ និងប្រជាពលរដ្ឋកម្ពុជា
- សំអាតផ្ទះសម្បែង ពង្រឹងសន្តិសុខក្នុង ប្រទេសដើម្បីសហការជាមួយសហគមន៍ សន្តិសុខអាស៊ាន សំដៅពង្រឹងសន្តិសុខ ផ្ទៃក្នុងជាតិយើង សន្តិសុខ ក្នុងតំបន់ការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យការគោរពសិទ្ធិមនុស្ស ស្ថេរភាព សុវត្ថិភាព និងសន្តិភាពដើម្បីអភិវឌ្ឍជាតិយើង ឱ្យរួចផុតពីភាពក្រីក្រ និងបានរុង រឿងទៅអនាគត។

## ឃ_សេចក្តីសន្និដ្ឋាន

វេទិកាទី ២ ប្រចាំខែមីនា ឆ្នាំ ២០០៤ ក្រោមប្រធានបទថា "**ប្រទេសកម្ពុជា និងសហគមន៍សន្តិសុខអាស៊ាន**" បានទទួលលទ្ធផលល្អ។ សមាជិកសមាជិកា នៃអង្គពិភាក្សាបានផ្លាស់ប្តូរទស្សនៈ **ចំណេះដឹងមតិយោបល់** និងបានចោទឆ្លើយជាសំណួរ និងចម្លើយជាច្រើនដែលពាក់ព័ន្ធដល់បញ្ហា នៃប្រទេស កម្ពុជា និងសហគមន៍សន្តិសុខអាស៊ាន។ អង្គពិភាក្សាបានរកឃើញថា សហគមន៍ សន្តិសុខអាស៊ាន ដែលនឹងត្រូវបង្កើតឡើងពិតជាមានប្រយោជន៍ដល់ការលើកស្ទួយសន្តិសុខ សន្តិភាព និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា។

ក៏ប៉ុន្តែ ទោះជាដូចម្តេចក្តី ការពឹងពាក់ទាំងស្រុងទៅលើសហគមន៍សន្តិសុខអាស៊ាន ដោយលះបង់ចោលនូវភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ខ្លួន ប្រទេស

កម្ពុជាអាចនឹងបាត់បង់នូវ "*ស្មារតីឧបត្ថម្ភខ្លួនដោយខ្លួនឯង*" ដែលជាវប្បធម៌ ដ៏ជឿនលឿន និងអភិវឌ្ឍបំផុតក្នុងសម័យនេះ។ ទាំងការពឹងពាក់លើសហគមន៍ សន្តិសុខអាស៊ាន ទាំងការពឹងពាក់លើខ្លួនឯង គឺជាកត្តាចម្បង ពីរដែលមិនអាចបដិសេធគ្នាបាន។

អង្គពិភាក្សាស្នើសុំអំពាវនាវ ឱ្យមានការលើកស្ទួយវប្បធម៌ទាំងពីរនេះ ដើម្បីបុព្វហេតុសន្តិសុខ ស្ថេរភាព សុវត្ថិភាព សន្តិភាព និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា និងក្នុងតំបន់។

# វេទិកា ទី ៣ ប្រទេសកម្ពុជា និង តំបន់ពាណិជ្ជកម្មសេរីអាស៊ាន

## ក_សេចក្តីផ្តើម

បន្ទាប់ពីបានសម្រេចលទ្ធផលក្នុងការចងក្រង និងផ្សព្វផ្សាយចំណេះដឹង បទពិសោធន៏, និងអនុសាសន៏នៃវេទិកាទី២ ស្តីពី "**ប្រទេសកម្ពុជា និងសហគមន៍សន្តិសុខអាស៊ាន**" ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៤ មក វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព (CICP) ក៏បានរៀបចំវេទិកាទី ៣ មួយទៀត ស្តីពី "**ប្រទេសកម្ពុជានិងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន** (Cambodia and Asean Free Trade Area (AFTA) កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៤។ វេទិកាទី៣ នេះចូលរួមដោយគណៈវាគ្មិន កិត្តិយស ៣ រូបគឺ: **(១)-ឯកឧត្តមបណ្ឌិត គុណ ញឹម** នាយករងទីចាត់ ការគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអ្នកស្រាវជ្រាវជាន់ ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព **(២)-បណ្ឌិត ចាប សុថារិទ្ធ** ប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អម វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព **(៣)-លោក ម៉ី សុជាតិ** អនុប្រធាននាយកដ្ឋានអាស៊ាន និងសមាហរណកម្មសេដ្ឋកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ វេទិកានេះ សម្របសម្រួល និងដឹកនាំកិច្ចពិភាក្សាដោយ **លោក សំរ៉ាំង កំសាន្ត** អ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសហប្រតិបត្តិការ

និងសន្តិភាព និងចូលរួមជាសមាជិក សមាជិកា ក្នុងកិច្ចពិភាក្សារួមដោយអ្នកតំណាងក្រសួងស្ថាប័ន ពាក់ព័ន្ធសមាជិក រដ្ឋសភា និងព្រឹទ្ធសភា អ្នកតំណាងអង្គការសង្គមស៊ីវិល និស្សិត បញ្ញវន្ត អ្នកសិក្សាស្រាវជ្រាវ និងអ្នកសារពត៌មាន។

ដើម្បីបានជាមូលដ្ឋានដល់ការមានមតិរបស់គណៈវាគ្មិន និងអង្គពិភាក្សារួម **លោក សំរ៉ាំង កំសាន្ត** បានធ្វើការផ្តួចផ្តើមគំនិត សម្រាប់កិច្ចប្រជុំក្នុងវេទិកាទី ៣ ស្តីពី "**ប្រទេសកម្ពុជា និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន**" ដោយបានស្នើសុំឱ្យគណៈវាគ្មិន និងអង្គពិភាក្សាប្រមូលផ្តុំការមានមតិ និងការពិភាក្សាលើគោលដៅសំខាន់ៗបីដូច ខាងក្រោម :

- ស្នើសុំប្រមូលផ្តុំការមានមតិទៅលើសំណួរថា តើអ្វីទៅជាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន? តើតំបន់ពាណិជ្ជកម្មសេរីនេះ ត្រូវបានបង្កើតឡើងដើម្បីអ្វី? តើគេធ្វើពាណិជ្ជកម្មសេរីក្នុងតំបន់នេះដូចម្តេច?
- តើតំបន់ពាណិជ្ជកម្មសេរីអាស៊ាន មានគុណប្រយោជន៍ដូចម្តេចដល់សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ ពិសេសគឺដល់ប្រទេសកម្ពុជា ដែលជាសមាជិកមួយក្នុងតំបន់នេះ? គុណសម្បត្តិ និងការខាតបង់ ឬផលប៉ះពាល់ក្នុងគ្រាដំបូង និងនៅទីបញ្ចប់?
- តើប្រទេសកម្ពុជាគួរធ្វើដូចម្តេច? ដើម្បីចូលរួមធ្វើពាណិជ្ជកម្មសេរីក្នុងតំបន់អាស៊ានឱ្យបានល្អ និងទទួលផលចំណេញពិតប្រាកដ? តួនាទី និងភារកិច្ចរបស់អ្នកដឹកនាំ និងប្រជាពលរដ្ឋកម្ពុជា? សំណូមពរជាអនុសាសន៍?

## ខ_អំពីទស្សនៈ និង មតិរបស់គណៈវាគ្មិនកិត្តិយស

ប្រទេសកម្ពុជាបានចូលជាសមាជិក តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ចាប់តាំងពីថ្ងៃទី១ ខែមករាឆ្នាំ ២០០០ ពោលគឺ បន្ទាប់ពីបានចូលជាសមាជិកពេញសិទ្ធិនៃប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា អាស៊ាននេះមកម្ល៉េះ។ ជាការពិតណាស់ ទាំងបញ្ញវន្ត ទាំងមន្ត្រីរាជការ និងអ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាប្រជាពលរដ្ឋខ្មែរមួយចំនួនធំសុទ្ធតែធ្លាប់បានស្គាល់ និងយល់ដឹងអំពីពាក្យ AFTA នេះហើយ។ ដូច្នេះការនិយាយឱ្យបានច្រើនអំពីសកម្មភាពអនុវត្តន៍របស់ AFTA គឺជាការចាំបាច់ណាស់ដែលអង្គពិភាក្សា គប្បីយកចិត្តទុកដាក់។

កិច្ចព្រមព្រៀង នៃការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន AFTA នេះមានគោលបំណងជាច្រើន ក៏ប៉ុន្តែ គោលដៅជាសក្តានុពលមានដូចខាងក្រោម :

- ដើម្បីបង្កើតឱ្យមានការប្រកួតប្រជែងលើវិស័យពាណិជ្ជកម្ម និងការវិនិយោគទុន នៅតំបន់អាស៊ីអាគ្នេយ៍
- ដើម្បីអូសទាញឱ្យមានការវិនិយោគ ដោយផ្ទាល់លើបរទេស (FDI) និង
- ដើម្បីប្រែក្លាយតំបន់អាស៊ាន ដែលមានប្រជាពលរដ្ឋចំនួន ៥១៥ លាននាក់នេះឱ្យទៅជាទីផ្សារដ៏ធំមួយនៅក្នុងតំបន់ ក៏ដូចជា នៅលើពិភពលោក។

**អំពីយន្តការអនុវត្តន៍ :**

របៀបរបបអនុវត្តន៍ក្នុងការចូលក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន AFTA មានដំណើរការ ដូចខាងក្រោមនេះ :

- ត្រូវរៀបចំបញ្ជីទំនិញដាក់បញ្ចូល ក្នុងកម្មវិធីកាត់បន្ថយពន្ធគយឱ្យស្របទៅតាមគម្រោងអនុគ្រោះពន្ធគយរួម (Common Effective Preferential Tariff CEPT)
- ត្រូវលុបបំបាត់ពន្ធគយនៅក្នុងតំបន់ ពិសេសគឺ នៅក្នុងបណ្តាប្រទេសជាសមាជិកនីមួយៗ
- ត្រូវលុបបំបាត់កម្រិតបរិមាណ គឺត្រូវបើកទីផ្សារឱ្យធំទូលាយដោយត្រូវលុបបំបាត់រនាំងពុំមែនពន្ធគយថែមទៀត។ រនាំងពុំមែនពន្ធគយ គឺបានដល់ការលុបបំបាត់នីតិវិធីគយ និងការគ្រប់គ្រងរដ្ឋបាលគយ។

ប្រទេសកម្ពុជាបានចូលជាសមាជិកពេញសិទ្ធិរបស់អាស៊ាននៅ ថ្ងៃទី ៣១ ខែមេសា ឆ្នាំ ១៩៩៩ ក៏ប៉ុន្តែ ប្រទេសកម្ពុជាត្រូវតែគោរពកិច្ចព្រមព្រៀងអាស៊ានទាំងអស់ ចាប់តាំងពីឆ្នាំ ១៩៦៧ មក។ រហូតមកដល់ពេលនេះ កិច្ចព្រមព្រៀងដែលប្រទេសកម្ពុជា ត្រូវគោរពមានរហូតដល់ ២៧ កញ្ចប់។

**អំពីកិច្ចព្រមព្រៀង AFTA:**

កិច្ចព្រមព្រៀង AFTA បានកំណត់រយៈពេលអនុវត្ត ១០ ឆ្នាំ ក្នុងការកាត់បន្ថយពន្ធគយឱ្យអស់រហូតដល់0-៥%។

ប្រទេសកម្ពុជា បានត្រៀមបញ្ជីមុខទំនិញសម្រាប់អនុវត្តន៏ក្នុង AFTA នេះ ចប់សព្វគ្រប់តាំងតែពី ឆ្នាំ១៩៩៧ មកម្ល៉េះ។ ក៏ប៉ុន្តែ ដោយឆ្នាំនោះ ប្រទេសកម្ពុជា មានវិបត្តិផ្ទៃក្នុងរបស់ជាតិខ្លួន ការចូលជាសមាជិកអាស៊ាន និងការត្រៀមខ្លួនចូលជា សមាជិក AFTA នេះ ត្រូវបានពន្យារហួតដល់ឆ្នាំ ១៩៩៩។

ការងារត្រៀមបញ្ជីស្នាមសម្រាប់ចូលអនុវត្តក្នុង AFTA មាន :

- ការធ្វើបញ្ជីមុខទំនិញដាក់បញ្ចូល (Inclusive list-IL)
- ការធ្វើបញ្ជីមុខទំនិញលើកលែងបណ្តោះអាសន្ន (Temporary Exclusive List-TEL) សម្រាប់អនុវត្ត
- ការធ្វើបញ្ជីមុខទំនិញដែលមានលក្ខណះរសើប (Sensitive List-SL) សម្រាប់ត្រៀមធ្វើការចរចា
- ការធ្វើបញ្ជីមុខទំនិញដាក់ក្នុងបញ្ជីលើកលែងជាទូទៅ (General Exception List-GEL) ដែលជាមុខទំនិញពុំមែនជាកម្មវត្ថុ នៃការធ្វើពាណិជ្ជកម្ម ) ការកាត់បន្ថយពន្ធ។

*ការងារអនុវត្តន៏ជាក់ស្តែង :*

ជារួម គឺមានការបង្កើតឱ្យមានច្រកបែតងចំនួន ៨ កន្លែង នៅប្រទេសយើង សម្រាប់ជួយសម្រួលដល់ការកាត់បន្ថយពន្ធគយតាមដំណាក់កាលនីមួយៗ រហូតដល់ចប់ ជាស្ថាពរនៅឆ្នាំ ២០១៥។

*ការកែប្រែនីតិវិធីគយ :*

- ការកែប្រែនីតិវិធីគយជាដំបូង គឺការបង្កើតច្រកបែតងចំនួន ៨ កន្លែង នេះដើម្បីជួយសម្រួលការអនុវត្តន៍គម្រោងអនុគ្រោះពន្ធគយរួម （CEPT） ឱ្យបានល្អ
- របៀបគិតតម្លៃពន្ធគយឱ្យមានភាពដូចៗ គ្នាឱ្យស្រមតាម WTO
- ការកែប្រែប្រព័ន្ធលេខកូដមុខទំនិញ（Harmonized System）ឱ្យដូចៗគ្នា ដើម្បីងាយស្រួលដល់ការផ្លាស់ប្តូរក្នុងតំបន់។

<u>អំពីគុណប្រយោជន៏របស់ AFTA ចំពោះប្រទេសកម្ពុជា</u> :

ជាទូទៅ បណ្តាប្រទេសជាសមាជិកទាំងអស់ ក្នុងសមាគមអាស៊ានសុទ្ធតែបានទទួលផលប្រយោជន៏ពីតំបន់ពាណិជ្ជកម្មសេរីអាស៊ានតាមរយៈគម្រោង CEPT ដូចៗគ្នា ទៅតាមលទ្ធភាពអំណោយផលជាសក្យានុម័តរបស់ស្ថានភាពសេដ្ឋកិច្ចផ្ទៃក្នុង របស់ជាតិខ្លួន។

ក៏ប៉ុន្តែ ចំពោះប្រទេសកម្ពុជា តាមការព្យាករណ៏របស់អ្នកបច្ចេកទេស និងជំនាញការអាស៊ានថា ប្រទេសកម្ពុជាអាចនឹងទទួលបានផលប្រយោជន៏ធំៗជាច្រើន តាមរយៈការលើវិស័យថ្លៃប្រឌិតមុខទំនិញ ការកែទម្រង់ប្រព័ន្ធច្បាប់ ការពង្រីកទីផ្សារធំទូលាយ ការទទួលបានវត្ថុធាតុដើមបច្ចេកទេសវិជ្ជាថ្មីឯកទេសកម្ម និងមុខទំនិញសម្បូរបែប។

ជាមូលប្រវត្តិ ដែលទាក់ទងនឹងការចូល AFTA នេះ រាជរដ្ឋាភិបាល កម្ពុជាអាណត្តិទី ២ ឆ្នាំ ១៩៩៨-២០០៣ បានដាក់ចេញនូវយុទ្ធសាស្ត្រត្រីកោណ ពោលគឺៈ（១）-ការស្តារ និងរក្សាសន្តិភាព ស្ថេរភាពរបស់ប្រទេសកម្ពុជា តាមរយៈការរំលាយ

បានទាំងស្រុង នូវរចនាសម្ពន្ធខ្មែរក្រហម (២)-ការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ និងការធ្វើសមាហរណកម្មទៅក្នុងតំបន់និងលើពិភពលោក និង (៣)-ការកាត់បន្ថយភាពក្រីក្រ។

អំពីផលប៉ះពាល់ និងផលចំណេញដែលបានមកពីការចាត់តាំងអនុវត្តន៏កម្មវិធី AFTA

ការចូល AFTA តម្រូវឱ្យមានការប្រយ័ត្នប្រយែង។ ក្នុងរយៈពេលខ្លី យើងអាច សម្របសម្រួល ក្នុងការធ្វើបញ្ជីស្នាមមុខទំនិញទាំង ៤ ប្រភេទ ដូចបានលើកឡើងខាងលើ។ ក៏ប៉ុន្តែសម្រាប់រយៈពេលយូរអង្វែងអាចនឹងមានផលប៉ះពាល់ដល់ចំណូលថវិកាជាតិ ដោយត្រូវកាត់បន្ថយពន្ធគយរហូតដល់0-៥% ក្នុងរយៈពេល១០ឆ្នាំ។ ដូច្នេះ ប្រទេសកម្ពុជាគួរតែមានវិធានការឱ្យបានត្រឹមត្រូវ ដើម្បីប្រមូលយកពន្ធលើប្រាក់ចំណេញ (២0%) និងតម្លៃពន្ធប្រើប្រាស់ (VAT) លើមុខទំនិញនាំចូលសម្រាប់បំពេញជំនួសការបាត់បង់ពន្ធគយ។ ម្យ៉ាងទៀតការបង្កើនចំណូលសារពើពន្ធ និងអាករផ្សេងៗ គឺជាការចាំបាច់ណាស់ ដែលត្រូវធ្វើដើម្បីរក្សាតុល្យភាពនៃចំណូលថវិការដ្ឋក្នុងការកាត់បន្ថយពន្ធគយនេះ។

ផលប៉ះពាល់មួយទៀត នោះគឺការនាំចូលមកច្រើននូវទំនិញក្នុងតំបន់ និងក្រៅតំបន់ដែលអាចធ្វើឱ្យផលិតផលក្នុងស្រុករបស់យើងបាត់បង់គុណភាព និងការប្រើប្រាស់។ ក៏ប៉ុន្តែ យើងក៏អាចទទួលបានមកវិញនូវបច្ចេកវិជ្ជាថ្មី និងគំនិតច្នៃប្រឌិតមុខទំនិញថ្មីដើម្បីប្រកួតប្រជែងជាមួយ បរទេស។

ជាផលវិជ្ជមានការចូលក្នុង AFTA របស់ប្រទេសកម្ពុជា អាចនឹងទទួលបាននូវផលចំណេញជាច្រើន ដូចជា (១)-គំនិតច្នៃប្រឌិតក្នុងការ ផលិតមុខទំនិញ (២)-កំណែទម្រង់ច្បាប់ដើម្បីអូសទាញជំនឿ និងទំនុកចិត្តរបស់វិនិយោគិន ការទទួលបាន

ទីផ្សារធំ ទូលាយសម្រាប់ប្រជាពលរដ្ឋ អាស៊ានជាង ៥១៥ លាននាក់ (៣)-ការទទួលបានវត្ថុធាតុដើមសម្រាប់ ផលិតទំនិញក្នុងស្រុក (៤)-ការទទួលបានជំនាញគ្រប់គ្រងបច្ចេកវិជ្ជា និងផលិតផលថ្មី (៥)-ការទទួលបានឯកទេសកម្ម និង (៦)-ការទទួលបានមុខទំនិញច្រើនប្រភេទតែមានតម្លៃថោក។

<u>អំពីបញ្ហាប្រឈមមុខក្នុងការអនុវត្តន៍កម្មវិធី</u> AFTA :

ការអនុវត្តន៍កម្មវិធីតំបន់ពាណិជ្ជកម្មសេរីអាស៊ាន មានបញ្ហាប្រឈមមុខ មួយចំនួនដែលចាំបាច់ត្រូវខិតខំជម្នះឱ្យបាន ដើម្បីកាត់បន្ថយគ្រោះអវិជ្ជមាន ដែលបានមកពីការអនុវត្តន៍នេះ។ បញ្ហាប្រឈមមុខទាំង នោះគឺ :

- ការប្រកួតប្រជែងធ្វើពាណិជ្ជកម្ម ក្នុងតំបន់សេរីអាស៊ាន ដែលទាមទារឱ្យមានផលិតផលក្នុងស្រុកសម្បូរបែប និងប្រកបដោយគុណភាព
- បញ្ហាធនធានមនុស្ស និងសមត្ថភាព
- ភាពទន់ខ្សោយនៃផលិតកម្មក្នុងស្រុក
- ការផ្លាស់ប្តូរឥតឈប់ឈរនៃការវិនិយោគទុនទៅតាមចង្វាក់នៃសាកលភាវូប-នីយកម្ម និងសេរីភាវូបនីយកម្មលើវិស័យសេដ្ឋកិច្ច
- ជីវភាពក្រីក្ររបស់ប្រជាពលរដ្ឋ និង
- អស្ថេរភាពនយោបាយ និងភាពយឺតយ៉ាវនៃដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ល។

**គ_ការបូកសរុបលទ្ធផលនៃកិច្ចពិភាក្សារួម: ចំណេះដឹង និង អនុសាសន៍ :**

បន្ទាប់ពីបានស្ដាប់ការមានមតិរបស់គណៈវាគ្មិនកិត្តិយស ស្ដីពី ប្រទេសកម្ពុជា និងតំបន់ពាណិជ្ជកម្មសេរីអាស៊ានមកអង្គពិភាក្សារួមក៏បាន ចាប់ផ្ដើមផ្លាស់ប្ដូរមតិទៅលើការខាតបង់ និងផលចំណេញរបស់ប្រទេសកម្ពុជាក្នុងការចូល AFTA បញ្ហាវិនិយោគទុន ផលិតកម្មមុខទំនិញក្នុងស្រុក ការលើកទឹកចិត្តផលិតករ និងកសិករបញ្ហានៃការធ្វើចរាចរទំនិញ និងពន្ធអាករ។ គណៈវាគ្មិនកិត្តិយសបានឆ្លើយបំភ្លឺ សំណួរទាំងនោះ ដែលមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម :

*១- អំពីមូលប្រវត្តិនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន :*

ទស្សនាទាននៃការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ដែលហៅកាត់ថា (AFTA) នេះមានមកតាំងតែពីឆ្នាំ ១៩៩០ មកម្ល៉េះ។ គំនិត នេះត្រូវបានផ្ដួចផ្ដើមឡើងដោយអតីតនាយករដ្ឋមន្ត្រីថៃ ឈ្មោះអាណន់ដ៏ ប៉ានញ៉ារ៉ាជុន (Annand Panyarachun)។ បន្ទាប់មកនៅខែមករា ឆ្នាំ ១៩៩២ ប្រទេសជាសមាជិកអាស៊ានចំនួន ៦ ប្រទេស ដែលរួមមានប្រទេសថៃ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ហ្វីលីពីន សឹង្ហបុរី និងព្រុយណេ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្ដីពី "គម្រោងអនុគ្រោះពន្ធគយរួម (Common Effective Prefential Tariff Scheme)" នៅសឹង្ហបុរី សម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ដែលត្រូវអនុវត្តឱ្យបានសម្រេចនៅឆ្នាំ ២០០៨។ ក៏ប៉ុន្តែ, នៅឆ្នាំ១៩៩៥ ថ្នាក់ដឹកនាំអាស៊ានបានឯកភាពជំរុញការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ឱ្យបានសម្រេចនៅឆ្នាំ ២០០៣ និងមានការផ្លាស់ប្ដូរជាបន្តបន្ទាប់ទៀត។ គោលដៅសំខាន់នៃ AFTA គឺ ដើម្បីធ្វើសេរីភាវូបនីយកម្ម និងបង្កើតទីផ្សារអាស៊ានក្នុងស្រុក

ដែលធ្វើសមាហរណកម្មគ្នាមួយសម្រាប់ប្រជាពលរដ្ឋចំនួន ៥១៥ លាននាក់នោះគឺ ជាការផ្តល់មូលដ្ឋានដ៏មានប្រសិទ្ធិភាព និងប្រកួតប្រជែងមួយដល់ពាណិជ្ជកម្មនៅក្នុងតំបន់ និង ការវិនិយោគផ្ទាល់ពីបរទេស ។

## ២- *អំពីគោលបំណងសំខាន់នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន :*

អង្គពិភាក្សាបានរកឃើញថា "តំបន់ពាណិជ្ជកម្មសេរីអាស៊ាន" មានគោលដៅសំខាន់ជាច្រើន ក្នុងការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មរបស់អាស៊ានឱ្យមានសេរីភាវូបនីយកម្ម និងការអភិវឌ្ឍន៍ ។ គោលដៅទាំងនោះគឺ : (១) -ដើម្បីធ្វើកិច្ចសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្មសេរីក្នុងតំបន់ ឱ្យមានការរីកដុះដាល (២) -ដើម្បីប្រែក្លាយតំបន់អាស៊ីអាគ្នេយ៍ ឱ្យទៅជាតំបន់ពាណិជ្ជកម្មសេរីពិតប្រាកដមួយសំដៅសម្រួល កិច្ចការវិនិយោគ និងទាក់ទាញវិនិយោគគិនបរទេស (៣) -ដើម្បីជួយបង្កើនពាណិជ្ជកម្មក្នុងតំបន់សំដៅកាត់បន្ថយការពឹងផ្អែក តែទៅលើសេដ្ឋកិច្ចពីខាងក្រៅ (៤) -ជំរុញការបើកចំហសេដ្ឋកិច្ច និងការធ្វើសមាហរណកម្មទៅក្នុងតំបន់ និង(៥) -ជួយជំរុញបន្ថែមការបែងចែកពលកម្មក្នុងតំបន់ ដែលទាំងអស់នេះមានគោលដៅចម្បងមួយ នោះគឺធ្វើឱ្យសម្រេចជោគជ័យនូវទស្សនាទាននៃសហគមន៍សេដ្ឋកិច្ច អាស៊ាន ។

## ៣- *អំពីគោលបំណង និងផលប្រយោជន៍របស់កម្ពុជាក្នុងការចូល* AFTA :

ប្រទេសកម្ពុជាចូល AFTA ដោយមានបំណង :

ទី១- ដើម្បីធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និងលើពិភពលោក សំដៅធ្វើឱ្យសម្រេចការអភិវឌ្ឍន៍ប្រទេសជាតិ ឱ្យមានសមធម៌ យុត្តិធម៌ សន្តិភាព

តាមរយៈការលើកស្ទួយវឌ្ឍនភាពលើវិស័យសេដ្ឋកិច្ច និងគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ទី២- ដើម្បីយក AFTA ជាមូលដ្ឋានហ្វឹកហ្វឺនត្រៀមចូលជាសមាជិក APEC និង WTO ។

ទី៣- ដើម្បីលើកស្ទួយការអភិវឌ្ឍន៍ធនធានមនុស្ស ការហ្វឹកហ្វឺនវិជ្ជាជីវៈ និងសហប្រតិបត្តិការសេដ្ឋកិច្ច។

ទី៤- ដើម្បីជាវិភាគទានដល់ការកែទម្រង់វិស័យសេដ្ឋកិច្ច និងអភិបាលកិច្ចល្អនៅកម្ពុជា និង

ទី៥- ដើម្បីបង្កើនទីផ្សារពង្រីកផលិតផលទំនិញ ដែលអាចអូសទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) សំដៅដោះស្រាយបញ្ហាការងារ និងមុខរបរជូនប្រជាពលរដ្ឋ។ ដើម្បីសម្រេចគោលដៅនេះ ប្រទេសកម្ពុជាចាំបាច់ត្រូវលើកស្ទួយផលប្រយោជន៍ប្រៀបធៀប តាមរយៈ ការផ្លាស់ប្តូរមុខទំនិញ និងសេវាក្នុងតំបន់។ ដូច្នេះប្រទេសកម្ពុជា ត្រូវបង្កើនផលិតផល និងគុណភាពមុខទំនិញ និងការផ្តល់សេវារបស់ខ្លួនឱ្យបានល្អ ដើម្បីប្រកួតប្រជែងជាមួយគេឯងក្នុងតំបន់។

៤- *<u>អំពីការលំបាកជាសន្ទានុម័តរបស់ប្រទេសកម្ពុជា ក្នុងសមាជិក AFTA</u> :*

- បញ្ហាធនធានមនុស្ស ដែលចាំបាច់ត្រូវមានសមត្ថភាពយល់ដឹងលើគ្រប់វិស័យពិសេសគឺវិស័យគយ និងរដ្ឋាករ

- បញ្ហាផលិតកម្មមុខទំនិញក្នុងស្រុក ដែលនៅមានភាពទន់ខ្សោយ និងកង្វះបច្ចេកវិជ្ជាផលិតកម្មខ្ពស់
- បញ្ហាហិរញ្ញវត្ថុ ថវិការដ្ឋ និងការប្រមូលពន្ធ
- បញ្ហាជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងភាពក្រីក្រ
- បញ្ហាដឹកនាំគ្រប់គ្រង និងអភិបាលកិច្ចល្អដែលកំពុងត្រូវបានកែលំអ និងកែទម្រង់
- បញ្ហាការិយាធិបតេយ្យ និងការអនុវត្តនីតិវិធីកំណែទម្រង់ថ្មី ដែលទាមទារឱ្យមានឆន្ទៈនយោបាយ ការប្តេជ្ញាចិត្តខ្ពស់ និងពេលវេលាអនុវត្តន៍យូរអង្វែង។

## ៥- *អំពីទិសដៅដែលត្រូវអនុវត្តទៅអនាគត និងសំណូមពរជាអនុសាសន៍ :*

អង្គពិភាក្សារួម បានរកឃើញទិសដៅ និងសំណូមពរដែលត្រូវអនុវត្តមួយចំនួនដូចខាងក្រោម :

- ស្នើសុំលើកស្ទួយការអភិវឌ្ឍន៍ធនធានមនុស្ស លើវិស័យគយ និងរដ្ឋាករឱ្យមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងរបស់ AFTA ដើម្បីទទួលបានផលប្រយោជន៍ពិតប្រាកដ ពីគម្រោងអនុគ្រោះពន្ធគយរួម (CEPT)
- ស្នើសុំបន្តការខិតខំប្រឹងប្រែងលើកស្ទួយការអភិវឌ្ឍន៍ ផ្នែកឯកជន លើវិស័យផលិតកម្ម, ផលិតមុខទំនិញ និងបច្ចេកវិជ្ជាផលិត

- ស្នើសុំបន្តការកែទម្រង់ប្រព័ន្ធច្បាប់ និងនីតិរដ្ឋលើវិស័យពាណិជ្ជកម្ម និងពន្ធគយ ឱ្យស្របតាមកិច្ចព្រមព្រៀងក្នុងការចូល AFTA និង គម្រោងអនុគ្រោះពន្ធគយរួមរបស់អាស៊ាន

- ស្នើសុំលើកស្ទួយការប្រមូលពន្ធក្នុងស្រុក ដើម្បីជំនួសពន្ធគយដែលត្រូវកាត់បន្ថយ ក្នុងពេលអនុវត្តគម្រោងអនុគ្រោះពន្ធគយរួមដែលនឹងប្រព្រឹត្តទៅ នៅឆ្នាំ ២០០៧ ខាងមុខនេះ

- ស្នើសុំពង្រឹងឆន្ទៈនយោបាយ និងសេរីភាវូបនីយកម្មលើវិស័យសេដ្ឋកិច្ច ដើម្បីជំរុញការអនុវត្តន៍កម្មវិធី AFTA កម្ពុជាឱ្យបានល្អ

- ស្នើសុំបន្តការអប់រំផ្សព្វផ្សាយ អំពីផលប្រយោជន៍របស់ប្រទេសកម្ពុជា ដែលបានពីមកការចូល AFTA ឱ្យបានទូលំទូលាយសំដៅស្ថាបនាកម្លាំងគាំទ្រ និងការចូលរួមរបស់ប្រជាពលរដ្ឋ

- ស្នើសុំបន្តការលើកស្ទួយមត្តទ្ទេសភាព និងការគ្រប់គ្រងប្រកបដោយលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អដើម្បីស្ថាបនាបរិស្ថានដឹកនាំស្អាតស្អំសំដៅអូសទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) និងការអនុវត្តន៍គម្រោងអនុគ្រោះពន្ធគយរួមឱ្យបានទទួលលទ្ធផលល្អ។

## ឃ_ សេចក្តីសន្និដ្ឋាន

ជាសេចក្តីសន្និដ្ឋាន កិច្ចពិភាក្សាក្នុងវេទិកា ទី ៣ ស្តីពី "ប្រទេសកម្ពុជា និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន" បានទទួលលទ្ធផលល្អដោយបាននាំមកនូវចំណេះដឹង និងពត៌មានថ្មីៗជាច្រើន ស្តីពីប្រទេសកម្ពុជានិង AFTA។ បន្ទប់ពីបានទទួលការយល់ដឹង

តាមរយៈការបំភ្លឺរបស់គណៈវាគ្មិន និងការផ្លាស់ប្តូរមតិយោបល់លើប្រធានបទនេះ។ អង្គពិភាក្សាបានធ្វើសំណូមពរ និងអនុសាសនសំខាន់ៗ ជាច្រើនដែលពាក់ព័ន្ធដល់ការលើកស្ទួយការអនុវត្តន៏កិច្ចព្រមព្រៀង AFTA។ និងប្រទេសកម្ពុជា ឱ្យបានល្អប្រសើរទៅអនាគត។ សំណូមពរទាំងនោះគឺជាទស្សនៈ និងមតិរបស់អង្គពិភាក្សា ទោះបីមិនតិចក៏ច្រើន នោះគឺជាការរួមចំណែករបស់សង្គមស៊ីវិល ដែលផ្អែកឯកជនក្នុងការលើកស្ទួយវិស័យសេដ្ឋកិច្ចជាតិ និងការធ្វើសមាហរណកម្មទៅក្នុងតំបន់ ឱ្យបានប្រកបដោយជោគជ័យ។

សង្ឃឹមថា ទស្សនៈ និងសំណូមពរទាំងនេះអាចនឹងបំពេញបាននូវសេចក្តីត្រូវការរបស់ប្រទេសជាតិ និងប្រជាពលរដ្ឋក្នុងការកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ឱ្យបានរុងរឿងទៅអនាគត។

# វេទិកា ទី ៤ ប្រទេសកម្ពុជា និង សហគមន៍សេដ្ឋកិច្ចអាស៊ាន

## ក_សេចក្តីផ្តើម :

វេទិកាទី ៤ ស្តីពី "**ប្រទេសកម្ពុជា និងសហគមន៍សេដ្ឋកិច្ចអាស៊ាន**" (Cambodian and ASEAN Economic Community) គឺជាវេទិកាដ៏សំខាន់មួយនៃវេទិកាទាំង ១០ ក្នុងឆ្នាំ ២០០៤ ដែលរៀបចំឡើងដោយវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព និងឧបត្ថម្ភ ដោយមូលនិធិ **ហ្វ្រីឌ្រីច អេប៊ែត** និងដែលប្រមូលផ្តុំកិច្ចពិភាក្សាទៅលើប្រធានបទសំខាន់ៗ ពាក់ព័ន្ធប្រទេសកម្ពុជា ទៅនឹងសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា អាស៊ាន (ASEAN)។

ចូលរួមជាវាគ្មិនកិត្តិយស នៃវេទិកានេះរួមមាន : **(១)-ឯកឧត្តម សុន គន្ធរ** ប្រធានអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ **(២)-លោក ឌី សុវណ្ណ** អនុប្រធាននាយកដ្ឋានផែនការគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង **បណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី** ប្រធាននាយកដ្ឋានត្រួតពិនិត្យគម្រោង គណៈកម្មការវិនិយោគកម្ពុជា ក្រុមប្រឹក្សាវិនិយោគកម្ពុជា (CDC)។ វេទិកាលើកទី ៤ ត្រូវបានសម្របសម្រួល និងដឹកនាំកិច្ចពិភាក្សាដោយ **លោក សំរ៉ាំង កំសាន្ត** អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព។ សមាជិក

សមាជិកានៃកិច្ចពិភាក្សា គឺសុទ្ធសឹងជាអ្នកតំណាង ស្ថាប័នរដ្ឋ អ្នកដឹកនាំអង្គការសង្គមស៊ីវិលផ្នែក ឯកជន និស្សិត បញ្ញវន្ត និង អ្នកសារពតិមាន។

មុននឹងបើកកិច្ចពិភាក្សា អ្នកសម្របសម្រួល និងដឹកនាំកិច្ចពិភាក្សាបាន ធ្វើរបាយការណ៍ ដោយសង្ខេបមួយ ស្តីពី លទ្ធផលនៃវេទិកាទី ៣ ដែលបានប្រព្រឹត្តទៅកាលពីខែមុនជុំវិញប្រធានបទមួយ ដែលផ្តោតការយកចិត្តទុកដាក់ ទៅលើការអនុវត្តន៍កិច្ចព្រមព្រៀង "តំបន់ពាណិជ្ជកម្មសេរីអាស៊ាន" និងប្រទេសកម្ពុជា។ ការលើក យកលទ្ធផលនៃកិច្ចពិភាក្សាលើកទី ៣ មកជំរាបជូនក្នុងពេលនេះគឺ ដើម្បីបានជាមូលដ្ឋានដល់កិច្ចពិភាក្សាក្នុងវេទិកាទី ៤ នេះ។

## ខ_ អំពីការផ្តួចផ្តើមគំនិតសម្រាប់វេទិកាទី ៤ ស្តីពី ប្រទេសកម្ពុជា និង សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)

មុននឹងប្រគល់វេទិកាជូនគណៈវាគ្មិនកិត្តិយសទាំងបី **លោក សំរ៉ាំង កំសាន្ត** បានស្នើសុំឱ្យគណៈវាគ្មិន និងអង្គពិភាក្សាចូលរួមបញ្ចេញទស្សនៈ និងប្រមូលផ្តុំការមានមតិទៅលើចំណុចមួយចំនួនដូចខាងក្រោម ៈ

- ស្នើសុំបញ្ចេញមតិទៅលើសញ្ញាណគោលដៅនិងសំណូមពររបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន ថាតើមានគោលដៅដូចម្តេច ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់?
- ស្នើសុំបញ្ចេញមតិទៅលើអត្ថប្រយោជន៍ ពិសេសគឺ លទ្ធផលជាអវិជ្ជមានរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន ថាតើសហគមន៍នេះនឹង ផ្តល់ផល

ប្រយោជន៍អ្វីខ្លះ ដល់បណ្តាប្រទេសជាសមាជិក ពិសេសគឺ ប្រទេសកម្ពុជា?

- ស្នើសុំបញ្ចេញមតិ ដើម្បីរកឱ្យឃើញថា តើប្រទេសកម្ពុជាគួរធ្វើដូចម្តេចដើម្បីចូលរួមឱ្យបានល្អ នឹងទទួលបានផលប្រយោជន៍ពិតប្រាកដ ពីសហគមន៍សេដ្ឋកិច្ចអាស៊ាននេះ? ទិសដៅដែលត្រូវអនុវត្ត? សំណូមពរជាអនុសាសន៍?

## គ_ មតិរបស់គណៈវាគ្មិនកិត្តិយស

គណៈវាគ្មិនកិត្តិយសទាំងបី គឺ : **(១)-ឯកឧត្តម សុន គន្ធរ** ប្រធានអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ **(២)-លោក ឌី សុខណ្ណ** តំណាង ឯកឧត្តម **ហង់ ជួនណារ៉ុន** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង **បណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី** ប្រធាននាយកដ្ឋានត្រួតពិនិត្យគម្រោងគណៈ កម្មការវិនិយោគកម្ពុជា ក្រុមប្រឹក្សាវិនិយោគកម្ពុជា (CDC) បានមានមតិទៅតាមទស្សនៈ និងជំនាញផ្ទាល់របស់លោក ដែលពាក់ព័ន្ធទៅនឹងសហគមន៍សេដ្ឋកិច្ចអាស៊ាននេះ។ ទស្សនៈគោលមួយចំនួនត្រូវបានយកធ្វើជាប្រធានបទនៃកិច្ចពិភាក្សា។ ជារួមទស្សនៈរបស់គណៈវាគ្មិនកិត្តិយសទាំងបី អាចឆ្លើយតបទៅនឹងបំណងដែលវិទ្យាស្ថានចង់បានដូច **លោក កំសាន្ត** បានផ្តួចផ្តើមគំនិត ស្នើសុំឱ្យគណៈវាគ្មិន និងអង្គពិភាក្សារួមប្រមូលផ្តុំការមានមតិបកស្រាយ។

ខាងក្រោមនេះ គឺជាចំណេះដឹងមួយចំនួន ដែលយើងប្រមូលផ្តុំ បានតាមរយៈទស្សនៈ និងមតិរបស់គណៈវាគ្មិន :

**អំពីសហគមន៍សេដ្ឋកិច្ចអាស៊ាន :**

សហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community) គឺជាសហគមន៍ធំមួយក្នុងចំណោមសហគមន៍ទាំង III របស់អាស៊ាន គឺសហគមន៍សន្តិសុខសហគមន៍សេដ្ឋកិច្ច និងសហគមន៍សង្គមវប្បធម៌អាស៊ាន។

សហគមន៍នេះគឺ ជាសមិទ្ធផលចុងក្រោយ ដែលត្រូវធ្វើឱ្យសម្រេចក្នុងឆ្នាំ ២០២០ (ASEAN Vision 2020) បន្ទាប់ពីបានធ្វើសមាហរណកម្មវិស័យសេដ្ឋកិច្ច នៃបណ្ដាប្រទេសជាសមាជិកទាំងអស់ទៅក្នុងសហគមន៍រួមតែមួយរបស់អាស៊ាន នោះគឺ សហគមន៍សេដ្ឋកិច្ចនោះឯង។

**អំពីគោលដៅរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន :**

ជាគោលដៅរួមរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាននោះគឺ ដើម្បីបង្កើតឱ្យមានការប្រកួតប្រជែងលើវិស័យសេដ្ឋកិច្ច ក្នុងតំបន់សំដៅធ្វើឱ្យបណ្ដាប្រទេសជាសមាជិកមានស្ថេរភាពវិបុលភាព និងការប្រឡងប្រណាំងអភិវឌ្ឍសេដ្ឋកិច្ច របស់ខ្លួនឱ្យបានរុងរឿងទៅអនាគត។ ជាសកម្មភាពអនុវត្ត គឺត្រូវធ្វើឡើងតាមរយៈពាណិជ្ជកម្ម ដោយសេរី ការផ្ដល់សេវាទៅវិញទៅមកការវិនិយោគរួមគ្នាការដាក់ដើមទុន រួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយគម្លាតនៃសេដ្ឋកិច្ចសង្គម។ កិច្ចការទាំងអស់នេះត្រូវធ្វើឱ្យសម្រេចក្នុងឆ្នាំ ២០២០ (តាមទស្សនៈឆ្នាំ ២០២០ របស់អាស៊ាន Bali Concord II ខែតុលា ឆ្នាំ ២០០៣)។

គោលដៅជាយុទ្ធសាស្ត្រចម្បងបំផុត របស់សហគមន៍សេដ្ឋកិច្ចអាស៊ាន គឺផ្អែកទៅលើផលប្រយោជន៍រួម (Convergence of Interests) របស់បណ្ដាប្រទេសជា

សមាជិកទាំងអស់ដោយត្រូវចាក់គ្រឹះ និងពង្រីកការខិតខំប្រឹងប្រែង ធ្វើសមាហរណកម្ម លើវិស័យទាំងអស់ របស់សហគមន៍អាស៊ានឱ្យទៅជាសហគមន៍សេដ្ឋកិច្ចតែមួយគត់ក្នុងឆ្នាំ ២០២០។

ដូច្នេះ ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះអាស៊ានត្រូវ : (១)-ស្ថាបនា តំបន់អាស៊ានឱ្យទៅជាមូលដ្ឋានផលិតកម្ម និងជាទីផ្សារតែមួយគត់ដោយត្រូវប្រែក្លាយភាពដោយឡែកនៃប្រទេសជាតិនីមួយៗ ឱ្យទៅជាភាពរួមក្នុងតំបន់ដើម្បីឱ្យអាស៊ាន ក្លាយទៅជាតំបន់ផ្គត់ផ្គង់សេដ្ឋកិច្ចដ៏មានថាមភាព និងដ៏ខ្លាំងក្លាមួយ ក្នុងតំបន់ និងលើពិភពលោក (២)-លើកស្ទួយការប្រកួតប្រជែងលើវិស័យសេដ្ឋកិច្ច នៃបណ្តាប្រទេសជាសមាជិកទាំងអស់ក្នុងតំបន់។

ម្យ៉ាងទៀត ដើម្បីធ្វើដំណើរឆ្ពោះទៅរកសហគមន៍សេដ្ឋកិច្ចនេះឱ្យបានជោគ-ជ័យសមាគមអាស៊ានចាំបាច់ត្រូវ : (១)-រៀបចំយន្តការស្ថាប័ន និងយន្តការថ្មី និងវិធានការពង្រឹងការអនុវត្តន៍កិច្ចព្រមព្រៀង AFTA, AFAS (កិច្ចព្រមព្រៀងលើវិស័យច្បាប់សេវាអាស៊ាន) (២)-បង្កើនល្បឿននៃការធ្វើសមាហរណកម្ម លើផ្នែកអាទិភាពដទៃទៀតក្នុងតំបន់ (៣)-សម្របសម្រួលចលនាពាណិជ្ជករពលកម្មជំនាញ និងឧបនិស្ស័យនិង (៤)-ពង្រឹងយន្តការស្ថាប័នអាស៊ានជារួម គឺត្រូវធ្វើឱ្យយន្តការដោះស្រាយទំនាស់របស់អាស៊ាន (ASEAN Dispute Settlement Mechanism) ឱ្យមានលក្ខណៈល្អប្រសើរដើម្បីធានា ការដោះស្រាយជំលោះ សេដ្ឋកិច្ចតាមផ្លូវច្បាប់។

***<u>អំពីការធានា</u> :***

ដើម្បីឱ្យសហគមន៍សេដ្ឋកិច្ចអាស៊ានបានសម្រេចជោគជ័យនៅក្នុង ឆ្នាំ ២០២០ អាស៊ានត្រូវធានាឱ្យបានថា ការចាក់គ្រឹះ និងការពង្រីកសមាហរណកម្មលើវិស័យសេដ្ឋកិច្ចនៃបណ្តាប្រទេសជាសមាជិក ត្រូវតែមានសហប្រតិបត្តិការលើវិស័យបច្ចេកទេស និងការអភិវឌ្ឍន៍។ ធ្វើដូច្នេះ គឺដើម្បីចែករំលែកការអភិវឌ្ឍន៍ និងល្បឿននៃការធ្វើសមាហរណកម្មលើវិស័យសេដ្ឋកិច្ចនៃបណ្តា ប្រទេសជាសមាជិកថ្មី ដូចជា កម្ពុជា ឡាវ ភូមា និងវៀតណាម តាមតំបន់វិនិយោគអាស៊ានទីមួយៗនេះ បានទទួលផលប្រយោជន៍ដូចគ្នា និងមានការអភិវឌ្ឍន៍ទៅមុខក្នុងល្បឿនដូចគ្នា។

ជាសេចក្តីសន្និដ្ឋាន ដើម្បីឱ្យសម្រេចទាំងស្រុង នូវសហគមន៍សេដ្ឋកិច្ចសមាហរណកម្មមួយបាន សមាគមអាស៊ានចាំបាច់ត្រូវតែមាន ការអនុវត្តន៍ វិធានការសំខាន់ៗពីរ គឺ : (I)_ការលើកស្ទួយផែនការសេរីភាវូបនីយកម្មលើ វិស័យសេដ្ឋកិច្ច និង (II)-ការលើកស្ទួយវិធានការនៃសហប្រតិបត្តិការ។

ម្យ៉ាងទៀត ដើម្បីឱ្យវិធានការទាំង II នេះបានសម្រេចសមាគមអាស៊ានចាំបាច់ត្រូវលើកស្ទួយសហប្រតិបត្តិការ និងសកម្មភាពសមាហរណកម្ម លើវិស័យសំខាន់ៗមួយចំនួន ដូចជាការអភិវឌ្ឍន៍ធនធានមនុស្ស និងការស្ថាបនា សមត្ថភាព ការទទួលស្គាល់គុណភាពអប់រំ ការប្រឹក្សាយោបល់ជិតស្និទ្ធទៅលើ គោលនយោបាយខាងមីក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ វិធានការផ្តល់ហិរញ្ញវត្ថុ ពាណិជ្ជកម្ម ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់គ្នានៃ គមនាគមន៍ការអភិវឌ្ឍន៍លើកិច្ចការជំនាញខាង Electronic តាមបណ្តាញរបស់ ASEAN ការធ្វើសមាហរណកម្មឧស្សាហកម្មឆ្លងកាត់តំបន់ និងការបង្កើនការចូលរួមរបស់ផ្នែកឯកជន។

## ង_លទ្ធផលនៃកិច្ចពិភាក្សារួម និងសំណូមពរជាអនុសាសន៍

ដើម្បីចូលរួមក្នុងសហគមន៍ សេដ្ឋកិច្ចអាស៊ានឱ្យបានល្អ ការលើកស្ទួយការអភិវឌ្ឍន៍ជនបទ គឺជាការសំខាន់ណាស់។ វឌ្ឍនភាពនៃសេដ្ឋកិច្ចគ្រួសារខ្មែរ ពុំអាចកាត់ផ្តាច់បានពីការផ្តល់ទុន និងឥណទានទេ។ ក៏ប៉ុន្តែ ការផ្តល់ឥណទាននេះ ចាំបាច់ត្រូវតែមានសមធម៌ ការប្រើប្រាស់ឥណទានឱ្យមានប្រសិទ្ធិភាព (ការប្រាក់តិច) និងការគ្រប់គ្រងឱ្យបានល្អ។

ការធ្វើសមាហរណកម្មទៅក្នុងសមាគមអាស៊ាន ពិសេសគឺការចូល AFTA និង សហគមន៍សេដ្ឋកិច្ចអាស៊ានចាំបាច់ត្រូវតែមានសមធម៌ ព្រោះអាស៊ាន តែងផ្តល់ផលប្រយោជន៍ គឺផលប្រយោជន៍ប្រៀបធៀបតម្លៃនៃឱកាស និងជំនាញលើកសិកម្ម។

ជាទូទៅ កំណើនសេដ្ឋកិច្ចពុំកំណត់កំណើនអភិវឌ្ឍទេ តែគឺប្រាក់ចំណូលក្នុងគ្រួសារទេ ដែលកំណត់ការអភិវឌ្ឍន៍របស់ជាតិមួយ។ អង្គពិភាក្សាស្នើសុំឱ្យរដ្ឋាភិបាលជួយជំរុញវិស័យឯកជន ដើម្បីឱ្យមានមុខរបរដែលផ្តល់ការងារផ្ទាល់ខ្លួន ឱ្យប្រាក់ចំណូលក្នុងគ្រួសារកើនឡើង នោះទើបអ្វីៗទាំងអស់ នៃការអភិវឌ្ឍន៍នឹងកើនឡើងដែរ។

នៅក្នុងចំណោមប្រទេសចំនួន ១៧០គេបានវាយតម្លៃ និងចាត់ថ្នាក់ថា ប្រទេសកម្ពុជា ជាប្រទេសដែលមានលក្ខណៈសេរីលើវិស័យពាណិជ្ជកម្មមួយ ដោយសារតែប្រទេសកម្ពុជា បាននឹងកំពុងធ្វើកំណែទម្រង់ឱ្យមានតម្លាភាពលើវិស័យពាណិជ្ជកម្ម ការទទួលខុសត្រូវ និងការកាត់បន្ថយជាបណ្តើរៗ នូវការិយាល័យធិបតេយ្យ។ នេះគឺជាចំណុច ដ៏ល្អមួយដែលអង្គពិភាក្សាស្នើសុំឱ្យរាជរដ្ឋាភិបាលសភាជាតិ និងអង្គការសង្គម

ស៊ីវិលខិតខំជួយបន្តឱ្យខ្លាំងក្លាថែមទៀតដើម្បីឱ្យប្រទេសកម្ពុជាទទួលបានផលប្រយោជន៍ពិតប្រាកដពីការធ្វើសមាហរណកម្មក្នុងតំបន់នេះ។

អង្គពិភាក្សាបានរកឃើញថា ទោះជាដូចម្ដេចក្ដី ការចូលរួមរបស់ប្រទេសកម្ពុជាទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅមានបញ្ហាប្រឈមមុខមួយចំនួន ដែលចាំបាច់ត្រូវកែលំអ។ បញ្ហាប្រឈមមុខទាំងនោះគឺ : (១)-ភាពទន់ខ្សោយ នៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (២)-ថ្លៃដឹកជញ្ជូនខ្ពស់ (៣)-ថ្លៃដើមផលិតកម្មខ្ពស់ ដែលទាំងអស់នេះ នាំឱ្យមានផលវិបាកដល់ការប្រកួតប្រជែងក្នុងការអូសទាញវិនិយោគិន ដោយផ្ទាល់ពីបរទេសមកក្នុងប្រទេសកម្ពុជា។

ចំពោះបញ្ហានេះ អង្គពិភាក្សាស្នើសុំរាជរដ្ឋាភិបាល និងសភាជាតិ លើកស្ទួយស្ថេរភាពខាងសេដ្ឋកិច្ច បង្កបរិស្ថានពាណិជ្ជកម្មអំណោយផល និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តល្អ ដើម្បីកាត់បន្ថយនូវការប្រឈមមុខខាងលើ។

ជាគោលដៅអនុវត្តអង្គពិភាក្សាយល់ថា ដើម្បីឱ្យការចូលរួមរបស់ប្រទេសកម្ពុជា ក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានបានល្អប្រសើរ ស្នើសុំឱ្យមានការយកចិត្តទុកដាក់លើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុក (សេដ្ឋកិច្ចគ្រួសារតាមរយៈការផ្ដល់ឥណទានឱ្យមានសមធម៌) ការអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យសេដ្ឋកិច្ច ការរក្សាស្ថេរភាពនយោបាយ និងសន្តិភាព ការប្រយុទ្ធនឹងអំពើពុករលួយ ការលើកស្ទួយសន្តិសុខ និងសុវត្ថិភាពសង្គម និងការបង្កើនការចូលរួមរបស់ផ្នែកឯកជន។

ជាអនុសាសន៍បន្ថែមអង្គពិភាក្សា ស្នើសុំឱ្យមានការខិតខំយកចិត្តទុកដាក់ផ្ដល់មធ្យោបាយផលិតកម្ម កសិកម្មក្នុងស្រុក ការលើកស្ទួយផ្នែកធារាសាស្ត្រ ការពង្រីក

ឧស្សាហកម្មធុនតូច និងធុនមធ្យម ការលើកស្ទួយធនធានធម្មជាតិ ធនធានមនុស្ស ទុនផលិតកម្ម និងបច្ចេកវិជ្ជាវិទ្យាសាស្ត្រ។

## ច_ សេចក្តីសន្និដ្ឋាន :

វេទិកា ទី ៤ ឆ្នាំ ២០០៤ ស្តីពី "**ប្រទេសកម្ពុជា និងសហគមន៍សេដ្ឋកិច្ចអាស៊ាន**" បានទទួលលទ្ធផលគួរជាទីពេញចិត្ត។ ចំណេះដឹង និង អនុសាសន៍ទាំងឡាយ ដែលអង្គពិភាក្សាបានរកឃើញអាចចាត់ទុកថា ជាចំណេះដឹង និងជាសំណូមពរដ៏ល្អមួយ ដើម្បីជួយលើកស្ទួយការចូលរួមរបស់ប្រទេសកម្ពុជា ទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ឱ្យកាន់តែបានទទួលផលកម្រៃ (Benefit) ពិតប្រាកដទៅអនាគត។

ក៏ប៉ុន្តែ ការយកចំណេះដឹងទាំងនេះ ទៅអនុវត្តជាក់ស្តែងពិតជាមានការលំបាក។ ដូច្នេះប្រសិនបើ គ្មានឆន្ទៈនយោបាយរួម ការខិតខំប្រឹងប្រែងរៀនសូត្រ ការលើកស្ទួយផលិតកម្មសេដ្ឋកិច្ចក្នុងស្រុក និងផ្នែកឯកជន ការពង្រឹងស្ថេរភាពនយោបាយ សន្តិភាព សហប្រតិបត្តិការតម្លាភាព និងការទទួលខុសត្រូវ ការប្រយុទ្ធនឹងអំពើមិនប្រក្រតី ការិយាល័យធិបតេយ្យ ការអភិវឌ្ឍន៍ធនធានមនុស្ស ការផ្តល់ទុនឥណទាន បច្ចេកវិជ្ជាផលិតកម្ម ការលើកស្ទួយប្រសិទ្ធភាពនៃការគោរពច្បាប់ និងសុចរិតធម៌ទេ នោះការអនុវត្តន៍ នឹងមានការលំបាក។ ក៏ប៉ុន្តែ ទោះជាដូចម្តេចក្តី បើមិនតិចក៏ច្រើន ការផ្សព្វផ្សាយចំណេះដឹង និងអនុសាសន៍ទាំងនេះ គឺជាវិភាគទានដ៏

ប្រសើរមួយ ដើម្បីលើកស្ទួយការផ្តល់ចំណេះដឹង និងការអនុវត្តន៍ជូនប្រទេសជាតិ និងប្រជាពលរដ្ឋយើង។

អង្គពិភាក្សា ស្នើសុំអំពាវនាវឱ្យអង្គការសង្គមស៊ីវិល ផ្នែកឯកជនមន្ត្រី នៃរាជរដ្ឋាភិបាល ស្ថាប័ន តំណាងរបស់ប្រជាពលរដ្ឋ ក៏ដូចជាបញ្ញវន្ត និងអ្នកសារពតិមានមេត្តាជួយស្វែងយល់សិក្សារៀនសូត្រ និងផ្សព្វផ្សាយចំណេះដឹងទាំងនេះ ដើម្បីឱ្យបានផលប្រយោជន៍ពិតប្រាកដល់ប្រទេសជាតិ និងប្រជាពលរដ្ឋយើងក្នុងការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានដ៏មានគុណប្រយោជន៍នេះ។

# វេទិកា ទី ៥ ប្រទេសកម្ពុជា និងសហគមន៍វប្បធម៌សង្គមអាស៊ាន

## ក_សេចក្តីផ្តើម :

នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៤ កន្លងទៅនេះ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព បានបង្កើតឱ្យមានវេទិកាមួយទៀតគឺ វេទិកាទី ៥ ស្តីពី **"ប្រទេសកម្ពុជា និងសហគមន៍វប្បធម៌សង្គមអាស៊ាន"** បន្ថែម ទៅលើវេទិកា ៤ ទៀតដែលបានរៀបចំកន្លងមក ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទំនាក់ទំនងរវាងប្រទេសកម្ពុជា និងសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ដែល ហៅកាត់ថា ASEAN នេះ។

ចូលរួមជាគណៈវាគ្មិនកិត្តិយស ក្នុងវេទិកាទី ៥ នេះរួមមាន : (១)-**ឯកឧត្តមបណ្ឌិត ឆយ យីហ៊ាង** ទីប្រឹក្សានៃរាជរដ្ឋាភិបាលទទួលបន្ទុកវិស័យ អប់រំ សមាជិករាជបណ្ឌិតសភាកម្ពុជា និងជាប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ **(២)–លោកបណ្ឌិត ហង្ស ពុទ្ធា** ប្រធានសមាគមវិចិត្រសិល្ប និងជានាយក ប្រតិបត្តិនៃគណៈកម្មាធិការអព្យាក្រឹត យុត្តិធម៌ ដើម្បីការបោះឆ្នោត ដោយសេរី និង យុត្តិធម៌ នៅកម្ពុជា (NICFEC) ។

អង្គពិភាក្សាត្រូវបានចូលរួមដោយ អ្នកដឹកនាំអង្គការ សង្គមស៊ីវិល ផ្នែកឯកជន អ្នកតំណាងស្ថាប័នសាធារណៈ សមាជិកព្រឹទ្ធសភា មន្ត្រីរាជការ សមាគមវិជ្ជាជីវៈ និស្សិត បញ្ញវន្ត និងអ្នកសារពត៌មាន។

វេទិកាកម្ពុជាអាស៊ានលើកទី ៥ នេះត្រូវបានសម្របសម្រួល និងដឹកនាំកិច្ចពិភាក្សាដោយ **លោក សំរ៉ាំង កំសាន្ត** អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព។

មុននឹងបើកកិច្ចពិភាក្សាលោក **សំរ៉ាំង កំសាន្ត** បានធ្វើរបាយការណ៍ដោយសង្ខេបមួយ ស្តីពី លទ្ធផលនៃវេទិកាលើកទី ៤ ដែលបានប្រមូលផ្តុំ ការពិភាក្សាទៅលើប្រធានបទ ស្តីពី "**ប្រទេសកម្ពុជា និងសហគមន៍សេដ្ឋកិច្ច អាស៊ាន** កាលពីថ្ងៃ ទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ ។

## ខ_ អំពីការផ្តួចផ្តើមគំនិតសម្រាប់កិច្ចពិភាក្សាក្នុងវេទិកាទី៥ ស្តីពី "ប្រទេសកម្ពុជា និងសហគមន៍វប្បធម៌សង្គមអាស៊ាន"

មុននឹងជូនវេទិកាទៅគណៈវាគ្មិនកិត្តិយសទាំងពីរ **លោក សំរ៉ាំង កំសាន្ត** បានធ្វើការផ្តួចផ្តើមគំនិតស្នើសុំឱ្យគណៈវាគ្មិន និងអង្គពិភាក្សារួមប្រមូលផ្តុំការមានមតិទៅលើចំណុចសំខាន់បីដូចខាងក្រោម :

- ស្នើសុំឱ្យអង្គពិភាក្សារកឱ្យឃើញថា តើអ្វីទៅជាសហគមន៍សង្គមវប្បធម៌អាស៊ាន? តើសហគមន៍នេះមានគោលដៅដូចម្តេច ក្នុងការអភិវឌ្ឍន៍តំបន់អាស៊ានឱ្យក្លាយទៅជាតំបន់មួយ ដែលយកចិត្តទុកដាក់ដល់សុខុមាលភាពសង្គមជាចម្បង?

- តើសហគមន៍វប្បធម៌សង្គមអាស៊ាន មានសកម្មភាពដូចម្តេចខ្លះ? ហេតុដូចម្តេចបានជាចាំបាច់មានសហគមន៍វប្បធម៌នេះ?
- តើសហគមន៍វប្បធម៌សង្គមអាស៊ាន អាចនឹងផ្តល់ផលប្រយោជន៍ដូចម្តេចខ្លះ ដល់សហគមន៍អាស៊ាន ពិសេសគឺ **ប្រទេសកម្ពុជា?** តើប្រទេសកម្ពុជា គួរធ្វើដូចម្តេច ដើម្បីចូលរួមឱ្យបានល្អ និងទទួលបានផលប្រយោជន៍ពិតប្រាកដ ពីសហគមន៍វប្បធម៌សង្គមអាស៊ាន?

## គ–អំពីទស្សនៈរបស់គណៈវាគ្មិនកិត្តិយស និងលទ្ធផលនៃកិច្ចពិភាក្សារួម

សហគមន៍វប្បធម៌សង្គមអាស៊ាន គឺជាសហគមន៍ធំទីបីនៃសហគមន៍អាស៊ាន ដែលក្នុងនោះមានសហគមន៍សន្តិសុខ (ASC) និងសហគមន៍សេដ្ឋកិច្ច (AEC) និងសហគមន៍វប្បធម៌ ដែលត្រូវធ្វើឱ្យសម្រេចជារូបរាង និងជោគជ័យ នៅឆ្នាំ ២០២០-តាមទស្សនៈឆ្នាំ២០២០ របស់អាស៊ាន ដែលបានសម្រេចឡើងដោយកិច្ចប្រជុំកំពូល របស់អាស៊ាន (Bali Conord II) នៅទីក្រុងបាលី ប្រទេស ឥណ្ឌូណេស៊ី កាលពីថ្ងៃ ទី៧ ខែតុលា ឆ្នាំ២០០៣។

សហគមន៍វប្បធម៌សង្គមអាស៊ាន (ASCC) មានគោលដៅរួមមួយ និងគោលដៅដោយឡែកប្រាំយ៉ាង។ គោលដៅរួមគឺ ដើម្បីចងបាច់គ្នាជាចង្កោម ក្នុងភាពជាដៃគូសំដៅស្ថាបនា សហគមន៍អាស៊ានដ៏ធំមួយឱ្យមានស្មេរភាព សុវត្ថិភាព សន្តិភាព វិបុលភាព និងយកចិត្តទុកដាក់ ដល់សុខុមាលភាព សង្គមជាចម្បង។

ជាគោលដៅដោយឡែកគឺ :

(១) -លើកស្ទួយសហប្រតិបត្តិការក្នុងការ អភិវឌ្ឍន៍សង្គម ពោលគឺ លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអាស៊ាន ពិសេសគឺជនក្រីក្រ និងអ្នកក្រខ្សត់ដែលងាយទទួលរងគ្រោះ ដូចជាស្ត្រីកុមារ យុវជន និងសហគមន៍មូលដ្ឋាន

(២) -លើកស្ទួយ សហប្រតិបត្តិការ ក្នុងការហ្វឹកហ្វឺនកម្លាំងពលកម្មសង្គម ដើម្បីឱ្យបានទទួលផល ប្រយោជន៍ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចដូចៗគ្នា។ ដូច្នេះ ដើម្បីសម្រេចគោលដៅនេះ អាស៊ានត្រូវធ្វើការវិនិយោគធំៗ ដើម្បីវឌ្ឍនភាពលើមុខសញ្ញា ៩ យ៉ាងគឺការអប់រំ ថ្នាក់មូលដ្ឋាន និងឧត្តមសិក្សាការ បណ្តុះបណ្តាលវិជ្ជាជីវៈ ការអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកទេស ការបង្កើតការងារ ការការពារសង្គម ការកាត់បន្ថយភាពក្រីក្រ និងគំលាត គ្នានៃសេដ្ឋកិច្ចសង្គម ការធានាវឌ្ឍនភាព សេដ្ឋកិច្ចដោយសមធម៌ ការលើកស្ទួយវិជ្ជាជីវៈ ឧបនិស្ស័យ ការអភិវឌ្ឍន៍ជំនាញឯកទេស និងការអភិវឌ្ឍន៍ធនធានមនុស្ស ដែលជា យុទ្ធសាស្ត្រគន្លឹះសម្រាប់ស្វែងរកការងារឱ្យមនុស្សជំនាន់ក្រោយ ។

(៣) -លើកស្ទួយសហប្រតិបត្តិការ លើវិស័យសុខភាពសាធារណៈ ដូចជាក្នុងការពារជំងឺឆ្លងគ្រប់ប្រភេទ ពិសេសគឺ HIV/AIDS/ SARS, និង ជំងឺគ្រុនផ្តាសាយបក្សី ។ល។ ក្នុងការរួមគ្នាផ្គត់ផ្គង់ឱសថ និងក្នុងការថែទាំសុខភាពជូនប្រជាពលរដ្ឋ។

(៤) -លើកស្ទួយសហប្រតិបត្តិការ ក្នុងការអប់រំឧបនិស្ស័យ ភាពពូកែការផ្លាស់ប្តូរអ្នកប្រាជ្ញ អ្នកនិពន្ធ សិល្បករ បណ្តាញពត៌មាន វប្បធម៌ដោយឡែករបស់អាស៊ាន

និងអត្តសញ្ញាណតំបន់ និងអប់រំផ្សព្វផ្សាយ អំពីចំណេះដឹងអាស៊ានជូនមហាជន និងប្រជាពលរដ្ឋ និង

(៥) -លើកស្ទួយសហប្រតិបត្តិការក្នុងការដោះស្រាយបញ្ហា ដែលទាក់ទងនឹងកំណើនរបស់ប្រជាពលរដ្ឋ បញ្ហាការងារ ភាពគ្មានការងារធ្វើការរេចរិលនៃបរិស្ថាន ការបំពុលបរិស្ថាន ឆ្លងដែន និងការគ្រប់គ្រងគ្រោះមហន្តរាយក្នុងតំបន់។

ធ្វើដូច្នេះ គឺដើម្បីឱ្យរដ្ឋជាសមាជិកទាំងអស់ សម្រេចបានសក្តានុពល អភិវឌ្ឍន៍របស់ខ្លួននឹងពង្រឹងបានស្មារតីរបស់អាស៊ាន។

ទាំងអស់នេះ គឺជាគោលដៅចម្បង នៃសហគមន៍វប្បធម៌សង្គម អាស៊ាន (ASCC) ដែលជាស្មារតី នៃសម័យប្រជុំកំពូលរបស់អាស៊ាន (Bali Concord II) សម្រេចដោយអ្នកដឹកនាំអាស៊ានទាំង ១០ ប្រទេស កាលពីថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៣ កន្លងទៅនេះ។

ឯកឧត្តម **ឆយ យីហ៊ាង** ក៏បានលើកយកការជះឥទ្ធិពលជាអវិជ្ជមាន មួយចំនួនរបស់សមាហរណកម្មវប្បធម៌ ក្នុងសម័យសកលភាវូបនីយកម្ម ដល់កម្ពុជាផងដែរ។ ឥទ្ធិពលជាអវិជ្ជមាននោះរួមមានការត្រេកត្រអាលនឹងសម្ភារៈនិយម ការមិនស្តាប់បង្គាប់ឪពុកម្តាយ ការនិយមទំនៀមទំលាប់រស់នៅ និងស្លៀកពាក់តាមបែបបរទេស ការភ្លើតភ្លើនក្នុងយុវវ័យជាដើម។

## <u>អំពីសកម្មភាពរបស់សហគមន៍វប្បធម៌សង្គមអាស៊ាន</u>

ជាសកម្មភាពជាក់ស្តែង សហគមន៍វប្បធម៌សង្គមអាស៊ាន (ASCC) គឺត្រូវធ្វើឡើង តាមរយៈការលើកស្ទួយការអភិវឌ្ឍន៍វប្បធម៌ សង្គម និងការអប់រំចំណេះ

ដឹងជាមូលដ្ឋានទៅលើ ចំណេះដឹងទូទៅ ចំណេះដឹងខាងវិទ្យាសាស្ត្របច្ចេកទេស អត្តសញ្ញាណវប្បធម៌ សុខភាពសាធារណៈ ការការពារបរិស្ថាន ការលើកស្ទួយគុណភាពនៃជីវភាពរស់នៅការផ្លាស់ប្តូរ វប្បធម៌ ការស្តាបនាភូមិស្ថាន ខេត្ត ខ័ណ្ឌ និងតំបន់វប្បធម៌ ការហ្វឹកហ្វឺនវិជ្ជាជីវៈ ការស្ថាបនាកម្លាំងពលកម្ម ការអភិវឌ្ឍន៍ សេដ្ឋកិច្ចប្រកបដោយសមធម៌ និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ល។

**<u>អំពីផលប្រយោជន៍ដែលកម្ពុជាអាចនឹងទទួលបានពីសហគមន៍វប្បធម៌សង្គមអាស៊ាន</u>**

ផលប្រយោជន៍ដ៏សំខាន់បំផុត ដែលប្រទេសកម្ពុជាអាចនឹងទទួលបានពីសហគមន៍ នេះគឺ :

- ចំណេះដឹងតាមរយៈការប្រជុំសិក្សា ពិភាក្សាការផ្លាស់ប្តូរបទពិសោធន៍រវាងបណ្តា ប្រទេសជាសមាជិក ដូចជាចំណេះដឹង ខាងវិទ្យាសាស្ត្របច្ចេកទេស ការគ្រប់គ្រងជំនាញឯកទេសកម្ម ការដឹកនាំសហគមន៍ និងការដោះស្រាយបញ្ហាសេដ្ឋកិច្ច វប្បធម៌ នយោបាយ អប់រំ សង្គមកិច្ច និងសុខាភិបាល ។ល។
- ការអភិវឌ្ឍន៍វប្បធម៌ តាមរយៈការអប់រំហ្វឹកហ្វឺន អំពីឧបនិស្ស័យនិងភាពពូកែ (Ability) ការផ្លាស់ប្តូរ អ្នកប្រាជ្ញ សិល្បករ ការផ្លាស់ប្តូរបណ្តាញ សារពត៌មាន និងអ្នកសារពត៌មាន ការរក្សាបានអត្តសញ្ញាណខ្លួនថា ជាអត្តសញ្ញាណរបស់អាស៊ាន ដែលអាស៊ាន ចាំបាច់ត្រូវជួយរក្សាការពារ ( គ្មានការឈ្លានពានលើវិស័យវប្បធម៌)

- ការអភិវឌ្ឍន៍ធនធានមនុស្ស ឱ្យមានសមត្ថភាពបំពេញការងារ និងទទួលផលពីសមាហរណកម្មសេដ្ឋកិច្ច
- ការមានការងារ និងមុខរបរតាមរយៈការហ្វឹកហ្វឺនវិជ្ជាជីវៈ ឯកទេសកម្ម
- ការលើកស្ទួយគុណភាព នៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ ឱ្យបានទទួលផលពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចដោយសមធម៌
- ការលើកស្ទួយសុខភាពសាធារណៈ ការការពារជំងឺឆ្លង ការផ្គត់ផ្គង់ឱសថ ការគាំពារសុខភាពរបស់ប្រជាពលរដ្ឋ និង
- ការដោះស្រាយបញ្ហារួមដែលពាក់ព័ន្ធនឹងកំណើន នៃប្រជាពលរដ្ឋបញ្ហាគ្មានការងារធ្វើ និងភាពរេចរិលនៃបរិស្ថាន។

**ដើម្បីចូលរួមឱ្យបានល្អនិងទទួលបានផលប្រយោជន៍ពិតប្រាកដពីសហគមន៍ វប្បធម៌ សង្គមអាស៊ាន ប្រទេសកម្ពុជាគួរតែ**

- ស្គាល់ខ្លួនឯងឱ្យច្បាស់ថាខ្លួនមានអ្វី? ខ្វះខាតអ្វី? ត្រូវលើកស្ទួយអ្វីដែលមានឱ្យគង់វង្ស និងត្រូវធ្វើអ្វីដែលគ្មានឱ្យមាន
- មានការយល់ដឹងច្បាស់លាស់ អំពីការអភិវឌ្ឍន៍សហគមន៍វប្បធម៌ សង្គមអាស៊ាន អ្វីទៅASCC? សកម្មភាព? បានផលប្រយោជន៍ ដូចម្តេច?
- លើកស្ទួយការយល់ដឹង និងផ្សព្វផ្សាយចំណេះដឹងឱ្យមហាជន និងប្រជាពលរដ្ឋមានការយល់ដឹង ដើម្បីស្ថាបនាកម្លាំងគាំទ្រ

- រៀបចំការអភិវឌ្ឍន៍សមត្ថភាពបំពេញការងារ (ការអភិវឌ្ឍន៍ធនធានមនុស្សដែលត្រូវធ្វើការជាមួយគេឱ្យបានស្មើមុខ) និងការពារផលប្រយោជន៍ជាតិឱ្យបាន

- រៀបចំផែនការធ្វើគម្រោងកម្មវិធី លើកស្ទួយការអប់រំវប្បធម៌

- ស្រាវជ្រាវគំនិតល្អៗ ដើម្បីធ្វើគម្រោងដាក់ស្នើសុំថវិកាអាស៊ាន សម្រាប់ការអភិវឌ្ឍន៍ វិស័យវប្បធម៌ ពត៌មាន និងសុខាភិបាលជាតិ

- ខិតខំរៀនសូត្រដកពិសោធន៍ពីគេ ដើម្បីឱ្យខ្លួនយើងមានការយល់ដឹងពូកែក្នុងការធ្វើកិច្ចសហប្រតិបត្តិការ ការពង្រឹងភាពជាដៃគូ និងការប្រកួតប្រជែង

- លើកស្ទួយអភិបាលកិច្ចល្អ ការទទួលខុសត្រូវ ការប្រយុទ្ធនឹងអំពើពុករលួយ ប្រឆាំងនឹងភាពល្ងង់ខ្លៅ ការមិនចេះច្បាប់ទម្លាប់ បំផុសចលនារក្សាការពារសម្បត្តិវប្បធម៌ជាតិ

- រកឱ្យឃើញអ្នកប្រាជ្ញលើវិស័យវប្បធម៌ ដើម្បីចូលរួមប្រជុំដកពិសោធន៍ជាមួយគេ ហ្វឹកហ្វឺនឱ្យមានសិល្បករជំនាញ និងអ្នកឯកទេសពិតប្រាកដ ដើម្បីត្រៀមផ្លាស់ប្តូរ និងស្ថាបនាឱ្យបានស្នាដៃវប្បធម៌ល្អៗ ថ្មី និងប្លែក ដើម្បីធ្វើការអប់រំផ្សព្វផ្សាយ អំពីការស្ថាបនាសហគមន៍វប្បធម៌សង្គមអាស៊ាន ។ល។

- ឧស្សាហ៍ធ្វើការប្រជុំ សិក្សាដកពិសោធន៍ និងទិសដៅអនុវត្តទៅអនាគត ។

**អំពីសំណូមពរជាអនុសាសន៍ :**

ជាការពិតណាស់ការចូលរួម ក្នុងសហគមន៍វប្បធម៌សង្គមអាស៊ានអាច នឹងបានផលចំណេញច្រើនជាងការខាតបង់ ក៏ប៉ុន្តែ ប្រទេសជាតិយើងចាំបាច់ត្រូវតែមានការខិតខំប្រឹងប្រែង ចូលរួមប្រកួតប្រជែងជាមួយគេឯងក្នុងតំបន់ បើពុំដូច្នោះទេ ពុំអាចទទួលបានផលចំណេញឡើយ។ អង្គពិភាក្សាស្នើសុំក្រសួងទទួលបន្ទុក និងស្ថាប័នពាក់ព័ន្ធមេត្តាខិតខំប្រឹងប្រែងស្វែងយល់សិក្សា និងចូលរួមប្រកួតប្រជែងឱ្យបានល្អ និងដើម្បីទទួលផលប្រយោជន៍ពីសហគមន៍នេះ។

អត្តសញ្ញាណវប្បធម៌រួមរបស់សហគមន៍អាស៊ាន គឺជាអត្តសញ្ញាណវប្បធម៌ដោយឡែករបស់បណ្តាប្រទេសជាសមាជិកទាំង ១០ ។ ដូច្នេះ ដើម្បីរក្សាបាននូវអត្តសញ្ញាណវប្បធម៌របស់ជាតិយើងដ៏រឹងមាំមួយ ក្នុងអត្តសញ្ញាណ ទាំង១០ អង្គពិភាក្សា ស្នើសុំអំពាវនាវឱ្យក្រសួងទទួលបន្ទុក និងស្ថាប័នពាក់ព័ន្ធ ក៏ដូចជាអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋខ្មែរទាំងមូល មេត្តាខិតខំរក្សា ការពារ និងអប់រំផ្សព្វផ្សាយអំពីអត្តសញ្ញាណ និងព្រលឹងវប្បធម៌ជាតិឱ្យបានជាប់ជាប្រចាំ ទាំងក្នុងប្រទេស និងក្រៅប្រទេស។

ដោយវឌ្ឍភាពនៃសហគមន៍វប្បធម៌សង្គមអាស៊ាន យកចិត្តទុកដាក់ជាសំខាន់ដល់ការអប់រំ ចំណេះដឹង ការហ្វឹកហ្វឺនវិជ្ជាជីវៈ ការលើកស្ទួយសុខភាពសាធារណៈ និងការផ្លាស់ប្តូរវប្បធម៌និងការអប់រំ អង្គពិភាក្សាស្នើសុំអំពាវនាវ ឱ្យក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាគ្រឹះស្ថានឧត្តម សិក្សាសាធារណៈ និងឯកជន មេត្តាខិតខំប្រឹងប្រែងលើកស្ទួយគុណភាពអប់រំ និងប្រសិទ្ធិភាពនៃការស្ថាបនាធនធានមនុស្ស នៃ

ប្រទេសកម្ពុជា ឱ្យក្លាយទៅជាធនធានចម្បង ក្នុងការស្ថាបនាសហគមន៍វប្បធម៌កម្ពុជាមួយដោយផ្សារភ្ជាប់ទៅនឹងសហគមន៍ វប្បធម៌សង្គមអាស៊ាន។ ធ្វើដូច្នេះបាននោះប្រទេសជាតិយើងនឹងបានទទួលផលប្រយោជន៍ពិតប្រាកដពីសហគមន៍នេះ។

អង្គពិភាក្សាបានរកឃើញថា ពីអតីតកាលប្រទេសជាតិយើង គឺជាមហាអំណាចខាងវប្បធម៌ ក៏ប៉ុន្តែ បច្ចុប្បន្នវប្បធម៌ជាតិយើងកំពុងស្រុតចុះយ៉ាងខ្លាំងក្លា នេះគឺដោយសារតែជាតិយើង ពុំបានយកចិត្តទុកដាក់យកខ្លឹមសារសិល្បៈ វប្បធម៌ជាតិធ្វើជាទស្សនាទាន អប់រំគុណធម៌ខាងផ្លូវចិត្តគំនិត។ ជារួម សព្វថ្ងៃនេះ ស្នាដៃ សិល្បៈវប្បធម៌ជាច្រើនបានបំរើការកំសាន្តសប្បាយ និងកាមគុណជាងការអប់រំ។ អាស្រ័យហេតុនេះ អង្គពិភាក្សាបានស្នើសុំរាជរដ្ឋាភិបាល សភាទាំងពីរ និងក្រសួងដែលពាក់ពន្ធពិសេសគឺក្រសួងវប្បធម៌ ឃោសនាការ និងអប់រំ មេត្តាមានគោលការណ៍ជួយណែនាំលើកស្ទួយ និងតម្រង់ទិសផលិតកម្មស្នាដៃសិល្បៈ វប្បធម៌ជាតិយើងឱ្យមានទស្សនាទានអប់រំច្រើនជាងការបម្រើភាពភ្លើតភ្លើនក្នុងកាមគុណ។ ស្ថានីយទូរទស្សន៍ខ្មែរ ការបោះពុម្ពផ្សាយរូបភាព និងព្រឹត្តិប័ត្រ អាសអាភាសទាំងឡាយគួរតែត្រូវបានកែលំអ និងប្រែក្លាយសកម្មភាពនោះ ឱ្យទៅជាការអប់រំច្រើនជាង ការបម្រើកាមគុណ និងភាពពាលាអាវ៉ាសែ នោះទើបប្រសើរ។

សហគមន៍វប្បធម៌សង្គមអាស៊ាន ពុំមានគោលការណ៍រំលោភបំពាន និងឈ្លានពានលើវិស័យវប្បធម៌របស់ជាតិមួយទេ។ ក៏ប៉ុន្តែ វប្បធម៌ជាតិមួយអាចនឹងបាត់បង់ ប្រសិនបើជាតិនោះភ្លេចខ្លួន ហើយបោះបង់ចោលនូវវប្បធម៌ ប្រពៃណី និងអត្តសញ្ញាណរបស់ជាតិខ្លួន។ គឺមានតែការខិតខំប្រឹងប្រែងថែរក្សា និងលើកស្ទួយវប្បធម៌ប្រពៃណីជាតិរបស់ខ្លួនឱ្យបានរីកចម្រើន និងគង់វង្សទេ នោះទើប អត្តសញ្ញាណ

វប្បធម៌ជាតិមិនត្រូវបានបាត់បង់។ ដោយយល់ឃើញ ដូច្នេះ អង្គពិភាក្សាស្នើសុំអំពាវនាវ ឱ្យអ្នកដឹកនាំ និងជនជាតិខ្មែរគ្រប់រូប មេត្តាមើលឱ្យឃើញការខ្វះខាតនេះ ហើយខិតខំប្រឹងប្រែងជួយថែរក្សា និងការពារមរតក សិល្បៈ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ជាតិយើងឱ្យបាន គង់វង្ស នោះទើបអត្តសញ្ញាណវប្បធម៌នោះមិនត្រូវបាត់បង់ ក្នុងសហគមន៍ វប្បធម៌សង្គមអាស៊ានដ៏ធំធេងនេះ។

ជាសេចក្តីសន្និដ្ឋាន វេទិកាទី ៥ ឆ្នាំ ២០០៤ ស្តីពី "**ប្រទេសកម្ពុជា និងសហគមន៍វប្បធម៌សង្គមអាស៊ាន**" បានទទួលលទ្ធផលល្អគួរជាទីមោទនៈ។ ទស្សនៈ និងចំណេះដឹង ក៏ដូចជាអនុសាសន៍ទាំងឡាយ ដែលអង្គពិភាក្សាបានរកឃើញអាចចាត់ទុកថា ជាកម្រងចំណេះដឹង និងជាបទពិសោធន៍ ដ៏ល្អដល់ការលើកស្ទួយសហប្រតិបត្តិការរបស់ប្រទេសកម្ពុជា ក្នុងការស្ថាបនាសហគមន៍វប្បធម៌សង្គម អាស៊ាន។

ក៏ប៉ុន្តែ ការប្រែក្លាយទស្សនៈ និងចំណេះដឹងទាំងនោះ ឱ្យកើតជាប្រយោជន៍ជាក់ស្តែង គឺវាទាមទារឱ្យមានការយកចិត្តទុកដាក់ និងការចូលរួម ពីគ្រប់ថ្នាក់គ្រប់ផ្នែក ព្រមទាំងឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តខ្ពស់របស់ស្ថាប័នដឹកនាំ អ្នកគ្រប់គ្រង និងប្រជាពលរដ្ឋផង។

អង្គពិភាក្សាស្នើសុំអំពាវនាវ ឱ្យមានការសហប្រតិបត្តិការពីស្ថាប័ន ទទួលបន្ទុក និងអង្គការសង្គមស៊ីវិល ព្រមទាំងប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ក្នុងការប្រតិបត្តិ ក៏ដូចជាការអប់រំផ្សព្វផ្សាយ ចំណេះដឹងទាំងនេះ ដើម្បីជាគុណប្រយោជន៍ដល់ការស្ថាបនាសហគមន៍វប្បធម៌សង្គមកម្ពុជាអាស៊ានមួយ ដែលគិតគូរពីសុខុមាលភាពសង្គមជាចម្បង។

# វេទិកាទី ៦ ប្រទេសកម្ពុជា និងដៃគូចរចាអាស៊ាន

## សេចក្តីផ្តើម

នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៤ ពីម៉ោង ៨:៣០ នាទីព្រឹកដល់ម៉ោង ១១:៤៥ នាទី វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព បាន បើកវេទិកាមួយទៀត គឺវេទិកាទី ៦ ស្តីពី **"ប្រទេសកម្ពុជា និងដៃគូចរចាអាស៊ាន"។** កិច្ចពិភាក្សានេះត្រូវបានសំរបសំរួលដោយ **លោក ស៊ីសុវត្ថិ ដួងច័ន្ទរ៉ា** ជានាយកប្រតិបត្តិរង នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព។ ចូលរួមជាគណៈវាគ្មិនដោយៈ **(១)-លោកជំទាវបណ្ឌិត សៀង រត្នធិ** អគ្គនាយក អគ្គនាយកដ្ឋានអាស៊ាននៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **(២)-លោក អ៊ុំ ស៊ីថុល** ប្រធានការិយាល័យអាស៊ាន នៃទីស្តីការគណៈរដ្ឋមន្ត្រី។ កិច្ចពិភាក្សានេះ ចូលរួមជាសមាជិកដោយអ្នកដឹកនាំអង្គការសង្គមស៊ីវិល ផ្នែកឯកជន អ្នកតំណាងស្ថាប័នរដ្ឋ និស្សិត បញ្ញវ័ន្ត និងអ្នកសារពតិមាន។

**<u>អំពីការផ្តួចផ្តើមគំនិតសម្រាប់កិច្ចពិភាក្សាលើកទី ៦ ស្តីពី "ប្រទេសកម្ពុជា និងដៃគូចរចាអាស៊ាន"</u> :**

ខាងក្រោមនេះ គឺជាការផ្តួចផ្តើមគំនិតសម្រាប់វេទិកាលើកទី ៦ នៅក្នុង ឆ្នាំ ២០០៤ :

- ស្នើសុំឱ្យគណៈវាគ្មិន និងអង្គពិភាក្សាស្វែងរកឱ្យឃើញថា តើប្រទេសណាខ្លះ ហើយនៅទីណា ដែលជាដៃគូសន្ទនាដ៏ប្រសើររបស់ប្រទេសកម្ពុជា?
- តើប្រទេសកម្ពុជា និងដៃគូសន្ទនាអាស៊ាននេះនឹងផ្តល់ផលប្រយោជន៍ដូចម្តេចដល់ប្រទេសកម្ពុជា?
- តើប្រទេសកម្ពុជាគួរធ្វើដូចម្តេច ដើម្បីទទួលបានផលប្រយោជន៍ពិតប្រាកដពីដៃគូសន្ទនារបស់អាស៊ាននេះ?
- តើអង្គពិភាក្សាមានបំណងចង់លើកឡើង នូវអនុសាសន៍ដូចម្តេចខ្លះ ដើម្បីលើកស្ទួយទំនាក់ទំនង និងកិច្ចសន្ទនាជាមួយដៃគូសន្ទនារបស់អាស៊ានបានល្អប្រសើរ?

**អំពីទស្សនៈរបស់គណៈវាគ្មិន និងលទ្ធផលនៃកិច្ចពិភាក្សារួម**

***ការរៀបចំបង្កើតឱ្យមានវេទិកា ស្តីពី "ប្រទេសកម្ពុជា និងអាស៊ាននៅក្នុងឆ្នាំ២០០៤ នេះគឺជាការងារត្រឹមត្រូវ :***

ចំណេះដឹងល្អបំផុតដែល បានមកពីកិច្ចពិភាក្សានេះ នោះគឺចំណេះដឹងស្រាវជ្រាវ និងការអភិវឌ្ឍន៍ (R&D)។ បញ្ហាប្រឈមមុខរបស់ជនជាតិយើងនោះ គឺកង្វះការយល់ដឹង និងការលើកស្ទួយការសិក្សាស្រាវជ្រាវ។ ដូច្នេះ ការយកចិត្តទុកដាក់បំផុស

ការសិក្សាស្រាវជ្រាវផ្សេងៗ ដើម្បីប្រមូលចំណេះដឹងជាក់ស្តែង ដូចវេទិកាកម្ពុជាអាស៊ាននេះ គឺជាការចាំបាច់ណាស់ ដើម្បីយល់ដឹងអំពីអាស៊ាន និងជួយរាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយចំណេះដឹងនេះ ឱ្យបានដល់ប្រជាពលរដ្ឋសំដៅរួមចំណែកគាំទ្រដល់សមាជិកភាពរបស់ប្រទេសកម្ពុជា ក្នុងសមាគមអាស៊ាន និងទទួលផលប្រយោជន៍ពីអង្គការនេះ ឱ្យបានល្អទៅអនាគត។

## ***ទស្សនាទាននៃការចរចាជាដៃគូរបស់អាស៊ាន មានមកតាំងតែពីឆ្នាំ ១៩៧៦***

ពីដំបូងដៃគូសន្ទនារបស់អាស៊ានមានតែ ៤ ប្រទេសទេគឺ *ប្រទេស អូស្ត្រាលី ជប៉ុន ញូសីឡង់ដ៍ និងអង្គការ UNDP* ។ ក្រៅពី UNDP ប្រទេសធំៗ ទាំងបី គឺជាដៃគូពាណិជ្ជកម្មដ៏ធំរបស់អាស៊ាន ចាប់តាំងពីឆ្នាំ ១៩៧៦។ លុះមកដល់ឆ្នាំ១៩៧៧ អាស៊ានក៏បានពង្រីងដៃគូសន្ទនារបស់ខ្លួន ជាមួយសហរដ្ឋអាមេរិក ជាមួយ EU នៅក្នុងឆ្នាំ ១៩៨០ ជាមួយកាណាដា នៅឆ្នាំ ១៩៨១ ជាមួយសាធារណរដ្ឋកូរ៉េ (ROK) នៅឆ្នាំ១៩៩១ ជាមួយឥណ្ឌា នៅឆ្នាំ១៩៩៣ និងបានក្លាយជាដៃគូពេញសិទ្ធិ នៅឆ្នាំ ១៩៩៥ ជាមួយប្រទេសចិន និងរុស្ស៊ីតាមផ្នែកខ្លះ នៅឆ្នាំ ១៩៩១ និងបានក្លាយជាដៃគូពេញសិទ្ធិក្នុងរយៈពេល ០៥ ឆ្នាំក្រោយមក និងជាមួយ ប៉ាគីស្ថានតាមផ្នែកខ្លះនៅឆ្នាំ ១៩៩៧ ។

## ***តើដៃគូចរចាអាស៊ាននេះបានផ្តល់ផលប្រយោជន៍ដូចម្តេច ដល់ប្រទេសកម្ពុជា?***

- ប្រទេសកម្ពុជាបានចូលជាសមាជិកអាស៊ានពេញសិទ្ធិតាំងពីឆ្នាំ ១៩៩៩។ ចាប់តាំងពីពេលនោះមក ទំនាក់ទំនងរបស់កម្ពុជា ជាមួយដៃគូសន្ទនាអាស៊ានកាន់តែមានសារៈសំខាន់ខ្លាំងឡើង

- គោលបំណងនៃកិច្ចសន្ទនានេះ គឺដើម្បីធ្វើសហប្រតិបត្តិការលើវិស័យ សេដ្ឋកិច្ច និងនយោបាយ តាមរយៈការពិគ្រោះយោបល់លើបញ្ហាគន្លឹះ សំខាន់ៗ មួយចំនួន លើវិស័យសេដ្ឋកិច្ច និងនយោបាយ

- ប្រទេសកម្ពុជាមានទស្សនៈ និងយុទ្ធសាស្ត្រច្បាស់លាស់ ក្នុងការទំនាក់ ទំនងជាមួយដៃគូសន្ទនាអាស៊ាននេះ។ ជាគោលដៅរួម គឺដើម្បីជួយ ពង្រឹងផលប្រយោជន៍ខាងនយោបាយសេដ្ឋកិច្ច និងសន្តិសុខ ក្នុងតំបន់ និងអនុតំបន់ ក៏ដូចជាតាមរយៈទំនាក់ទំនងជាទ្វេភាគី ។

តាមរយៈការស្ថាបនាបណ្តាញ ជាមួយដៃគូសន្ទនារបស់អាស៊ាននេះ ប្រទេសកម្ពុជា នឹងបានផលប្រយោជន៍ ដូចខាងក្រោម :

- អាចនឹងមានច្រកដ៏ធំមួយ សម្រាប់ចូលឱ្យដល់មហាអំណាច សេដ្ឋកិច្ចធំៗ

- អាចស្ថាបនាបរិស្ថាននយោបាយខាងក្រៅ ឱ្យកាន់តែអំណោយផល ដើម្បី ជួយបង្កើននយោបាយក្នុងប្រទេស និងលើវិស័យ សេដ្ឋកិច្ច

- បានលើកស្ទួយទំនាក់ទំនងសេដ្ឋកិច្ច និងសហប្រតិបត្តិការលើ វិស័យនេះ ជាមួយប្រទេសជប៉ុន អូស្ត្រាលី សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប និង UNDP ។ល។

- បានទទួលជំនួយការបរទេស និងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ដែល រួមមានការបង្កើនខាងការវិនិយោគទុន ពាណិជ្ជកម្ម ទេសចរណ៍ គមនាគមន៍ និងដឹកជញ្ជូន ថាមពល (ប្រេងឥន្ធនៈ) និង ការផ្ទេរបច្ចេកវិទ្យា ។ល។

***តើប្រទេសកម្ពុជាចង់បានអ្វី ពីទំនាក់ទំនងជាមួយមិត្តចរចាររបស់អាស៊ាននេះ?***

ជាការពិតណាស់ ប្រទេសជាតិយើងចង់បាន :

- ការអភិវឌ្ឍន៍ធនធានមនុស្ស ជំនួយការអភិវឌ្ឍន៍ទីផ្សារធំទូលាយ
- ការអភិវឌ្ឍន៍ផ្នែកឯកជន ជាពិសេសគឺការអភិវឌ្ឍន៍សហគ្រាស ធុនតូច និងធុនមធ្យម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច
- កាត់បន្ថយភាពក្រីក្រ (ជាអាទិភាពចម្បង)
- កាត់បន្ថយគម្លាតគ្នារវាងអ្នកមាន និងអ្នកក្រីក្រ រវាងក្រុង និងជនបទ
- ការរត់តាមឱ្យទាន់គេឯងក្នុងតំបន់ (ដែលមានកម្រិតសេដ្ឋកិច្ច និង អាទិភាពអភិវឌ្ឍន៍ខុសគ្នា)
- សហប្រតិបត្តិការ ដើម្បីបង្កើនការអភិវឌ្ឍន៍ជាតិយើង និងបង្កើន សុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ការពង្រឹងការងារទូតក្នុងតំបន់ និងសហគមន៍អន្តរជាតិ
- ការលើកស្ទួយកិត្យានុភាពជាតិ និងការទទួលស្គាល់លើឆាក អន្តរជាតិ
- ការស្តារមុខមាត់ប្រទេសជាតិបន្ទាប់ ពីសង្គ្រាម និងជម្លោះជាច្រើន ទសវត្សកន្លងមក ឱ្យអន្តរជាតិកាន់តែទទួលស្គាល់ស្របច្បាប់នៅក្នុងតំបន់ និងលើពិភពលោក។

## តើប្រទេសកម្ពុជា គួរធ្វើដូចម្ដេច ដើម្បីឱ្យបានទទួលផលពិតប្រាកដពីទំនាក់ទំនងជាមួយដៃគូចរចារបស់អាស៊ាននេះ?

- គួរផ្ដល់ជំរឿនឱ្យតំបន់ និងសហគមន៍អន្តរជាតិថា ប្រទេសកម្ពុជា ពិត ជាមាន ស្ថេរភាព សុវត្ថិភាព សន្តិភាព និងការអភិវឌ្ឍន៍ ដើម្បីអូសទាញជំនួយវិនិយោគពីបរទេស
- គួរមានគោលនយោបាយការបរទេសច្បាស់លាស់មួយ ជាមួយដៃគូសន្ទនារបស់អាស៊ាន ដើម្បីលើកស្ទួយសហប្រតិបត្តិការឱ្យ បានខ្លាំងក្លាលើវិស័យសេដ្ឋកិច្ច និងនយោបាយ
- គួរផ្ដល់ផលប្រយោជន៍ឱ្យគេដោយសេចក្ដីស្មោះត្រង់ និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក
- គួរបែងចែកផលប្រយោជន៍នេះឱ្យដល់ភាគី និងដៃគូសន្ទនាទាំងអស់ ដោយសមធម៌
- គួរលើកស្ទួយប្រសិទ្ធិភាពនៃការគោរពច្បាប់ ដើម្បីប្រយុទ្ធនឹងភាពមិនប្រក្រតី រដ្ឋបាលស្មុគស្មាញ និងការកេងផលប្រយោជន៍
- គួរស្ថាបនាគម្រោងកម្មវិធី (Project Proposals) ឱ្យស្របតាមគោលនយោបាយរបស់សមាគមអាស៊ាន ដើម្បីអភិវឌ្ឍប្រទេសកម្ពុជា ពិសេសគឺការអភិវឌ្ឍន៍ធនធានមនុស្សការលើកស្ទួយកម្លាំងពលកម្ម ផលិតកម្ម សេដ្ឋកិច្ចវប្បធម៌ សន្តិសុខសង្គម និងសុខភាពសាធារណៈ

- គួរលើកស្ទួយឆន្ទៈនយោបាយផ្ទៃក្នុង និងទស្សនៈមើលឆ្ពោះទៅខាងក្រៅ ដើម្បីអភិវឌ្ឍប្រទេសជាតិ ឱ្យស្របតាមនិន្នាការក្នុងសម័យថ្មី គឺសម័យសកលភាវូបនីយកម្មនេះ។

## អំពីសំណូមពរជាអនុសាសន៍

- ស្នើសុំលើកស្ទួយសហប្រតិបត្តិការ ជាមួយដៃគូសន្ទនារបស់អាស៊ានឱ្យកាន់តែបានល្អប្រសើរថែមទៀត ដើម្បីប្រឆាំងនឹងការរត់ពន្ធគ្រឿងញៀន ការជួញដូរមនុស្ស (ស្ត្រី និងកុមារ) និងភេរវកម្មអន្តរជាតិ តាមរយៈការលើកស្ទួយប្រសិទ្ធិភាពនៃការគោរពច្បាប់ មនសិការសង្គម និងការយល់ដឹងអំពីស្ត្រី ។ល។
- ស្នើសុំបន្តលើកកំពស់តួនាទីរបស់រដ្ឋ របស់អង្គការសង្គមស៊ីវិល ក្នុងការអប់រំអំពីប្រធានបទនេះ ដើម្បីធ្វើឱ្យសម្រេចការពង្រឹងភាពជាដៃគូសន្ទនារបស់អាស៊ាន ដើម្បីអភិវឌ្ឍប្រទេសជាតិឱ្យរួចផុតពីភាពក្រីក្រ ឱ្យរួចផុតពីគំលាតគ្នារវាងអ្នកមាន និងអ្នកក្រ រវាងទីក្រុង និងជនបទ រវាងអ្នកចេះដឹង និងអ្នកមិនចេះដឹង
- ស្នើសុំបន្តការលើកស្ទួយទំនាក់ទំនងទ្វេភាគី និងពហុភាគីឱ្យបានល្អ ដើម្បីដោះស្រាយបញ្ហា ឬអរិភាពផ្សេងៗ ដោយសន្តិវិធីទាំងនៅក្នុងតំបន់ និងក្រៅតំបន់ សំដៅធានា ស្ថេរភាព សន្តិភាព និងការអភិវឌ្ឍប្រទេសជាតិយើង និងការអភិវឌ្ឍក្នុងតំបន់
- ស្នើសុំឱ្យមានគម្រោងកម្មវិធីសិក្សារៀនសូត្រជាប្រចាំ អំពីចំណេះដឹង អាស៊ាន និងស្នើសុំឱ្យការអប់រំផ្សព្វផ្សាយ អំពីចំណេះដឹងនេះឱ្យបានទូលំទូលាយ ដើម្បីបង្កើនការយល់ដឹងរបស់មហាជន និងប្រជាពលរដ្ឋ

- ស្នើសុំលើកកំពស់ប្រសិទ្ធិភាពនៃការគ្រប់គ្រងធនធាន និងវប្បធម៌នៃការទទួលខុសត្រូវ ដើម្បីភាពស្ថិតស្ថេរគង់វង្សនៃធនធានធម្មជាតិខ្មែរ សម្រាប់ធ្វើជាធនធានអភិវឌ្ឍន៍យូរអង្វែងទៅអនាគត។

**សេចក្តីសន្និដ្ឋាន :**

កិច្ចពិភាក្សារួម ក្នុងវេទិកាទី ៦ ឆ្នាំ ២០០៤ ស្តីពី "**ប្រទេសកម្ពុជា និងដៃគូចរចារអាស៊ាន**" បានបញ្ចប់ទៅនៅវេលាម៉ោង ១១:៤៥ នាទី ពេលព្រឹក ប្រកបដោយលទ្ធផលល្អ និងបរិយាកាសរីករាយ។ ចំណេះដឹង បទពិសោធន៍ និងអនុសាសន៍ទាំងឡាយ ដែលអង្គពិភាក្សាបានរកឃើញអាចនឹងផ្តល់ នូវប្រយោជន៍ដ៏សំខាន់ ដល់ការពង្រឹងភាពដៃគូរវាងប្រទេសកម្ពុជា និងបណ្តាប្រទេសជាដៃគូចរចារបស់អាស៊ាន។ ក៏ប៉ុន្តែ ចំណេះដឹងទាំងនេះ ពុំអាចធានាបាននូវគុណប្រយោជន៍នេះទេ ប្រសិនបើគ្មានការផ្សព្វផ្សាយ និងការអនុវត្តន៍។ ការយល់ដឹងរបស់មហាជន និងប្រជាពលរដ្ឋ ពិសេសគឺមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ គឺជាការសំខាន់ណាស់ ដើម្បីស្ថាបនាកម្លាំងគាំទ្រ និងប្រតិបត្តិ។ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ក៏ដូចជាស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិលមានភារកិច្ច ធ្វើឱ្យសម្រេចគោលដៅនេះ ដើម្បីផ្សព្វផ្សាយចំណេះដឹង និងការអភិវឌ្ឍន៍។ ក៏ប៉ុន្តែ អ្វីដែលសំខាន់ជាងនោះ គឺឆន្ទៈនយោបាយ ការទទួលខុសត្រូវ និងការចាត់តាំងអនុវត្តន៍របស់ស្ថាប័នទទួលបន្ទុក ទាំងឡាយដែលពាក់ព័ន្ធ នឹងប្រធានបទនេះ។

# វេទិកាទី ៧ ប្រទេសកម្ពុជា និងវេទិកាតំបន់អាស៊ាន

## សេចក្តីផ្តើម

ដោយគោរពទៅតាមគម្រោងកម្មវិធីប្រចាំឆ្នាំ ២០០៤ ជាបន្តបន្ទាប់ គ្នាក្នុងរយៈពេលមួយខែម្តង វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព បានរៀបចំវេទិកាមួយទៀត ជាវេទិកាទី ៧ កាលពីថ្ងៃទី ២៧ ខែសីហា ក្រោមប្រធានបទថា **"ប្រទេសកម្ពុជា និងវេទិកាតំបន់អាស៊ាន"**។ កិច្ចពិភាក្សាលើកទី ៧ នេះ ដឹកនាំដោយ **ឯកឧត្តម អ៊ុន នឹង** អនុប្រធានគណៈកម្មាធិការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពត៌មាននៃរដ្ឋសភា និងជាសមាជិកគណៈកម្មការនាយក នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព។ ចូលរួមជាគណៈវាគ្មិនកិត្តិយសរួមមាន (១)-លោក **ច្រឡឹង សុមេធា** អនុប្រធាននាយកដ្ឋានអាស៊ាន ក្រសួងទេសចរណ៍ តំណាង **ឯកឧត្តម នុត និនដឿន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ (២)-**លោក សំរ៉ាំង កំសាន្ត** អ្នកស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ជាវាគ្មិនពិភាក្សា។ ចូលរួមជាសមាជិកសមាជិកានៃអង្គពិភាក្សាមានអ្នកដឹកនាំ អង្គការសង្គមស៊ីវិល ផ្នែកឯកជន អ្នកតំណាងស្ថាប័នរដ្ឋ និស្សិត បញ្ញវន្ត និង អ្នកសារពត៌មាន។

ឯកឧត្តម **អ៊ុន នីង** ប្រធានអង្គប្រជុំ បានបើកកម្មវិធីវេទិកាទី ៧ ស្តីពី **"ប្រទេសកម្ពុជា និងវេទិកាតំបន់អាស៊ាន"** ដោយបានថ្លែង អំណរគុណ ចំពោះគណៈវាគ្មិនកិត្តិយស និងសមាជិក សមាជិកានៃអង្គពិភាក្សា ទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួម ក្នុងវេទិកាទី ៧ ដ៏មានសារៈសំខាន់នេះ។ បន្ទាប់មក អង្គពិភាក្សាបានស្តាប់របាយការណ៍បូកសរុបលទ្ធផល នៃកិច្ចពិភាក្សាលើកទី ៦ ស្តីពី **"ប្រទេសកម្ពុជា និងដៃគូចរចាអាស៊ាន"**។

## អំពីលទ្ធផលសំខាន់ៗ នៃវេទិកាលើកទី ៧ ស្តីពី "ប្រទេសកម្ពុជា និង វេទិកាតំបន់អាស៊ាន : ទស្សនៈគណៈវាគ្មិន និងមតិ ពិភាក្សារួម"

### *ក -ចំណេះដឹងអំពីវេទិកាតំបន់អាស៊ាន :*

វេទិកាតំបន់អាស៊ាន (ASEAN Regional Forum) គឺជាវេទិកាពិភាក្សាពហុភាគីលើវិស័យនយោបាយ និងសន្តិសុខនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ ទស្សនាទាននៃការបង្កើត **"វេទិកាតំបន់អាស៊ាន"** គឺត្រូវបានស្ថាបនាឡើង នៅឆ្នាំ ១៩៩៤ (ខែកក្កដា) នៅទីក្រុងបាងកក។

គោលដៅចម្បងនៃការបង្កើត **"វេទិកាតំបន់អាស៊ាន"** នេះគឺ ដើម្បីរក្សានិរន្តរភាព ពង្រឹងសន្តិភាព និងវិបុលភាពក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ព្រោះថា : នេះគឺជាលើកទី ១ ហើយក្នុងរយៈពេល ១០០ ឆ្នាំចុងក្រោយនេះ ដែលតំបន់អាស៊ីប៉ាស៊ីហ្វិកគ្មានស្នូរកាំភ្លើង។ ដោយហេតុដូច្នោះហើយ បានជាមាននិន្នាការនៃបណ្តាប្រទេសក្នុងតំបន់ចង់ពង្រឹងកិច្ចពិភាក្សាអំពីសហប្រតិបត្តិការ ដើម្បីថែរក្សានិរន្តរភាព សន្តិភាព និងវិបុលភាពក្នុងតំបន់នេះ។ ម្យ៉ាងទៀត ព្រោះថាតំបន់អាស៊ីប៉ាស៊ីហ្វិកក៏ល្បីថា ជាតំបន់

ដ៏មានថាមពល និងវឌ្ឍនភាព លើវិស័យសេដ្ឋកិច្ចនៅលើពិភពលោកផងដែរ។ ហេតុដូច្នោះហើយ បានជា **"វេទិកាតំបន់អាស៊ាន"** ត្រូវបានបង្កើតឡើងដោយការដឹកនាំ និងផ្តួចផ្តើមគំនិតរបស់អាស៊ាន។

ក៏ប៉ុន្តែ ការថែរក្សានិរន្តរភាពលើវិស័យនយោបាយ និងសន្តិសុខនេះ ក៏ដូចជាការពង្រឹងសន្តិភាព និងវិបុលភាពក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកនេះ ក៏ពុំមែន ជារឿងងាយស្រួលទេ។ នៅសតវត្សទី ២០ តំបន់អាស៊ីប៉ាស៊ីហ្វិក ក៏មានបទពិសោធន៍ល្វីងជូរចត់អំពីសង្គ្រាមបំផ្លិចបំផ្លាញ ដោយសារជម្លោះវប្បធម៌ ជនជាតិ សាសនា និងប្រវត្តិសាស្រ្តច្រើនណាស់ដែរ។ ហើយទម្លាប់ធ្វើសហប្រតិបត្តិការលើផ្នែកខ្លះក្នុងតំបន់នោះ ក៏ពុំទាន់បានចាក់គ្រឹះល្អនៅឡើយ ដែរ។

ដូច្នេះហើយ បានជាអាស៊ានមានតួនាទីសំខាន់ណាស់ ក្នុងការដើរតួនៅក្នុងវេទិកាតំបន់នេះ ដើម្បីលើកស្ទួយសហប្រតិបត្តិការ និងផ្តល់នូវកតលិករ (Catalyst) ជាច្រើនដើម្បីបង្កើនសហប្រតិបត្តិការ លើវិស័យនយោបាយ និងសន្តិសុខក្នុងតំបន់នេះ។

អាស៊ានយល់ថា : ការបង្កើតវេទិកាតំបន់អាស៊ាននេះ គឺដើម្បីលើកស្ទួយកិច្ចពិភាក្សាជាមួយភាគីខាងក្រៅ ដើម្បីពង្រឹងនយោបាយសន្តិសុខក្នុងតំបន់ផង និងដើម្បីលើកស្ទួយកិច្ចពិភាក្សាលើវិស័យនយោបាយ និងសន្តិសុខ អន្តរសមាគមអាស៊ានរបស់ខ្លួនផង។

<u>អំពីសមាជិកភាពរបស់វេទិកាតំបន់អាស៊ាន</u> :

ពីដំបូង (១៩៩៤) បណ្តាប្រទេសជាសមាជិកនៃ **"វេទិកាតំបន់អាស៊ាន"** មានតែ ១៨ ប្រទេសទេ។ ប្រទេសទាំង ១៨ នោះគឺ : (១)-ខាង

សមាគម អាស៊ានមាន ៦ ប្រទេសគឺ ប្រទេសប្រ៊ុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងថៃ (២)-ខាងប្រទេសដែលជាដៃគូសន្ទនារបស់អាស៊ានមាន ៨ ប្រទេសគឺ អូស្ត្រាលី កាណាដា សហគមន៍អឺរ៉ុប ជប៉ុន កូរ៉េខាងជើង កូរ៉េខាងត្បូង (ROK), ញូសេឡេនដ៏ និងសហរដ្ឋអាមេរិក (៣)-ខាងប្រទេសសង្កេតការណ៍មាន ៣ ប្រទេសគឺ វៀតណាម ឡាវ និងប៉ាពួញូវហ្គីណេ (៤)-ខាងដៃគូប្រឹក្សាយោបល់ (Consultative States) មាន ២ ប្រទេសគឺ ចិន និងរុស្ស៊ី។

ដោយឡែកប្រទេសកម្ពុជា បានចូលជាសមាជិកទី ១៩ នៅឆ្នាំ១៩៩៥ ប្រទេសភូមា បានចូលជាសមាជិក ទី ២០ និងប្រទេសឥណ្ឌា បានចូលជាសមាជិកទី ២១ នៅឆ្នាំ ១៩៩៦។

**<u>តើប្រទេសកម្ពុជាយល់ដូចម្តេចអំពី "វេទិកាតំបន់អាស៊ាន" ហើយសង្ឃឹមថា និង បានទទួលផលប្រយោជន៏ដូចម្តេច ពីវេទិកាក្នុងតំបន់នេះ?</u>**

ប្រទេសកម្ពុជាយល់ថា :

ការដែលអាស៊ានបង្កើត **"វេទិកាតំបន់អាស៊ាន"** នេះ ពោលគឺដើម្បីបង្កើតបរិស្ថាននយោបាយ និងសន្តិសុខ ឱ្យប្រកបដោយសន្តិភាព និងស្ថេរភាពមួយ សំដៅលើកស្ទួយការអភិវឌ្ឍន៏ក្នុងតំបន់អាស៊ាន ក៏ដូចជាក្នុងតំបន់ស៊ីប៉ាស៊ីហ្វិក ឱ្យមានភាពរុងរឿង។

វេទិកាតំបន់អាស៊ាន គឺជាឧបករណ៍ដ៏សំខាន់ និងជាវេទិកាតែមួយគត់ ដើម្បីផ្លាស់ប្តូរទស្សនៈក្រៅផ្លូវការ តែនៅលើមូលដ្ឋានស្មើភាព អំពីបញ្ហានយោបាយ និងសន្តិសុខនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកដ៏ធំធេង និងប្រកបដោយថាមពលនេះ។

វេទិកាតំបន់អាស៊ាន គឺជាវេទិកាដែលប្រទេសកម្ពុជាអាចចែករំលែក នូវក្ដីកង្វល់ខាងសន្តិសុខរបស់ខ្លួន មិនត្រឹមតែការពារប្រទេសផ្ទាល់ទេ តែគឺដើម្បីបង្កើតផលប្រយោជន៍ខាងនយោបាយ និងសន្តិសុខនៅក្នុងតំបន់ផងដែរ ។

ក្នុងឋានៈជាប្រទេសតូចមួយ ប្រទេសកម្ពុជាអាចប្រើប្រាស់ នូវវេទិកា សន្តិសុខពហុភាគីដ៏មានសារៈសំខាន់ដើម្បីនិយាយអំពីជំហរ ឬក៏បញ្ចេញមតិទៅលើបញ្ហាសំខាន់ៗដែលទាក់ទងដល់បញ្ហាសន្តិភាព និងសន្តិសុខរបស់ខ្លួន ។

តាមរយៈវេទិកាតំបន់អាស៊ាន ប្រទេសកម្ពុជាអាចនឹងចូលរួមសន្ទនា ឬពិភាក្សាជាមួយបណ្ដាប្រទេសជាច្រើន អំពីក្ដីកង្វល់រួមគ្នាទៅលើបញ្ហានយោបាយ និងសន្តិសុខ ។

ជាការពិតណាស់ វេទិកាតំបន់អាស៊ានមានសារៈសំខាន់ណាស់ ពិសេសដល់ការថែរក្សាសន្តិភាព និងសន្តិសុខនៅលើពិភពលោក ។

## តើប្រទេសកម្ពុជាអាចនឹងទទួលបានផលប្រយោជន៍ដូចម្ដេច ពីវេទិកាតំបន់អាស៊ាន?

អង្គពិភាក្សាសង្ឃឹមថា ប្រទេសកម្ពុជាអាចនឹងទទួលបានផលប្រយោជន៍ ៤ យ៉ាងពីវេទិកាតំបន់អាស៊ាន-ARF គឺ : (១)-អាចប្រើប្រាស់វេទិកានេះ ជាវេទិកាសន្តិសុខពហុភាគី ដើម្បីនិយាយ និងបញ្ចេញមតិលើបញ្ហាសំខាន់ៗ ដែល ទាក់ទងដល់បញ្ហាសន្តិសុខ និងសន្តិភាពរបស់ខ្លួន (២)-អាចចូលរួមសន្ទនា និងពិភាក្សាជាមួយបណ្ដាប្រទេសធំៗ ជាច្រើនក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក អំពីក្ដីកង្វល់ទៅលើបញ្ហានយោបាយសន្តិសុខរបស់ខ្លួន (៣)-អាចដោះស្រាយបញ្ហា សន្តិសុខពីខាងក្រៅ និងស្ថាបនា សន្តិសុខផ្ទៃក្នុងប្រទេស និង (៤)-អាចសិក្សារៀនសូត្រអំពីបរិស្ថាន សន្តិសុខរបស់តំបន់ និង

ពិភពលោកដែលផ្លាស់ប្តូរជានិច្ច ពោលគឺសិក្សារៀនសូត្រ ក្នុងការស្ថាបនាជំនឿ និងទំនុកចិត្តជាមួយយោធាក្នុងតំបន់។

## ៩-អំពីយុទ្ធសាស្ត្រលើវិស័យទេសចរណ៍កម្ពុជា ១៤ យ៉ាងដែលអាចដកស្រង់យកធ្វើជា ទស្សនាទានសំខាន់ៗ សម្រាប់ពិភាក្សាក្នុងវេទិកាតំបន់អាស៊ាន:

លោក **ច្រឡឹង សុះមេធា** តំណាង ឯកឧត្តម **ធុក និនវឿន** រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ បានពន្យល់បកស្រាយ អំពីយុទ្ធសាស្ត្រលើវិស័យទេសចរណ៍១៤ យ៉ាង។ អង្គពិភាក្សាបានចាប់អារម្មណ៍ទៅលើសន្តិសុខសំរាប់ទេសចរណ៍ ហើយក៏ផ្តោតជាពិសេសគឺ ទេសចរណ៍ផ្លូវភេទ ដែលអាចធ្វើឱ្យប៉ះពាល់ដល់តម្លៃប្រពៃណីជាតិយើង ។ ការជំរុញទេសចរណ៍ វប្បធម៌ និងធម្មជាតិជាគោលបំណងចម្បងរបស់កម្ពុជា។

យុទ្ធសាស្ត្រលើវិស័យទេសចរណ៍នៅកម្ពុជាទាំង ១៤ ចំណុចនោះគឺ : (១)-ការបន្តកិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន (២)-ការបង្កើននិងធានា សន្តិសុខ និងសុវត្ថិភាពរបស់ទេសចរណ៍ (៣)-ការកសាងច្បាប់ និងបទដ្ឋាននានា ដើម្បីគ្រប់គ្រងវិស័យទេសចរណ៍ (៤)-ការស្ថាបនាផែនការថ្នាក់លើ និងថ្នាក់តំបន់ (៥)-ការទប់ស្កាត់អាជីវកម្មផ្លូវភេទ និងកុមារ (៦)-ការជំរុញសហប្រតិបត្តិការ លើវិស័យទេសចរណ៍អាស៊ាន (៧)-ការគាំទ្រ និងចូលរួម ក្នុងយុទ្ធនាការ "ទស្សនាអាស៊ាន" (៨)-ការពង្រឹង និងបង្កើនគុណភាពផលិតផលទេសចរណ៍ (៩)-ការហ្វឹកហ្វឺនប្រជាពលរដ្ឋឱ្យចេះផលិតផលិតផលទេសចរណ៍ (១០)-ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន (១១)-ការសម្រួលដល់ការធ្វើដំណើររបស់ទេសចរណ៍ (១២)-ការជំរុញ និងលើកទឹកចិត្ត

ដល់ការវិនិយោគទុនជាតិ (១៣)-ការធ្វើផែនការរកចំណូលលើវិស័យទេសចរណ៍ និង (១៤)-ការលើកស្ទួយការហ្វឹកហ្វឺនធនធានមនុស្ស (រដ្ឋ និងឯកជន) ដោយសហការជាមួយអាស៊ាន និងសហគមន៍អន្តរជាតិ ។

**គ-អំពីសំណូមពរជាអនុសាសន៍ :**

ដើម្បីឱ្យប្រទេសកម្ពុជា ទទួលបានផលប្រយោជន៍ពិតពី **"វេទិកាតំបន់អាស៊ាន"** ពិតប្រាកដ ទាំងគណៈវាគ្មិន ទាំងអង្គពិភាក្សារួមបានផ្តល់ មតិថា :

- ប្រទេសកម្ពុជា គួរមានទំនាក់ទំនងល្អខាងការទូត ជាមួយប្រទេសមហាអំណាចធំៗទាំងអស់ ដើម្បីធានាផលប្រយោជន៍ខាងសន្តិសុខរបស់ខ្លួន។ ការមានលំអៀងក្នុងប្លុកណាមួយនឹងធ្វើឱ្យយើងទទួលគ្រោះថ្នាក់ ។
- ប្រទេសកម្ពុជាក៏ចាំបាច់ត្រូវបង្កើនទំនាក់ទំនងទ្វេភាគី និងពហុភាគី ឱ្យបានច្រើនថែមទៀត ជាមួយបណ្តាប្រទេសជិតខាង ក្នុងតំបន់ដើម្បីសន្តិសុខក្នុងតំបន់ ។
- ប្រទេសកម្ពុជា គួរតែបន្តប្រើប្រាស់ការងារការទូតរបស់ខ្លួន ឱ្យមានប្រសិទ្ធិភាពថែមទៀត លើវិស័យនយោបាយសន្តិសុខនេះ ដើម្បីលើកស្ទួយកិត្តិសព្ទជាតិយើង ។
- ប្រទេសកម្ពុជាគួរជំរុញមន្ត្រីយោធាកម្ពុជា ឱ្យចូលរួមសិក្សាស្រាវជ្រាវពិភាក្សា អំពីបញ្ហាសន្តិសុខ ក្នុងតំបន់ឱ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីវិភាគ និងស្វែងយល់អំពីយុទ្ធសាស្ត្រការពារសន្តិសុខជាតិ និងសន្តិសុខតំបន់ឱ្យបានល្អប្រសើរ ។

- ប្រទេសកម្ពុជាគួរបង្កើតបណ្តាញក្រុម អ្នកជំនាញការកម្ពុជាមួយដែលមានសមាសភាពទាំងមន្ត្រីរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល ដើម្បីតាមដានសិក្សាស្រាវជ្រាវ និងពិនិត្យមើលទំនាក់ទំនងបរទេស និងសន្តិសុខ។ ក្រុមអ្នកជំនាញការ នេះអាចផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល និងក្រសួងមន្ទីរពាក់ព័ន្ធអំពីបញ្ហាសំខាន់ៗ ដែលទាក់ទងទៅនឹងសន្តិសុខ និងសហប្រតិបត្តិការអន្តរជាតិជាពិសេសដើម្បីផ្តល់ យោបល់សំរាប់វេទិកាតំបន់អាស៊ាន។

- ប្រទេសកម្ពុជាគួរតែបង្កើតស្ថាប័នវិភាគី (Think Tanks Institutions) ឱ្យបានច្រើនថែមទៀត ដើម្បីជួយធ្វើការរាជរដ្ឋាភិបាល ក្នុងការសិក្សាស្រាវជ្រាវ អំពីបញ្ហាជាតិ បញ្ហាតំបន់ និងយុទ្ធសាស្ត្រអន្តរជាតិ?

- ប្រទេសកម្ពុជាមិនគួរភ្លេចខ្លួនក្នុងសន្តិភាពពេកទេ ពោលគឺពុំគួរពឹងគេឱ្យជួយដោះស្រាយបញ្ហា សន្តិសុខរបស់ខ្លួន ជាងការពឹងខ្លួនឯងឡើយ។ ចំពោះបញ្ហានេះ បន្ថែមទៅលើសហប្រតិបត្តិការ ពហុភាគី លើវិស័យនយោបាយ សន្តិសុខក្នុងតំបន់ ប្រទេសកម្ពុជាគួរតែបង្កើនសមត្ថភាពរក្សាការពារ ស្ថេរភាព សន្តិសុខ និងសន្តិភាពផ្ទៃក្នុងរបស់ប្រទេសជាតិខ្លួនដោយខ្លួនឯង ឱ្យបានច្រើនជាងការពឹងអ្នកដទៃ។

**សេចក្តីសន្និដ្ឋាន :**

ជារួម កិច្ចពិភាក្សាក្នុងវេទិកាលើកទី ៧ ឆ្នាំ ២០០៤ ស្តីពី "**ប្រទេស កម្ពុជា និងវេទិកាតំបន់អាស៊ាន**" បានទទួលលទ្ធផលល្អ។ ចំណេះដឹងនិង អនុសាសន៍

ទាំងឡាយ ដែលអង្គពិភាក្សាបានរកឃើញ គឺពិតជាមានប្រយោជន៍ ដល់ការលើកស្ទួយការយល់ដឹងរបស់មន្ត្រីរាជការ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋយើងក្នុងការចូលរួមពិភាក្សា ក្នុងវេទិកាតំបន់អាស៊ាន ដើម្បីរក្សាការពារ និងលើកស្ទួយ នូវនិរន្តរភាពនៃស្ថេរភាពនយោបាយ សន្តិសុខ និងវិបុលភាពរបស់ប្រទេសជាតិ យើងក្នុងតំបន់ ក៏ដូចជាលើពិភពលោក។

ការផ្សព្វផ្សាយចំណេះដឹងទាំងនេះ គឺជាការចាំបាច់ណាស់ ដែលត្រូវធ្វើ ជាបន្តដើម្បីបង្កើន ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីចំណេះដឹងអាស៊ាន ដែល ជាគន្លឹះ នៃការស្ថាបនាកម្លាំងមហាជនគាំទ្រ ក្នុងការរក្សាការពារសន្តិសុខ សុវត្ថិភាព សន្តិភាព និងការអភិវឌ្ឍន៍នៅប្រទេសជាតិយើង។

វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពនឹងខិតខំប្រឹងផ្សព្វផ្សាយនូវកម្រងនៃចំណេះដឹង និងអនុសាសន៍ទាំងនេះ និងផ្ញើជូនថ្នាក់ដឹកនាំ នៃរាជរដ្ឋាភិបាលសភាជាតិ ព្រឹទ្ធសភា និងក្រសួងមន្ទីរពាក់ព័ន្ធ ដើម្បីពិនិត្យពិចារណា ដើម្បីបានជាមូលដ្ឋានខ្លះ ដល់ការស្ថាបនាគោលនយោបាយថ្មី និងប្លែកសម្រាប់ត្រៀមចូលរួមពិភាក្សាក្នុងវេទិកាតំបន់អាស៊ាន ដែលមានសារៈសំខាន់លើវិស័យសន្តិសុខក្នុងតំបន់នេះ។

# វេទិកាទី ៨ ប្រទេសកម្ពុជា និងអាស៊ាន+៣

## សេចក្តីផ្តើម

នេះគឺជាវេទិកាទី ៨ ហើយ ដែលវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ដោយបានទទួលការឧបត្ថម្ភពី មូលនិធិ ហ្វ្រិឌ្រិច នៃប្រទេស អាឡឺម៉ង់ដ៏ បានរៀបចំកិច្ចភាក្សា ស្តីពី "**ប្រទេសកម្ពុជា និងសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍**" ដែលហៅថាកាត់ថា "**អាស៊ាន**"។ ប្រធានបទលើកទី ៨ នេះបាន ពិភាក្សាចូលជ្រៅទៅក្នុងទំនាក់ទំនងនៃប្រទេសកម្ពុជា និង អាស៊ាន+៣។

វេទិកាលើកទី៨ នេះមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដោយបានទទួល **ឯកឧត្តម អ៊ុង ហួត** ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា និងជាអនុប្រធាននៃគណៈកម្មាធិការ នាយក នៃ វិទ្យាស្ថាន ខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ជាអ្នកដឹកនាំអង្គប្រជុំ។

ម្យ៉ាងវិញទៀត វេទិកាលើកទី៨ នេះ ក៏បានទទួលវត្តមានដ៏សំខាន់ពី គណៈវាគ្មិនកិត្តិយសបីរូប ដែលសុទ្ធសឹងជាវាគ្មិនជំនាញលើការងារអាស៊ាន+៣ ដូចជា (១)- អ្នកតំណាង **ឯកឧត្តម នាង ផាត** រដ្ឋលេខាធិការក្រសួងការពារជាតិ **(២)- លោក កេត សុផាន់** ប្រធាននាយកដ្ឋានអាស៊ាន នៃទីស្តីការគណៈរដ្ឋមន្ត្រី និង

(៣) –**លោក សំរ៉ាំង កំសាន្ត** អ្នកស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព បានចូលរួមជា គណៈវាគ្មិនពិភាក្សា និងជាអ្នកបូកសរុបលទ្ធផលនៃអង្គពិភាក្សា ។

ព្រមជាមួយនោះ វេទិកាលើកទី ៨ ក៏បានទទួលការចូលរួមដោយស្មោះស្ម័គ្រពីអ្នកដឹកនាំ និងតំណាងស្ថាប័នរដ្ឋ អ្នកដឹកនាំ និងតំណាងអង្គការសង្គម ស៊ីវិល និស្សិត បញ្ញវន្ត ផ្នែកឯកជន និងអ្នកសារពតិមានជាតិជាច្រើនជាសមាជិក នៃអង្គពិភាក្សាផង ។

## លទ្ធផលនៃកិច្ចពិភាក្សាក្នុងវេទិកាលើកទី ៨ ស្តីពី "ប្រទេសកម្ពុជា និង អាស៊ាន+៣"

### ក -អំពីគោលបំណង និងសំណួចពរ :

មុននឹងបើកកិច្ចពិភាក្សាវេទិកាលើកទី ៨ ស្តីពី "**ប្រទេសកម្ពុជា និង អាស៊ាន+៣** : អ្នកសម្របសម្រួលកម្មវិធី បានជម្រាបអង្គពិភាក្សាអំពីបំណងនៃអង្គប្រជុំនេះថា គឺដើម្បីស្វែងយល់អំពីអត្ថន័យនិងសកម្មភាពរបស់អាស៊ាន+៣ ពិសេសគឺទំនាក់ទំនងរវាងប្រទេសកម្ពុជា និងបណ្តាប្រទេសអាស៊ាន+៣ នេះ ។

*វិទ្យាស្ថានមានបំណងស្វែងរកឱ្យឃើញ :*

១- <u>អំពីសញ្ញាណរបស់អាស៊ាន+៣</u> :

- អ្វីទៅអាស៊ាន+៣
- ហេតុដូចម្តេចបានជាចាំបាច់មានអាស៊ាន+៣?

២- <u>អំពីគុណប្រយោជន៏នៃអាស៊ាន+៣</u> :

- តើទំនាក់ទំនងរវាងអាស៊ាន ១០ និង អាស៊ាន+៣ មានគុណប្រយោជន៏ដូចម្តេចដល់អ្នកទាំងពីរ (គឺអាស៊ាន ១០ និង អាស៊ាន+៣)?

៣- <u>អំពីទំនាក់ទំនងរវាងប្រទេសកម្ពុជា និងអាស៊ាន+៣</u> :

- តើទំនាក់ទំនងរវាងប្រទេសកម្ពុជា និងអាស៊ាន+៣ បានផលប្រយោជន៏ ដូចម្តេចដល់ប្រទេសកម្ពុជា?

៤- <u>អំពីភារកិច្ចចំពោះមុខ និងទស្សនវិស័យទៅអនាគត</u> :

- តើប្រទេសកម្ពុជាគួរធ្វើដូចម្តេច ដើម្បីទទួលបានផលប្រយោជន៏ពិតប្រាកដពីអាស៊ាន+៣?
- ទស្សនវិស័យទៅអនាគត?
- សំណួមពរជាអនុសាសន៏?

**ខ-អំពីលទ្ធផលសំខាន់ៗ នៃកិច្ចពិភាក្សារួច :**

១- អាស៊ាន+៣ គឺអាស៊ាន១០+ចិន ជប៉ុន និងកូរ៉េខាងត្បូង។

ប្រទេសទាំងបីនេះ ស្ថិតនៅភូមិភាគអាស៊ីភាគឦសាន (Northeast Asia) ។

២- ហេតុផលដែលនាំឱ្យកើតមានអាស៊ាន +៣ គឺដោយសារតែ :

(1)- និន្នាការក្នុងតំបន់ទៅលើសេរីភាវូបនីយកម្ម និងឧស្សាហូបនីយកម្ម

(2)- ការផ្តួចផ្តើមគំនិតចេញពីដៃគូសន្ទនា (Dialogue partners) គឺ ចិន, ជប៉ុន និងកូរ៉េខាងត្បូង

(3)- ការបង្កើតឱ្យមានសហប្រតិបត្តិការ លើវិស័យសេដ្ឋកិច្ច នយោបាយ វប្បធម៌ និងសន្តិសុខរវាងអាស៊ាន ១០ និងអាស៊ាន+៣

(4)- វិបត្តិហិរញ្ញវត្ថុអាស៊ីក្នុងឆ្នាំ ១៩៩៧-១៩៩៨ ដែលបណ្តាលមកពីបញ្ហាប្រឈមមុខធំៗ ពីរបស់អាស៊ាន គឺ : ១-វិបត្តិហិរញ្ញវត្ថុ និង ២-ការបង្កើនសហប្រតិបត្តិការក្នុងតំបន់ ។

គឺដោយសារតែហេតុផលទាំង ៤ នេះហើយបានជាអាស៊ាន+៣ ត្រូវបានបង្កើតឡើង។

៣- បំណងនៃការបង្កើតអាស៊ាន+៣ មានពីរយ៉ាង គឺ :

- <u>បំណងចំពោះមុខ</u> : គឺដើម្បីពង្រឹងសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រវាងប្រទេសសមាជិកអាស៊ានទាំង ១០ និងប្រទេសធំៗ ទាំងបីនៅអាស៊ីបូព៌ា គឺប្រទេសចិន ប្រទេសជប៉ុន និងកូរ៉េខាងត្បូង។

- <u>បំណងទៅអនាគត ឬបំណងជាយុទ្ធសាស្ត្រ</u> : គឺដើម្បីបង្កើតឱ្យបាននូវសហគមន៍អាស៊ីបូព៌ាមួយដែលមានរូបភាព និងខ្លឹមសារស្រដៀងគ្នានឹងសហគមន៍អឺរ៉ុបដែរ ពោលគឺ អាចនឹងមានទីផ្សារ រួមរូបិយវត្ថុរួម និងសេដ្ឋកិច្ចរួម។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ការបង្កើតឱ្យបាន

សហគមន៍អាស៊ីបូព៌ានេះ គឺពិតជាមានការលំបាក និងបញ្ហាស្មុគស្មាញជាច្រើន ។

៤- ការបង្កើតអាស៊ាន+៣ នៅមានបញ្ហាប្រឈមមុខជាច្រើន ។ បញ្ហាប្រឈមមុខទាំងនោះគឺ :

- តួនាទីដឹកនាំរវាង បណ្តាប្រទេសធំៗ ទាំងបី : តើនរណាជាអ្នកដឹកនាំ? (បញ្ហានេះ) កំពុងពិភាក្សាយ៉ាងខ្លាំងក្លា
- ទស្សនៈឆ្ពោះទៅការបង្កើតសហគមន៍អាស៊ីបូព៌ា ដែលមានបញ្ហាមិនចុះសម្រុងនិងគ្នាជាច្រើន
- កិច្ចប្រជុំរបស់អាស៊ាន+៣ មានរយៈពេលខ្លីពេកជាហេតុបណ្តាលឱ្យបញ្ហាទាំងអស់ ពុំអាចដោះស្រាយបាន
- បញ្ហាភេរវកម្ម និងការរត់ពន្ធគ្រឿងញៀន
- បញ្ហាសន្តិសុខឆ្លងដែន
- ភាពដោយឡែកនៃវប្បធម៌
- ស្លាកស្នាមនៃការបែកបាក់ រវាងបណ្តាប្រទេសទាំងបីពីអតីតកាល
- ការបាត់បង់ទំនុកចិត្ត និងកង្វះជំនឿរវាងគ្នា និងគ្នា និង
- វិបត្តិចិនដីគោក និងតៃវ៉ាន់ ។

៥- ដើម្បីបង្កើតអាស៊ាន+៣ និងដោះស្រាយបញ្ហាប្រឈមមុខទាំងនេះ អាស៊ានបានបង្កើតឱ្យមានកិច្ចប្រជុំកំពូល ស្តីពី អាស៊ាន+៣ ជាច្រើន ដូចជានៅទីក្រុងម៉ានីល ទីក្រុងឈៀងម៉ៃ ទីក្រុងហាណូយ និងទីក្រុងបាលីជាដើម ។ល។ ជាលទ្ធផលកិច្ចប្រជុំបានបង្កើតឱ្យមាន **"ក្រុមចក្ខុវិស័យអាស៊ីបូព៌ា"** ដើម្បីធ្វើសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និង ការអភិវឌ្ឍ ។

៦- អំពីផលប្រយោជន៍ដែលប្រទេសកម្ពុជាអាចនឹងទទួលបានពីអាស៊ាន+៣ :

អង្គប្រជុំបានពិភាក្សាឃើញថា ប្រទេសកម្ពុជានឹងបានទទួលជំនួយហិរញ្ញវត្ថុអភិវឌ្ឍន៍ជាច្រើនលើវិស័យវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីប្រទេសជប៉ុន ចិន និងកូរ៉េខាងត្បូង ដែលបានសន្យាថា នឹងផ្តល់ទុនសម្រាប់អភិវឌ្ឍន៍បណ្តាប្រទេសជាសមាជិកអាស៊ានថ្មីៗទាំងអស់ ដែលក្នុងនោះមានប្រទេសកម្ពុជាមួយផងដែរ ។ ក៏ប៉ុន្តែ ផលប្រយោជន៍ជាក់ស្តែង និងចំពោះមុខដែលប្រទេសកម្ពុជា អាចទទួលបានពីទំនាក់ទំនងអាស៊ាន+៣ នោះគឺ :

- កម្ពុជាលែងរស់នៅក្នុងភាពឯកោលើឆាកអន្តរជាតិទៀតហើយ
- កំណើនទេសចរណ៍ពីប្រទេសអាស៊ាន+៣ ដែលជាប្រទេសមានកម្លាំងសេដ្ឋកិច្ចខ្លាំងក្លា
- ទទួលជំនួយជាច្រើន ជាពិសេសលើការអភិវឌ្ឍន៍ធនធានមនុស្ស
- ទទួលការវិនិយោគទុនពីអាស៊ាន+៣
- ទទួលវិទ្យាសាស្ត្របច្ចេកទេសថ្មីៗ

- ទទួលផលប្រយោជន៍ជាយុទ្ធសាស្ត្រ សេដ្ឋកិច្ច ការទូត កិត្យានុភាព និង ភាពស្របច្បាប់លើឆាកអន្តរជាតិ
- លើវិស័យការពារជាតិ គឺអាចជួយរក្សាការពារសន្តិភាព សន្តិសុខ ការអភិវឌ្ឍយោធា ការលុបបំបាត់ការគំរាមកំហែងពីខាងក្រៅ ការទប់ស្កាត់ ឧក្រិដ្ឋកម្មឆ្លងដែន។ ការហ្វឹកហ្វឺនកងកម្លាំងយោធា និងសន្តិសុខ ការទប់ស្កាត់ការរត់ពន្ធអាវុធ និងវត្ថុបុរាណ ការលើកស្ទួយចំណេះដឹងខាងវិស្វកម្ម កិច្ចការជំនាញយោធា និង ការប្រយុទ្ធនឹងគ្រោះធម្មជាតិ។

៧- កិច្ចពិភាក្សាអំពីបញ្ហាព្រំដែនកម្ពុជា-វៀតណាម-ឡាវ :

វិបត្តិនៃបញ្ហាព្រំដែនកម្ពុជា-វៀតណាម-ឡាវ គឺបណ្ដាលមកពីភាពពុំច្បាស់លាស់ នៃការគូសព្រំដែនរបស់បារាំងដែលបានធ្វើយូរឆ្នាំ គ្មានមធ្យោបាយទំនើបតាមរយៈគូសតៗគ្នា ដោយគ្មានភាពប្រាកដប្រជា។ ព្រំដែនដែលគូសដោយបារាំងនោះ គឺគ្រាន់តែជាព្រំដែនរដ្ឋបាល (សម្រាប់យកពន្ធ) ពុំមែនជាព្រំដែនអន្តរជាតិទេ។ ហេតុដូច្នោះហើយបានជាព្រំដែននេះបង្កឱ្យមានទំនាស់ និងបញ្ហាលំបាកដល់សព្វថ្ងៃ។ ដូច្នេះ ដំណោះស្រាយអំពី បញ្ហាព្រំដែននេះ ត្រូវការពេលវេលាយូរអង្វែង។ ជាសំខាន់គឺត្រូវការឆន្ទៈនយោបាយរបស់ប្រទេសទាំងបី ដែលចាំបាច់ត្រូវចេះរួមគ្នាដោះ ស្រាយដោយសន្តិវិធី។ យើងសង្ឃឹមថា កិច្ចសហប្រតិបត្តិការរវាងបណ្ដា ប្រទេសទាំងបី ដែលជាសមាជិកអាស៊ានដូចគ្នា អាចនឹងដោះស្រាយបញ្ហានេះបាន។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលកម្ពុជា នឹងបង្កើតឱ្យមានឧត្ដមក្រុមប្រឹក្សាព្រំដែនជាតិមួយ ដើម្បីជួយដោះស្រាយបញ្ហានេះតាមច្បាប់អន្តរជាតិ។

## ៨- អំពីទំនាក់ទំនងកម្ពុជា-ចិន និងការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា

ទំនាក់ទំនងកម្ពុជា-ចិន មានអាយុកាលរាប់សតវត្សមកហើយ។ តាមប្រវត្តិសាស្ត្រ (ឯកសារប្រវត្តិសាស្ត្ររបស់លោក **ត្រឹង ងារ**) បានឱ្យដឹងថា ទំនាក់ទំនងកម្ពុជា-ចិន នេះ មានមកតាំងពីសតវត្សទី ៣ នៃគ្រិស្តសករាជ។ ទំនាក់ទំនងនេះភាគច្រើនមានលក្ខណៈល្អប្រសើរ និងផ្តល់ផលប្រយោជន៍ជាច្រើនឱ្យប្រទេសកម្ពុជា។ កន្លងមករដ្ឋាភិបាល និងប្រជាពលរដ្ឋចិនបានជួយប្រទេសកម្ពុជាជាច្រើន។ ក៏ប៉ុន្តែជំនួយនេះពុំអាចជួយកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋកម្ពុជាទាំងស្រុងបានទេ។ ការពិតមធ្យោបាយដែលមានប្រសិទ្ធិភាពបំផុត ដល់ការបន្ថយភាពក្រីក្រ គឺអាស្រ័យដោយប្រទេសជាតិយើង នោះគឺការអភិវឌ្ឍសេដ្ឋកិច្ច ជាតិយើង ឱ្យបានរុងរឿងដោយខ្លួនយើង។ ជំនួយខាងក្រៅ គឺគ្រាន់តែជាកំដៅ ដែលជួយឱ្យជំនួយខ្លួនឯងបានសម្រេចជោគជ័យប៉ុណ្ណោះ។ ក៏ប៉ុន្តែ ទោះជាដូចម្តេចក្តី ការជួយខ្លួនឯងដោយខ្លួនឯងមានតម្លៃ និងប្រសិទ្ធិភាពជាងការពឹងអ្នកដទៃ។

### គ-អំពីអនុសាសន៍ :

ដើម្បីឱ្យទំនាក់ទំនងកម្ពុជា និងអាស៊ាន+៣ បានទទួលលទ្ធផលល្អ ប្រសើរទៅអនាគត អង្គពិភាក្សាបានផ្តល់ទស្សនៈ និងមតិយោបល់ជាច្រើន ដែលអាចចាត់ទុកថាជាអនុសាសន៍ ដូចខាងក្រោម :

- គួរខិតខំលើកស្ទួយការយល់ដឹងអំពីគោលដៅ និងសំណូមពរ នៃទំនាក់ទំនងអាស៊ាន+៣ និងប្រទេសជាតិយើងឱ្យបានល្អ ដើម្បីរៀបចំខ្លួន ធ្វើ

ផែនការ និងសកម្មភាពឱ្យស្របតាមគោលដៅនោះ ទើបបានទទួលផលប្រយោជន៍ពិតប្រាកដ

- គួរតែមានធនធានមនុស្សប្រកបដោយសមត្ថភាព និងគុណភាពបំពេញការងារគ្រប់គ្រាន់ដើម្បីចរចា និងធ្វើសហប្រតិបត្តិការជាមួយអាស៊ាន+៣ ឱ្យមានប្រសិទ្ធិភាព
- គួរតែមានដើមទុន និងធនធានសម្ភារៈ និងហិរញ្ញវត្ថុគ្រប់គ្រាន់សំរាប់ធ្វើសហប្រត្តិបត្តិការ លើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយ អាស៊ាន+៣ ឱ្យបានល្អ
- គួរតែពង្រឹងគោលនយោបាយការទូត ជាមួយអាស៊ាន+៣ឱ្យបានខ្លាំងក្លាថែមទៀត
- គួរពង្រឹងការគ្រប់គ្រងលើវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ពាណិជ្ជកម្ម កសិកម្ម និងឧស្សាហកម្មឱ្យបានល្អបំផុត ដើម្បីទាក់ទាញ ការវិនិយោគផ្ទាល់ពីបរទេសផ្តល់ជំនឿឱ្យដៃគូអភិវឌ្ឍន៍ និងលើកស្ទួយកិត្យានុភាពជាតិនៅលើឆាកអន្តរជាតិ
- គួរតែឧស្សាហ៍ព្យាយាម ឈ្វេងយល់សិក្សាអំពីការប្រព្រឹត្តទៅនៃទំនាក់ទំនងអាស៊ាន+៣ និងតាមដានពិនិត្យមើលទំនាក់ទំនងនេះ ដើម្បីវាយតម្លៃកែលំអឱ្យបានត្រឹមត្រូវតាមពេលវេលា
- គួរតែខិតខំរក្សាស្ថេរភាពនយោបាយ សន្តិភាព និងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិសេសគឺការអភិវឌ្ឍន៍ លើវិស័យកសិកម្ម

ពាណិជ្ជកម្ម ឧស្សាហកម្ម សហគ្រាសធុនតូច និងធុនមធ្យម និងការផ្ដល់ទុនវិនិយោគឱ្យបានល្អលើវិស័យនេះ ដើម្បីត្រៀមផ្លាស់ប្ដូរទុន ក៏ដូចជាផលិតផល និងបទពិសោធន៍ជាមួយអាស៊ាន+៣ និង

- គួរតែឧស្សាហ៍ព្យាយាមចូលរួម ប្រជុំសិក្សាដកពិសោធន៍ និងបង្កើតការស្រាវជ្រាវ និងពិភាក្សាលើ "**ទំនាក់ទំនងកម្ពុជាអាស៊ាន+៣**" ដើម្បីដៅទិសអនុវត្តឱ្យបានល្អ និងឱ្យបានទទួលផលប្រយោជន៍ ពិតប្រាកដពីសហប្រតិបត្តិការ នេះ។

## សេចក្ដីសន្និដ្ឋាន

កិច្ចពិភាក្សាក្នុងវេទិកាទី ៨-ឆ្នាំ ២០០៤ ស្ដីពី "**ប្រទេសកម្ពុជា និងអាស៊ាន+៣**" បានទទួលលទ្ធផលល្អយ៉ាងត្រចះត្រចង់។ ទាំងគណៈវាគ្មិនកិត្តិយស ក៏ដូចជាសមាជិកអង្គពិភាក្សា និងគណៈដឹកនាំអង្គប្រជុំបានផ្ដល់ចំណេះដឹងថ្មីៗជាច្រើនលើប្រធានបទ។

ចំណេះដឹងជាបទពិសោធន៍ និងអនុសាសន៍ទាំងនេះ ពិតជាមានតម្លៃដល់ការលើកស្ទួយទំនាក់ទំនងកម្ពុជា និងអាស៊ាន+៣ ដែលជាគន្លឹះដ៏សំខាន់មួយដល់ការលើកស្ទួយវឌ្ឍនភាព លើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។

# វេទិកាទី ៩ ប្រទេសកម្ពុជា និង ផែនការសកម្មភាពវៀងច័ន្ទ

## សេចក្តីផ្តើម

នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ ពីម៉ោង ៩:០០ ដល់ម៉ោង ១១:៣០នាទីព្រឹក វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ដោយ បានទទួលការឧបត្ថម្ភពី **មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត** នៃប្រទេសអាឡឺម៉ង់ដ៏ បានរៀបចំវេទិកាមួយ គឺវេទិកាទី៩ ស្តីពី "**ប្រទេសកម្ពុជា និង ផែនការសកម្មភាពវៀងច័ន្ទ** ។ វេទិកាទី ៩ នេះដឹកនាំកិច្ចពិភាក្សាដោយ **ឯកឧត្តម អ៊ុន នីង** អនុប្រធានគណៈកម្មាធិការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពតិមាននៃរដ្ឋសភា និងជាសមាជិកនៃគណៈកម្មាធិការនាយក នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព។ ចូលរួមជាវាគ្មិនក្នុងវេទិកាទី ៩ នេះមាន : **(១)-លោក នង សាកល** អនុប្រធាននាយកដ្ឋាន វេទិកាតំបន់អាស៊ាន អគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **(២)-លោក សំរ៉ាំង កំសាន្ត**

អ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ដែលបានអញ្ជើញ ចូលរួមក្នុងនាមជាគណៈវាគ្មិនពិភាក្សា និងជាអ្នកសម្របសម្រួលវេទិកាផង។

ក្នុងពិធីផ្តើមបើកអង្គពិភាក្សា **ឯកឧត្តម អ៊ុន នីង** អនុប្រធាន គណៈកម្មធិការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពតិមាន នៃរដ្ឋសភា និងជាសមាជិកនៃគណៈកម្មាធិការនាយក នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព បានថ្លែងអំណរគុណដោយស្មោះ ចំពោះគណៈវាគ្មិនកិត្តិយស និងសមាជិក សមាជិកានៃអង្គពិភាក្សាទាំងអស់ ដែលបានឆ្លៀតឱកាសដ៏មមាញឹកមកចូលរួមក្នុងវេទិកាទី ៩ ដ៏មានសារៈសំខានះនោះ។ បន្ទាប់មក **ឯកឧត្តម** បានអញ្ជើញឱ្យ **លោក សំរ៉ាំង កំសាន្ត** ឡើងធ្វើរបាយការណ៍នៃវេទិកាលើកទី ៨ ដើម្បីបានជា មូលដ្ឋានដល់កិច្ចពិភាក្សាលើកទី៩ មុនពេលប្រគល់វេទិកាជូនលោក និងសាកល។

## អំពីលទ្ធផល នៃកិច្ចពិភាក្សាក្នុងវេទិកាទី ៩ ស្តីពី “ប្រទេសកម្ពុជា និងផែនការសកម្មភាពវៀងច័ន្ទ”

### ១-<u>អំពីគោលបំណង និង សំណួចពរ</u>

ប្រធានបទនៃកិច្ចពិក្សានេះ និយាយអំពី **“ប្រទេសកម្ពុជា និងផែនការសកម្មភាពវៀងច័ន្ទ”**។

ប្រធានបទនេះមានសារៈសំខាន់ណាស់ដល់ប្រទេសជាតិយើង ព្រោះនោះគឺជាផែនការ និងជាកម្មវិធីការងារ ដែលបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់ត្រូវអនុវត្តសម្រាប់ រយៈពេល៦ឆ្នាំ (២០០៥- ២០១០) ដើម្បីឆ្ពោះទៅធ្វើឱ្យសម្រេចនូវទស្សនៈឆ្នាំ ២០២០ របស់ អាស៊ាន។

ការលើកយកប្រធានបទនេះមកពិភាក្សា ក្នុងវេទិកាលើកទី ៩ គឺដើម្បីរកឃើញថា :

- តើអ្វីទៅជាផែនការសកម្មភាពអាស៊ានវៀងច័ន្ទ? តើផែនការសកម្មភាពនេះមានខ្លឹមសារ និងសារៈសំខាន់ដូចម្ដេច សម្រាប់សមាគមអាស៊ានទាំងមូល?
- តើប្រទេសកម្ពុជាមានតួនាទី និងភារកិច្ចដូចម្ដេច ក្នុងការអនុវត្តន៍ផែនការសកម្មភាពនេះ?
- តើផែនការសកម្មភាពអាស៊ានវៀងច័ន្ទអាចនឹងផ្ដល់ប្រយោជន៍ដូចម្ដេច ដល់ប្រទេសកម្ពុជា?
- តើប្រទេសកម្ពុជា ពោលគឺរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា គួរធ្វើដូចម្ដេច ដើម្បីឱ្យបានទទួលផលប្រយោជន៍ពិតប្រាកដ ពីផែនការសកម្មភាពនេះ?
- តើអង្គពិភាក្សាមានទស្សនៈ និងអនុសាសន៍ដូចម្ដេច ចំពោះប្រធានបទនេះ?

**២ -<u>អំពីលទ្ធផលនៃកិច្ចពិភាក្សារួម</u> :**

**ផែនការសកម្មភាពអាស៊ានវៀងច័ន្ទ :**

ផែនការសកម្មភាអាស៊ានវៀងច័ន្ទគឺ : ជាផែនការសកម្មភាពរបស់ អាស៊ានសម្រាប់អនុវត្តន៍រយៈពេល ៦ ឆ្នាំ (២០០៥-២០១០) បន្ទាប់ពីផែនការសកម្មភាពហាណូយ ដែលបានដាក់ឱ្យអនុវត្តពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៤ ត្រូវបានបញ្ចប់ទៅ ។

ផែនការសកម្មភាពអាស៊ានវៀងច័ន្ទនេះ ក៏ដូចជាផែនការសកម្មភាព ហាណូយដែរ គឺត្រូវបានបង្កើតឡើង ដើម្បីធ្វើឱ្យសម្រេចទស្សនៈឆ្នាំ ២០២០ របស់អាស៊ាន ដែលមានគោលដៅស្ថាបនានូវសហគមន៍ធំៗ បីរបស់អាស៊ានគឺ សហគមន៍សន្តិសុខ សហគមន៍សេដ្ឋកិច្ច និងសហគមន៍វប្បធម៌សង្គមអាស៊ាន។

ជាការពិតណាស់ ផែនការសកម្មភាពវៀងច័ន្ទ ពុំទាន់សម្រេចនៅឡើយទេ ព្រោះត្រូវអនុម័តជាផ្លូវការ ដោយថ្នាក់ដឹកនាំអាស៊ាននៅក្នុងសម័យប្រជុំកំពូលរបស់អាស៊ាន (ASEAN Summit) នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋ ប្រជាមានិតប្រជាធិបតេយ្យឡាវ (Lao PDR) ដែលនឹងប្រព្រឹត្តទៅនៅ ថ្ងៃទី ២៩-៣០ ខែវិច្ឆិកា ខាងមុខនេះ។

**ទស្សនៈឆ្នាំ ២០២០ របស់អាស៊ាន :**

ទស្សនៈឆ្នាំ ២០២០ របស់អាស៊ានត្រូវបានអនុម័តឡើង នៅថ្ងៃ ទី ១៥ ខែធ្នូ ឆ្នាំ ១៩៩៧ នៅក្នុងសម័យប្រជុំកំពូលលើកទី II នៅទីក្រុង Kula Lumpur នៃប្រទេសម៉ាឡេស៊ី។

ទស្សនៈឆ្នាំ ២០២០ របស់អាស៊ាន គឺផ្តើមចេញពីកិច្ចព្រមព្រៀង ប្រកបដោយសាមគ្គីភាពមួយរវាងប្រទេសជាសមាជិកទាំងអស់ ដោយមើលឆ្ពោះទៅខាងក្រៅ (Outward Looking) ដើម្បីរស់ក្នុងសន្តិភាព ស្ថេរភាព វិបុលភាព និងចងបាច់គ្នាជាចង្កោម (Bonded together) ក្នុងភាពជាដៃគូ ក្នុងវឌ្ឍនភាព ប្រកបដោយថាមវន្ត (Dynamic) នៅក្នុងសហគមន៍អាស៊ាន មួយដែលយកចិត្តទុក ដាក់ជាចម្បងដល់សុខុមាលភាពសង្គម និងការអភិវឌ្ឍន៍។

**សហគមន៍ទាំង ៣ ដែលត្រូវសម្រេចឱ្យបាន នៅឆ្នាំ ២០២០ :**

*១-សហគមន៍សន្តិសុខ :* (ASEAN Security Community - ASC)

សហគមន៍នេះមានរូបភាព និងខ្លឹមសារដើម្បីធ្វើឱ្យសម្រេចបំណងតែមួយគត់របស់អាស៊ាន នោះគឺដើម្បីពង្រឹងសន្តិភាព ស្ថេរភាព លទ្ធិប្រជាធិបតេយ្យ វិបុលភាព និងការអភិវឌ្ឍន៍ក្នុងតំបន់ តាមរយៈការលើកស្ទួយសហប្រតិបត្តិការ លើវិស័យសន្តិសុខជាចម្បង ។

*២-សហគមន៍សេដ្ឋកិច្ច* (ASEAN Economic Community - AEC)

សហគមន៍សេដ្ឋកិច្ចតំបន់អាស៊ាន មានគោលដៅអភិវឌ្ឍន៍វិស័យ សេដ្ឋកិច្ចតាមរយៈការធ្វើសមាហរណកម្ម វិស័យសេដ្ឋកិច្ចអាស៊ានទាំងអស់ ទៅក្នុងសហគមន៍តែមួយនៅឆ្នាំ ២០២០។ សហគមន៍នេះអាចនឹងមានរូបរាងឡើយ តាមរយៈការធ្វើពាណិជ្ជកម្ម ទំនិញ និងសេវាកម្ម ការវិនិយោគរួម ដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយសមធម៌ ការកាត់បន្ថយភាពក្រីក្រ និងគំលាតគ្នានៃសេដ្ឋកិច្ចសង្គម ។

*៣-សហគមន៍វប្បធម៌សង្គមអាស៊ាន: (Asean Socio-Culture Community-ASCC)*

សហគមន៍វប្បធម៌សង្គមអាស៊ាន មានលក្ខណៈសម្បត្តិលើកស្ទួយ សហប្រតិបត្តិការ ក្នុងការអភិវឌ្ឍន៍សង្គម តាមរយៈការលើកស្ទួយចំណេះដឹងលើកស្ទួយសហប្រតិបត្តិការក្នុងការហ្វឹកហ្វឺនកម្លាំងពលកម្ម ការអប់រំ ចំណេះដឹងវិជ្ជាជីវៈ ការអភិវឌ្ឍន៍ វិទ្យាសាស្ត្រ បច្ចេកទេស ការបង្កើត ការងារ ការការពារសង្គម

ការកាត់បន្ថយភាពក្រីក្រ ការកាត់បន្ថយគម្លាតតំបន់សេដ្ឋកិច្ចសង្គម ការអភិវឌ្ឍន៍ធនធានមនុស្ស ជំនាញឯកទេសវិជ្ជាជីវៈ និងឧបនិស្ស័យ ។ល។

**អំពីខ្លឹមសារសំខាន់ៗ នៃផែនការសកម្មភាពវៀងច័ន្ទ :**

ផែនការសកម្មភាពវៀងច័ន្ទ មានផែនការជាប្រតិបត្តិការ (Operation Plan) សំខាន់ៗ ៤ គឺៈ

១-ផែនការធ្វើប្រតិបត្តិការ លើវិស័យសន្តិសុខអាស៊ាន (សហគមន៍សន្តិសុខអាស៊ាន)

២-ផែនការធ្វើប្រតិបត្តិការ លើវិស័យសេដ្ឋកិច្ចអាស៊ាន (សហគមន៍ សេដ្ឋកិច្ចអាស៊ាន)

៣-ផែនការធ្វើប្រតិបត្តិការលើវិស័យវប្បធម៌សង្គមអាស៊ាន (សហគមន៍វប្បធម៌សង្គមអាស៊ាន) និង

៤- ផែនការប្រតិបត្តិការ កាត់បន្ថយគម្លាតគ្នារវាងសមាជិកថ្មី និងសមាជិកចាស់ រួមទាំងផែនការធំៗ បីទៀត គឺផែនការរៀបចំស្ថាប័ន ផែនការរៀបចំយន្តការប្រមូលផ្តុំធនធាន និងផែនការរៀបចំប្រព័ន្ធឃ្លាំមើល និងការត្រួតពិនិត្យវាយតម្លៃគោលដៅជាយុទ្ធសាស្ត្រទាំងនេះ ។

ផែនការសកម្មភាពទាំងនេះនឹងត្រូវពិភាក្សា និងអនុម័តជាឯកច្ឆន្ទ រវាងអ្នកដឹកនាំអាស៊ានទាំង ១០ នៅក្នុងសម័យប្រជុំកំពូល (ASEAN Summit) នៅថ្ងៃទី ២៩-៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ខាងមុខនេះ នៅទី ក្រុងវៀងច័ន្ទនៃប្រទេសឡាវ ។

**អំពីគោលដៅយុទ្ធសាស្ត្រក្នុងការកាត់បន្ថយគម្លាតគ្នា រវាងបណ្តាប្រទេសអាស៊ានអ្នកមាន និងអាស៊ានថ្មីដែលនៅក្រីក្រ :**

គំលាតគ្នារវាងបណ្តាប្រទេសជាសមាជិកអាស៊ានចាស់ ( ប្រទេសអ្នកមាន) និងសមាជិកអាស៊ានថ្មី (ដែលនៅក្រីក្រ) ដូចជា ប្រទេសកម្ពុជា ឡាវ វៀតណាម និងភូមា គឺស្តែងចេញឱ្យឃើញតាមរយៈ

- គម្លាតគ្នារវាងចំណូលរបស់ប្រជាពលរដ្ឋ (Income Per Capita-GDP)
- គម្លាតគ្នារវាងកម្រិតនៃការអភិវឌ្ឍន៏ធនធានមនុស្ស) ទំហំនៃធនធាន មនុស្ស និង
- គម្លាតគ្នារវាងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

នៅឆ្នាំ ២០០១ បណ្តាប្រទេសអាស៊ានដែលជាអ្នកមាន, (អាស៊ាន ចាស់) មានចំណូលជាផលទុនជាតិប្រចាំឆ្នាំ សម្រាប់ប្រជាពលរដ្ឋម្នាក់ (Per Capita-GDP) ចំនួន ២២ ដងខ្ពស់ជាងបណ្តាប្រទេសអាស៊ានដែល ក្រីក្រ។

ដូច្នេះហើយ បានជាអាស៊ានយល់ថា គឺមានតែខិតខំកសាងសហគមន៍ សេដ្ឋកិច្ចអាស៊ានឱ្យជឿនលឿនទេ ទើបអាចកាត់បន្ថយគម្លាតគ្នា នៃការអភិវឌ្ឍន៏រវាងបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់។

គោលដៅ នៃផែនការសកម្មភាពវៀងច័ន្ទ ក្នុងការកាត់បន្ថយ គំលាតគ្នារវាងបណ្តា ប្រទេសជាសមាជិកអាស៊ានទាំងអស់ គឺត្រូវកាត់បន្ថយគម្លាតនៃផលទុនជាតិសម្រាប់ប្រជាពលរដ្ឋម្នាក់ក្នុងប្រទេសនីមួយៗនោះឯង។ ការកាត់បន្ថយនូវគម្លាតខុសគ្នា

នៃការអភិវឌ្ឍនេះ អាចនឹងធ្វើបានលុះណាតែអាស៊ានស្ថាបនាបាន នូវសហគមន៍សេដ្ឋកិច្ចរបស់ខ្លួននៅក្នុងឆ្នាំ ២០២០។

ជាគោលការណ៍អនុវត្តន៍ ការកាត់បន្ថយគំលាតនៃការអភិវឌ្ឍ នេះគឺត្រូវធ្វើឡើង តាមរយៈសកម្មភាព និងការអនុវត្តន៍ ដូចខាងក្រោម :

- ជួយបណ្តាប្រទេសជាសមាជិក ឱ្យពន្លឿនល្បឿននៃការធ្វើសមាហរណកម្មលើវិស័យសេដ្ឋកិច្ច នៃបណ្តាប្រទេសជាសមាជិកដែលនៅក្រីក្រ (ឱ្យ សមាជិកអាស៊ានទាំង ៦ ជួយសមាជិកក្រីក្រទាំង ៤) តាមរយៈការពង្រឹងផែនការផ្តួចផ្តើមធ្វើសមាហរណកម្ម ទៅក្នុងសមាគម អាស៊ាន (Initiatives for ASEAN Integration: IAI) ពង្រឹងការប្រមូលផ្តុំធនធានដើម្បីអភិវឌ្ឍន៍ និងពង្រឹងយន្តការសម្រាប់ការអភិវឌ្ឍន៍ នៅបណ្តា ប្រទេសជាសមាជិកអាស៊ានក្រីក្រ ពង្រឹងគម្រោង និងយន្តការសម្រាប់ធ្វើសហប្រតិបត្តិការនៅក្នុងអនុតំបន់អាស៊ាន ។ល។
- ជួយលើកស្ទួយសកម្មភាពធ្វើសមាហរណកម្ម លើវិស័យសេដ្ឋកិច្ចតាមរយៈការអភិវឌ្ឍន៍គោលនយោបាយ ដែលគាំទ្រការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា ឡាវ ភូមា និង វៀតណាម (CLMV) និងបង្កើតនាទីពិភាក្សាដើម្បីពិនិត្យអនុសាសន៍នៃ ការសិក្សា និងបង្កើនយុទ្ធសាស្ត្រអនុវត្តន៍។
- ជួយលើកស្ទួយការអភិវឌ្ឍសង្គមដោយជួយបន្ថែមល្បឿន នៃកម្មវិធី កាត់បន្ថយភាពក្រីក្រ តាមរយៈការបញ្ចូលគ្នា នូវការអភិវឌ្ឍវិស័យកសិកម្ម, កសិ-ឧស្សាហកម្មឱ្យទៅជាការអភិវឌ្ឍរួមគ្នាតែមួយនៅក្នុងតំបន់។

**អំពីសំណូមពរជាអនុសាសន៍ :**

- ស្នើសុំឱ្យអាស៊ានជួយលើកស្ទួយ ការអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យសេដ្ឋកិច្ច ការដឹកនាំ និងការគ្រប់គ្រងវិស័យសាធារណៈនៃប្រទេសក្រីក្រ និងស្នើសុំឱ្យមានការបណ្ដាក់ទុនវិនិយោគទុនដោយផ្ទាល់ពីបរទេស ការបង្កើនមុខទំនិញនិងមូលដ្ឋានផលិតកម្ម ការលើកស្ទួយបច្ចេកទេសវិទ្យាសាស្ត្រ ការលើកស្ទួយការអភិវឌ្ឍន៍ សហគ្រាសធុនតូច និងមធ្យម និងសេដ្ឋកិច្ចជាតិដើម្បីជួយកាត់បន្ថយ ភាពក្រីក្រ នៅក្នុងបណ្ដាប្រទេសជាសមាជិក ដែលស្ថិតនៅក្នុងការអភិវឌ្ឍទាប ។
- ស្នើសុំលើកស្ទួយសមត្ថភាព ក្នុងការប្រមូលរូបិយវត្ថុ និងឧបត្ថម្ភដល់ផលិតកម្មសេដ្ឋកិច្ច ដើម្បីប្រមូលផ្ដុំធនធាន និងសម្ភារៈឱ្យបានល្អប្រសើរដល់ការអនុវត្តន៍ផែនការសមត្ថភាពអាស៊ានវៀងច័ន្ទ នៅប្រទេសជាតិ យើង ។
- ស្នើសុំរាជរដ្ឋាភិបាល មេត្តាផ្ដល់លទ្ធភាពថវិកាឱ្យបានទាន់ពេល ឱ្យស្ថាប័នជំនាញចូលរួមក្នុង កិច្ចប្រជុំនានា របស់អាស៊ាន ដែលរៀបចំ ឡើងនៅក្នុងតំបន់ឱ្យបានច្រើន ដើម្បីដកស្រង់បទពិសោធន៍ និងទទួលបានចំណេះដឹងល្អៗសម្រាប់កាត់បន្ថយភាពក្រីក្រ និងគំលាតលើការអភិវឌ្ឍរវាងប្រទេសជាតិយើង និងបណ្ដាប្រទេសជា សមាជិកនៅក្នុងតំបន់ ។
- ស្នើសុំរាជរដ្ឋាភិបាល បន្តការខិតខំប្រឹងប្រែងលើកស្ទួយការអភិវឌ្ឍន៍លើវិស័យកសិកម្ម ពិសេសគឺការរៀបចំប្រព័ន្ធធារាសាស្ត្រ ទូទាំងប្រទេស

ឱ្យបានល្អ ដើម្បីធ្វើស្រែឱ្យបានច្រើនរដូវសំដៅបង្កើនទិន្នផលកសិកម្ម និងកសិផល និងរួមចំណែកកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ។

## សេចក្តីសន្និដ្ឋាន

វេទិកាទី ៩ ឆ្នាំ ២០០៤ ស្តីពី **"ប្រទេសកម្ពុជា និងផែនការសកម្មភាពវៀងច័ន្ទ"** បានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមទាំងអស់។ ថ្វីបើផែនការសកម្មភាពនេះ ពុំទាន់ត្រូវបានអនុម័តឱ្យអនុវត្តនៅឡើយ ក៏ប៉ុន្តែ អង្គពិភាក្សាបានពិនិត្យមើលដោយ យកចិត្តទុកដាក់នូវសេចក្តីព្រាង ខ្លឹមសារសំខាន់ៗ ទាំងឡាយ ដើម្បីសិក្សា ស្រាវជ្រាវជាចំណេះដឹង និងផ្តល់មតិយោបល់ជូនរាជរដ្ឋាភិបាល ក្នុងការចូលពិភាក្សា និងអនុម័តសម្រេចនៅក្នុងសម័យប្រជុំកំពូលអាស៊ាន នាទីក្រុងវៀងច័ន្ទ ប្រទេសឡាវក្នុងពេលឆាប់ៗនេះ។ ចំណេះដឹង និងពត៌មានទាំងនេះ ពិតជាមានសារៈសំខាន់ដល់ការលើកស្ទួយសមាជិកភាពរបស់កម្ពុជាក្នុងតំបន់ ដើម្បីស្វែងរកឱ្យបាននូវផលប្រយោជន៍ជូនប្រទេសជាតិ និងមាតុភូមិយើង។ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព សូមថ្លែងអំណរគុណ ដ៏ខ្ពង់ខ្ពស់ចំពោះ គណៈវាគ្មិន និងសមាជិកសមាជិកានៃអង្គពិភាក្សាទាំងមូលដែលបានផ្តល់ទស្សនៈ និងមតិពិភាក្សា ដ៏ល្អៗ ជាច្រើននៅក្នុងវេទិកាដ៏មានសារៈសំខាន់នេះ។ យើងសង្ឃឹមថា ទស្សនៈជាចំណេះដឹង និងអនុសាសន៍ទាំងឡាយ ដែលបានមកពីវេទិកានេះនឹងបានជាវិភាគទាន ដ៏សំខាន់មួយដល់ការលើកស្ទួយការស្ថាបនាជាតិ និងការអភិវឌ្ឍជាតិយើងឱ្យបានរុងរឿងទៅអនាគត។

# វេទិកា ទី ១០ ប្រទេសកម្ពុជា និងការងារទូតអាស៊ានបណ្ដាញទី ២
(Track II Deplomacy)

## សេចក្ដីផ្ដើម

កាលពីថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៤ កន្លងទៅនេះ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព បានរៀបចំវេទិកាលើកទី ១០ របស់ខ្លួន ស្ដីពី "**ប្រទេសកម្ពុជា និងការងារទូតអាស៊ាន** Track II" នៅសាលប្រជុំនៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព នៅភូមិពោងពាយ សង្កាត់ភ្នំពេញ រាជធានីភ្នំពេញ។ វេទិកាទី ១០ នេះ ត្រូវបានចូលរួមដោយអ្នកដឹកនាំសង្គមស៊ីវិល អ្នកតំណាងស្ថាប័នផ្នែកឯកជន អ្នកស្រាវជ្រាវអ្នកសារពតិមាន និងអ្នកតំណាងមូលនិធិហ្វ្រីឌ្រីត អេប៊ែត (FES)។

វេទិកាលើកទី ១០ ស្ដីពី "**ប្រទេសកម្ពុជា និងការងារទូត អាស៊ាន** Track II : មានកិត្តិយស ដោយបានអញ្ជើញគណៈវាគ្មិនជំនាញពីររូបចូលរួមមានមតិមុននឹងបើកកិច្ចពិភាក្សា។ គណៈវាគ្មិនទី ១ គឺ **លោក បណ្ឌិត ចាប សុថារិទ្ធិ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព និងវាគ្មិន

ទី ២ គឺ **បណ្ឌិត ឡៅ ម៉ុងហៃ** ប្រធានផ្នែកច្បាប់ នៃមជ្ឈមណ្ឌល អភិវឌ្ឍន៍សង្គម (CSD)។

ក្នុងពេលចាប់ផ្តើម វេទិកាដំបូង **លោក សំរ៉ាំង កំសាន្ត** អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងជាអ្នកសម្របសម្រួលវេទិកានេះ បានឡើងធ្វើរបាយការណ៍ដោយសង្ខេបមួយ ស្តីពី លទ្ធផលនៃកិច្ចពិភាក្សាក្នុងវេទិកាលើកទី ៩ ដើម្បីបានជាមូលដ្ឋាន ដល់កិច្ចប្រជុំពិភាក្សានៃវេទិកាលើកទី ១០ ។

បន្ទាប់មក **លោក សំរ៉ាំង កំសាន្ត** បានធ្វើការផ្តួចផ្តើមគំនិត សំខាន់ៗមួយចំនួនសម្រាប់វេទិកាលើកទី ១០ ដែលជាវេទិកាចុងក្រោយ ក្នុងឆ្នាំ ២០០៤ នេះ។

**លោក សំរ៉ាំង កំសាន្ត** បានផ្តួចផ្តើមគំនិតថា វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព មានបំណងសំខាន់ ៣ យ៉ាងក្នុងការលើកយក ប្រធានបទស្តីពី "**ប្រទេសកម្ពុជា និងការងារទូតអាស៊ាន** Track II" មកដល់ជូនពិភាក្សាក្នុងវេទិកាលើកទី ១០ នេះ។

- *បំណងទី ១* គឺដើម្បីស្វែងរកឱ្យឃើញថា តើអ្វីទៅជាការងារទូត អាស៊ាន Track II ឬការងារទូតក្រៅរង្វង់រដ្ឋាភិបាលឬសម្រាប់អ្នកសិក្សាស្រាវជ្រាវអាស៊ាននេះ។
- *បំណងទី ២* គឺដើម្បីស្វែងរកឱ្យឃើញថា តើការងារទូតអាស៊ាន Track II មានគុណប្រយោជន៍ដូចម្តេចដល់ប្រទេសកម្ពុជា។

- *បំណងទី ៣* គឺដើម្បីស្វែងរកឱ្យឃើញថា តើប្រទេសកម្ពុជា គួរធ្វើម្តេចដើម្បីឱ្យបានទទួលផលប្រយោជន៍ពិតប្រាកដ ពីការងារទូត អាស៊ាន Track II នេះ។

នៅទីបញ្ចប់នៃការផ្តួចផ្តើមគំនិតនេះ **លោក សំរ៉ាំង កំសាន្ត** បានស្នើសុំឱ្យគណៈវាគ្មិនកិត្តិយស និងសមាជិក សមាជិកានៃអង្គពិភាក្សាទាំង មូលបញ្ចេញទស្សនៈ និងមតិយោបល់ ក៏ដូចជា អនុសាសន៍ប្រមូលផ្តុំទៅលើ បំណងសំខាន់ ទាំងបីដូចបានលើកឡើងខាងលើនេះ។

**ក_អំពីទស្សនៈរបស់គណៈវាគ្មិនកិត្តិយស និងលទ្ធផលនៃកិច្ចពិភាក្សារួម : ចំណេះដឹង និងអនុសាសន៍ :**

បន្ទាប់ពីទទួលបានការផ្តួចផ្តើមគំនិតមក គណៈវាគ្មិន និងអង្គពិភាក្សារួម ក៏បានបញ្ចេញទស្សនៈ ផ្លាស់ប្តូរមតិយោបល់ ទទួលបានលទ្ធផលដូចខាងក្រោម :

ការងារទូតអាស៊ាន Track II គឺជាការងារទូតរបស់វិទ្យាស្ថានយុទ្ធសាស្ត្រ និងការសិក្សាអន្តរជាតិរបស់អាស៊ាន (ASEAN Institute of Strategic and International Studies-ASEAN ISIS) ដែលយកចិត្តទុកដាក់ជា សំខាន់ដល់ការស្ថាបនាគោលនយោបាយ (Policy oriented) នៅអាស៊ី អាគ្នេយ៍ ក៏ដូចជាអាស៊ីបូព៌ា និងអាស៊ីប៉ាស៊ីហ្វិក ដោយប្រមូលផ្តុំការវិភាគ ពិចារណាទៅលើបញ្ហា សំខាន់ៗ ដែលពាក់ព័ន្ធនឹងការរក្សាសន្តិភាព សន្តិសុខ ស្ថេរភាព សហប្រតិបត្តិការ និងការអភិវឌ្ឍន៍ក្នុងតំបន់ទាំងនេះ។

វិទ្យាស្ថានយុទ្ធសាស្ត្រ និងការសិក្សាអន្តរជាតិរបស់អាស៊ាន មានតួនាទី ចម្បងបីគឺ (១)-តួនាទីពង្រឹងសហប្រតិបត្តិការ និងទំនាក់ទំនងរវាង វិទ្យាស្ថានទាំងអស់ក្នុងតំបន់ (២)-តួនាទីស្រាវជ្រាវ និងសិក្សាអំពីបញ្ហា អាស៊ាន ដើម្បីជួយផ្តល់ការគាំទ្រខាងគំនិតបញ្ញាស្មារតីលើវិស័យ សន្តិសុខ សេដ្ឋកិច្ច និងវប្បធម៌សង្គមអាស៊ាន និងបណ្តាប្រទេសជាសាមុី និង (៣)-តួនាទីស្ពានបាសហគមន៍ បញ្ញវន្ត ក្រៅរដ្ឋាភិបាលដែលអាចជួយមតិ ស្ពានា និងដោះស្រាយបញ្ហាផ្សេងៗ ជូនរដ្ឋាភិបាលរបស់ខ្លួនទាំងក្នុងតំបន់ និងលើពិភពលោក។

ប្រវត្តិនៃ Track II មានមកតាំងពីសម័យសង្គ្រាមត្រជាក់មកម្ល៉េះ។ សហរដ្ឋអាមេរិកមានចេតនាចង់បង្កើតឱ្យមានទំនាក់ទំនង រវាងស្ថាប័នពុំមែនរដ្ឋាភិបាល ទាំងខាងសហរដ្ឋ ទាំងខាងសហភាពសូវៀត ក្នុងសម័យនេះ ដើម្បីលើកស្ទួយកិច្ចចរចាក្រៅផ្លូវការ សំដៅធ្វើឱ្យទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងសហភាពសូវៀតបានធូរស្រាល និងផ្តល់នូវគំនិតថ្មីៗ និងប្លែកៗ ក្នុងការដោះស្រាយវិវាទរវាងមហាអំណាចទាំងពីរ។ ជាការពិតណាស់គំរូ Track II មានច្រើនបែបច្រើនយ៉ាង ក៏ប៉ុន្តែសមាគម អាស៊ានយកតាមគំរូតាមសហរដ្ឋអាមេរិក។

ជាទូទៅការងារទូត ពុំមែនគ្រាន់តែជារបស់រដ្ឋាភិបាលទេ តែគឺជារបស់ ប្រជាជាតិទាំងអស់ទាំងមូល។ ការងារទូតនេះមានច្រើនបណ្តាញ។ បណ្តាញដែលសំខាន់មានដូចខាងក្រោម :

- បណ្តាញទី ១ (Track 1)គឺជាបណ្តាញរបស់រដ្ឋាភិបាល

- បណ្ដាញទី២ (Track 2)គឺជាបណ្ដាញស្ថាប័នវិភាគី ឬបណ្ដាញក្រៅរដ្ឋាភិបាល
- បណ្ដាញទី ៣ (Track 3)គឺជាបណ្ដាញរបស់សមាគមន៍នានា រួមមានផ្នែកឯកជន ឬអង្គការពហុជាតិ
- បណ្ដាញទី ៤ (Track 4) គឺជាបណ្ដាញរបស់ប្រជាជន (People to people exchange program)
- បណ្ដាញទី ៥ (Track 5) គឺជាបណ្ដាញរបស់ប្រព័ន្ធផ្សព្វផ្សាយ។

ក៏ប៉ុន្តែ, ជាការ អនុវត្តន៍ជាក់ស្តែង គេច្រើនប្រើជារួមតែបណ្ដាញបីទេ គឺ :（១）-បណ្ដាញ រដ្ឋាភិបាល (Track I) （២）-បណ្ដាញស្ថាប័នវិភាគី (Track II) និង（៣）-បណ្ដាញប្រជាជន Track III៕

តាមបទពិសោធន៍របស់ប្រទេសអូស្ត្រាលី ការងារទូត Track II គឺជាការងារក្រៅផ្លូវការជាការងារបុគ្គល ឬឯកជនដែលមិនយកសម្រេចជាផ្លូវការបានឡើយ។ ការងារ Track II គឺជាការស្ទាបស្ទង់ក្រៅផ្លូវការដោយ ស្ថាប័នក្រៅរដ្ឋាភិបាល ឬឯកជនដើម្បីត្រួសត្រាយផ្លូវជូនរដ្ឋាភិបាល។ ការងារទូត Track II នេះកំពុងរីកដុះដាលយ៉ាងខ្លាំងនៅលើពិភពលោកនេះ។

តាមបទពិសោធន៍របស់សហគមន៍អឺរ៉ុប (EU) ការកាត់បន្ថយគម្លាតគ្នារវាងសមាជិកសហគមន៍អឺរ៉ុបដែលជាអ្នកមាន និងសមាជិកសហគមន៍អឺរ៉ុប ដែលជាអ្នកក្រ គឺត្រូវបានធ្វើឡើង តាមរយៈការផ្តល់ហិរញ្ញវត្ថុ ឱ្យសមាជិកដែលនៅក្រីក្រធ្វើការអភិវឌ្ឍន៍ប្រទេសជាតិខ្លួន ដើម្បីអូសទាញការវិនិយោគទុនពីបរទេស（FDI）

ដោយខ្លួនឯង ។ បទពិសោធន៍សហគមន៍អឺរ៉ុប ធ្វើបានជោគជ័យ ។ ដូច្នេះ សមាគមអាស៊ាន ក៏គួរតែពិនិត្យពិចារណាមើល បទពិសោធន៍នេះដែរ ។

តាមបទពិសោធន៍របស់ប្រទេសសឹង្ហបុរី និងថៃ ការកាត់បន្ថយភាពក្រីក្របានឆាប់រហ័ស គឺអាស្រ័យដោយការពន្លឿន ការអនុវត្តន៍តំបន់ពាណិជ្ជកម្ម សេរីជាមួយប្រទេសជាច្រើន រួមមានសហរដ្ឋអាមេរិក អូស្ត្រាលី កូរ៉េខាងត្បូង និងចិន។ ប្រទេស កម្ពុជា ក៏គួរតែយកតាមបទពិសោធន៍នេះដែរ ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ កម្ពុជាឱ្យបានឆាប់រហ័ស ។

តួនាទីជាយុទ្ធសាស្ត្ររបស់បណ្តាញការងារទូត Track II មាន៧ យ៉ាងគឺ :

- ផ្លាស់ប្តូរផ្នត់គំនិត និងអាកប្បកិរិយារបស់ប្រជាពលរដ្ឋ
- បើកច្រកសម្រាប់ការចរចាជូនរដ្ឋាភិបាល
- បង្កើនគុណភាពនៃការប្រាស្រ័យទាក់ទង
- ស្ថាបនាទំនុកចិត្ត
- ផ្លាស់ប្តូរទស្សនវិស័យ ដើម្បីសន្តិភាព
- ផ្តល់ជំរើសថ្មីៗ សម្រាប់ការចរចា និង
- ផ្តល់ចំណេះដឹង ស្តីពី ការងារបរទេសជូនរដ្ឋាភិបាល និងជួយកែប្រែនយោបាយក្នុងប្រទេស ។

ម្យ៉ាងទៀត បណ្តាញការងារទូត Track II ក៏មានតួនាទីស្ថាបនា និងពង្រឹងនីតិរដ្ឋ និងឯករាជ្យភាពនយោបាយរបស់តំបន់ និងប្រទេសជាតិនីមួយៗ ផងដែរ។ តួនាទីនេះ អាចធ្វើឡើងតាមរយៈការទាមទារឬការ ផ្តួចផ្តើមប្រព័ន្ធច្បាប់ ការអនុវតន៏របស់តុលាការ និងឯករាជ្យភាពនយោបាយ របស់តំបន់ និងប្រទេសនីមួយៗ ដោយយកការគោរព និងអនុវត្តន៏ច្បាប់ជា មូលដ្ឋាន។

- សមាគមអាស៊ានមានគោលនយោបាយត្រឹមត្រូវ ក្នុងការដោះស្រាយបញ្ហា ឬទំនាស់ផ្សេងៗ ដែលកើតមានរវាងសមាជិក និងសមាជិក។ គោលនយោបាយទាំងនោះ គឺ :
- ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសនីមួយៗ
- គោលនយោបាយសម្រេចរួម (Consensus)
- គោលនយោបាយស្ថាបស្ទង់ និងចរចា
- ការគោរពច្បាប់ជាមូលដ្ឋាន
- ការគោរពសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស (Paris Peace Agreement) និង
- ការគោរពតាមសេចក្តីសម្រេចរបស់តុលាការអន្តរជាតិ ។ល។,,

ជាទស្សនវិស័យនៅអនាគត ការងារទូតអាស៊ាន Track II គួរខិតខំរួមចំណែកជួយដោះស្រាយបញ្ហា ដែលមានឥទ្ធិពលអាក្រក់ដល់ប្រទេសជាតិនិងតំបន់ និងជួយបំពេញគំលាតនៃការខ្វះខាតខាងការទូតនានា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ

ក្នុងតំបន់ឱ្យបានកាន់តែប្រសើរថែមទៀត។ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ដែលជាសមាជិកមួយ នៃវិទ្យាស្ថាន អាស៊ាន ដើម្បីយុទ្ធសាស្ត្រ និងការសិក្សាអន្តរជាតិ (ASEAN-ISIS) គួរតែខិតខំ ពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការសិក្សាស្រាវជ្រាវ អំពីយុទ្ធសាស្ត្រសន្តិសុខ សន្តិភាព និងការអភិវឌ្ឍន៍ឱ្យបានល្អទៅអនាគត។

ជាយុទ្ធសាស្ត្រចម្បង វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព គួរតែខិតខំផ្សព្វផ្សាយពតិមាន ស្តីពីអាស៊ានជូនសាធារណជន ដើម្បីឱ្យមានការយល់ដឹងអំពីការងារផ្សេងៗ របស់អាស៊ានជាមួយនឹង អត្ថបទ ផ្សព្វផ្សាយផ្សេងៗ របស់សារពតិមានខ្មែរ។ បើធ្វើដូច្នេះបាន នោះការយល់ដឹង ជាសាធារណៈអំពីអាស៊ាន នឹងត្រូវបានលើកកំពស់ ហើយសមាជិកភាពរបស់កម្ពុជា នឹងកាន់តែរឹងមាំក្នុងអាស៊ាន ព្រមទាំងអាចនាំមកនូវផលប្រយោជន៍ ពិតប្រាកដជូនប្រទេសជាតិយើងផង។

ការងារទូតរបស់ Track II កម្ពុជាក្នុងអាស៊ានអាចនឹងនាំមក នូវផលប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋកម្ពុជា។ ផលប្រយោជន៍ទាំងនោះគឺ :

- ជួយស្តារមុខមាត់កម្ពុជា ដែលធ្លាប់ឯកោក្នុងសម័យសង្គ្រាម និងជួយលើកស្ទួយកិត្យានុភាពរបស់ ស្ថាប័នក្រៅរដ្ឋាភិបាលកម្ពុជា ឱ្យមានសមត្ថភាព និងគុណភាពបំពេញការងារដូចគេឯងក្នុងតំបន់
- ជួយបញ្ចូលគោលគំនិតធំៗ នៃការស្ថាបនាគោលនយោបាយការទូតរបស់កម្ពុជា ទៅក្នុងតំបន់
- ជួយថែរក្សាការពារផលប្រយោជន៍របស់កម្ពុជាក្នុងតំបន់

- ជួយស្ថាបនានិងហ្វឹកហ្វឺនធនធានបញ្ញវន្តខ្មែរ អ្នកសិក្សាស្រាវជ្រាវ និងប្រជាជនខ្មែរ អំពីបញ្ហាឬចំណេះដឹងរបស់អាស៊ាន ដើម្បីជួយ អាស៊ានផង និងជួយជាតិយើងផង

- ជួយនាំមកនូវចំណេះដឹងប្លែកៗ អំពីអាស៊ាន និងជួយផ្តល់ចំណេះដឹងទាំងនេះ ជូនរាជរដ្ឋាភិបាល សង្គមស៊ីវិល និងប្រជាពលរដ្ឋឱ្យមានការយល់ដឹងកាន់តែកើនឡើងថែមទៀត ដើម្បីកសាង និងអភិវឌ្ឍជាតិឱ្យបានរុងរឿងអនាគត។

**អំពីអនុសាសន៍ :**

ស្នើសុំបន្តពង្រឹងវិសាលភាព និងពង្រីកសមត្ថភាព ក៏ដូចជា គុណភាពបំពេញការងាររបស់ស្ថាប័ន Track II កម្ពុជា ឱ្យកាន់តែរឹងមាំ ថែមទៀត តាមរយៈការឧបត្ថម្ភមូលនិធិ ការពង្រឹងសមត្ថភាពស្ថាប័ន និង ការស្ថាបនាបណ្តាញ។

ម្យ៉ាងទៀត អង្គពិភាក្សាស្នើសុំឱ្យប្រព័ន្ធពត៌មានជួយផ្សព្វផ្សាយ អំពីពត៌មាន និងចំណេះដឹងផ្សេងៗ អំពីសមាគមអាស៊ាន ដើម្បីលើកស្ទួយការយល់ដឹង និងសហប្រតិបត្តិការរបស់ប្រជាពលរដ្ឋក្នុងការចូលរួមស្ថាបនា ភាពរឹងមាំនៃសមាជិកភាពកម្ពុជាក្នុងអាស៊ាននេះ។

**សេចក្តីសន្និដ្ឋាន**

វេទិកា ទី ១០-ឆ្នាំ ២០០៤ ស្តីពី "ប្រទេសកម្ពុជា និងការងារទូតអាស៊ានក្រៅផ្លូវការ Track II Deplomacy បានប្រព្រឹត្តទៅប្រកបដោយលទ្ធផលល្អ។ គណៈវាគ្មិន និងសមាជិក សមាជិកា នៃអង្គពិភាក្សាទាំងអស់ បានចូលរួម

បញ្ចេញ ទស្សនៈ មតិយោបល់ និងបទពិសោធន៍ជាច្រើនដែល មានគុណប្រយោជន៍ ដល់ការលើកស្ទួយការងារទូតអាស៊ាន Track II នៅកម្ពុជា ក៏ដូចជានៅក្នុងតំបន់។ វឌ្ឍនភាពនៃការងារទូតកម្ពុជាអាស៊ាន Track II ពុំអាចកាត់ផ្តាច់បានពីការ ពង្រឹងសមត្ថភាព និងវិសាលភាពស្ថាប័នទេ។ គឺមានតែការស្ថាបនា សមត្ថភាព និងគុណភាពបំពេញការងារឱ្យបានល្អប្រសើរ និងភាពរឹងមាំខាងមូលនិធិ និងការស្ថាបនាបណ្តាញទេ ដែលអាចជួយធ្វើឱ្យស្ថាប័ន ការងារទូត កម្ពុជា-អាស៊ាន Track II បំពេញតួនាទីរបស់ខ្លួនបានល្អប្រសើរ ទៅអនាគត។ ទន្ទឹមនោះសហប្រតិបត្តិការ និងការពង្រឹងជំនឿទុកចិត្តរបស់រាជរដ្ឋាភិបាល ក៏ដូចជា អង្គការសង្គមស៊ីវិលមកលើស្ថាប័ន ការងារទូតកម្ពុជា-អាស៊ាន Track II គឺ ជាការចាំបាច់ណាស់ដែលត្រូវលើកស្ទួយ។ម្យ៉ាងវិញទៀត, ប្រទេសកម្ពុជា ពិតអាចទទួលបានផលប្រយោជន៍ ពិតប្រាកដពីទំនាក់ទំនងនៃការងារទូតអាស៊ាន Track II ប្រសិនបើមានការលើកស្ទួយ និងការផ្សព្វផ្សាយចំណេះដឹងស្តីពី ការងារទូតអាស៊ាន Track II ឱ្យបានទូលំទូលាយនៅក្នុងមជ្ឈដ្ឋានស្ថាប័ន ក៏ដូច ជាអង្គការ សង្គមស៊ីវិល និងប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាល និងអង្គការពាក់ព័ន្ធគួរតែខិតខំ លើកស្ទួយទស្សនៈនេះឱ្យបានល្អ និងជាប់ជាប្រចាំ ដើម្បីអាចរក្សាបាននូវវឌ្ឍនភាពនេះទៅអនាគត។

# ឧបសម្ព័ន្ធ៣ សំណូមពរ និង អនុសាសន៍

ឆ្លងកាត់វេទិកាសាធារណៈទាំង១០ និងសន្និសីទជាតិ ស្តីពី កម្ពុជាក្នុងអាស៊ាន : ប្រាំឆ្នាំក្រោយមក យើងអាចប្រមូលបាននូវសំណូមពរ និងអនុសាសន៍សំខាន់ៗ ដូចខាងក្រោមនេះ :

១. ស្នើសុំឱ្យមានការលើកស្ទួយ **"ឧស្សាហៈ និងការយល់ដឹង"** អំពីគុណប្រយោជន៍ទាំងឡាយរបស់ប្រទេសកម្ពុជា ដែលបានមកពីការចូលអាស៊ាន ព្រមទាំងស្នើសុំឱ្យមានការអប់រំផ្សព្វផ្សាយចំណេះដឹងទាំងនោះ ឱ្យបានទូលំទូលាយ ដើម្បីពង្រឹងកម្លាំងគាំទ្រ និងការចូលរួមរបស់ប្រជាពលរដ្ឋ ពីសំណាក់រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ ។

២. ស្នើសុំឱ្យមានវិធានការកែលំអ និងទប់ស្កាត់បញ្ហាប្រឈមមុខទាំងឡាយ ដែលអាចកើតមានឡើង ក្នុងពេលចំពោះមុខ និងទៅអនាគតដល់ សមាជិកភាពរបស់ប្រទេសកម្ពុជាក្នុងអាស៊ាន ដូចជាការអភិវឌ្ឍន៍នៃ ធនធានមនុស្ស ពង្រឹងផលិតកម្ម ស្ពានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ។

៣. ជាទិសដៅទៅអនាគត ដើម្បីឱ្យសមាជិកភាពនៃប្រទេសកម្ពុជា ក្នុងសមាគមអាស៊ានកាន់តែមានភាពរឹង មាំអង្គសន្និសីទជាតិ ស្នើសុំឱ្យមាន :

- ✓ ការលើកស្ទួយស្ថេរភាពនយោបាយ សន្តិសុខសង្គម សន្តិភាព និង ការអភិវឌ្ឍ
- ✓ ការលើកស្ទួយការអភិវឌ្ឍ កម្លាំងពលកម្មអោយមានសមត្ថភាព និងគុណភាពបំពេញការងារជឿនលឿនស្អាតស្អំ សន្សំសំចៃ ឧស្សាហ៏ព្យាយាម សច្ចៈយុត្តិធមិ គោរពច្បាប់ និងមានសមត្ថភាព លើគ្រប់ វិស័យ
- ✓ ការលើកស្ទួយការអភិវឌ្ឍន៏ជាតិលើគ្រប់វិស័យ ពិសេសគឺលើវិស័យកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៏ វប្បធមិ អប់រំសិក្សាសង្គមកិច្ច និងសុខាភិបាល និងវិទ្យាសាស្ត្រ និងបច្ចេកទេស
- ✓ ការលើកស្ទួយប្រសិទ្ធិភាពនៃការគោរពច្បាប់ អភិបាលកិច្ចល្អ កំណែទម្រង់រដ្ឋបាល និងប្រព័ន្ធច្បាប់ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល
- ✓ ការលើកស្ទួយវប្បធមិនៃសហប្រតិបត្តិការ ការពិភាក្សា និងភាពជាដៃគូនៅក្នុងវេទិកាជាតិ និងតំបន់សំដៅលុបបំបាត់អវិភាព ទំនាស់ អំពីបញ្ហានយោបាយដែលនាំឱ្យមានទំនាស់ខាងផលប្រយោជន៏ ភាពបែកបាក់ និងការខាតបង់ ជាពិសេស បញ្ហាព្រំដែន អន្តោប្រវេសន៏ខុសច្បាស់ ពុករលួយ អយុត្តិធមិក្នុងសង្គម ។ល។

៤~ ស្នើសុំឱ្យមានការលើកស្ទួយការអភិវឌ្ឍន៏ធនធានមនុស្ស លើវិស័យគយ និង រដ្ឋាករ ការអភិវឌ្ឍន៏ផ្នែកឯកជន ការប្រមូលពន្ធដារក្នុងស្រុកឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីជំនួសពន្ធគយ ដែលនឹងត្រូវកាត់បន្ថយក្រោយឥទ្ធិពលនៃ AFTA ។

លើកស្ទួយកំណែទម្រង់ទ្រង់ទ្រាយធំរបស់ប្រទេសជាតិ ប្រឆាំងតបនឹងរដ្ឋបាលស្មុគស្មាញ និងភាពមិនប្រក្រតី ក្នុងការកេងបន្លំពន្ធ គេចពន្ធនានា និងស្នើសុំឱ្យមានការអប់រំផ្សព្វផ្សាយ ចំណេះដឹង និងការអនុវត្តនីកិច្ចព្រមព្រៀងស្ដីពី "**គម្រោងអនុគ្រោះពន្ធគយរួម**" ដើម្បីឱ្យមហាជន និងប្រជាពលរដ្ឋ ពិសេសវិស័យ ឯកជនបានយល់ជ្រួតជ្រាប និងអនុវត្ត។

**៥.** អង្គសន្និសីទជាតិស្នើសុំឱ្យមាន :

- ✓ ការលើកស្ទួយតួនាទីការទូតរបស់ប្រទេសកម្ពុជា ក្នុងតំបន់ឱ្យកាន់តែខ្លាំងក្លា និងរឹងមាំ ពិសេសជំរុញផ្នែកផ្សព្វផ្សាយពាណិជ្ជកម្ម ទាក់ទាញទេសចរណ៍ និងវិនិយោគទុនពីបរទេស។
- ✓ ស្នើសុំឱ្យមានការលើកទឹកចិត្តក្រុមជំនាញការកម្ពុជាមួយ ខាងទំនាក់ទំនងអន្តរជាតិ សន្តិសុខ និងយុទ្ធសាស្ត្រអន្តរជាតិ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ អំពីបញ្ហានានាជុំវិញវេទិកាតំបន់អាស៊ាន សម្រាប់ជួយផ្ដល់អនុសាសន៍ជូនរាជរដ្ឋាភិបាល ពិនិត្យពិចារណាមុននឹងចូលរួម ប្រជុំក្នុងសម័យប្រជុំនីមួយៗ នៃវេទិកានេះ។
- ✓ ត្រូវជំរុញវិស័យទេសចរណ៍ ដើម្បីទាក់ទាញឱ្យប្រទេសអាស៊ាន+៣ មកទស្សនា ប្រទេសយើងតាម រយៈការផ្សព្វផ្សាយ និងផ្ដល់សេវាល្អទៅតាមចំណង់ចិត្តនៃទេសចរណ៍ រួមមាន ការលើកលែងទិដ្ឋាការ និងការផ្ដល់សេវាមគ្គុទ្ទេសក៏ជាភាសាផ្សេងៗ។

៦. ស្នើស៊ីវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព រៀបចំបើកសិក្ខាសាលា ឬការប្រជុំសិក្សាឱ្យបានច្រើនស្តីពី (**អភិបាលកិច្ចល្អ និងកំណែទម្រង់ប្រព័ន្ធច្បាប់**) ដើម្បីស្វែងរកឃើញនូវទំនាក់ទំនងអន្តរជាតិ អភិបាលកិច្ចល្អ និងប្រព័ន្ធច្បាប់ ដើម្បីបុព្វហេតុនៃការស្ថាបនា និងអភិវឌ្ឍ នៅប្រទេសកម្ពុជា។

៧. ការធ្វើសមាហរណកម្មទៅក្នុងតំបន់ ពិសេសគឺការចូល AFTA នៃប្រទេស កម្ពុជា ពិតជាមានសារៈសំខាន់ដល់ការស្ថាបនា និងការអភិវឌ្ឍជាតិ ក្រោយសម័យសង្គ្រាម។ ក៏ប៉ុន្តែ រាជរដ្ឋាភិបាល គួរតែរកមធ្យោបាយទប់ស្កាត់ ការជួលរលំនៃផលិតផលក្នុងស្រុកដែលខូចខាត ដោយសារការនាំចូលនៃផលិតផល ដែលគេលក់បង្ខូចថ្លៃ (Dumping) ពីបណ្តាលប្រទេស មិត្តដែលមានតម្លៃថោក។ ចំពោះបញ្ហានេះ អង្គសន្និសីទជាតិស្នើសុំរាជរដ្ឋាភិបាល បង្កើតឱ្យមានគោលនយោបាយទប់ស្កាត់បាតុភាពនេះតាមរយៈ ការតាមដាននិងរាយការណ៍ដល់ស្ថាប័នមានសមត្ថកិច្ចប្រសិនបើមានភស្តុតាងក្នុងករណី លក់បង្ខូចថ្លៃ ដើម្បីបំផ្លាញផលិតផលក្នុងស្រុក។ និងស្នើសុំឱ្យមានការលើកទឹកចិត្តកសិករ កម្ពុជា ឱ្យប្រើប្រាស់ ជីធម្មជាតិតាមបែបប្រពៃណី ជាជាងការប្រើប្រាស់ ជីគីមី ដែលនាំឱ្យខូចខាតគុណភាពផ្ទៃដីកសិកម្ម និងប៉ះពាល់ដល់ សន្តិសុខស្បៀង។

៨. ការធ្វើសមាហរណកម្មនៃសេដ្ឋកិច្ចទៅក្នុងតំបន់ គឺជាយុទ្ធសាស្ត្រដ៏ប្រសើរ សម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ ឱ្យរួចផុតពីភាពឯកោ។ ក៏ប៉ុន្តែ ដើម្បីធ្វើឱ្យគោលដៅនេះបានសំរេច ប្រទេសកម្ពុជា គួរតែខិតខំប្រឹងប្រែងប្រើប្រាស់ ការអនុគ្រោះពាណិជ្ជកម្ម (GSP) ឱ្យមានប្រសិទ្ធភាពបំផុត និងគួរតែអូសទាញការចូលរួម

របស់ ផ្នែកឯកជនឱ្យបានខ្លាំងក្លាបំផុតផង ដើម្បីផលិតទំនិញដែលអាចប្រកួតប្រជែងក្នុងទីផ្សារតំបន់ និងពិភពលោកបាន។

អង្គសន្និសីទជាតិ ស្នើសុំរាជរដ្ឋាភិបាល និងសភាទាំងពីរ មេត្តាពិនិត្យពិចារណានូវសំណូមពរ និងអនុសាសន៍ទាំងអស់នេះ ដើម្បីបានជាមូលដ្ឋានដល់ការបង្កើត និងកែលំអ គោលនយោបាយកម្ពុជាអាស៊ានចំពោះ មុខ និងទៅអនាគត។

# ឧបសម្ព័ន្ធ៤ កម្មវិធីនៃវេទិកាទាំង ១០ លើក និងសន្និសីទជាតិ

## ក-កម្មវិធីនៃវេទិកាទាំង ១០ លើក

### កម្មវិធីវេទិកា ទី ១ ស្តីពី

### "កម្ពុជា និងសមាគមអាស៊ាន : ទស្សនៈរួម"

---------

ឧបត្ថម្ភដោយ អង្គការ មូលនិធិ ហ្រ្វីឌ្រីច អេប៊ែត

Friedrich-Ebert-Stiftung (FES)

ទីកន្លែង : បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៤, ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

៨:៣០-៩:០០ ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៩:០០-៩:២០ ប្រធានវេទិកា

**ឯកឧត្តម អ៊ុន និង** អនុប្រធានគណៈកម្មការ កិច្ចការ

បរទេស សហប្រតិបត្តិការអន្តរជាតិ និងពតិមាននៃរដ្ឋសភាជាតិ និងជា សមាជិកគណៈកម្មាធិការនាយក វ,ខ,ស,ស មតិផ្ដើម បើកការ ពិភាក្សា និងសំរបសំរួល ដោយ **លោក សំរ៉ាំង កំសាន្ត** អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នក ស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថាន វ,ខ,ស,ស

៩:២០-១០:០០ វាគ្មិនទី ១:**បណ្ឌិត ចាប សុថារិទ្ធ** ប្រធាននាយកដ្ឋានអាស៊ានទីស្ដីការគណៈរដ្ឋមន្ត្រីនិងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ វ,ខ,ស,ស

វាគ្មិនទី ២: **បណ្ឌិត កៅ គឹមហួន** ទីប្រឹក្សាអមក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិទទួលបន្ទុកកិច្ចការអាស៊ាន និងជា នាយកប្រតិបត្តិ វ,ខ,ស,ស

១០:០០-១០:១៥ សំរាកពិសាភេសជ្ជះ

១០:១៥-១១:០០ បើកកិច្ចពិភាក្សា

១១:០០-១០:៣០ បូកសរុបលទ្ធផលវេទិកាលើកទី ១

# កម្មវិធីវេទិកាទី ២ ស្តីពី

# កម្ពុជា និងសហគមន៍សន្តិសុខអាស៊ាន

---------

ឧបត្ថម្ភដោយ អង្គការ មូលនិធិ ហ្វ្រីឌ្រីច អេប៊ែត

(Friedrich-Ebert-Stiftung (FES)

ទីកន្លែង : បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៤ , ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

៨:៣០-៩:០០ ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៩:០០-៩:២០ មតិផ្តើមបើកការពិភាក្សា និងសំរបសំរួល ដោយ **លោក សំរាំង កំសាន្ត** អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថាន វ.ខ.ស.ស

៩:២០-១០:០០ វាគ្មិនកិត្តិយស

-បណ្ឌិត **កៅ គឹមហួន** ទីប្រឹក្សាអមក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិទទួលបន្ទុកកិច្ចការអាស៊ាន និងជានាយកប្រតិបត្តិ វ.ខ.ស.ស

(ទស្សនៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ)

**-ឯកឧត្តមឧត្តមសេនីយ៍ទោ ណឹម សុវត្ថិ** អគ្គនាយករង

អគ្គនាយកដ្ឋាន យោធសេវា នាយក នាយកដ្ឋាននយោបាយ និងផែនការក្រសួងការពារជាតិ និងជាអ្នកស្រាវជ្រាវ ជាន់ខ្ពស់ អម វ.ខ.ស.ស (ទស្សនៈក្រសួងការពារជាតិ)

១០:០០-១០:១៥ សំរាកពិសាភេសជ្ជៈ

១០:១៥-១១:០០ បើកកិច្ចពិភាក្សា

១១:០០-១០:៣០ បូកសរុបលទ្ធផលវេទិកាលើកទី ២

# កម្មវិធីវេទិកា ទី ៣ ស្តីពី

# កម្ពុជា និង តំបន់ពាណិជ្ជកម្មសេរីអាស៊ាន

ឧបត្ថម្ភដោយ អង្គការ មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត

(Friedrich-Ebert-Stiftung (FES)

ទីកន្លែង : បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៤, ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

| | |
|---|---|
| ៨:៣០-៩:០០ | ការចុះឈ្មោះនៃភ្ញៀវកិត្តិយស |
| ៩:០០-៩:២០ | មតិផ្តើមបើកការពិភាក្សា និងសំរបសំរួល ដោយ **លោក សំរ៉ាំង កំសាន្ត** អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថាន វ.ខ.ស.ស |
| ៩:២០-១០:០០ | វាគ្មិនកិត្តិយស<br>**-ឯកឧត្តមបណ្ឌិត គុណ ញឹម** នាយករងទីចាត់ការ គយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអ្នក ស្រាវជ្រាវជាន់ខ្ពស់អម វ.ខ.ស.ស (ទស្សនៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>**-លោក មី សុជាតិ** អនុប្រធាននាយកដ្ឋានអាស៊ាន និងសមាហរណកម្មសេដ្ឋកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

**-បណ្ឌិត ចាប សុថារិទ្ធ** ប្រធាននាយកដ្ឋានអាស៊ានទីស្តីការគណៈរដ្ឋមន្ត្រី និង ជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវ.ខ.ស.ស

១០:០០-១០:១៥ សំរាកពិសាភេសជ្ជៈ

១០:១៥-១១:០០ បើកកិច្ចពិភាក្សា

១១:០០-១០:៣០ បូកសរុបលទ្ធផលវេទិកាលើកទី ៣

# កម្មវិធីវេទិកា ទី ៤ ស្តីពី

# កម្ពុជា និង សហគមន៍សេដ្ឋកិច្ចអាស៊ាន

**--------**

ឧបត្ថម្ភដោយ អង្គការ មូលនិធិ ហ្វ្រីឌ្រីច អេប៊ែត

(Friedrich-Ebert-Stiftung (FES)

ទីកន្លែង : បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ , ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០

ថ្ងៃត្រង់

៨:៣០-៩:០០ ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៩:០០-៩:២០ មតិផ្តើមបើកការពិភាក្សា និងសំរបសំរួល ដោយ **លោក សំរ៉ាំង កំសាន្ត** អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថាន វ.ខ.ស.ស

៩:២០-១០:០០ វាគ្មិនកិត្តិយស

-**ឯកឧត្តម សុន គន្ធរ** ប្រធានអគ្គនាយក ធនាគារអភិវឌ្ឍន៍ជនបទ

-**លោក ឌី សុខណ្ណា** អនុប្រធាននាយកដ្ឋានផែនការគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**-លោកបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី** ប្រធាននាយកដ្ឋានត្រួតពិនិត្យគំរោង គណៈកម្មការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ វ.ខ.ស.ស

១០:០០-១០:១៥ សំរាកពិសាភេសជ្ជៈ

១០:១៥-១១:០០ បើកកិច្ចពិភាក្សា

១១:០០-១០:៣០ បូកសរុបលទ្ធផលវេទិកាលើកទី ៤

# កម្មវិធីវេទិកា ទី ៩ ស្តីពី

# កម្ពុជា និង សហគមន៍សង្គមវប្បធម៌អាស៊ាន

ឧបត្ថម្ភដោយ អង្គការ មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត

(Friedrich-Ebert-Stiftung (FES)

ទីកន្លែង : បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៤, ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

៨:៣០-៩:០០ ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៩:០០-៩:២០ មតិផ្តើមបើកការពិភាក្សា និងសំរបសំរួលដោយ **លោក សំរាំង កំសាន្ត** អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថាន វ,ខ,ស,ស

៩:២០-១០:០០ វាគ្មិនកិត្តិយស

-**ឯកឧត្តម ឌុច ភឿន** អនុរដ្ឋលេខាធិការក្រសួង វប្បធម និងវិចិត្រសិល្បៈ

-**លោកបណ្ឌិត ហង្ស ពុទ្ធា** ប្រធានសមាគមវិចិត្រ សិល្បៈ និងជានាយកប្រតិបត្តិ គណៈកម្មាធិការអព្យាក្រិត យុត្តិធមិ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា

-**ឯកឧត្តមបណ្ឌិត ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិ-

បាលទទួលបន្ទុកវិស័យអប់រំ ប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ សមាជិករាជបណ្ឌិតសភាកម្ពុជា និង ជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថាន វ.ខ.ស.ស

១០:០០-១០:១៥ សំរាកពិសាភេសជ្ជៈ

១០:១៥-១១:០០ បើកកិច្ចពិភាក្សា

១១:០០-១០:៣០ បូកសរុបលទ្ធផលវេទិកាលើកទី ៥

# កម្មវិធីវេទិកា ទី ៦ ស្តីពី

# កម្ពុជា និង ដៃគូចចារអាស៊ាន

~~~~~~~~

ឧបត្ថម្ភដោយ អង្គការ មូលនិធិ ហ្វ្រីឌ្រីច អេប៊ែត

(Friedrich-Ebert-Stiftung (FES)

ទីកន្លែង : បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៤, ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

៨:៣០-៩:០០ ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៩:០០-៩:២០ មតិផ្តើមបើកការពិភាក្សា និងសំរបសំរួលដោយ **លោក ស៊ីសុវត្ថិ ជូង ច័ន្ទតោ** នាយកប្រតិបត្តិរង នៃ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

៩:២០-១០:០០ វាគ្មិនកិត្តិយស

**-លោកជំទាវបណ្ឌិត សឿង រត្ន័ធាវី** អគ្គនាយក អគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិ-បត្តិការអន្តរជាតិ

**-លោក អ៊ឹម ស៊ីថុល** ប្រធានការិយាល័យអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី
~~~~~~~~

១០:០០-១០:១៥ សំរាកពិសាភេសជ្ជៈ

១០:១៥-១១:០០ បើកកិច្ចពិភាក្សា

១១:០០-១០:៣០ បូកសរុបលទ្ធផលវេទិកាលើកទី ៦

## កម្មវិធីវេទិកា ទី ៧ ស្តីពី

## កម្ពុជា និងវេទិកាតំបន់អាស៊ាន

-----------

ឧបត្ថម្ភដោយ អង្គការ មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត

(Friedrich-Ebert-Stiftung (FES)

<u>ទីកន្លែង</u> : បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤ , ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

៨:៣០-៩:០០ ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៩:០០-៩:២០ ប្រធានដឹកនាំការពិភាក្សា និងសំរបសំរួល ដោយ

**ឯកឧត្តម អ៊ុន នីង** អនុប្រធានគណៈកម្មការ កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងពតិមាននៃរដ្ឋសភាជាតិ និងជាសមាជិកគណៈកម្មាធិការនាយក វ.ខ.ស.ស

៩:២០-១០:០០ វាគ្មិនកិត្តិយស

-**លោក ច្រឡឹង សុមេធា** អនុប្រធាននាយកដ្ឋាន អាស៊ាន ក្រសួងទេសចរណ៍

-**ឯកឧត្តម សំរាំង កំសាន្ត** អនុរដ្ឋលេខាធិការ ទទួលបន្ទុកទំនាក់ទំនងវប្បធម៌ និងកិច្ចការអាស៊ាន នៃក្រសួង វប្បធម៌

|  |  |
|---|---|
|  | និងវិចិត្រសិល្បះ |
| ១០:០០-១០:១៥ | សំរាកពិសាភេសជ្ជះ |
| ១០:១៥-១១:០០ | បើកកិច្ចពិភាក្សា |
| ១១:០០-១០:៣០ | បូកសរុបលទ្ធផលវេទិកាលើកទី ៧ |

# កម្មវិធីវេទិកា ទី ៨ ស្តីពី

# កម្ពុជា និងអាស៊ាន +៣

------------

ឧបត្ថម្ភដោយ អង្គការ មូលនិធិ ហ្វ្រីឌ្រីច អេប៊ែត

(Friedrich-Ebert-Stiftung (FES)

ទីកន្លែង : បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៤ , ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

៨:៣០-៩:០០ ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៩:០០-៩:២០ ប្រធានដឹកនាំការពិភាក្សា និងសំរបសំរួល ដោយ **ឯកឧត្តម អ៊ិង ហួត** ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជានិងជាអនុប្រធានក្រុមប្រឹក្សាភិបាល វ,ខ,ស,ស

៩:២០-១០:០០ វាគ្មិនកិត្តិយស

**-តំណាងឯកឧត្តមឧត្តមសេនីយ៍ឯក នាង ផាត** រដ្ឋលេខាធិការក្រសួងការពារជាតិ

***-លោក កេត សុផាន់*** ប្រធាននាយកដ្ឋានអាស៊ានទីស្តីការគណៈរដ្ឋមន្ត្រី និងជាអ្នកស្រាវជ្រាវ វ.ខ.ស.ស

វាគ្មិនពិភាក្សា

**ឯកឧត្តម សំរ៉ាំង កំសាន្ត** អនុរដ្ឋលេខាធិការ ទទួលបន្ទុកទំនាក់ទំនងវប្បធម៌ និងកិច្ចការអាស៊ាន នៃក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ

១០:០០-១០:១៥ សំរាកពិសាភេសជ្ជៈ

១០:១៥-១១:០០ បើកកិច្ចពិភាក្សា

១១:០០-១០:៣០ បូកសរុបលទ្ធផលវេទិកាលើកទី ៨

# កម្មវិធីវេទិកាទី ៩ ស្តីពី

# កម្ពុជា និង ផែនការសកម្មភាពវៀងច័ន្ទ

---------

ឧបត្ថម្ភដោយ អង្គការ មូលនិធិ ហ្វ្រីឌ្រិច អេប៊ែត

(Friedrich-Ebert-Stiftung (FES)

ទីកន្លែង : បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤, ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

៨:៣០-៩:០០ ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៩:០០-៩:២០ ប្រធានដឹកនាំការពិភាក្សា និងសំរបសំរួល ដោយ

**ឯកឧត្តម អ៊ិន នឹង** អនុប្រធានគណៈកម្មាធិការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពតមាននៃរដ្ឋសភាជាតិ និងជាសមាជិកគណៈកម្មាធិការ នាយក វ.ខ.ស.ស

៩:២០-១០:០០ គណៈវាគ្មិនកិត្តិយស

**លោក នង សាកល** អនុប្រធាននាយកដ្ឋាន វេទិកាតំបន់អាស៊ាន អគ្គនាយកដ្ឋានអាស៊ាន ក្រសួងការ បរទេស និងសហប្រតិបត្តិការអន្តរជាតិ

**-ឯកឧត្តម សំរ៉ាំង កំសាន្ត** អនុរដ្ឋលេខាធិការ ទទួលបន្ទុកទំនាក់ទំនងវប្បធម និងកិច្ចការអាស៊ាន នៃក្រសួង វប្បធមិ និងវិចិត្រសិល្បៈ

១០:០០-១០:១៥ សំរាកពិសាភេសជ្ជះ

១០:១៥-១១:០០ បើកកិច្ចពិភាក្សា

១១:០០-១០:៣០ បូកសរុបលទ្ធផលវេទិកាលើកទី ៩

# កម្មវិធីវេទិកាទី ១០ ស្តីពី

# កម្ពុជា និង ការងារការទូតអាស៊ានបណ្តាញទី២

---------

ឧបត្ថម្ភដោយ អង្គការ មូលនិធិ ហ្វ្រីឌ្រីច អេប៊ែត

(Friedrich-Ebert-Stiftung (FES)

ទីកន្លែង : បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤, ពីម៉ោង ០៨:៣០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់

៨:៣០-៩:០០ ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៩:០០-១០:០០ ប្រធានដឹកនាំការពិភាក្សា និងសំរបសំរួល ដោយ **ឯកឧត្តម សំរ៉ាំង កំសាន្ត** អនុរដ្ឋលេខាធិការ ទទួល បន្ទុកទំនាក់ទំនង វប្បធម៌ និងកិច្ចការអាស៊ាន នៃក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ វាគ្មិនកិត្តិយស

**-បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរ សំរាប់សហ ប្រតិបត្តិការ និងសន្តិភាព

**-លោកបណ្ឌិត ឡៅ ម៉ុងហៃ** ប្រធានអង្គភាពច្បាប់ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម

១០:០០-១០:១៥ សំរាកពិសាភេសជ្ជៈ

១០:១៥-១១:០០ បើកកិច្ចពិភាក្សា

១១:០០-១០:៣០ បូកសរុបលទ្ធផលវេទិកាលើកទី ១០

# ៩-កម្មវិធីអង្គសន្និសីទជាតិ

## សន្និសីទជាតិ ស្តីពី

## "កម្ពុជា និង អាស៊ាន : ប្រាំឆ្នាំក្រោយមក"

----------

សហការរៀបចំដោយ

វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) និង

មូលនិធិ ហ្រ្វីឌ្រីច អេប៊ែត Friedrich- Ebert Stiftung (FES)

ថ្ងៃទី ២១-២២ ខែ ធ្នូ ២០០៤

ទីកន្លែង: សាលប្រជុំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា វិមានរដ្ឋាភិបាល វត្តភ្នំ ភ្នំពេញ

**មូលប្រវត្តិ :**

ក្នុងនាមជាប្រទេសតូចមួយដែលកំពុងដើរពីរយៈពេលដ៏វែងនៃសង្គ្រាម និង ជំលោះ ប្រទេសកម្ពុជាមិនអាចបន្តគោលនយោបាយ នៃភាពឯកោរបស់ ខ្លួនបានទេ។ ដោយមានការតាំងចិត្តដ៏រឹងមាំរបស់ខ្លួន និងការរៀបចំដ៏យូរអង្វែង សម្រាប់ សមាជិក-ភាពរបស់ខ្លួនប្រទេសកម្ពុជា នៅទីបញ្ចប់ត្រូវបាន ទទួលយល់ព្រម ធ្វើជាសមាជិក ទី ១០ នៃអង្គការអាស៊ាននៅខែមេសា ក្នុងឆ្នាំ ១៩៩៩។ ចាប់តាំងពីបាន ក្លាយខ្លួនពេញសិទ្ធ ជាសមាជិកមក ប្រទេសកម្ពុជា បានចូលរួមយ៉ាងសកម្មនៅក្នុងអង្គការអាស៊ាន ដោយ ជំរុញតួនាទីតំបន់របស់ខ្លួន និងវិស័យការទូតពហុភាគីរបស់ខ្លួន ដើម្បីទាញយកផល

ប្រយោជន៍លើគ្រប់វិស័យនៃ កិច្ចសហប្រតិបត្តិការពីសេដ្ឋកិច្ច និងពាណិជ្ជកម្ម រហូតដល់វិស័យនយោបាយ និងសន្តិសុខនៅក្នុងតំបន់។

ដើម្បីរំលឹកឡើងវិញនូវខួបទី ១០ របស់ខ្លួន នៅក្នុងឆ្នាំ ២០០៤ នេះ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) បានសហការជា មួយមូលនិធិ ហ្វ្រីឌ្រិច-អេប៊ែត (FES) រៀបចំសន្និសីទជាតិ ស្តីអំពី "**កម្ពុជា និងអាស៊ាន : ប្រាំឆ្នាំក្រោយមក**" ដែលនឹងពិនិត្យមើលឡើងវិញ និងវាយតម្លៃអំពី សមាជិកភាពរបស់កម្ពុជា នៅក្នុងអង្គការអាស៊ាន ដោយហេតុថា ទាំងប្រទេស កម្ពុជា និងអង្គការអាស៊ានបានចូលពាក់ព័ន្ធគ្នា នៅក្នុងរយៈពេល ពាក់កណ្តាល ទសវត្សក្រោយនេះ។

សន្និសីទជាតិនេះ ត្រូវបានរៀបចំដោយផ្អែកលើគម្រោងរួមគ្នា រវាងវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) និង មូលនិធិ ហ្វ្រីឌ្រិច-អេប៊ែត (FES) ដោយឆ្លងកាត់វេទិកាចំនួន១០ លើក ក្នុងឆ្នាំ ២០០៤ ដែលរួមមានប្រធានបទដូចខាងក្រោម :

- ការប្រជុំតុមូលលើកទីមួយ : **ប្រទេសកម្ពុជា និងអង្គការអាស៊ាន ការពិនិត្យមើលជារួម**
- ការប្រជុំតុមូលលើកទីពីរ : **កម្ពុជា និងតំបន់ពាណិជ្ជកម្មសេរី អាស៊ាន**
- ការប្រជុំតុមូលលើកទីបី : **កម្ពុជា និង ដៃគូរចរចាអាស៊ាន**
- ការប្រជុំតុមូលលើកទីបួន : **កម្ពុជា និងអាស៊ានបូកបី**
- ការប្រជុំតុមូលលើកទីប្រាំ : **កម្ពុជា និងវេទិកាតំបន់អាស៊ាន**

ការប្រជុំតុមូលលើកទីប្រាំមួយ : **កម្ពុជា និងសហគមន៍សន្តិសុខអាស៊ាន**

ការប្រជុំតុមូលលើកទីប្រាំពីរ : **កម្ពុជា និងសហគមន៍សេដ្ឋកិច្ចអាស៊ាន**

ការប្រជុំតុមូលលើកទីប្រាំបី : **កម្ពុជា និងសហគមន៍សង្គមវប្បធម៌ អាស៊ាន**

ការប្រជុំតុមូលលើកទីប្រាំបួន : **កម្ពុជា និងផែនការសកម្មភាព ទីក្រុងវៀងច័ន្ទ**

ការប្រជុំតុមូលលើកទីដប់ : **កម្ពុជា និង វិស័យការទូតអាស៊ាន** Track II

នៅពេលដែលវេទិកានីមួយៗ ត្រូវបានរៀបចំនៅក្នុងកិច្ចប្រជុំដែលមានលក្ខណៈជាសិក្ខាសាលាសន្និសីទជាតិនេះ មានលក្ខណៈ និងទិសដៅពាក់ព័ន្ធធំទូលាយ និងស៊ីជំរៅជាងវេទិកាដែលការចូលរួមមានកម្រិត។ ទោះយ៉ាងនេះ ក៏ដោយវេទិកាជាបន្តបន្ទាប់ក្នុងរយៈពេល ១១ ខែកន្លងមកនេះបានបង្ហាញថា មានការពិភាក្សាយ៉ាងសកម្ម និងប្រកបដោយន័យស្ថាបនាលើប្រធានបទ ដែលបានគូសបញ្ជាក់ខាងលើ។

## <u>គោលបំណងនៃសន្និសីទជាតិ</u>

***គោលបំណងនៃសន្និសីទជាតិនេះគឺ***

- ដើម្បីពិនិត្យមើលឡើងវិញ និងធ្វើទំនើបកម្មឡើងវិញ នូវការអភិវឌ្ឍន៍ថ្មីៗ ក្នុងរង្វង់អង្គការអាស៊ាន (ដែលប្រជាជនកម្ពុជា ខ្លះមិនបានដឹង) នៅក្នុងកម្រិតជាតិ។
- ដើម្បីផ្សព្វផ្សាយពត៌មាន ស្តីអំពី ទិសដៅទៅអនាគតនៃអង្គការអាស៊ាន ក៏ដូចជា បញ្ហាថ្មីៗ ចំពោះអង្គការតំបន់នេះ ដែលប្រទេសកម្ពុជាអាចយល់បានយ៉ាងល្អប្រសើរ អំពីការវិវត្តន៍របស់អង្គការអាស៊ាន។

- ដើម្បីចូលរួមពាក់ព័ន្ធទាំងសាធារណៈ និងអ្នកធ្វើគោលនយោបាយនៅក្នុងការចរចាបើកចំហ និងប្រកបដោយអត្ថន័យស្ថាបនាដែលពួកគេ អាចមានឱកាសលើកបញ្ហាគួសបញ្ជាក់ពីកង្វល់ ក៏ដូចជា ផ្តល់នូវចំណេះដឹងចាំបាច់ជូនទៅដល់ Track I (រដ្ឋាភិបាល)។

- ដើម្បីផ្តោតទៅលើប្រធានបទ និងបញ្ហាដ៏ជាក់លាក់ ដែលមានផលប៉ះពាល់ធំធេងលើប្រជាជនកម្ពុជា និងប្រទេសកម្ពុជាទាំងមូល។

- ដើម្បីបង្ហាញពីតួនាទីរបស់កម្ពុជា ការរំពឹងទុកកង្វល់ សេចក្តីសង្ឃឹម ក៏ដូចជា ការប្រឈមនៅក្នុងបញ្ហាអាស៊ានដែលជាគន្លឹះនីមួយៗ និង

- ដើម្បីជំរុញការគិតគូរដ៏សកម្មរបស់អង្គការសង្គមស៊ីវិលនិងរបស់ប្រទេសកម្ពុជា រួមទាំងការចូលរួមពាក់ព័ន្ធ ដ៏ល្អប្រសើរនៅក្នុងអង្គការអាស៊ាន (មានអ្នកធ្វើការលើកិច្ចការអាស៊ានជាច្រើន នាក់មិនត្រឹមតែមន្ត្រីរដ្ឋា-ភិបាលប៉ុណ្ណោះទេ)។

អ្នកចូលរួម៖

សន្និសីទជាតិនឹងប្រមូលផ្តុំអ្នកចូលរួមប្រហែល ២០០ នាក់ មកពី ស្ថាប័នផ្សេងៗ រួមមានសមាជិកនៃអង្គទូតប្រចាំនៅទីក្រុងភ្នំពេញ មន្ត្រីរដ្ឋាភិបាលកម្ពុជា សមាជិករដ្ឋសភា និងព្រឹទ្ធសភា សមាជិក នៃអង្គការសង្គមស៊ីវិល សហគមន៍បញ្ញវន្តកម្ពុជា អ្នកសារពតិមាន និងសាធារណៈជនទូទៅ។

# <u>**ក ម្ម វិ ធី**</u>

***ថ្ងៃទីមួយ: ថ្ងៃអង្គារ ទី ២១ ខែធ្នូ ឆ្នាំ ២០០៤***

០៧:៣០-០៨:០០ ចុះឈ្មោះអ្នកចូលរួម

០៨:៣០-០៩:០០ ការយាង និងអញ្ជើញមកដល់របស់ភ្ញៀវកិត្តិយស

០៩:០០-១០:៣០ ការបើកអង្គសន្និសីទជាតិ

-ព្រះសុន្ទរកថាស្វាគមន៍របស់ **សម្តេច នរោត្តម សិរិវុឌ្ឍ** ព្រះប្រធានក្រុមប្រឹក្សាភិបាល វិទ្យាស្ថានខ្មែរសំរាប់សហ ប្រតិបត្តិការ និងសន្តិភាព

-សុន្ទរកថាបើកអង្គសន្និសីទដោយ **លោក ណរបឺត វុន ហូម៉ាន់** (Nobert Von Hofmann) ប្រធានការិយាល័យ សម្រាប់សហប្រតិបត្តិការភូមិភាគអាស៊ីអាគ្នេយ៍នៃមូលនិធិ ហ្វ្រីឌ្រិចអេប៊ែត (FES) សិង្ហបុរី

-ព្រះសុន្ទរកថាបើករបស់ **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភានៃព្រះរាជាណាចក្រ កម្ពុជា

១០:៣០-១០:៤៥ សំរាកពិសាភេសជ្ជៈ

១០:៤៥-១២:០០ **<u>សម័យប្រជុំទី១</u> :របាយការណ៍នៃកិច្ចប្រជុំ តុមូលទាំង១០លើក ក្នុងឆ្នាំ ២០០៤ ស្តីពី "កម្ពុជា**

**និង អាស៊ាន"**

**ប្រធាន :**

**បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ នៃ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

**វាគ្មិន :**

**ឯកឧត្តម សំរាំង កំសាន្ត** អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

១២:០០-១៤:០០ សំរាកពិសាអាហារថ្ងៃត្រង់

១៤:០០-១៥:៤៥ **សម័យប្រជុំទី២ : កម្ពុជា និងអាស៊ាន "ទស្សនៈរួម"**

**ប្រធាន :**

**ឯកឧត្តមឧត្តមសេនីយ៍ឯក នាង ផាត** រដ្ឋលេខាធិការ ក្រសួងការពារជាតិ

**វាគ្មិន :**

**-ឯកឧត្តមបណ្ឌិត កៅ គឹមហួន** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**-ឯកឧត្តម នៅ កាស៊ី** រដ្ឋលេខាធិការក្រសួងយុត្តិធម៌

**-លោកបណ្ឌិត ឡៅ ម៉ុងហៃ** ប្រធានអង្គភាពច្បាប់ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម

**-ឯកឧត្តមឧត្តមសេនីយឯក ខៀវ សុភ័ក្រ** ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី អគ្គលេខាធិការរងក្រសួងមហាផ្ទៃ និងអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន

សំណួរ និងចំលើយ

១៥:៤៥-១៦:០០ សំរាកពិសាភេសជ្ជៈ

១៦:០០-១៧:៤៥ **សម័យប្រជុំទី៣ : កម្ពុជា និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន : "ការអនុវត្តន៍ និងផលប៉ះពាល់"**

**<u>ប្រធាន</u> :**

ឯកឧត្តម **នៅ កាស៊ី** រដ្ឋលេខាធិការក្រសួងយុត្តិធម៌

**<u>វាគ្មិន</u> :**

**-លោកបណ្ឌិត ពេជ ឫទ្ធី** ឧត្តមមន្ត្រី សេដ្ឋកិច្ច

អាស៊ាន និងជាអគ្គនាយករង អគ្គនាយកដ្ឋាន បច្ចេកទេស ក្រសួងពាណិជ្ជកម្ម

-**លោក អ៊ុយ សម្បត្តិ** ប្រធាននាយកដ្ឋាន សមាហ-រណកម្មសេដ្ឋកិច្ច និងអាស៊ានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-**លោកបណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ នៃ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

សំណួរ និង ចំលើយ

***ថ្ងៃទី២: ថ្ងៃពុធ ទី ២២ ខែ ធ្នូ ឆ្នាំ ២០០៤***

៨:០០-១០:០០ **<u>សម័យប្រជុំទី៤</u> : "កម្ពុជា និងទស្សនវិស័យរបស់អាស៊ានក្នុងឆ្នាំ២០២០ : សហគមន៍សន្តិសុខ សេដ្ឋកិច្ច និងវប្បធម៌សង្គម"**

**<u>ប្រធាន:</u>**

**ឯកឧត្តម អ៊ឹង ហួត** អនុប្រធានក្រុមប្រឹក្សាភិបាល វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

**<u>វាគ្មិន:</u>**

-**ឯកឧត្តមឧត្តមសេនីយ៍ទោ មៀច សុផាន់ណា** ប្រធានសេនាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួង

មហាផ្ទៃ

**-ឯកឧត្តម សុន គន្ធរ** ប្រធានអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងជាអនុប្រធានឧត្តមក្រុមប្រឹក្សា សេដ្ឋកិច្ចជាតិ

**-លោក លី សែ** អនុប្រធាននាយកដ្ឋានសមាហរណ កម្មសេដ្ឋកិច្ច និងអាស៊ានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំណួរ និង ចំលើយ

| | |
|---|---|
| ១០:០០-១០:១៥ | សំរាកពិសាភេសជ្ជៈ |
| ១០:១៥-១២:០០ | **<u>សម័យប្រជុំទី៥:</u> "កម្ពុជា និង វេទិកាតំបន់អាស៊ាន : បទពិសោធន៍ និងទស្សនវិស័យ"** |

**<u>ប្រធាន</u> :**

**ឯកឧត្តមបណ្ឌិត ស៊ន សំណាង** ប្រធានរាជបណ្ឌិតសភាកម្ពុជា

**<u>វាគ្មិន</u> :**

**-លោក ច្រឹងឡឹង សុះមេធា** អនុប្រធាននាយកដ្ឋានអាស៊ានក្រសួងទេសចរណ៍

**-លោក នង សាកល** អនុប្រធាននាយកដ្ឋានវេទិកា

តំបន់អាស៊ាន អគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំនណួរ និង ចំលើយ

១២:00-១៤:00 សំរាកពិសារអាហារថ្ងៃត្រង់

១៤:0-១៦:00 **សម័យប្រជុំទី៦ : "កម្ពុជា និងអាស៊ានបុកបីៈ អនាគតនៃសហគមន៍អាស៊ីបូព៌ា"**

**ប្រធានៈ**

**ឯកឧត្តម ឡាយ ព្រហស្ត** រដ្ឋមន្ត្រីក្រសួង- ទេសចរណ៍

**វាគ្មិនៈ**

**-លោក ឡាយ ខណ្ឌៈ** មន្ត្រីជំនាញ នាយកដ្ឋាន អាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី

**-លោក ឥន ចឿន** ប្រធាននាយកដ្ឋានអាស៊ាន និង សហប្រតិបត្តិការអន្តរជាតិ ក្រសួងទេសចរណ៍

១៦:00-១៦:១៥ សំរាកពិសាភេសជ្ជៈ

១៦:១៥-១៧:៣0 ពីធីបិទអង្គសន្និសីទ

**ប្រធានៈ**

**ឯកឧត្តម អ៊ុន និង** អនុប្រធានគណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ និងពត៌មាននៃរដ្ឋសភា និងជាសមាជិកក្រុមប្រឹក្សាភិបាល វ.ខ.ស.ស.

ពិធីបូកសរុបលទ្ធផលអង្គសន្និសីទជាតិដោយ **បណ្ឌិត ចាប សុថារិទ្ធ** នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

សុន្ទរកថាសំខាន់ប្រកាសបិទអង្គសន្និសីទ ស្តីពី "**កម្ពុជា និង អាស៊ាន : ប្រាំឆ្នាំក្រោយមក**" ដោយ **ឯកឧត្តម បណ្ឌិត កៅ គឹមហួន** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ជាតំណាង ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហ ប្រតិបត្តិការអន្តរជាតិ ។

# ឧបសម្ព័ន្ធ៥ បញ្ជីរាយនាមប្រធានសម័យប្រជុំ និងវាគ្មិន

| | |
|---|---|
| **សម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិ** | ព្រះប្រធានរដ្ឋសភានៃព្រះរាជាណាចក្រ កម្ពុជា |
| **សម្តេច នរោត្តម សិរីវុឌ្ឍ** | ព្រះប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព |
| **ឯកឧត្តម ឡាយ ព្រហស្ល** | រដ្ឋមន្ត្រី ក្រសួងទេសចរណ៍ |
| **ឯកឧត្តម អ៊ុន នឹង** | អនុប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងពតិមាននៃរដ្ឋសភាជាតិ និងជាសមាជិកគណៈកម្មាធិការនាយក វ.ខ.ស.ស |
| **ឯកឧត្តម អ៊ឹង ហួត** | ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជានិងជាអនុប្រធានក្រុមប្រឹក្សាភិបាល វ.ខ.ស.ស |
| **បណ្ឌិត កៅ គឹមហួន** | -រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>-អតីតទីប្រឹក្សាអមក្រសួងការបរទេស និងសហប្រតិ |

| | |
|---|---|
| | បត្តិការអន្តរជាតិទទួលបន្ទុកកិច្ចការអាស៊ាន និងជាអតីតនាយកប្រតិបត្តិ វ.ខ.ស.ស |
| **ឯកឧត្តម សុន គន្ធរ** | ប្រធានអគ្គនាយកធនាគារ អភិវឌ្ឍន៍ជនបទ និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| **បណ្ឌិត ចាប សុថារិទ្ធ** | -នាយកប្រតិបត្តិ វ.ខ.ស.ស |
| **លោកជំទាវបណ្ឌិត ស្មឿង រត្ន័ឆវី** | អគ្គនាយក នាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិ បត្តិការអន្តរជាតិ |
| **លោក ស៊ីសុវត្ថិ ដូង ច័ន្ទនោ** | នាយករងប្រតិបត្តិ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព |
| **លោក ណរ័បឺត ខុន ហ្វម៉ាន់** | ប្រធានការិយាល័យ សម្រាប់សហប្រតិបត្តិការភូមិភាគអាស៊ីអាគ្នេយ៍ នៃមូលនិធិ ហ្វ្រីឌ្រិច-អេប៊ែត (FES) សិង្ហបុរី |
| **ឯកឧត្តមឧត្តមសេនីយ៍ឯក ឆាន ផាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា |
| **ឯកឧត្តម នៅ ភាស៊ី** | រដ្ឋលេខាធិការ ក្រសួង យុត្តិធមិ |
| **លោក សំរាំង កំសាន្ត** | អ្នកសំរបសំរួលគំរោងកម្មវិធីនិងជាអ្នកស្រាវជ្រាវ |

ជាន់ខ្ពស់អមវិទ្យាស្ថាន វ,ខ,ស,ស

**ឯកឧត្តមឧត្តមសេនីយ៍ ទោ ណឹម សុខគ្គិ** — អគ្គនាយករង អគ្គនាយកដ្ឋាន យោធសេវា នាយក នាយកដ្ឋាននយោបាយ និងផែនការ ក្រសួងការពារជាតិ និងជាអ្នកស្រាវជ្រាវជាន់ ខ្ពស់អម វ,ខ,ស,ស

**ឯកឧត្តមបណ្ឌិត គុណ ញឹម** — នាយករងទីចាត់ការគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អម វ,ខ,ស,ស

**លោក មី សុជាតិ** — អនុប្រធាននាយកដ្ឋានអាស៊ាន និងសមាហរណ- កម្មសេដ្ឋកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**លោក ឌី សុខណ្ណា** — អនុប្រធាននាយកដ្ឋានផែនការ គោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**លោកបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី** — ប្រធាននាយកដ្ឋានត្រួតពិនិត្យគំរោង គណៈកម្មការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជា អ្នកស្រាវជ្រាវជាន់ខ្ពស់អម វ,ខ,ស,ស

**លោកបណ្ឌិត** — ប្រធានសមាគមវិចិត្រសិល្បៈ និងជានាយក ប្រតិបត្តិ

| | |
|---|---|
| **ហាខ្សុ ពុទ្ធា** | គណៈកម្មាធិការអព្យាក្រិត យុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា |
| **ឯកឧត្តមបណ្ឌិត ឆយ យីហ៊ាង** | ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកវិស័យអប់រំ ប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ សមាជិករាជបណ្ឌិតសភាកម្ពុជា និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថាន វ,ខ,ស,ស |
| **លោក អ៊ឹម ស៊ីថុល** | ប្រធានការិយាល័យអាស៊ានទីស្តីការគណៈរដ្ឋមន្ត្រី |
| **លោក ច្រឡឹង សុមេធា** | អនុប្រធាននាយកដ្ឋាន អាស៊ានក្រសួងទេសចរណ៍ |
| **លោក កេត សុផាន់** | ប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី |
| **លោក លី សែ** | អនុប្រធាននាយកដ្ឋានសមាហរណកម្ម អាស៊ាននិងអង្គការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **លោកបណ្ឌិត ឡៅ ម៉ុងហៃ** | ប្រធានអង្គភាពច្បាប់ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម |
| **ឯកឧត្តមឧត្តមសេនីយឯក ខៀវ សុភ័ក្រ** | ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ និងអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន |

| | |
|---|---|
| **លោកបណ្ឌិត ពេជ ឫទ្ធី** | ឧត្តមមន្ត្រី សេដ្ឋកិច្ចអាស៊ាន និងជាអគ្គនាយករង អគ្គនាយកដ្ឋាន បច្ចេកទេស ក្រសួងពាណិជ្ជកម្ម |
| **លោក អ៊ុយ សម្បត្តិ** | ប្រធាននាយកដ្ឋាន សមាហរណកម្មសេដ្ឋកិច្ច និង អាស៊ានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **ឯកឧត្តមឧត្តមសេនីយ៍ទោ មៀច សុផាន់ណា** | ប្រធានសេនាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ |
| **ឯកឧត្តមបណ្ឌិត ស៊ន សំណាង** | ប្រធានរាជបណ្ឌិត សភាកម្ពុជា |
| **លោក ច្រឡឹង សុមេធា** | អនុប្រធាននាយកដ្ឋាន អាស៊ានក្រសួងទេសចរណ៍ |
| **លោក នង សាកល** | អនុប្រធាននាយកដ្ឋានវេទិកាតំបន់អាស៊ាន អគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេស និង សហប្រតិបត្តិការ និងអន្តរជាតិ |
| **លោក ឡាយ ខណ្ណៈ** | មន្ត្រីជំនាញនាយកដ្ឋានអាស៊ាន ទីស្តីការគណៈ រដ្ឋមន្ត្រី |
| **លោក ឥន ធឿន** | ប្រធាននាយកដ្ឋានអាស៊ាន និង សហប្រតិបត្តិការ អន្តរជាតិ ក្រសួងទេសចរណ៍ |

# អំពីអ្នករៀបរៀង

បណ្ឌិត **ចាប សុថារិទ្ធ** ជានាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព ។ លោកបណ្ឌិត បានធ្វើការក្នុងស្ថាប័នរដ្ឋាភិបាល និងអង្គការអន្តរជាតិជាច្រើន រួមមាន ជាជំនួយការផ្ទាល់រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី នាយកគំរោងកម្មវិធីអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ (UNDP) នៅភ្នំពេញ និងធ្លាប់ធ្វើជាទីប្រឹក្សា និងជំនាញការ ជូនអង្គការអន្តរជាតិ ជាច្រើន រួមមាន FAO, UNCTAC, & World Bank ជាដើម។ បច្ចុប្បន្ន លោកបណ្ឌិតក៏ជាទីប្រឹក្សារបស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ លោកបណ្ឌិត **ចាប សុថារិទ្ធ** ដែលបាន ទទួលសញ្ញាប័ត្រ បណ្ឌិតផ្នែកសេដ្ឋកិច្ច ពីប្រទេសអូស្ត្រាលី បានសរសេរអត្ថបទ និងរៀបរៀបសៀវភៅជាច្រើន ស្តីអំពីការងារអាស៊ាន គោលនយោបាយការបរទេស សន្តិសុខ និងទំនាក់ទំនងអន្តរជាតិ ហើយលោកបានចូលរួមធ្វើវាគ្មិន និងអ្នកវិភាគក្នុងវេទិកាជាតិ វេទិកាតំបន់ និងវេទិកាអន្តរជាតិនានា។ ក្នុងកំឡុងឆ្នាំ ២០០២-២០០៤ លោកបណ្ឌិត បានធ្វើបឋកថានិងបង្រៀនមុខវិជ្ជាស្តីពី ប្រធានបទនានារួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុ ច្បាប់ពាណិជ្ជកម្ម និងសេដ្ឋកិច្ច នៅតាមមហា វិទ្យាល័យ នានា ក្នុងទីក្រុងភ្នំពេញ ដូចជា វិទ្យាស្ថានបច្ចេកវិទ្យានិងគ្រប់គ្រង (ITM) សាលា ភូមិន្ទរដ្ឋបាល និងវិទ្យាស្ថានអន្តរជាតិកម្ពុជា (IIC) ហើយបានធ្វើជាសាស្ត្រាចារ្យ ណែនាំនិស្សិតសរសេរនិក្ខេបបទថ្នាក់អនុបណ្ឌិត នៃសាកលវិទ្យាល័យជាតិគ្រប់ផង (NUM) ផងដែរ។

# អំពីវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) គឺជា វិទ្យាស្ថានស្រាវជ្រាវវិភាគ (Think Tank) ឯករាជ្យ ក្នុងមានគោលបំណង ស្ថាបនាគោលនយោបាយឈានមុខមួយ ដែលបានបង្កើតឡើង ក្នុងឆ្នាំ១៩៩៤ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់ ការយោគយល់គ្នា ឱ្យកាន់តែប្រសើរឡើងថែមទៀត អំពីបញ្ហាអភិវឌ្ឍន៍ជាតិ និងសហប្រតិបត្តិការតំបន់ និង អន្តរជាតិ ។ ដើម្បីបំពេញបេសកកម្មនេះ វិទ្យាស្ថានបានរៀបចំបង្កើតឱ្យមាន បឋកថា សិក្ខាសាលា វេទិកាសាធារណៈ សន្និសីទជាតិ និងអន្តរជាតិ វគ្គបណ្តុះបណ្តាលអំពីយុទ្ធសាស្ត្រ ទំនាក់ទំនងអន្តរជាតិ គោលនយោបាយ ការបរទេស សេដ្ឋកិច្ច និងនយោបាយ។ វិទ្យាស្ថានក៏ជា ស្ថាប័ន សិក្សាស្រាវជ្រាវ ដែលជាសមាជិកដ៏សកម្ម ក្នុងបណ្តាញស្រាវជ្រាវតំបន់ និង ពិភពលោក និងបាន បោះពុម្ពផ្សាយលើវិស័យសំខាន់ៗ មួយចំនួនដូចជា ការស្ថាបនាសន្តិភាព ទំនាក់ ទំនងស៊ីវិល-យោធា ការអភិវឌ្ឍន៍សេដ្ឋកិច្ច នយោបាយ ការបរទេស សន្តិសុខ អាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក។


អាស័យដ្ឋាន : ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ  រាជធានីភ្នំពេញ

ប្រៃសណីយ៍ : ប្រអប់សំបុត្រលេខ ១០០៧ ភ្នំពេញ

ទូរស័ព្ទ-ទូរសារៈ   (855) 023 982 559    ទូរស័ព្ទៈ   012 819 953

ហ្វាក់ៈ   (855) 023 982 559

E-mail: cicp@everyday.com.kh
Website: http://www.cicp.org.kh